# អភិធម្មត្ថសង្គហបរិច្ឆេទទី១

## មាន១៧គាថា ចិត្តសង្គហវិភាគ

## គាថាផ្តើមបករណ៍

១ សម្មាសម្ពុទ្ធមតុលំ        សសទ្ធម្មគណុត្តមំ
អភិវាទិយ ភាសិស្សំ        អភិធម្មត្ថសង្គហំ ។

១ខ្ញុំព្រះករុណា សូមនមស្សការចំពោះព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ ជាអគ្គបុគ្គលដ៏ប្រសើរលើស រកបុគ្គលឯណាមួយប្រៀប ស្មើនឹងព្រះអង្គមិនមាន ព្រមទាំងព្រះសទ្ធម្ម និងព្រះអរិយសង្ឃ ដ៏ឧត្តម ហើយនឹងពោលបករណ៍ឈ្មោះថា អភិធម្មត្ថសង្គហៈ ។

២ តត្ថ វុត្តាភិធម្មត្ថា        ចតុធា បរមត្ថតោ
ចិត្តំ ចេតសិកំ រូបំ        និព្វានមិតិ សព្វថា ។

២ អត្ថ (សេចក្តី) ក្នុងព្រះអភិធម្មទាំងឡាយ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ទុកក្នុងគម្ពីរព្រះអភិធម្មនោះ ដោយបរិយាយអស់សេចក្តីពោលដោយបរមត្ថមាន៤ប្រការ គឺ ចិត្ត ចេតសិក រូប និង ព្រះនិព្វាន ។

## គាថាសង្គហៈ

### សង្គហគាថា ក្នុងកាមាវចរចិត្ត៥៤ដួង

៣ អដ្ឋធា លោភមូលានិ        ទោសមូលានិ ច ទ្វិធា
មោហមូលានិចទ្វេតិ        ទ្វាទសាកុសលា សិយុំ ។

៣ អកុសលចិត្ត១២ដួងគឺ លោភមូលចិត្ត៨ដួងទោសមូលចិត្ត២ដួង មោហមូលចិត្ត២ដួង ។

៤ សត្តាកុសលបាកានិ          បញ្ចបាកានិ អដ្ឋធា
ក្រិយាចិត្តានិ តីណីតិ          អដ្ឋារស អហេតុកា ។

អកុសលវិបាកចិត្ត៧ដួង កុសលវិបាកចិត្ត៨ដួង កិរិយាចិត្ត៣ដួង រួមជាអហេតុកចិត្ត១៨ដួង។

៥ បាបាហេតុកមុត្តានិ          សោភណានីតិ វុច្ចរេ
ឯកូនសដ្ឋី ចិត្តានិ          អថេកនវុតីបិ វា ។

ចិត្តទាំងឡាយ ដែលផុតចាកអំពីបាប (គឺផុតអំពីអកុសលចិត្ត ១២ ដួង)និង អហេតុកចិត្តនោះមានចំនួន ៥៩ ដួង ឬ ៩១ ដួងបណ្ឌិតហៅថា សោភណចិត្ត ។

៦ វេទនាញាណសង្ខារ          ភេទេន ចតុវីសតិ
សហេតុកាមាវចរ          បុញ្ញបាកក្រិយា មតា ។

កុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ជាកាមាវចរសហេតុកចិត្ត លោកពោលទុក ២៤ ដួង ដោយសេចក្តី ផ្សេងគ្នានៃវេទនា ញាណ និងសង្ខារ ។

៧ កាមេ តេវីស បាកានិ          បុញ្ញាបុញ្ញានិ វីសតិ
ឯកា ទស ក្រិយា ចេតិ          ចតុបញ្ញាស សព្វថា ។

ចិត្តក្នុងកាមភូមិ (គឺចិត្តដែលត្រាច់ទៅក្នុងកាមភូមិ ១១ ភូមិដោយច្រើន ) ដោយប្រការទាំងពួង មាន ៥៤ ដួងគឺវិបាកចិត្ត ២៣ ដួងកុសលនិង អកុសលចិត្ត២០ដួង និងកិរិយាចិត្ត១១ដួង ។

**កាមាវចរចិត្ត៥៤ដួងចប់**

## សង្គហគាថាក្នុងមហគ្គតចិត្ត២៧ដួង

៨ បញ្ចធា ឈានភេទេន    រូបាវចរមានសំ
បុញ្ញបាកក្រិយាភេទា    តំ បញ្ចទសធា ភវេ ។

រូបាវចរចិត្ត  ដោយប្រភេទនៃឈាន មាន ៥ យ៉ាង ចំណែកដោយកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ក៏មាន១៥យ៉ាង ។

៩ អាលម្ពនប្បភេទេន    ចតុធារុប្បមានសំ
បុញ្ញាបាកកិរិយាភេទា    បុន ទ្វាទសធា ឋិតំ ។

អរូបាវចរចិត្ត  ដោយប្រភេទនៃអារម្មណ៍ មាន ៤ យ៉ាង ចំណែកដោយប្រភេទនៃកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ក៏មាន ១២ យ៉ាង ។

## មហគ្គតចិត្ត២៧ដួងចប់

## សង្គហគាថា ក្នុងលោកុត្តរចិត្ត៨ដួង

១០ ចតុមគ្គប្បភេទេន    ចតុធាកុសលន្តថា
បាកន្តស្ស ផលត្តាតិ    អដ្ឋធានុត្តរំ  មតំ ។

១០ អនុត្តរចិត្ត (លោកុត្តរចិត្ត) បណ្ឌិតពោលទុក ៨ ប្រភេទគឺ កុសលចិត្ត ៤ យ៉ាងដោយប្រភេទនៃមគ្គ វិបាកចិត្តក៏មាន ៤ យ៉ាង ព្រោះជាផលរបស់កុសលចិត្តនោះ ។

## សម្តែងចិត្ត៨៩ដួងដោយជាតិ

១១ ទ្វាទសាកុសលានេវ    កុសលានេកវីសតិ
ឆត្តឹសេវ វិបាកានិ    ក្រិយាចិត្តានិ វីសតិ ។

អកុសលចិត្ត ១២ កុសលចិត្ត ២១ ដួង វិបាកចិត្ត ៣៦ ដួង និង

កិរិយា២០ដួង (រួម៨៩ដួង)

## សម្ដែងចិត្ត ៨៩ ដួងដោយភូមិ

១២ ចតុបញ្ញាសជា កាមេ រូបេ បណ្ណរសីរិយេ
ចិត្តានិ ទ្វាទសារូបេ អដ្ឋធានុត្តរេ តថា ។

បណ្ឌិតពោលចិត្តក្នុងកាមភូមិ ៥៤ ដួងចិត្តក្នុងរូបភូមិ ១៥ ដួង ចិត្តក្នុងអរូបភូមិ១២ដួងនិង អនុត្តរចិត្ត៨ដួង ។

## សម្ដែងចិត្ត៨៩ឬ១២១ដួង

១៣ ឥត្ថមេកូននវុតិ- ប្បភេទំ បន មានសំ
ឯកវីសសតំ វាថ វិភជន្តិ វិចក្ខណា ។

បណ្ឌិតអ្នកមានប្រាជ្ញា ឃើញច្បាស់ រមែងចែកមានស (ចិត្ត) ក្នុងទីនេះ ជាចិត្ត៨៩ដួង ឬ ជាចិត្ត ១២១ ដួង ។

## សម្ដែងលោកុត្តរចិត្ត៤០ដួងដោយឈាន

១៤ ឈានង្គយោគភេទេន កត្វេកេកន្តុ បញ្ចធា
វុច្ចតានុត្តរំ ចិត្តំ ចិត្តាឡីសវិធន្តិ ច ។

បណ្ឌិត ធ្វើលោកុត្តរចិត្ត មួយដួងៗជា៥យ៉ាងដោយសេចក្ដីផ្សេងគ្នានៃការប្រកបដោយអង្គឈានហើយ ពោលថា លោកុត្តរៈ ៤០ ដួង ។

## សម្ដែងលោកុត្តរចិត្តដោយរូបជ្ឈាន និងអរូបជ្ឈាន

១៥ យថា ច រូបាវចរំ គយ្ហតានុត្តរំ តថា
បឋមាទិជ្ឈានភេទេ អារុប្បញ្ចាបិ បញ្ចមេ ។

រូបាវចរចិត្តក្នុងប្រភេទនៃឈាន មានបឋមជ្ឈានជាដើម យ៉ាងណា លោកុត្តរក៏ដូច្នោះសូម្បីអរូបជ្ឈាន ក៏សង្គ្រោះចូលក្នុងបញ្ចមជ្ឈាន ។

## សម្តែងឈានចិត្តរួមជាមួយលោកុត្តរចិត្ត

ឯកាទសវិធំ តស្មា បឋមាទិកមីរិតំ
ឈានមេកេកមន្តេ តុ តេវីសតិវិធំ ភវេ ។

ព្រោះហេតុនោះឈានចិត្តមួយដួងៗដែលលោកហៅថាបឋមជ្ឈាន ជាដើម ទើបមាន១១ដួងចំណែកឈានចិត្តដួងខាងចុងបំផុត(បញ្ចមជ្ឈាន) មានចិត្ត២៣ដួង ។

## សម្តែងចិត្តដោយពិស្តារ ១២១ដួង

១៧ សត្តតឹសវិធំ បុញ្ញំ ទ្វិបញ្ញាសវិធន្តថា
បាកមិច្ចាហុ ចិត្តានិ ឯកវីសសតម្ពុធាតិ។

កុសលចិត្ត ៣៧ដួង វិបាកចិត្ត៥២ដួង បណ្ឌិតពោល(ដោយពិស្តារ) ថាមាន ១២១ដួង។ (គាថានេះ មិនបានសំដែង អកុសលចិត្ត១២ដួង និង កិរិយាចិត្ត២០ដួងទេ ) ។

## ចិត្តសង្គហវិភាគ បរិច្ឆេទទី១ចប់

## *អភិធម្មត្ថសង្គហៈ*

*ពាក្យថា អភិធម្មត្ថសង្គហៈ ចែកចេញជា៥បទគឺ* ***អភិ+ធម្ម+អត្ថ+សំ+គហ=អភិធម្មត្ថសង្គហ*** ***អភិ*** *ប្រែថាប្រសើរ* ***ធម្ម*** *ប្រែថា សភាវៈដែលទ្រទ្រង់* ***អត្ថ*** *ប្រែថា អត្ថ ឬសេចក្តី* ***សំ*** *ប្រែថាសង្ខេប* ***គហ*** *ប្រែថា រួបរួម ដូច្នោះពាក្យថា* ***អភិធម្មត្ថសង្គហ*** *ប្រែថា ការរួបរួមសេចក្តីនៃព្រះអភិធម្ម (៧គម្ពីរ) ដោយសង្ខេប ។*

## *សិក្សាបរមត្ថធម៌*

*ពាក្យថាបរមត្ថធម៌ ចែកចេញជាពីបទគឺ* ***បរម + អត្ថ = បរមត្ថ បរម*** *ប្រែថា ប្រសើរខ្ពង់ខ្ពស់មិនវិបរិត* ***អត្ថ*** *ប្រែថា អត្ថ ឬ សេចក្តី*

***បរមត្ថមានវចនត្ថៈថា***

***បរមោ ឧត្តមោ អវិបរិតោ អត្ថោ បរស្ស វា***

***ឧត្តមស្ស ញាណស្ស អត្ថោ គោចរោតិ បរមត្ថោ***

*ប្រែថា អត្ថដ៏ប្រសើរខ្ពង់ខ្ពស់ មិនប្រែប្រួល ឈ្មោះថា* ***បរមត្ថ*** *ន័យម្យ៉ាងទៀតថា គោចរនៃញាណដ៏ប្រសើរខ្ពង់ខ្ពស់ ឈ្មោះថា* ***បរមត្ថ*** *។*

***បរមត្ថនោះមានពីរយ៉ាងគឺ***

*១* ***សង្ខតបរមត្ថ*** *ធម៌ដែលមានបច្ច័យតាក់តែង បានដល់ ចិត្ត ចេតសិក រូប*

*២* ***អសង្ខតបរមត្ថ*** *ធម៌ដែលមិនមានបច្ច័យតាក់តែង គឺ ព្រះនិព្វាន។*

## បរមត្ថធម៌មាន៤យ៉ាងគឺ

១- **ចិត្តបរមត្ថ**

២- **ចេតសិកបរមត្ថ**

៣- **រូបបរមត្ថ**

៤- **និព្វានបរមត្ថ**

ពាក្យថាចិត្តមានវចនត្ថថា **អារម្មណំចិន្តេតីតិ=ចិត្តំ** ប្រែថា ធម្មជាតិណារមែងគិត គឺដឹងអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតិនោះឈ្មោះថាចិត្ត ន័យម៉្យាងទៀតគឺ **ចិន្តេន្តិ សម្បយុត្តធម្មា ឯតេនាតិ=ចិត្តំ** ប្រែថា ឈ្មោះថាចិត្តនោះ ព្រោះអត្ថថា ជាហេតុញុំាង សម្បយុត្តធម៌ឲ្យដឹង នូវអារម្មណ៍

ក្នុងអដ្ឋសាលិនី ពោលទុកថា

**យំ ចិត្តំ មនោ ហទយំ មានសំ បណ្ឌរំ**

**មនាយតនំ មនិន្ទ្រិយំ វិញ្ញាណក្ខន្ធោ**

**តជ្ជា មនោវិញ្ញាណធាតុ ឥទំ ចិត្តំ**

១- ធម្មជាតិណារមែងគិត ធម្មជាតិនោះឈ្មោះថា **ចិត្ត**

២- ធម្មជាតិណារូបរួមអារម្មណ៍ ទុកខាងក្នុង ធម្មជាតិនោះឈ្មោះថា**ហទយៈ**

៣- ធម្មជាតិណា រមែងបង្អោនទៅ ធម្មជាតិនោះ ឈ្មោះថា **មនោ**

៤- ចិត្តនោះឯងមានឆន្ទៈ គឺសេចក្តីប្រាថ្នា ឈ្មោះថា **មានសៈ**

៥- ចិត្តនោះឯងជាធម្មជាតិ ផូរផង់ ឈ្មោះថា **បណ្ឌរៈ** (បានដល់

កវគ្គចិត្ត)

៦- **មនៈ**ដែលជាអាយតនៈ ខាងក្នុងឈ្មោះថា **មនាយតនៈ**

៧- **មនៈ**ដែលជាឥន្ទ្រិយ៍ ឈ្មោះថា**មនិន្ទ្រិយ៍**

៨- ធម្មជាតិណា ដែលដឹងច្បាស់នូវអារម្មណ៍ឈ្មោះថា **វិញ្ញាណ**

៩- ខន្ធគឺកងនៃវិញ្ញាណ មានវិញ្ញាណជាអតីតជាដើម ឈ្មោះថា **វិញ្ញាណក្ខន្ធ**

១០- **មនៈ**ដែលជាធាតុដឹងច្បាស់ នូវអារម្មណ៍ ឈ្មោះថា **មនោ-វិញ្ញាណធាតុ**

## សច្ចៈ២យ៉ាង

ព្រះដ៏មានព្រះភាគជាម្ចាស់ ជាធម្មរាជា ទ្រង់ត្រាស់សំដែងសច្ចៈ២យ៉ាងគឺ បរមត្ថសច្ចៈ១ សម្មតិសច្ចៈ១ ក្នុងមនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ សំដែងថា

**ទុវេ សច្ចានិ អក្ខាសិ សម្ពុទ្ធោ វទតំ វរោ**
**សម្មតឹ បរមត្ថញ្ច តតិយំ នុបលព្ភតិ**

ព្រះសម្ពុទ្ធជាម្ចាស់ ប្រសើរជាងអស់អ្នកប្រាជ្ញ បានត្រាស់សំដែងនូវសច្ចៈពីរយ៉ាងគឺ បរមត្ថសច្ចៈ១ និងសម្មតិសច្ចៈ១ មិនបានត្រាស់សច្ចៈទី៣ឡើយ ។

## ហេតុដែលព្រះសម្មាសម្ពុទ្ធត្រាស់សច្ច៨យ៉ាង

១ ដើម្បីទ្រង់សំដែង ដល់ហិរិ និងឱត្តប្បៈ

២ ដើម្បីទ្រង់សំដែង ដល់កម្មស្សកតា

៣ ដើម្បីទ្រង់សំដែង ដល់បុគ្គលអ្នកធ្វើចំពោះខ្លួន

៤ ដើម្បីទ្រង់សំដែង ដល់អនន្តរិយកម្ម

៥ ដើម្បីទ្រង់សំដែង ដល់ព្រហ្មវិហារធម៌

៦ ដើម្បីទ្រង់សំដែង ដល់បុព្វេនិវាសញ្ញាណ

៧ ដើម្បីទ្រង់សំដែង ដល់ទក្ខិណាវិសុទ្ធិ

៨ ដើម្បី ទ្រង់មិនលុះ បញ្ញត្តិនៃលោក

## គាថាធម្មបទ

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា មនសា ចេ បទុដ្ឋេន**
**ភាសតិ វា ករោតិ វា តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។**

ប្រែថា ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ)សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោស ប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ ។

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា មនសា ចេ បសន្នេន**
**ភាសតិ វា ករោតិ វា តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

ប្រែថា ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី(នូវសុចរិត)ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

# អំណាចរបស់ចិត្ត

១-**វិចិត្តករណាចិត្តំ** ឈ្មោះថាចិត្ត ព្រោះថាធ្វើឲ្យវិចិត្តផ្សេងៗ និងធ្វើវត្ថុផ្សេងៗ ឲ្យវិចិត្តដូចជាវត្ថុដែលកើតអំពីសិល្បៈវិទ្យាផ្សេងៗ ក៏ព្រោះ ចិត្តមានរូបគំនូរ រូបចម្លាក់ ជាដើម និងធ្វើកិរិយាមារយាទ ឲ្យសមរម្យ ក៏ព្រោះ ចិត្ត ម៉្យាងទៀត សំដៅដល់ទីកើតច្រើនយ៉ាងដូចជា នរក ប្រេត អសុរកាយ តិរច្ឆាន មនុស្ស ទេវតា ជាដើម ។

២-**អត្តនោ ចិត្តតាយ វា** ឈ្មោះថា ចិត្តព្រោះសភាវៈនៃខ្លួនឯងជាចិត្ត គឺវិចិត្តដោយខ្លួនឯង បានសេចក្តីថា ចិត្តនោះឯង ជាកុសល ក៏មាន ជា អ-កុសលក៏មាន ជាកិរិយាក៏មាន ជាវិបាកក៏មាន ។

៣-**ចិត្តំ កម្មកិលេសេហិ** ឈ្មោះថាចិត្តព្រោះសន្សំនូវកម្មនិងកិលេស សន្សំនូវកម្មនោះ គឺកម្មជាកុសល កម្មជាអកុសល សន្សំនូវកិលេសនោះគឺ រាគៈ ទោសៈ មោហៈ ជាដើម ដូចជារាគៈកើតឡើងហើយក៏សន្សំរាគៈនោះ ឲ្យច្រើនឡើងៗជាដើម

៤-**ចិត្តំ តាយតិ វា តថា** ឈ្មោះថាចិត្ត ព្រោះរក្សាទុក នូវវិបាករបស់ខ្លួនគឺ កម្មណាកិលេសណា ដែលសន្សំហើយនោះ កាលណាមានឱកាស ហើយ នឹងឲ្យផលតាមផ្លូវភ្នែក ផ្លូវត្រចៀកជាដើម

៥-**ចិនោតិ អត្តសន្តានំ** ឈ្មោះថាចិត្ត ព្រោះសន្សំនូវសន្តានរបស់ខ្លួន គឺថា ចិត្តនោះឯងតែងសន្សំសេចក្តីល្អខ្លះ អាក្រក់ខ្លះ ទុកក្នុងខន្ធសន្តានមិន ឲ្យរលាយសាបសូន្យ ធ្វើឲ្យទៅជាទំលាប់ផ្សេងៗ រហូតទៅជានិស្ស័យ ឬ ចរិតក្នុងសន្តាន

៦-**វិចិត្តារម្មណត្តិ វា** ឈ្មោះថាចិត្តព្រោះអារម្មណ៍វិចិត្រដោយប្រការផ្សេងៗគឺ ដឹងអារម្មណ៍បានទាំងប្រាំមួយទ្វារដូចជាដឹងរូបារម្មណ៍ជាដើម

**លក្ខណាទិចតុក:របស់ចិត្ត**

-**វិជាននលក្ខណំ** មានការដឹងនូវអារម្មណ៍ ជាលក្ខណ:

-**បុព្វង្គមរសំ** មានសភាពជាប្រធានជាកិច្ច

-**សន្ធានបច្ចុប្បដ្ឋានំ** មានការកើតបន្ត គ្នាជាអាការ:ប្រាកដ

-**នាមរូបបទដ្ឋានំ** មាននាមនិងរូបជាបទដ្ឋាន (ជាហេតុជិត ឬ ជាគ្រឿងទ្រ)

**ចិត្ត៤យ៉ាង**

**តត្ថ ចិត្តំ តាវ ចតុព្វិធំ ហោតិ កាមាវចរំ**

**រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ**

ប្រែថា បណ្តាអត្ថនៃព្រះអភិធម្មទាំង៤នោះ លំដាប់ ដំបូង គឺចិត្តមាន៤យ៉ាង

១- **កាមាវចរចិត្ត ៥៤ដួង**

២- **រូបាវចរចិត្ត ១៥ដួង**

៣- **អរូបាវចរចិត្ត ១២ដួង**

៤- **លោកុត្តរចិត្ត ៨ដួង ឬ ៤០ដួង**

បណ្តាចិត្ត៤យ៉ាងនោះឈ្មោះថា កាមាវចរចិត្ត តើដូចម្តេច ?

ឈ្មោះថា **កាមាវចរចិត្ត** គឺចិត្តដែលប្រព្រឹត្តទៅក្នុងកាម ក៏ចិត្តដែលជាកាមាវចរនោះមាន៥៤ដួងគឺ

-អកុសលចិត្ត ១២ដួង

-អហេតុកចិត្ត ១៨ដួង

-កាមាវចរសោភណៈចិត្ត ២៤ដួង ត្រូវជា៥៤ដួង

ពាក្យថាកាមាវចរចិត្ត ចែកជា៣បទគឺ (**កាម+អវចរ+ចិត្ត**)

ពាក្យថា**កាម** បានដល់កិលេសកាម និងវត្ថុកាម

ពាក្យថា**អវចរ** បានដល់ការត្រាច់ទៅ

ពាក្យថា**ចិត្ត** បានដល់ធម្មជាតិដឹងនូវអារម្មណ៍

សរុប ប្រែថា ចិត្តត្រាច់ទៅក្នុងកាម គឺកិលេសកាម១ វត្ថុកាម១ បណ្ដាកាមពីរយ៉ាងនោះ កិលេសកាម មានពាក្យវិគ្រោះថា **កាមេតីតិ=កាមោ** សភាវៈណារមែងញុំាងឲ្យស្រឡាញ់ សភាវៈនោះឈ្មោះថា **កិលេសកាម** បានដល់កាមតណ្ហា **វត្ថុកាម** មានពាក្យវិគ្រោះថា **កាមីយតីតិ វា=កាមោ** សភាវៈណាដែលចិត្តរមែងស្រឡាញ់ ព្រោះហេតុនោះ សភាវៈនោះឈ្មោះថាវត្ថុកាម បានដល់កាមភព ១១ជាន់ ដែលប្រព្រឹត្តទៅ ជាមួយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាអារម្មណ៍ ពាក្យថា កាមាវចរចិត្តឬកាមចិត្ត មានន័យ៣យ៉ាងគឺ

១-សំដៅដល់ ចិត្តដែលកើតក្នុងកាមភូមិ ១១ ជាន់ ជាចំនួនច្រើន ព្រោះកាមភូមិ ១១ជាន់នោះបរិបូរណ៍ដោយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាភូមិរបស់ កាមបុគ្គល កាមភូមិ១១នោះគឺ នរក ប្រេត អសុរកាយ តិរច្ឆាន មនុស្ស ទេវតា៦ជាន់ ឬ ដូចជាព្រះខីណាស្រព ព្រះសម្មាសម្ពុទ្ធ ក៏ចាត់ជាកាមបុគ្គលដែរ ចំណែកចិត្តនៃបុគ្គលទាំងនោះ ហៅថាកាមាវចរចិត្តខ្លះ

ហៅថា វិបាកចិត្តខ្លះហៅថា កិរិយាចិត្តខ្លះ

២-សំដៅដល់ចិត្ត របស់អ្នកជាប់ស្អិត នៅក្នុងកាមារម្មណ៍ គឺជាប់ស្អិតនៅក្នុង កិលេសកាម និងវត្ថុកាម មានរូបារម្មណ៍ សទ្ទារម្មណ៍ជាដើម

៣-សំដៅដល់ចិត្តដែលទទួលកាមារម្មណ៍ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ក្តៅ ត្រជាក់ ទន់ រឹង តឹង កម្រើក ញ័រ ហើយកាមចិត្តនេះ ជាចិត្តរបស់អ្នកណាក៏ដោយ គេកើតក្នុងភូមិណាក៏ដោយ កាលមានរូប សំឡេង ក្លិន ជាដើមជាអារម្មណ៍ក្នុងខណៈណាហើយ ខណៈនោះហៅថាកាមចិត្ត សូម្បីតែព្រះសម្មាសម្ពុទ្ធ ក៏មានកាមចិត្ត ព្រោះកាលព្រះអង្គមិនទាន់ ចូលបរិនិព្វាន ក៏មានចិត្តឃើញរូប ឮសំឡេងជាដើម ជាអារម្មណ៍ ។

ពោលដោយអកុសលចិត្ត ១២ដួង អកុសលចិត្តគឺជាចិត្តមិនល្អ មិនស្អាត អាក្រក់ ថោកទាប ជាចិត្តប្រកបដោយ អកុសលចេតសិក រមែងឲ្យផលជាទុក្ខ ។

## អកុសលចិត្ត១២ដួង

អកុសលចិត្ត១២ដួងនោះគឺ លោភមូលចិត្ត៨ដួង ទោសមូលចិត្ត២ដួង និងមោហមូលចិត្ត២ដួង

## លោភមូលចិត្ត៨ដួង

**១-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ** ប្រែថា លោភមូលចិត្ត ដែលកើតព្រមជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិជាអសង្ខារិកៈ (មានកំលាំងខ្លាំងក្លា មិនមានអ្នកដទៃដឹកនាំ)

**២-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ** ប្រែថា លោភ

***មូលចិត្ត*** *ដែលកើតព្រមជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ ជាសសង្ខារិក: (មានកម្លាំងខ្សោយ មានអ្នកដទៃដឹកនាំ)*

*៣-**សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ** ប្រែថា **លោភមូលចិត្ត** ដែលកើតព្រមជាមួយសោមនស្សវេទនា(មិនប្រកបដោយមច្ឆាទិដ្ឋិ ជាអសង្ខារិក:)*

*៤-សោមនស្សសហគតំ ទិដ្ឋិគត វិប្បយុត្តំ សសង្ខារិកំ ប្រែថា **លោភមូលចិត្ត** ដែលកើតព្រមជាមួយសោមនស្សវេទនា ( មិនប្រកបដោយ មិច្ឆា-ទិដ្ឋិ ជាសសង្ខារិក:)*

*៥-**ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ** ប្រែថា **លោភមូលចិត្ត** ដែលកើតព្រមជាមួយ ឧបេក្ខាវេទនា ( ប្រកបដោយ មិច្ឆាទិដ្ឋិ ជាអសង្ខារិក:)*

*៦-**ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ** ប្រែថា **លោភមូលចិត្ត** ដែលកើតព្រមជាមួយ ឧបេក្ខាវេទនា ( ប្រកបដោយ មិច្ឆាទិដ្ឋិ ជាសសង្ខារិក:)*

*៧-**ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំអសង្ខារិកំ** ប្រែថា **លោភមូលចិត្ត** ដែលកើតព្រមជាមួយឧបេក្ខាវេទនា ( មិនប្រកបដោយ មិច្ឆាទិដ្ឋិ ជាអសង្ខារិក:)*

*៨-**ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ** ប្រែថា **លោភមូលចិត្ត** ដែលកើតព្រមជាមួយ ឧបេក្ខាវេទនា ( មិនប្រកបដោយ មិច្ឆាទិដ្ឋិ ជាអសសង្ខារិក:) បណ្តាលោភមូលចិត្ត៨ដួងនោះ មួយដួងៗចែកជា៣វគ្គ គឺ*

-សោមនស្សសហគតំ ១វគ្គ

-ទិដ្ឋិគតសម្បយុត្តំ ១វគ្គ

-អសង្ខារិកំ ១វគ្គ

រីឯ ៧ដួងទៀត ក៏ចែកជារបៀបដូចគ្នា

**លក្ខណាទិចតុក:របស់លោភ:**

-**អារម្មណគហណលក្ខណោ** លោភ:មានការប្រកាន់ ទាញគោង នូវអារម្មណ៍ជាលក្ខណ:

-**អភិសង្គរសោ** មានការជាប់ស្អិតក្នុងអារម្មណ៍ជាកិច្ច

-**អបរិចាគបច្ចុប្បដ្ឋានោ** មានការមិនលះបង់ ជាអាការ:ប្រាកដ

-**សំយោជនីយធម្មេសុអស្សាទ ទស្សនំ បទដ្ឋានោ** មានការពេញចិត្ត នូវធម៌ទាំងឡាយ ដែលជាទីតាំងនៃសំយោជនធម៌ ជាបទដ្ឋាន

**លោភមូលចិត្តនេះ** ជាបរមត្ថធម៌ មិននៅក្នុងការបង្គាប់បញ្ជានៃ អ្នកណាឡើយ កាលបើមានហេតុ បច្ច័យហើយក៏កើតឡើង

**អធិប្បាយលោភ:ទី១ជាដើម**

កាលបុគ្គលធ្វើមិច្ឆាទិដ្ឋិ ឲ្យជាខាងដើមថា ទោសក្នុងកាមទាំងឡាយ មិនមានដូច្នេះហើយ បរិភោគកាម ដោយសេចក្តីរីករាយ ឬជឿតាម ទិដ្ឋមង្គលជាដើម ថា ជាសារ:ក្តី ដោយចិត្តដែលក្លាហានខ្លួនឯង មិនមានអ្នក-ណាដាស់តឿនជំរុញ កាលនុះ អកុសលចិត្តដួងទី១កើតឡើង កាលណា បុគ្គលធ្វើមិច្ឆាទិដ្ឋិថាទោសក្នុងកាមទាំងឡាយមិនមានដូច្នេះហើយបរិភោគ កាមដោយសេចក្តីរីករាយ តែមានអ្នកដទៃជំរុញ កាលនុះ អកុសលចិត្តដួង

ទី២កើតឡើង សូម្បីតែលោភមូលចិត្ត ៦ដួងទៀតក៏មានន័យដូចគ្នា ។

**ហេតុឲ្យកើតលោភមូលចិត្តមាន៤ប្រការ**

១-**លោភបរិវារកម្ម បដិសន្ធិកតា**បដិសន្ធិដោយកម្មដែលមានលោភៈ ជាបរិវារ បុគ្គលខ្លះបដិសន្ធិក្នុងសុគតិភូមិដោយការធ្វើកុសលណាមួយមានការឲ្យទាន រក្សាសីលជាដើមដោយអំណាចនៃលោភ ចង់បានរូបស្អាតចង់បានទ្រព្យច្រើន ចង់បានអាយុវែងជាដើម មិនមែនដើម្បីជុសខាត់កិលេស គិតតែពីស្វែងរកចង់បាន វត្ថុដែលពេញចិត្តឲ្យបានច្រើនយ៉ាងនេះហៅថាមានលោភៈជាបរិវារ មានទាំងខាងមុខ មានទាំងខាងក្រោយ ក៏ជាបច្ច័យ ឲ្យកើតលោភៈក្នុងភពថ្មី ។

២-**លោភឧស្សន្នភវតោ ច វនតា** ចុតិអំពីភពដែលច្រើនឬក្រាស់ទៅដោយលោភៈ មានន័យថា អ្នកដែលចុតិអំពីភព ដែលក្រាស់ ទៅដោយអារម្មណ៍របស់លោភៈ កាលកើតក្នុងជាតិថ្មីនេះ លោភៈក៏ជាប់មកតាម ជានិស្ស័យ ដែលហៅថារាគចរិត ប្រាថ្នារូប សំឡេង ក្លិន រស ផោដ្ឋព្វៈដែលល្អប្រសើរទើបជាហេតុឲ្យកើតលោភៈ បន្តទៅទៀត ។

៣-**ឥដ្ឋារម្មណ សមាយោគា** ប្រកបដោយអារម្មណ៍ ដែលគួរប្រាថ្នាក្នុងជាតិដែលខ្លួនកើតមកនេះ ប្រកប ឬប្រសព្វនឹងអារម្មណ៍ដែលល្អដែលគួរប្រាថ្នា ប្រសិនបើប្រកបដោយអារម្មណ៍មិនល្អទោសៈក៏កើតឡើង តែបើជួបប្រសព្វអារម្មណ៍ដែលល្អ លោភៈមានឱកាសក៏កើតឡើង ហើយកាលដែលជួបអារម្មណ៍ល្អ ក៏ប្រាថ្នាអារម្មណ៍នោះបន្ថែមទៀត គឺមិនចេះឆ្អែតមិនចេះពេញឡើយ ។

៤-**អស្សាទ ទស្សនំ** ឃើញវត្ថុដែលពេញចិត្ត សេចក្តីថា លោកមូលចិត្ត ដែលកើតឡើង ត្រូវមានការឃើញរូបដែលពេញចិត្ត ស្តាប់សំឡេងដែលពេញចិត្តជាដើម លោភៈក៏កើតឡើង ។

## ហេតុឲ្យកើតសោមនស្សមាន៤ប្រការ

១-**សោមនស្សបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិ ដោយសោមនស្ស មានន័យថា សភាពរបស់បដិសន្ធិចិត្តកើតព្រមជាមួយ សោមនស្សវេទនា ធម្មតាបុគ្គលដែលបដិសន្ធិដោយសោមនស្សនោះរមែងជាបុគ្គលមានសេចក្តីពេញចិត្ត ត្រេកត្រអាលនឹងអារម្មណ៍ដែលជាទីគាប់ចិត្ត តែប្រសិនបើជួបអារម្មណ៍មិនល្អវិញ ក៏កើតសេចក្តីក្តៅក្រហាយ ព្រោះដូច្នោះ កាលបដិសន្ធិដោយ សោមនស្ស ទើបជាហេតុឲ្យកើត លោភសោមនស្ស ។

២-**អគម្ភីរបកតិតា** ភាពជាអ្នកមានប្រក្រតីមិនសុខុមគឺ បុគ្គលដែលមិនមានសេចក្តីសុខជាប្រក្រតី ពេលលោភចិត្តកើតព្រមនឹង សោមនស្ស ក៏រមែងកើតសេចក្តីសប្បាយ ត្រេកត្រអាលរីករាយឡើង ទៅនឹងអារម្មណ៍នោះ យ៉ាងនេះឯងទើបហៅថា បុគ្គលមានប្រក្រតីមិនសុខុម ទើបជាហេតុឲ្យកើតមាន **លោភសោមនស្ស**។

៣-**ឥដ្ឋារម្មណ សមាយោគោ** ប្រកបនឹងឥដ្ឋារម្មណ៍គឺ ប្រសព្វតែនឹងរបស់ ដែលហែហមទៅដោយសេចក្តី ពេញចិត្តត្រេកត្រអាលជានិច្ច ទើបជាហេតុឲ្យកើត លោភសោមនស្ស ។

៤-**ព្យសនវិមុត្តិ** ផុតចាកសេចក្តីវិនាស៥យ៉ាង គឺថាផុតចាកសេចក្តីវិនាសណាមួយហើយ ក៏ជាហេតុឲ្យកើត លោភសោមនស្ស ។

## ព្យសនៈ សេចក្ដីវិនាស៥យ៉ាង

១- ញាតិព្យសនៈ សេចក្ដីវិនាសញាតិ

២- ភោគព្យសនៈ សេចក្ដីវិនាសភោគៈ

៣- រោគព្យសនៈ សេចក្ដីវិនាសព្រោះរោគ

៤- សីលព្យសនៈ សេចក្ដីវិនាសសីល

៥- ទិដ្ឋិព្យសនៈ សេចក្ដីវិនាសព្រោះទិដ្ឋិ

កាលបើព្យសនៈ ទាំង៥នេះ ណាមួយកើតឡើងហើយ លោកសោមនស្ស ចិត្តមិនងាយនឹងកើតឡើងឡើយ ។

## ហេតុឲ្យកើតទិដ្ឋិគតសម្បយុត្តមាន៥ប្រការគឺ

១-**ទិដ្ឋិជ្ឈាសយតា** ជាអ្នកមានការយល់ខុស ជាអធ្យាស្រ័យ មានសេចក្ដីថា លោកមូលចិត្ត ដែលប្រកបនឹងការយល់ខុស ព្រោះមាន អធ្យា-ស្រ័យ ចូលចិត្តតែគិតក្រៅហេតុផល ហើយសន្សំអប់រំតែក្នុងផ្លូវខុសទើបជាហេតុ ឲ្យកើត ទិដ្ឋិគតសម្បយុត្ត

២-**ទិដ្ឋិវិប្បន្នបុគ្គលសេវនតា** សេពគប់នឹងបុគ្គល ដែលយល់ខុស មានសេចក្ដីថា បុគ្គលដែលមានទិដ្ឋិវិបត្តិ គឺធ្វើឲ្យមានការយល់ខុស ដូចគ្នា ព្រោះបុគ្គលប្រភេទនោះតែងតែដឹកនាំ ឲ្យទៅតាមការយល់ឃើញរបស់ខ្លួន

## ទិដ្ឋិមានទោសច្រើននិងមានទោសធ្ងន់៣យ៉ាងគឺ

១-**អកិរិយទិដ្ឋិ** យល់ឃើញថាមិនមានការធ្វើល្អធ្វើអាក្រក់ទាំងអស់ ការបដិសេធការធ្វើហើយ រមែងមានការបដិសេធផលរបស់ការងារ នោះជាមិនខាន ។

២-**អហេតុកទិដ្ឋិ** យល់ថាអ្វីៗទាំងអស់មិនមានហេតុគឺបដិសេធផលរបស់ការធ្វើ កម្មមិនមានផលរបស់កម្ម មិនមានសេចក្តីព្យាយាម មិនមានអ្វីទាំងអស់ មិនថា សេចក្តីសុខ សេចក្តីទុក្ខ សេចក្តីបរិសុទ្ធ គឺកើតឡើងឯងដោយមិនមានហេតុបច្ច័យ

៣-**នត្ថិកទិដ្ឋិ** យល់ថាបុណ្យមិនមាន បាបមិនមាន គឺបដិសេធទាំងហេតុ ទាំងផល និងយល់ថាលោកនេះមិនមាន លោកខាងមុខមិនមានសត្វទាំងឡាយចប់ត្រឹមការស្លាប់ដូចគ្នានឹងឧច្ឆេទទិដ្ឋិដែរ សេចក្តីយល់ខុសទាំង៣នេះហៅថា **និយតមិច្ឆាទិដ្ឋិ** ជាការយល់ខុសលំបាកនឹងកែបាន ជាកម្មមានទោសធ្ងន់បំផុតផ្នែកខាងអកុសល ។

**៣សទ្ធម្មវិមុខតោ បែរមុខចេញអំពីព្រះសទ្ធម្ម**

- **ពាក្យថាវិមុខតោ** ប្រែថាបែរ ឬគេចមុខចេញគឺ មិនសិក្សា ព្រះសទ្ធម្ម

- ពាក្យថាព្រះសទ្ធម្ម នេះប្រែថា ធម៌របស់សប្បុរស ឬ ជាធម៌របស់អ្នកស្ងប់ ព្រះសទ្ធម្មនេះ ទីខ្លះហៅថា ពុទ្ធសាសនា ឬ ហៅថាព្រះធម៌វិន័យព្រះពុទ្ធសាសនានោះឬព្រះធម៌វិន័យនោះគឺ ព្រះត្រៃបិដក ។

**ព្រះសទ្ធម្មនោះមាន៣គឺ**

**១- បរិយត្តិ សទ្ធម្ម**

**២- បដិបត្តិ សទ្ធម្ម**

**៣- បដិវេធ សទ្ធម្ម**

ក្នុងអភិធម្មវិភង្គ ពោលនូវសទ្ធម្ម១០គឺ **មគ្គ៤ ផល៤ និព្វាន១ បរិយត្តិ១** កាលមិនបានសិក្សានូវព្រះសទ្ធម្មទេ ក៏មិនអាចលះបង់ការយល់ខុសបានឡើយ ។

៤-**មិច្ឆាវិតក្ក ពហុលតា** ជាអ្នកច្រើនទៅដោយ សេចក្តីត្រិះរិះខុសបានសេចក្តីថា ជាអ្នកត្រិះរិះនឹកគិតតែក្នុងផ្លូវខុស ដោយសភាពជាអ្នកមិនឈ្លាសវៃ ហៅថា មិច្ឆាវិតក្កៈ ឬ អកុសលវិតក្កៈ

**មិច្ឆាវិតក្កៈមាន៣យ៉ាងគឺ**

១-**កាមវិតក្ក** សេចក្តីត្រិះរិះនឹកគិត ក្នុង រូប សំឡេង ក្លិន រស និង ផោដ្ឋព្វៈ ដែលជាទីប្រាថ្នា ជាទីស្រឡាញ់ពេញចិត្ត ។

២-**ព្យាបាទវិតក្ក** សេចក្តីត្រិះរិះនឹកគិត ដោយអំណាច សេចក្តីព្យាបាទ ដូចអ្នកខ្លះខឹងក្រោធហើយ ក៏ចងកំហឹងនោះទុក ដោយការចងពៀរវេរា ។

៣-**វិហិង្សាវិតក្ក** សេចក្តីត្រិះរិះ នឹកគិតមិនចូលចិត្តនឹងអ្នកដទៃ ចង់ឲ្យតែអ្នកដទៃវិនាស ដោយសេចក្តីក្តៅក្រហាយណាមួយ ។

**៤-អយោនិសោ ឧម្មុជ្ជនំ**មិនពិចារណាដោយឧបាយនៃប្រាជ្ញាបានសេចក្តីថា ជាអ្នកមិនពិចារណាដោយត្រូវទំនង គឺកាលណាជួបប្រសព្វនឹងអារម្មណ៍ណាហើយ ក៏មិនពិចារណាអារម្មណ៍នោះ ឲ្យបានត្រឹមត្រូវ តាមសេចក្តីពិតយ៉ាងនេះ ក៏តែងធ្វើឲ្យកើតការយល់ខុស ។

**ហេតុឲ្យកើតទិដ្ឋិគតវិប្បយុត្តមាន៥ប្រការ**

១-**អទិដ្ឋិជ្ឈាសយតា** ជាអ្នកមិនមានសេចក្តីឃើញខុសជាអធ្យាស្រ័យ

២-**ទិដ្ឋិវិប្បន្ន បុគ្គលអសេវនតា** ជាអ្នកមិនសេពគប់បុគ្គលដែលមានការយល់ខុស

៣-**សទ្ធម្មសម្មុខតា** ជាអ្នកបែរមុខរកព្រះសទ្ធម្ម

៤-**មិច្ឆាវិតក្កា ពហុលតា** ជាអ្នកមិនច្រើន ទៅដោយការត្រិះរិះខុស

៥-**យោនិសោ ឧម្មុជ្ជនំ** មានការពិចារណាត្រូវទំនងអ្នកសិក្សាទាំងឡាយគប្បីជ្រាបថា សេចក្តីអធិប្បាយក្នុងទិដ្ឋិគតវិប្បយុត្តមានន័យផ្ទុយនឹងទិដ្ឋិគតសម្បយុត្ត ។

## ហេតុឲ្យកើតឧបេក្ខាលោភៈមាន៤ប្រការ

១-**ឧបេក្ខាបដិសន្ធិកតា** បដិសន្ធិដោយឧបេក្ខា មានន័យថា បុគ្គលដែលបដិសន្ធិ ដោយឧបេក្ខាវេទនា រមែងជាបុគ្គលព្រងើយៗ សូម្បីបានទទួលអារម្មណ៍ដែលល្អជាទីពេញចិត្តក៏ចិត្តនៅតែកណ្តាលមិនសោមនស្សភ្ញើតភ្ញើនច្រើនឡើយ ។

២-**គម្ភីរបកតិតា** ជាអ្នកមានប្រក្រតីសុខុម គឺមានសេចក្តីថា មិនប្រ-ថុយប្រថាន មិនងាយសប្បាយចិត្ត មិនងាយអន់ចិត្ត ចេះរម្ងាប់អារម្មណ៍បានអាចធ្វើឲ្យចិត្តជាកណ្តាល ពិចារណាអារម្មណ៍ យ៉ាងត្រឹមត្រូវ ដូច្នេះហើយទើបជាហេតុឲ្យកើត **ឧបេក្ខា** ។

៣-**មជ្ឈត្តតារម្មណ សមាយោគោ** ប្រកបនឹងអារម្មណ៍ ដែលជាកណ្តាល មានសេចក្តីថា ប្រកបដោយអារម្មណ៍យ៉ាងកណ្តាល ដែលធ្វើឲ្យចិត្តប្រសព្វអារម្មណ៍ល្មមប្រមាណមិនដល់ភាពជាសោមនស្សទើបជាហេតុឲ្យកើតឧបេក្ខា ។

៤-**ព្យសនវិមុត្តិ** ផុតចាកអំពីសេចក្តីវិនាស ព្រោះព្យសនៈធម៌តែងតែធ្វើឲ្យចិត្តកើតនូវទោមនស្សវេទនា ។

## ហេតុឲ្យកើតអសង្ខារិកៈមាន៦ប្រការ

១-**អសង្ខារិកកម្មជនិតបដិសន្ធិកតា** ជាអ្នកបដិសន្ធិដោយកម្មដែលជាអសង្ខារិកៈ ។

២-**កល្លកាយចិត្តតា** ជាអ្នកមានកាយ និងចិត្តរឹងមាំ បានសេចក្តីថា សភាពនៃកាយនិងចិត្តរបស់បុគ្គលនោះ មានអំណាចក្នុងខ្លួនហ៊ានសម្រេចហ៊ានធ្វើដោយខ្លួនឯង មិនត្រូវការដឹកនាំអំពីអ្នកដទៃ មិនងាយទៅតាមអ្នកណាៗឡើយ ។

៣-**ខន្តិពហុលតា** ជាអ្នកច្រើនទៅដោយការអត់ធន់ បានសេចក្តីថា ជាអ្នកមានការអត់ធន់ មានការព្យាយាមចំពោះភាពក្តៅ ត្រជាក់ អត់ធន់ចំពោះវត្ថុ ជាសឹកសត្រូវនឹងចិត្តរបស់ខ្លួនយ៉ាងនេះ ទើបជាហេតុធ្វើឲ្យ កើតអសង្ខារិកៈ ។

៤-**កត្តព្វកម្មេសុទិដ្ឋានិសំសតា** ជាអ្នកឃើញនូវប្រយោជន៍ ក្នុងការងារដែលគប្បីធ្វើ មានសេចក្តីថា ចិត្តរបស់គេបានឃើញផលនៃការធ្វើ គឺឃើញប្រយោជន៍ដែលសម្រេច អំពីការធ្វើ ក៏រមែងហ៊ានធ្វើ ដោយខ្លួនឯងដោយមិនអាស្រ័យអ្នកដទៃដឹកនាំ

៥-**កម្មេសុចិណ្ណវសិតា** ជាអ្នកជំនាញក្នុងការងារ ទាំងឡាយ បានសេចក្តីថា ជាអ្នកធ្លាប់បានធ្វើការងារនោះមកហើយ រួចក៏មានការជំនាញនោះ ទើបជាហេតុឲ្យកើតអសង្ខារិកៈ

៦- **ឧតុភោជនាទិសប្បាយលាភា** មានការសប្បាយចិត្តក្នុងឧតុ និង ភោជនជាដើម បានសេចក្តីថា បានទទួលនូវរដូវគឺឱកាសល្អ អាហារ សម រម្យក៏មានការស្រួលសុខសប្បាយ គឺមានអនាម័យល្អ ប្រាសចាកពោគភ័យ ចិត្តក៏សប្បាយរីករាយ អាចធ្វើកិច្ចការអ្វីៗ បានដោយចិត្តជាអសង្ខារិកៈ ។

**ហេតុឲ្យកើតសសង្ខារិកៈ មាន៦ប្រការ**

១-**សសង្ខារិកកម្មជនិត បដិសន្ធិកតា** បដិសន្ធិដោយកម្ម ដែលជា សសង្ខារិកៈ ។

២-**អកល្លកាយចិត្តតា** ជាអ្នកមានកាយ និងចិត្តមិនរឹងមាំ ។

៣-**អខន្តិពហុលតា** ជាអ្នកច្រើនទៅដោយការមិនអត់ធន់ ។

៤-**អកត្តព្វ កម្មេសុទិដ្ឋានិសំសតា** មិនបានឃើញនូវប្រយោជន៍ ក្នុង ការងារដែលធ្វើ ។

៥-**កម្មេសុអចិណ្ណវសិតា** ជាអ្នកមិនជំនាញ មិនឈ្លាសវៃក្នុងការងារ ទាំងឡាយ ។

៦-**ឧតុភោជនាទិអសប្បាយលាភា** មិនមានសេចក្តីសុខសប្បាយក្នុង ឧតុ និងភោជនជាដើម ហេតុដែលកើតសសង្ខារិកៈទាំង ៦ប្រការនេះមាន ន័យខ្ទីមសារ ផ្ទុយនឹងហេតុឲ្យកើតអសង្ខារិក៦ប្រការ ដូច្នេះអ្នកសិក្សាគប្បី ប្រៀបធៀបផងចុះ ។

**ចំណែកលោភមូលចិត្ត៨ដួងដោយន័យ១៤ គឺ**

១-**ន័យដោយជាតិ** លោភមូល៨ដួង ជាអកុសលជាតិ

២-**ន័យដោយភូមិ** លោភមូលចិត្ត៨ដួង កើតបាន៣០ភូមិ ( វៀរ

អសញ្ញីសត្តភូមិ)

៣-**ន័យដោយវេទនា** លោភមូលចិត្ត៨ដួង ជាសោមនស្ស៤ ដួង ជាឧបេក្ខា៤ដួង

៤-**ន័យដោយហេតុ** លោភមូលចិត្ត៨ដួង ជានហេតុនិងជាទ្វិហេតុកចិត្តទាំង៨ដួង

៥-**ន័យដោយសង្ខារ** លោភមូលចិត្ត៨ដួង ជាអសង្ខារិកៈ៤ដួង ជាសសង្ខារិកៈ៤ដួង

៦-**ន័យដោយសម្បយុត្ត** លោភមូលចិត្ត៨ដួង ជាទិដ្ឋិគតសម្បយុត្ត ៤ ដួង ជាទិដ្ឋិគតវិប្បយុត្ត ៤ដួង

៧-**ន័យដោយសោភណៈ** លោភមូលចិត្ត៨ដួង ជាអសោភណចិត្ត

៨-**ន័យដោយឈាន** លោភមូលចិត្ត៨ដួង ជាអឈានចិត្ត

៩-**ន័យដោយលោកិយៈ** លោភមូលចិត្ត៨ដួង ជាលោកិយចិត្ត

១០-**ន័យដោយកិច្ច** លោភមូលចិត្ត៨ដួង ធ្វើជវនកិច្ច

១១-**ន័យដោយអារម្មណ៍** លោភមូលចិត្ត៨ដួង ជាចិត្តកើតបានតាមអារម្មណ៍៦

១២-**ន័យដោយទ្វារ** លោភមូលចិត្ត៨ដួងជាចិត្តកើតបានតាមទ្វារ៦

១៣-**ន័យដោយវត្ថុ** លោភមូលចិត្ត៨ដួង កើតត្រង់ហទយវត្ថុ (នេះពោលដោយភូមិដែលមានខន្ធ៥ ចំណែកក្នុងអរូបភព លោភៈកើតមិនអាស្រ័យហទយវត្ថុទេ) ។

១៤-**ន័យដោយវិញ្ញាណធាតុ** លោភមូលចិត្ត៨ដួង ជាមនោវិញ្ញាណ

ធាតុ ។

## ផលរបស់លោភមូលចិត្ត

ផលនៃលោភមូលចិត្ត ដែលកើតប្រាកដក្នុងបច្ចុប្បន្ន ព្រះអង្គទ្រង់ត្រាស់ថា រមែងកើតស្រុកទុរ្ភិក្ស អន្តរាយផ្សេងៗដល់មហាជនមានប្រមាណមិនបាន កាលណាសន្តានចិត្ត នៃមនុស្ស ក្រាស់ទៅដោយលោភៈ ។ ផលនៃលោភមូលចិត្ត ដែលកើតប្រាកដក្នុងអនាគតកាល ព្រះអង្គទ្រង់ត្រាស់ថា សត្វទាំងឡាយជាច្រើន តែងទៅកាន់បេតវិស័យ គឺកំណើតប្រេត ព្រោះលោភៈជាហេតុ ។

(ចប់លោភមូលចិត្ត៨ដួង)

## ទោសមូលចិត្ត២ដួង

**១-ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ** ចិត្តកើតព្រមដោយទោមនស្សប្រកបដោយបដិឃៈគឺសេចក្ដីថ្នាំងថ្នាក់មិនមានការដឹកនាំ

**២-ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ** ចិត្តកើតព្រមដោយទោមនស្ស ប្រកបដោយបដិឃៈ គឺសេចក្ដីថ្នាំងថ្នាក់ មានការដឹកនាំ។

**ទោសមូលចិត្ត** ឬហៅថា **បដិឃសម្បយុត្តចិត្ត** ឬហៅថា **បដិឃចិត្ត** ជាចិត្តកើតព្រោះមានទោសជាហេតុ។ សេចក្ដីមិនប្រាថ្នាក្នុងអារម្មណ៍ផ្សេងៗនោះតែងតែកើតឡើងព្រោះ ទោសៈជាដើមហេតុ ។ទោសៈជាអកុសលចេតសិកតាក់តែងចិត្តឲ្យកើតសេចក្ដីក្រោធ សេចក្ដីស្អប់ខ្ពើម សេចក្ដីខ្លាចសេចក្ដីអន់ចិត្ត សេចក្ដីព្រួយបារម្ភ រំខានចិត្តជាដើម ព្រោះទោសៈ ជាសភាវៈ គ្រោតគ្រាតសៅហ្មង មិនល្អិតសុខុមនោះទេ ។

- ពាក្យថា**ទោមនស្សសហគត** ប្រែថាចិត្តកើតព្រមដោយទោមនស្សវេទនា គឺសភាពនៃចិត្តអាក្រក់ ឬសភាពលំបាកនៃចិត្ត ។

- ពាក្យថា **បដិឃសម្បយុត្ត** ប្រែថា ប្រកបដោយបដិឃៈ គឺសេចក្តីថ្នាំងថ្នាក់ចំពោះអារម្មណ៍ ។ ទោសមូលចិត្ត មានលក្ខណៈផ្ទុយអំពី លោភមូលចិត្ត គឺថាលោភមូលចិត្ត មានការជាប់ជំពាក់នឹងអារម្មណ៍ រីឯទោសចិត្តមានការប្រទូស្តនឹងអារម្មណ៍ ។ ស័ព្ទ ដែលជាឈ្មោះនៃទោសៈ មានច្រើនយ៉ាងដូចពាក្យថា

- **អាឃាតោ** = អាឃាតគឺជាសេចក្តីក្រោធ ព្យាបាទ
- **បដិឃាតោ** = ខឹង ស្អប់ មិនពេញចិត្ត
- **បដិឃំ** = សេចក្តីថ្នាំងថ្នាក់ ទាស់ចិត្ត
- **បដិវិរោធោ** = សេចក្តីគុំគួន ចងកំហឹងទុកក្នុងខ្លួន

## លក្ខណាទិចតុកៈនៃទោសៈ

-**ចណ្ឌិកលក្ខណោ** មានការ កាចសាហាវ ជាលក្ខណៈ
- **និស្សយទហនរសោ** មានការដុតពោលនូវសម្បយុត្តធម៌ជាកិច្ច
- **ទូស្សនបច្ចុប្បដ្ឋានោ** មានការប្រទូស្តរាយ ជាអាការប្រាកដ ។
- **អាឃាតវត្ថុបទដ្ឋានោ** មានអាឃាតវត្ថុ ជាបទដ្ឋាន ។

## អាឃាតវត្ថុ១០ប្រការ

១-អាឃាតគេដោយគិតថា អ្នកនោះបានធ្វើសេចក្តីវិនាសដល់យើង

២-អាឃាតគេ ដោយគិតថា អ្នកនោះកំពុងតែធ្វើនូវ សេចក្តីវិនាសដល់យើង

៣-អាឃាតគេដោយគិតថា អ្នកនោះនឹងធ្វើសេចក្ដីវិនាសដល់យើង

៤-អាឃាតគេដោយគិតថា អ្នកនោះធ្លាប់បានធ្វើ នូវសេចក្ដីវិនាសដល់អ្នកដែលយើងស្រឡាញ់

៥-អាឃាតគេដោយគិតថា អ្នកនោះកំពុងធ្វើ នូវសេចក្ដីវិនាស ដល់អ្នកដែលយើងស្រឡាញ់

៦-អាឃាតគេដោយគិតថា អ្នកនោះនឹងធ្វើ នូវសេចក្ដីវិនាសដល់អ្នកដែលយើងស្រឡាញ់

៧-អាឃាតគេដោយគិតថា អ្នកនោះធ្លាប់បានធ្វើ នូវប្រយោជន៍ដល់អ្នកដែលយើងស្អប់

៨-អាឃាតគេដោយគិតថា អ្នកនោះកំពុងធ្វើនូវប្រយោជន៍ដល់អ្នកដែលយើងស្អប់

៩-អាឃាតគេដោយគិតថា អ្នកនោះនឹងធ្វើ នូវប្រយោជន៍ ដល់អ្នកដែលយើងស្អប់

១០-អាឃាតក្នុងឋានៈមិនសមគួរ ដូចជាក្នុងខណៈ ដើរជំពប់ជើងឬជាន់ភ្លើងជាដើម ។

## ហេតុឲ្យកើតទោសមូលចិត្តមាន៤ប្រការ

១-**ទោសជ្ឈាសយតា** មានអធ្យាស្រ័យ ជាអ្នកចងនូវសេចក្ដី ក្រោធទុកមានសេចក្ដីថា ជាអ្នកមាននិស្ស័យខាង សេចក្ដីក្រោធ ព្រោះសន្សំទុកនូវសេចក្ដីក្រោធ ក្នុងសន្ដាន ជាយូរអង្វែងណាស់មកហើយ ។

២-**អគម្ភីរបកតិតា** មានសភាពមិនសុខុម ជាប្រក្រតី មានសេចក្ដីថាពេល

ទោសមូលចិត្តកើតឡើង ចិត្តទោសៈនេះ មិនបាននាំមក នូវសេចក្តីសុខមទេ តែងញុាំងសភាវៈ ដែលមិនមែនជាប្រយោជន៍ ឲ្យកើតឡើងជានីវរណៈ រាំងចិត្តមិនឲ្យដឹងនូវអត្ថ និងធម៌តាមសេចក្តីពិត ។

៣-**អប្បសុតតា** មានការស្តាប់នូវព្រះសទ្ធម្មតិច កាលណាបុគ្គលសិក្សារៀនសូត្រ នូវព្រះសទ្ធម្មតិចតួច តែងមិនដឹងថាធម៌ណា ជាគុណ ធម៌ណាជាទោស ធម៌ណាមានប្រយោជន៍ធម៌ណាគួរចម្រើន កាលមិនដឹងនូវសភាវៈធម៌នោះហើយ ជាហេតុឲ្យទោសៈកើតឡើង ។

៤-**អនិដ្ឋារម្មណ សមាយោគោ** ប្រកបនឹងអារម្មណ៍មិនល្អមិនគាប់ចិត្ត មានសេចក្តីថា ពេលបានជួបអារម្មណ៍ដែលមិនជាទីប្រាថ្នាដូចជាបានឃើញរូបមិនល្អជាដើម ទោសៈក៏កើតឡើង ។

**ធម៌ដែលជាហេតុលះទោសៈមាន៦ប្រការ**

១-**មេត្តានិមិត្តស្សឧគ្គហោ** ការរៀននូវមេត្តានិមិត្ត

២-**មេត្តាភាវនានុយោគោ** ការចម្រើននូវមេត្តាភាវនា

៣-**កម្មស្សកតា បច្ចវេក្ខណា** ការពិចារណាថាសត្វមានកម្មជារបស់ខ្លួន

៤-**បដិសង្ខាន ពហុលីកតា** ភាពជាអ្នកច្រើនទៅដោយការពិចារណា

៥-**កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត

៦-**សប្បាយកថា** សន្ទនារឿងដែលសប្បាយ (ដែលសមគួរ)

**ទោសនៃបុគ្គលអ្នកក្រោធមាន៩ប្រការ**

១-**ទុព្វណ្ណោ** ជាអ្នកមានសម្បុរអាក្រក់

២-**ទុក្ខំសេតិ** រមែងដេកជាទុក្ខ

៣-**ធនជានី និគច្ឆតិ** រមែងដល់នូវការសាបសូន្យ ទ្រព្យសម្បត្តិ

៤-**អាយសក្ខី និគច្ឆតិ** រមែងដល់នូវសេចក្ដីអាប់យស

៥-**ញាតិមិត្តតា សុហជ្ជា ច បរិវជ្ជន្តិ** រមែងឃ្លាតចាកញាតិមិត្ត

៦-**អនត្ថ ជននោ** ជាអ្នកមិនដឹងនូវសេចក្ដីចម្រើន

៧-**អត្ថំ នជានាតិ** រមែងមិនដឹងនូវ អត្ថ

៨-**ធម្មំ នបស្សតិ** រមែងមិនឃើញនូវធម៌

៩-ចិត្តប្បកោបនោ រមែងធ្វើចិត្តឲ្យកម្រើក

**ចំណែកទោសមូលចិត្ត២ដួងដោយន័យ១២**

១-**ន័យដោយជាតិ** ទោសមូលចិត្ត ២ដួង ជាអកុសលជាតិ

២-**ន័យដោយភូមិ** ទោសមូលចិត្ត ២ដួង ជាកាមាវចរភូមិ (កើតបានក្នុងភូមិ ១១ )

៣-**ន័យដោយវេទនា** ទោសមូលចិត្ត២ដួងជាទោមនស្សវេទនា

៤-**ន័យដោយហេតុ** ទោសមូលចិត្ត២ដួងជានហេតុនិងជាទ្វិហេតុក:

៥-**ន័យដោយសង្ខារ** ទោសមូលចិត្ត២ដួងជា អសង្ខារិក:១ដួង ជាសសង្ខារិក:១ ដួងៗ

៦-**ន័យដោយសម្បយុត្ត** ទោសមូលចិត្ត ២ដួង ជាបដិឃសម្បយុត្ត

៧-**ន័យដោយសោភណ:** ទោសមូលចិត្ត ២ដួង

ជាអសោភណចិត្ត

៨-**ន័យដោយឈាន** ទោសមូលចិត្ត ២ដួង ជាអឈានចិត្ត

៩-**ន័យដោយលោកិយ:** ទោសមូលចិត្ត ២ដួង ជាលោកិយចិត្ត

១០-**ន័យដោយកិច្ច** ទោសមូលចិត្ត ២ដួង ធ្វើជវនកិច្ច

១១-**ន័យដោយអារម្មណ៍** ទោសមូលចិត្ត ២ដួង មានអារម្មណ៍៦

១២-**ន័យដោយទ្វារ** ទោសមូលចិត្ត ២ដួង កើតក្នុងទ្វារ៦

១៣-**ន័យដោយវត្ថុ** ទោសមូលចិត្ត ២ដួង ជាចិត្តកើត ត្រង់ហទយវត្ថុ គឺបេះដូង

១៤-**ន័យដោយវិញ្ញាណធាតុ** ទោសមូលចិត្ត២ដួងជាមនោវិញ្ញាណធាតុ

## ផលរបស់ទោសមូលចិត្ត

សម័យណា មនុស្សមានចិត្តសន្តានអាក្រក់ ច្រើនទៅដោយទោសៈ សម័យនោះ តែងកើតសត្ថន្តរាយ (អន្តរាយដែលកើតអំពីការបៀតបៀនគ្នាដោយសស្ត្រាវុធផ្សេងៗ) ។ ក្នុងអនាគតកាល ព្រោះទោសៈជាហេតុ សត្វទើបទៅកាន់នរក ព្រោះសភាពនៃចិត្តនោះ ជាចិត្តសាហាវ ។

## មោហមូលចិត្ត២ដួង

១-**ឧបេក្ខាសហគតំ វិចិកិច្ឆា សម្បយុត្តំ** មោហមូលចិត្តដែលកើតឡើង ព្រមជាមួយឧបេក្ខាវេទនា ប្រកបដោយវិចិកិច្ឆា (គឺសេចក្តី សង្ស័យ)។

២-**ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ** មោហមូលចិត្តដែលកើត ព្រមជាមួយឧបេក្ខាវេទនា ប្រកបដោយឧទ្ធច្ចៈ (គឺសេចក្តីរវើរវាយ ) ។

មោហមូលចិត្តជាចិត្តមានមោហៈជាហេតុជាចិត្តមិនដឹង វង្វេង ល្ងង់ខ្លៅ មិនដឹងតាមសេចក្តីពិត ។ **វិចិកិច្ឆា**ជាធម្មជាតិដែលជាហេតុឲ្យសម្រេចសភាវធម៌បានដោយលំបាក ជាធម៌ឃាត់ឃាំងនូវបញ្ញា ។ ចិត្តដែលប្រកប

ដោយ វិចិកិច្ឆា ឈ្មោះថា វិចិកិច្ឆាសម្បយុត្តចិត្ត ។ ឧទ្ធច្ចៈ ជាសភាវៈនៃចិត្ត ដែលរវើរវាយ ចិត្តដែលប្រកបនឹងឧទ្ធច្ចៈឈ្មោះថា ឧទ្ធច្ចសម្បយុត្តចិត្ត ។ ឧទ្ធច្ចៈជាអកុសលចេតសិក កើតទូទៅក្នុងអកុសលចិត្ត ប៉ុន្តែជាប្រធានក្នុងសម្បយុត្តធម៌ ក្នុងមោហមូលចិត្តដួងទី ២គឺជាឧទ្ធច្ចនីវរណៈ ។ មោហមូលចិត្តទាំង ២ដួងនេះ មិនមែនជាចិត្តត្រេកត្រអាលនឹងខឹងក្រោធក្នុងអារម្មណ៍ ព្រោះជាសភាវៈនៃចិត្តវង្វេង លង់ខ្លៅ យ៉ាងក្រៃលែង និងញាប់ញ័រព្រោះប្រកបដោយវិចិកិច្ឆានិងឧទ្ធច្ចៈដែលប្រព្រឹត្តទៅជាមួយសេចក្តីរសាប់រសល់ និងការរវើរវាយ ហើយតែងកើតព្រមនឹងឧបេក្ខាវេទនាប៉ុណ្ណោះ មានមោហចេតសិកជាមូលហៅថា **ឯកហេតុកចិត្ត** គឺចិត្តមានហេតុ ១(មិនមានលោភៈនិងទោសៈជាហេតុទេ ) ។

**ហេតុឲ្យកើតមោហមូលចិត្តមាន ២ប្រការ**

១-**អយោនិសោមនសិការោ** ការធ្វើទុកក្នុងចិត្ត មិនដោយឧបាយនៃប្រាជ្ញា។

២-**អាសវសមុប្បាទោ** មានអាសវៈជាហេតុជិតឲ្យកើតឡើង ។

ពាក្យថា **អយោនិសោមនសិការោ** បានដល់ការមិនពិចារណា នូវអារម្មណ៍ដែលមកប៉ះខ្ទប់តាមទ្វារនោះហើយ មិនឲ្យឃើញតាមសេចក្តីពិត មិនពិចារណាផល មិនពិចារណាសភាវៈខាងដើមនិងខាងចុងទើបជាហេតុឲ្យកើត **មោហមូលចិត្ត** ២ដួង។ពាក្យថា **អាសវៈ**នោះបានដល់កិលេសដែលជាគ្រឿងដេកត្រាំនៅក្នុងចិត្តសន្តាន ។

**អាសវៈនោះមាន៤ប្រការ គឺ**

១-**កាមាសវៈ** អាសវៈគឺកាមបានដល់សេចក្តីស្រឡាញ់ ពេញចិត្តក្នុងរូបសំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ ។

២-**ភវាសវៈ** អាសវៈគឺភពបានដល់ សេចក្តីត្រេកអរ ជាប់ជំពាក់ចិត្តក្នុងភព ៣ ។

៣-**ទិដ្ឋាសវៈ** អាសវៈគឺទិដ្ឋិបានដល់ មិច្ឆាទិដ្ឋិទាំងអស់

៤-**អវិជ្ជាសវៈ** អាសវៈគឺអវិជ្ជាបានដល់ សេចក្តីល្ងង់ខ្លៅ មិនដឹងពិតក្នុងសភាវៈទាំងពួង ។

មោហចេតសិកនេះ ក្នុងធម្មសង្គណី លោកពោលទុកមានពាក្យជាដើមថា

១-**អញ្ញាណំ** ការមិនដឹង

២-**អទស្សនំ** ការមិនឃើញ

៣-**អនភិសមយោ** ការមិនត្រាស់ដឹង

៤-**អននុពោធោ** ការមិនដឹងដោយសមគួរ

**លក្ខណាទិចតុក:របស់មោហៈ**

- **អញ្ញាណលក្ខណោ** មានការមិនដឹងជាលក្ខណៈ
- **អារម្មណសភាវច្ឆាទនរសោ** មានការបាំងបិទនៃអារម្មណ៍ ជាកិច្ច
- **អន្ធការបច្ចុប្បដ្ឋានោ** មានការងងិតសូន្យឈឹង ជាអាការៈប្រាកដ
- **អយោនិសោមនសិការបទដ្ឋានោ** មានការធ្វើទុកក្នុងចិត្ត មិនត្រូវទំនង គឺមិនធ្វើទុកដោយឧបាយនៃប្រាជ្ញា ជាបទដ្ឋាន (ជាហេតុជិត) ។

**លក្ខណាទិចតុក:របស់ វិចិកិច្ឆា**

- ***សំសយលក្ខណា*** មានសេចក្តីសង្ស័យជាលក្ខណៈ

- ***កម្បនរសា*** មានការញាប់ញ័រ ក្នុងអារម្មណ៍ជាកិច្ច

- ***អនិច្ឆយបច្ចុប្បដ្ឋានា*** មានការសម្រេចចិត្តមិនបានជាអាការប្រាកដ

- ***អយោនិសោមនសិការ បទដ្ឋានា*** មានការធ្វើទុកក្នុងចិត្តមិនដោយឧបាយនៃប្រាជ្ញា ជា បទដ្ឋាន ។

## សេចក្តីសង្ស័យ ៨ប្រការ

១-***ពុទ្ធេកង្ខតិ*** សង្ស័យក្នុងព្រះពុទ្ធ

២-***ធម្មេកង្ខតិ*** សង្ស័យក្នុងព្រះធម៌

៣-***សង្ឃេកង្ខតិ*** សង្ស័យក្នុងព្រះសង្ឃ

៤-***សិក្ខាយកង្ខតិ*** សង្ស័យក្នុងសិក្ខា

៥-***បុព្វន្តេកង្ខតិ*** សេចក្តីសង្ស័យក្នុងខន្ធជាអតីត

៦-***អបរន្តេកង្ខតិ*** សេចក្តីសង្ស័យក្នុងខន្ធជាអនាគត

៧-***បុព្វន្តាបរន្តេកង្ខតិ*** សេចក្តីសង្ស័យក្នុងខន្ធជាអតីតនិងអនាគត

៨-***បដិច្ចសមុប្បាទេកង្ខតិ*** សេចក្តីសង្ស័យក្នុងបដិច្ចសមុប្បាទធម៌

## អធិប្បាយវិចិកិច្ឆា៨

១-ពាក្យថា***ពុទ្ធេកង្ខតិ*** គឺសង្ស័យក្នុងព្រះសរីរៈរបស់ព្រះពុទ្ធជាម្ចាស់ថា មានពិតមែនឬទេ ? ប្រហែលជាសន្មតិឡើង ដើម្បីជាឧបាយឲ្យ មនុស្សសាមគ្គីគ្នាប៉ុណ្ណោះទេ សង្ស័យក្នុងព្រះពុទ្ធគុណទាំង១០បទ មានពាក្យថា ***អរហំ*** ជាដើម តើព្រះនាមទាំងនេះមានពិតមែនទេ ?

២-ពាក្យថា ***ធម្មោកង្ខតិ*** សង្ស័យក្នុងព្រះធម៌គឺ មគ្គ៤ផល៤ និព្វាន១

ឬ ក្នុងព្រះធម្មគុណ៦បទ មានពាក្យថា **ស្វាក្ខាតោ** ជាដើម តើព្រះធម៌ទាំងនេះ នឹងឲ្យផុតទុក្ខពិត ឬមិនពិត ?

៣-ពាក្យថា **សង្ឃេកង្ខតិ** សង្ស័យក្នុងសង្ឃគុណ ទាំង៩បទថា មានពិត ឬទេ ?

៤-ពាក្យថា**សិក្ខាយកង្ខតិ** សង្ស័យក្នុងសិក្ខា៣គឺ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា ថាពិត ឬទេ ? សង្ស័យ ក្នុងផលានិសង្ស ក្នុងការបដិបត្តិក្នុងសិក្ខាទាំង៣នោះ ថាតើនឹងជួយមិនឲ្យទៅកាន់អបាយ ភូមិពិត ឬទេ ? **អធិសីលសិក្ខាលោកិយ:**គឺបាតិមោក្ខសំវរសីល បើជាលោកុត្តរសីល គឺសីលដែលសម្បយុត្ត ជាមួយ មគ្គ ផល ។ **អធិចិត្តសិក្ខាលោកិយ:**គឺសមាបត្តិ ៨ចិត្តដែលជាបាតនៃវិបស្សនា បើជាលោកុត្តរចិត្ត គឺ ចិត្តដែលសម្បយុត្តជាមួយ មគ្គ ផល ។

**អធិបញ្ញាសិក្ខាលោកិយ:** គឺវិបស្សនាញាណ បើជាលោកុត្តរបញ្ញា គឺ បញ្ញាដែលសម្បយុត្ត ជាមួយ មគ្គ ផល ។

៥-ពាក្យថា **បុព្វន្តេកង្ខតិ** សង្ស័យក្នុងខន្ធ អាយតន: ធាតុ ដែលជាអតីត:សន្មតិថាជាតួខ្លួន ជាសត្វបុគ្គលមានពិតឬទេ ? ហើយជាតិមុនមានពិតឬទេ ?

៦-អបរន្តេកង្ខតិ សង្ស័យក្នុង ខន្ធ អាយតន: ធាតុ ដែលជាអនាគត គឺ សភាវ:ធម៌ដែលសន្មតិថា ជាសត្វបុគ្គល តួខ្លួន នឹងប្រាកដក្នុងអនាគត តើមានឬទេ ? ឬ សង្ស័យថាសត្វស្លាប់ហើយ នឹងកើតក្នុងភពជាតិមុខមានពិតឬទេ ?

៧-ពាក្យថា **បុព្វន្តាបរន្តេកង្ខតិ** សង្ស័យក្នុង ខន្ធ អាយតនៈ ធាតុ ដែលជាអតីតៈ និងជាអនាគត នឹងមានពិតឬទេ ?

៨-ពាក្យថា **បដិច្ចសមុប្បាទេកង្ខតិ** សង្ស័យធម៌ដែលជា បដិច្ចសមុប្បាទ ក្នុងជាតិនេះថា អវិជ្ជា ជាបច្ច័យឲ្យកើតឡើងក្នុងភព ជាអភិសង្ខារ គឺជាកម្មដែលតាក់តែង ភពជាតិកំណើត បន្តទៅក្នុងភពថ្មីទៀត មានពិត ឬ ទេ ?

## សង្ស័យ១៦ប្រការតាមន័យក្នុងព្រះសូត្រ

បណ្តាការសង្ស័យនោះ មាន១៦ប្រការ តាមន័យក្នុងព្រះសូត្រ គឺ សង្ស័យក្នុងអតីតៈ៥ប្រការ ក្នុងអនាគត៥ប្រការ ក្នុងបច្ចុប្បន្ន៦ប្រការ

### សង្ស័យក្នុងអតីតៈមាន៥ប្រការគឺ

១-យើងធ្លាប់កើតមកហើយ ក្នុងអតីតៈ ឬមិនធ្លាប់ហ្ន៎ ?

២-យើងមិនធ្លាប់កើតមកហើយ ក្នុងអតីតៈ ឬក៏ធ្លាប់ហ្ន៎ ?

៣-យើងធ្លាប់កើត ក្នុងអតីតៈជាអ្វី ហ្ន៎ ?

៤-ក្នុងអតីតៈយើងមានរូបសណ្ឋាន យ៉ាងណាហ្ន៎ ?

៥-យើងធ្លាប់កើតជាអ្វី ហើយកើតជាសត្វអ្វី ដែរហ្ន៎ ?

### សង្ស័យក្នុងអនាគតមាន៥ប្រការគឺ

១-យើងនឹងកើតក្នុងអនាគត ឬទេហ្ន៎ ?

២-យើងនឹងមិនកើតក្នុងអនាគត ឬទេហ្ន៎ ?

៣-យើងនឹងកើតក្នុងអនាគត ជាអ្វីដែរហ្ន៎ ?

៤-អនាគតយើងនឹងមានរូបរាងយ៉ាងណាដែរហ្ន៎ ?

៥-យើងនឹងកើតជាអ្វី ហើយនឹងកើតជាសត្វអ្វី ហ្ន៎?

## សង្ស័យក្នុងបច្ចុប្បន្នមាន៦ប្រការគឺ

១-យើងកំពុងមាន ឬទេហ្ន៎?

២-យើងមិនមាន ឬទេហ្ន៎?

៣-យើងជាអ្វីហ្ន៎?

៤ យើងមានសណ្ឋានយ៉ាងណាហ្ន៎?

៥-យើងជាសត្វ មកអំពីណាហ្ន៎?

៦-សត្វគឺយើងនឹងកើតក្នុងទីណាហ្ន៎?

## ធម៌ដែលជាហេតុលះវិចិកិច្ឆាមាន៦ប្រការ

១-**ពហុស្សុតតា** ភាពជាអ្នកស្តាប់ច្រើន

២-**បរិបុច្ឆកតា** ភាពជាអ្នកចេះសាកសួរ

៣-**វិនយេបកតញ្ញុតា** សេចក្តីដឹងទូទៅក្នុងព្រះវិន័យ

៤-**អធិមោក្ខពហុលតា** ភាពជាអ្នកច្រើនទៅដោយអធិមោក្ខ (គឺការតាំងនៅស៊ប់)

៥-**កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អ

៦-**សប្បាយកថា** មានការពោលជាសេចក្តីសប្បាយ (តាមសមគួរ)

## លក្ខណាទិចតុក:របស់ឧទ្ធច្ច:

- **អវូបសមលក្ខណំ** មានសេចក្តីស្ងប់ ជាលក្ខណ:
- **អនវត្ថានរសំ** មានការមិនតាំងនៅក្នុងអារម្មណ៍ តែមួយជាកិច្ច
- **ភន្តត្តបច្ចុប្បដ្ឋានំ** មានសេចក្តីញាប់ញ័រ ភ័ន្តភាំង ជាអាការប្រាកដ

- **អយោនិសោមនសិការបទដ្ឋានំ** មានការធ្វើទុកក្នុងចិត្ត មិនត្រូវទំនងគឺធ្វើទុកក្នុងចិត្តមិនដោយឧបាយនៃប្រាជ្ញា ជា បទដ្ឋាន ។

**ធម៌ដែលជាហេតុលះឧទ្ធច្ចៈមាន៦ប្រការ**

១-**ពហុស្សុតតា** ភាពជាអ្នកស្តាប់ច្រើន

២-**បរិបុច្ឆកតា** ភាពជាអ្នកចេះសាកសួរ

៣-**វិនយេបកតញ្ញុតា** សេចក្តីដឹងទូទៅក្នុងព្រះវិន័យ

៤-**ពុទ្ធសេវិតា** ជាអ្នកពេញចិត្តក្នុងធម៌របស់ព្រះពុទ្ធជាម្ចាស់

៥-**កល្យាណមិត្តតា** ភាពអ្នកមានមិត្តល្អ

៦-**សប្បាយកថា** មានការពោលសេចក្តីសប្បាយ (តាមសមគួរ)

**ចំណែកមោហមូលចិត្ត២ដួងដោយន័យ១៤**

១-**ន័យដោយជាតិ** មោហមូលចិត្ត២ដួង ជាអកុសលជាតិ

២-**ន័យដោយភូមិ** មោហមូលចិត្ត២ដួង ជាកាមាវចរភូមិ

៣-**ន័យដោយវេទនា** មោហមូលចិត្ត២ដួង ជាឧបេក្ខាវេទនា

៤-**ន័យដោយហេតុ** មោហមូលចិត្ត២ដួង ជានហេតុ និងជា ឯកហេតុកចិត្ត

៥-**ន័យដោយសង្ខារ** មោហមូលចិត្ត២ដួង ជាអសង្ខារិកៈ

៦-**ន័យដោយសម្បយុត្ត** មោហមូលចិត្ត២ដួង ជាសម្បយុត្តចិត្ត

៧-**ន័យដោយសោភណៈ** មោហមូលចិត្ត២ដួង ជាអសោភណចិត្ត

៨-**ន័យដោយឈាន** មោហមូលចិត្ត២ដួង ជាអឈានចិត្ត

៩-**ន័យដោយលោកិយៈ** មោហមូលចិត្ត២ដួង ជាលោកិយចិត្ត

១០-**ន័យដោយកិច្ច** មោហមូលចិត្ត២ដួង ជាចិត្តធ្វើជវនកិច្ច

១១-**ន័យដោយអារម្មណ៍** មោហមូលចិត្ត២ដួង ជាចិត្តមាន អារម្មណ៍៦

១២-**ន័យដោយទ្វារ** មោហមូលចិត្ត២ដួងជាចិត្តកើតបានតាមទ្វារ៦

១៣-**ន័យដោយវត្ថុ** មោហមូលចិត្ត២ដួង កើតត្រង់ហទយវត្ថុ

១៤-**ន័យដោយវិញ្ញាណធាតុ** មោហមូលចិត្ត២ដួង ជាមនោវិញ្ញាណធាតុ ។

## វិបាកដែលកើតអំពីមោហមូលចិត្ត ២ដួង

មោហមូលចិត្ត ជាចិត្តល្ងង់ខ្លៅ បុគ្គលណាមានមោហចេតសិកគ្របសង្កត់ហើយ បុគ្គលនោះ រមែងងងឹតសូន្យឈឹង មិនដឹងនូវអារម្មណ៍ តាមសភាវៈពិតឡើយ មនុស្សក្នុងសម័យណា មានសន្ដានចិត្តពោរពេញទៅដោយមោហៈ រមែងកើតរោគន្ទ្រាយ (អន្ទ្រាយកើតអំពីរោគបៀតបៀន) ជាហេតុឲ្យកើតរោគខ្យល់ស្ទាប់ជាច្រើនយ៉ាងនេះជាដើម ។

បំណែកក្នុងអនាគតជាតិ មោហមូលចិត្តរមែងឲ្យមនុស្សជាអ្នកច្រើនដោយមោហៈនោះ កើតក្នុងកំណើតជាសត្វតិរច្ឆាន ។

## សេចក្ដីស្រវឹងមាន២៧ប្រការ

(ក្នុងអភិធម្មបិដក គម្ពីរវិភង្គតតិយភាគ)

១-**ជាតិមទោ** សេចក្ដីស្រវឹងព្រោះ ជាតិ

២-**គោត្តមទោ** សេចក្ដីស្រវឹងព្រោះ គោត្ត

៣-**អារោគ្យមទោ** សេចក្ដីស្រវឹងព្រោះ ការមិនមានរោគ

៤-***យោព្វនមទោ*** *សេចក្តីស្រវឹងព្រោះ វ័យ*

៥-***ជីវិតមទោ*** *សេចក្តីស្រវឹងព្រោះ ជីវិត*

៦-***លាភមទោ*** *សេចក្តីស្រវឹងព្រោះ លាភ*

៧-***សក្ការមទោ*** *សេចក្តីស្រវឹងព្រោះ សក្ការៈ*

៨-***គរុការមទោ*** *សេចក្តីស្រវឹងព្រោះ ការគោរព*

៩-***បុរេក្ខារមទោ*** *សេចក្តីស្រវឹងព្រោះ ខ្លួនជាប្រធាន*

១០-***បរិវារមទោ*** *សេចក្តីស្រវឹងព្រោះ បរិវារ*

១១-***ភោគមទោ*** *សេចក្តីស្រវឹងព្រោះ ភោគៈ*

១២-***វណ្ណមទោ*** *សេចក្តីស្រវឹងព្រោះ វណ្ណ(ពណ៌សម្បុរ)*

១៣-***សុតមទោ*** *សេចក្តីស្រវឹងព្រោះ ការចេះដឹង*

១៤-***បដិភាណមទោ*** *សេចក្តីស្រវឹងព្រោះ បញ្ញា*

១៥-***រត្តញ្ញូមទោ*** *សេចក្តីស្រវឹងព្រោះ ដឹងរាត្រីមុន*

១៦-***បិណ្ឌបាតិកមទោ*** *សេចក្តីស្រវឹងព្រោះ ការប្រព្រឹត្តបិណ្ឌបាត្រ*

១៧-***អនវញ្ញត្តិមទោ*** *សេចក្តីស្រវឹងព្រោះ ការគេមើលងាយមិនបាន*

១៨-***ឥរិយាបថមទោ*** *សេចក្តីស្រវឹងព្រោះ ឥរិយាបថ*

១៩-***ឥទ្ធិមទោ*** *សេចក្តីស្រវឹងព្រោះ ឫទ្ធិ*

២០-***យសមទោ*** *សេចក្តីស្រវឹងព្រោះ យស*

២១-***សីលមទោ*** *សេចក្តីស្រវឹងព្រោះ សីល*

២២-***ឈានមទោ*** *សេចក្តីស្រវឹងព្រោះឈាន*

២៣-***សិប្បមទោ*** *សេចក្តីស្រវឹងព្រោះសិល្ប៍សាស្ត្រ*

២៤-**អាពោហមទោ** សេចក្តីស្រវឹងព្រោះ កំពស់

២៥-**បរិណាហមទោ** សេចក្តីស្រវឹងព្រោះ ទំហំ

២៦-**សណ្ឋានមទោ** សេចក្តីស្រវឹងព្រោះ សណ្ឋាន គឺទ្រង់ទ្រាយ

២៧-**បារិបូរិមទោ** សេចក្តីស្រវឹងព្រោះ សរីរៈពេញលេញ

សេចក្តីស្រវឹងនោះតើដូចម្តេច? ការស្រវឹង អាការៈ ស្រវឹង ភាពនៃសេចក្តីស្រវឹង ការមើយងាយ អាការៈ មើលងាយ ភាពនៃសេចក្តីមើលងាយ ការឆ្មើងឆ្មៃ អាការៈព្រហើន ភាពដូចជាទង់ ការលើកកម្ពស់ សេចក្តីប្រាថ្នានៃចិត្តជាទង់ នេះហៅថា សេចក្តីស្រវឹង ។

## ចប់មោហមូលចិត្ត២ដួង

## សម្តែងសម្បយុត្តក្នុងអកុសលចិត្ត១២ដួង

ក្នុងអកុសលចិត្ត ១២ដួងគឺលោភមូលចិត្ត៨ដួងទោសមូលចិត្ត២ដួង មោហមូលចិត្ត២ដួង

ពាក្យថាសម្បយុត្ត គឺការប្រកបព្រមនោះ មាន៤ប្រការ គឺ

១-**ទិដ្ឋិគតសម្បយុត្ត** ប្រកបដោយមិច្ឆាទិដ្ឋិ (ក្នុងលោភមូលចិត្ត ៤ដួង)

២-**បដិឃសម្បយុត្ត** ប្រកបដោយសេចក្តីក្រោធ (ក្នុងទោសមូល ចិត្ត២ដួង)

៣-**វិចិកិច្ឆាសម្បយុត្ត** ប្រកបដោយសេចក្តីសង្ស័យ (ក្នុងមោមូលចិត្តដួង ទី១)

៤-**ឧទ្ធច្ចសម្បយុត្ត** ប្រកបដោយសេចក្តីរាយមាយ (ក្នុង

មោហមូលចិត្តដួងទី២ )

**ហេតុឲ្យកើតអកុសលចិត្ត១២ដួងមាន៤ប្រការ**

**១-បុព្វេអកតញ្ញុតា** មិនបានធ្វើបុណ្យទុកក្នុងកាលមុនខ្វះ

**២-អប្បដិរូបទេសវាស** នៅក្នុងប្រទេសដែលមិនសមគួរ

**៣-អសប្បុរិសូបនិស្សយ** មិនបានសេពគប់សប្បុរស

**៤-អសទ្ធម្មស្សវន** មិនបានស្តាប់ធម៌របស់សប្បុរស

**៥-អត្តមិច្ឆាបណិធិ** តម្កល់ខ្លួនទុកខុស គឺសេចក្តីប្រាថ្នាខុស

អកុសលចិត្ត១២ដួង មានទោសច្រើន ឬតិច ក៏ស្រេចតែនៅលើចេតនាកម្ម ដែលជាកម្មបថ ប្រសិនបើអកុសលចិត្តនោះជាកម្មបថក៏មានទោសច្រើន តែងតែនាំឲ្យកើតក្នុងអបាយភូមិ បើសិនជាមិនទាន់ដល់កម្មបថទេក៏មានទោសតិច ឲ្យផលតែក្នុងបវត្តិកាល(កាលបន្ទាប់ពីបដិសន្ធិ )ប៉ុណ្ណោះ ។

**សង្គ្រោះអកុសលចិត្ត១២ដួង ចូលក្នុងកម្មបថ១០**

**អកុសលចិត្ត កើតតាមកាយទ្វារ មាន៣ គឺ**

**១-បាណាតិបាត** ការសម្លាប់សត្វ

**២-អទិន្នាទាន** ការលួចទ្រព្យអ្នកដទៃ

**៣-កាមេសុមិច្ឆាចារ** ការប្រព្រឹត្តខុសក្នុងកាម

**អកុសលចិត្តកើតតាមវចីទ្វារមាន៤ គឺ**

**១-មុសាវាទ** មិននិយាយកុហក

**២-បិសុណាវាទ** និយាយញុះញង់ ចាក់ដោត

**៣-ផរុសវាទ** និយាយជេរប្រទេច

៤-**សម្ផប្បលាប** និយាយពោយពាយឥតប្រយោជន៍

**អកុសលចិត្តកើតតាមមនោទ្វារ មាន៣ គឺ**

១-**អភិជ្ឈា** ការសម្លឹងចង់បានទ្រព្យអ្នកដទៃ

២-**ព្យាបាទ** ការគុំគួនគឺបំណង៍អាក្រក់លើអ្នកដទៃ

៣-**មិច្ឆាទិដ្ឋិ** ការយល់ខុស ( និយតមិច្ឆាទិដ្ឋិ )

**អធិប្បាយអកុសលកម្មបថ ដោយអាការៈ ៥ប្រការ**

- អាការៈទី១ ដោយមូលមាន លោភមូល ទោសមូល និង មោហមូល
- អាការៈទី២ ដោយកម្មជា កាយកម្ម វចីកម្ម និង មនោកម្ម
- អាការៈទី៣ ដោយទ្វារជា កាយទ្វារ វចីទ្វារ និង មនោទ្វារ
- អាការៈទី៤ ដោយទោសជា អប្បសាវជ្ជៈ ( មានទោសតិច ) និង មហាសាវជ្ជៈ (មានទោសច្រើន )
- អាការៈទី៥ ដោយអង្គគឺ អង្គនៃការកន្ទង៍ល្មើស កម្មបថ

**អធិប្បាយបាណាតិបាត**

ពាក្យថា**បាណាតិបាត** ប្រែថា ការញុំាង៍ជីវិតសត្វឲ្យធ្លាក់ចុះ កន្ទង៍ (គឺសម្លាប់សត្វ) ដោយ**វធកចេតនា**។

បាណាតិបាតចែកចេញជា២បទគឺ **បាណ+អតិបាត=បាណាតិបាត**

**បាណ** ដោយន័យថា ដោយវោហារបានដល់សត្វទាំង៍ឡាយដោយសភាវៈ បរមត្ថ បានដល់ **ជីវិតិន្ទ្រិយចេតសិក** ។

**អតិបាត** ដោយន័យថា រហ័ស ឬឈានកន្ទង៍ គឺសេចក្តីបៀតបៀន។

រួមសេចក្តីមក បាណាតិបាតដោយន័យថា ញុំាង៍ជីវិតសត្វឲ្យធ្លាក់

ចុះកន្ទង់ គឺសម្លាប់សត្វ ។ កាលណាបុគ្គលគិតថា នឹងទៅដេញម្រឹក ទើបរៀបចំចង់ខ្សែធ្នូ និងលំពែង បរិភោគអាហារស្បៀកពាក់ខោអាវ ដោយហេតុត្រឹមប៉ុណ្ណោះ កម្មនេះក៏ដល់សេចក្តីកម្រើក ញាប់ញ័រតាមកាយទ្វារ ហើយគេចូលទៅក្នុងព្រៃ មិនបានសត្វអ្វីសូម្បីតែ១ ។ សួរថាអកុសលចិត្តនេះ ជាកាយកម្ម (ដាច់សិក្ខាបទឬទេ ?)ឆ្លើយថា មិនដាច់ទេសួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមិនដល់កម្មបថទេ តែគប្បីជ្រាបថា អកុសលចិត្តនេះ ឈ្មោះថា ជាកាយទុច្ចរិតតែម៉្យាង សូម្បីក្នុងការទៅរកត្រីជាដើម ក៏មានន័យដូចគ្នា ប្រសិនបើសត្វនោះត្រូវបានស្លាប់ ដោយអាការៈ ធ្វើនោះគប្បីជ្រាបថា ការសម្លាប់សត្វនោះដោយអាការៈ ៥យ៉ាង គឺ

១-**ដោយមូល** ការសម្លាប់សត្វកើតព្រោះ ទោសៈនិងមោហៈជាមូល

២-**ដោយកម្ម** ជាកាយកម្ម ព្រោះសម្រេចដោយការធ្វើ តាមផ្លូវកាយ

៣-**ដោយទ្វារ** ជា២ទ្វារគឺ កាយទ្វារ និងវចីទ្វារ

៤-**ដោយសាវជ្ជ** បានដល់មហាសាវជ្ជៈ និងអប្បសាវជ្ជៈ

**ក្នុងសាវជ្ជៈនេះមានវិនិច្ឆ័យដូច្នេះ**

- សម្លាប់សត្វមានគុណធម៌ច្រើន មានទោសធ្ងន់ ។
- សម្លាប់សត្វមានគុណធម៌តិច មានទោសស្រាល ។
- សម្លាប់សត្វមានគុណធម៌ មានទោសធ្ងន់ ។
- សម្លាប់សត្វគ្មានគុណធម៌ មានទោសស្រាល ។
- សម្លាប់សត្វធំ មានទោសធ្ងន់ ។
- សម្លាប់សត្វតូច មានទោសស្រាល ។

ប្រសិនបើគុណធម៌ និងសេរីភាពស្មើគ្នា កិលេស និងសេចក្តីព្យា-យាម ខ្លាំងក្លាមានទោសធ្ងន់ កិលេស និងសេចក្តីព្យាយាមខ្សោយ មានទោសតិច ។

៥- **ដោយអង្គបាណាតិមានអង្គ៥ គឺ**

១-**បាណោ** សត្វមានជីវិត

២-**បាណសញ្ញិតា** សេចក្តីដឹងថាសត្វមានជីវិត

៣-**វធកចិត្តំ** មានចិត្តគិតនឹងសម្លាប់

៤-**ឧបក្កមោ** មានសេចក្តីព្យាយាមនឹងសម្លាប់

៥-**តេនមរណំ** សត្វស្លាប់ដោយការព្យាយាមនោះ

កាលប្រព្រឹត្តគ្រប់អង្គទាំងប្រាំនេះហើយ សីលរមែងដាច់ ដល់នូវភាពជាកម្មបថ អាចឲ្យផលនាំបដិសន្ធិ ក្នុងអបាយភូមិ ប្រសិនបើមិនគ្រប់អង្គ៥នេះទេ ជាទុច្ចរិតកម្ម មិនឲ្យផលនាំបដិសន្ធិ ក្នុងអបាយភូមិទេ តែឲ្យផលក្នុងបវត្តិកាល គឺកាលបន្ទាប់អំពីបដិសន្ធិ រហូតដល់ចុតិកាល ។

បយោគ គឺជា សេចក្តីព្យាយាមក្នុងការធ្វើបាណាតិបាត ដែលជាអង្គប្រកបមួយផ្នែក ឲ្យចូលដល់អកុសលកម្មបថ ។

## ប្រយោគនៃបាណាតិបាត ៦យ៉ាង

១-**សាហត្ថិកបយោគ** ប្រយោគធ្វើឲ្យសត្វស្លាប់ ដោយខ្លួនឯង

២-**អាណត្តិកបយោគ** ប្រយោគគឺការប្រើអ្នកដទៃ ឲ្យសម្លាប់

៣- **និស្សគ្គិយបយោគ** ប្រយោគធ្វើឲ្យសត្វស្លាប់ ដោយការគ្រវែង បាញ់ បោះ ជាដើម ដែលធ្វើឲ្យវត្ថុប្រហារ ឃ្លាតផុតពីដៃ ។

៤-**ថាវរបយោគ** ប្រយោគដែលធ្វើឲ្យសត្វស្លាប់ដោយគ្រឿងប្រហារ ដែលជាវត្ថុមាំទាំ អាចតាំងនៅយូរ ដូចជា ជីកអណ្តូង អន្ទង់ ចម្រូង ថ្នាំពិស អន្ទាក់ វត្ថុបន្ទាច សរសេរពណ៌នាគុណនៃសេចក្តីស្លាប់ជាដើម ។

៥-**វិជ្ជាមយបយោគ** ប្រយោគដែល សម្រេចដោយវិជ្ជា ដូចជា ពាយ មន្តអាគមន៍ ឬដោយវិធីណាមួយ ដែលជាវិជ្ជាមយៈ អាចសម្លាប់សត្វបាន។

៦-**ឥទ្ធិមយបយោគ** ប្រយោគដែលសម្រេចដោយឫទ្ធិ ដែល កើត អំពីផលនៃកម្មដូចជា នាគ គ្រុឌ យក្ខ ឬ ឫទ្ធិព្រះរាជា ជាដើម ។

**ផលនៃបាណាតិបាតមាន៩ប្រការ គឺ**

១-ជាអ្នកទុព្វលភាព

២-ជាអ្នកមានរូបមិនស្អាត

៣-មានកម្លាំងកាយទន់ខ្សោយ

៤-ជាអ្នកមានកម្លាំងកាយ មិនរហ័ស កម្លាំងបញ្ញាមិនវាងវៃ

៥-ជាអ្នកច្រើនទៅដោយ ការភ័យខ្លាច

៦-ជាអ្នកសម្លាប់ខ្លួនឯង ឬត្រូវគេសម្លាប់

៧-ជាអ្នកមានរោគភ័យ បៀតបៀន

៨-ជាអ្នកដល់នូវសេចក្តីវិនាស បរិវារ

៩-ជាអ្នកមាន អាយុខ្លី

គប្បីជ្រាបថា បាណាតិបាតមានទោសដទៃទៀតច្រើនយ៉ាង។

## អធិប្បាយអទិន្នាទាន

ពាក្យថា **អទិន្នាទាន** ប្រែថាការកាន់យកទ្រព្យដែលគេមិនឲ្យ ប្រកបដោយ **ថេយ្យចេតនា** គឺចេតនាគិតថា លួចរបស់អ្នកដទៃដែលគេហួងហែងក៏ធម៌ឈ្មោះថា អទិន្នាទាននេះ អាចសម្រេចបាន ព្រោះមានថេយ្យចិត្ត ។

**អទិន្នាទាន** ចែកចេញជា៣បទគឺ **អ+ទិន្ន+អាទាន=អទិន្នាទាន**

**អ** ជាពាក្យបដិសេធ **ទិន្ន** ជាវត្ថុដែលគេឲ្យ **អាទាន**គឺការកាន់យករួមសេចក្តីមកដោយន័យថា **អទិន្នទាន**គឺការកាន់យកវត្ថុដែលគេមិនបានឲ្យ។

១-**ដោយមូល** ថេយ្យចេតនា កើតព្រោះលោភមូល ទោសមូល និងមោហមូល ។ បើលោភៈនោះ ជាមូល មោហៈ គ្រាន់តែជាធម៌ សម្បយុត្តប៉ុណ្ណោះ បើទោសៈ ជាមូល មោហៈ ក៏គ្រាន់តែជាធម៌សម្បយុត្តដែរ ធម្មតាលោភមូល និងទោសមូល ជាធម៌មិនអាចកើតរួមគ្នាម្តងពីរនោះទេ ។

ក្នុងការលួចនោះ បើមានលោភៈ ជាមូល គឺលួចដើម្បីឲ្យបាននូវវត្ថុដែលត្រូវការ បើមានទោសៈ ជាមូល គឺលួចដើម្បីឲ្យ ម្ចាស់ទ្រព្យវិនាស ហិនហោចនិងមិនត្រូវការទ្រព្យនោះទេ ដូចជាលួចដុតផ្ទះលួចដុតស្រែជាដើម។

២-**ដោយកម្ម** ជាកាយកម្ម ព្រោះសម្រេចទៅដោយការធ្វើ តាមផ្លូវកាយ

៣-**ដោយទ្វារ** កើតបានពីរទ្វារ គឺ កាយទ្វារ និងវចីទ្វារ ។

៤-**ដោយសាវជ្ជៈ** គឺ

- បើវត្ថុនោះ ប្រណិត មានតម្លៃខ្ពស់ មានទោសធ្ងន់
- បើវត្ថុនោះ អន់អាក្រក់ មានតម្លៃតិច មានទោសស្រាល
- បើវត្ថុនោះ ជារបស់អ្នកមានគុណធម៌ មានទោសធ្ងន់

- បើវត្ថុនោះ ជារបស់អ្នកមិនមានគុណធម៌ មានទោសស្រាល
- បើវត្ថុនោះ ធំ មានទោសធ្ងន់
- បើវត្ថុនោះ តូច មានទោសស្រាល
- បើវត្ថុនិងគុណស្មើគ្នា កិលេសនិងសេចក្តីព្យាយាម ច្រើនមានទោសធ្ងន់ កិលេសនិងសេចក្តីព្យាយាម តិចមានទោសស្រាល

៥-**ដោយអង្គ** អទិន្នាទាន មានអង្គ៥ គឺ

- **បរបរិគ្គហិតំ** វត្ថុនោះមានម្ចាស់ហួងហែងរក្សា
- **បរបរិគ្គហិតសញ្ញិតា** សេចក្តីដឹងថាមានម្ចាស់ហួងហែងរក្សា
- **ថេយ្យចិត្តំ** ចិត្តគិតនឹងលួច
- **ឧបក្កមោ** ព្យាយាមនឹងលួច
- **តេនហរណំ** លួចបានដោយសេចក្តីព្យាយាមនោះ ។

កាលបើការលួចនោះ គ្រប់អង្គ៥ហើយ សីលរមែងដាច់ដល់នូវភាពជាកម្មបថ កម្មនោះអាចឲ្យផលដើរតួជា**ជនកកម្ម** នាំឲ្យបដិសន្ធិក្នុងអបាយភូមិ បើមិនគ្រប់អង្គទាំង៥នោះទេ មិនដល់នូវសភាព ជាអ្នកដាច់ កម្មបថឡើយ តែកម្មនោះ ក៏ជាទុច្ចរិតកម្ម ឲ្យផលក្នុងបវត្តិកាល ។

**បយោគ ប្រយោគ គឺសេចក្តីព្យាយាមដើម្បីនឹងលួចមាន៦ប្រការ**

១-**សាហត្ថិកបយោគ** លួចដោយខ្លួនឯង

២-**អាណត្តិកបយោគ** ប្រយោគប្រើអ្នកដទៃឲ្យទៅលួចទ្រព្យដោយវាចា ឬចារអក្សរ សរសេរជាសំបុត្រ ឬប្រើគេឲ្យលួចដោយប្រការណាមួយ

៣-**និស្សគ្គិយបយោគ** ប្រយោគគ្រវែងវត្ថុនោះទុក ឬ បោះឲ្យអ្នក

ដទៃមួយពួកទៀត ឬបោះវត្ថុ ដែលត្រូវបង់ពន្ធចេញទៅឲ្យផុតពីព្រំប្រទល់

៤-**ថារវបយោគ** បញ្ជូនបក្សពួកទុកមានឱកាស ក៏ព្យាយាមលួចទ្រព្យនោះ

៥-**វិជ្ជាមយយោគ** ប្រើមន្តអាគមន៍ឲ្យម្ចាស់ទ្រព្យវង្វេង ភ្លេចស្មារតី ឬ ធ្វើអោយម្ចាស់ទ្រព្យនោះដេកលក់ហើយ គេក៏លួចទ្រព្យនោះទៅ

៦-**ឥទ្ធិមយបយោគ** ប្រើឫទ្ធិផ្សេងៗ ក្រៅអំពីវិជ្ជាមយបយោគ ប៉ុន្តែអ្នកមានឫទ្ធិទាំងឡាយ រមែងមិនធ្វើអទិន្នាទានដែលជាលោកវជ្ជៈគឺ ការធ្វើដែលមានទោសតាមផ្លូវលោក ធ្វើឲ្យទៅជាប្រយោជន៍ក្នុងមួយគ្រាៗ ដែលម្ចាស់ទ្រព្យមិនដល់នូវសេចក្តីវិនាស សេចក្តីនេះមិនចាត់ថាជាការលួចគ្រប់អង្គទេ។

## ផលនៃអទិន្នាទានមាន៦ប្រការ

១-ជាអ្នកមានទ្រព្យសម្បត្តិតិច (ក្រីក្រតោកយ៉ាក)

២-បានជាអ្នកស្មូមយាចក (ជាអ្នករស់បានអាស្រ័យការសុំទាន)

៣-ជាអ្នកស្រេកឃ្លាន (មាននៅក្នុងកំណើតប្រេតជាដើម)

៤-ជាអ្នកមិនបាននូវវត្ថុដែលខ្លួនប្រាថ្នា

៥-វិនាសក្នុងការធ្វើជំនួញ ផ្សេងៗ

៦-វិនាសព្រោះ **ភយវិបត្តិ** មានអគ្គិភ័យឧទកភ័យ រាជភ័យ ចោរភ័យជាដើម (គប្បីជ្រាបថា ទោសរបស់អទិន្នាទាន មានច្រើនដទៃទៀត) ។

## អធិប្បាយកាមេសុមិច្ឆាចារៈ

ពាក្យថាកាមេសុ បានដល់ការសេពមេថុនធម្ម ។ ពាក្យថាមិច្ឆាចារៈ

គឺការប្រព្រឹត្តដ៏លាមកដែលបណ្ឌិតតិះដៀលប៉ុន្តែបើពោលដោយលក្ខណៈបានដល់ចេតនាជាហេតុកន្លងល្មើសឋានៈ ដែលមិនគួរទាក់ទង អំពើនេះប្រព្រឹត្តតាមកាយទ្វារ ដោយចំណង់ក្នុងអសទ្ធម្មឈ្មោះថាកាមេសុមិច្ឆាចារៈ

ឋាន ដែលបុគ្គលមិនគប្បីទាក់ទង ដោយអសទ្ធម្ម ហៅថា អគ្គមនីយដ្ឋាន អគ្គមនីយដ្ឋាននោះ មាន២០ពួក គឺ

**ស្ត្រីមានមាតារក្សាជាដើមមាន១០ពួក**

១-**មាតុរក្ខិតា** ស្ត្រីមានមាតាគ្រប់គ្រង

២-**បិតុរក្ខិតា** ស្ត្រីមានបិតាគ្រប់គ្រង

៣-**មាតុបិតុរក្ខិតា** ស្ត្រីមានមាតាបិតាគ្រប់គ្រង

៤-**ភគិនីរក្ខិតា** ស្ត្រីមានបងស្រីឬប្អូនស្រីគ្រប់គ្រង

៥-**ភាតុរក្ខិតា** ស្ត្រីមានបងប្រុសឬប្អូនប្រុសគ្រប់គ្រង

៦-**ញាតិរក្ខិតា** ស្ត្រីមានញាតិគ្រប់គ្រង

៧-**គោត្តរក្ខិតា** ស្ត្រីមានត្រកូលគ្រប់គ្រង

៨-**ធម្មរក្ខិតា** ស្ត្រីមានធម៌រក្សាគឺអ្នកបដិបត្តធម៌ដូចគ្នាគ្រប់គ្រង

៩-**សបរិទណ្ឌា** ស្ត្រីដែលទទួលការស្តីដណ្តឹងហើយ

១០-**សារក្ខា** ស្ត្រីដែលមានច្បាប់គ្រប់គ្រង

**ស្ត្រីដែលជាភរិយា១០ពួកគឺ ( ស្ត្រីមានគូរហើយ)**

១-**ធនក្កីតា** ភរិយាដែលទិញឬលោះមកដោយទ្រព្យ

២-**ឆន្ទវាសិនី** ភរិយាដែលនៅជាមួយបុរសដោយសេចក្តីពេញចិត្ត

៣-**ភោគវាសិនី** ភរិយាដែលនៅជាមួយបុរសដោយភោគ

៤-**បដិវាសិនី** ភរិយាដែលនៅជាមួយបុរស ដោយប្រាថ្នាសំលៀកបំពាក់ ឬគ្រឿងអលង្ការ

៥-**ឱទបត្តកិនី** ភរិយាដែលតាំងឡើងដោយការច្រូចទឹក

៦-**ឱភសម្ពត្តា** ភរិយាដែលតាំងឡើងដោយបុរស ជួយដាក់ទំនូលពីលើក្បាល ( បានដល់ស្ត្រីកំពុងធ្វើការធ្ងន់ )

៧-**ទាសីភរិយា** ស្ត្រីដែលជាទាសីក្នុងផ្ទះហើយបុរសយកធ្វើជាប្រពន្ធ

៨-**កម្មការីភរិយា** ស្ត្រីដែលជួលមកធ្វើការងារ ហើយបុរសយកធ្វើជាប្រពន្ធ

៩-**ធជាហដា** ស្ត្រីដែលជាឈ្លើយសឹក ហើយបុរសយកធ្វើជាប្រពន្ធ

១០-**មុហុត្តិកា** ភរិយាដែលនៅជាមួយបុរសមួយគ្រាតូច

បណ្តាស្ត្រីទាំងនោះ ស្ត្រី៨ពួកខាងដើម បុរសអាចទាក់ទងធ្វើជាប្រពន្ធតាមប្រពៃណី ព្រោះស្ត្រី៨ពួកនោះ ជាម្ចាស់សម្ផស្សខ្លួនឯង រីឯស្ត្រី ១២ពួកខាងចុងរាប់តាំងពីសបរិទណ្ឌារហូតដល់មុហុត្តិកាបុរសមិនទាក់ទងឡើយ ត្រូវមានទោសឬក៏ស្ត្រីទាំង១២ពួកនេះ ក៏មិនត្រូវទាក់ទងជាមួយនឹងបុរសដោយប្រាថ្នាអសទ្ធម្មដែរ ។ ( គប្បីជ្រាបសេចក្តីនេះ ដោយពិស្តារមានក្នុង ព្រះវិន័យបិដក មហាវិភង្គទុតិយភាគ ចុះ ) ។

## ពោលដោយអាការៈ៥ នៃកាមេសុមិច្ឆាចារៈ

១-**ដោយមូល** កាមេសុមិច្ឆាចារៈ កើតព្រោះលោភៈនិង មោហៈ ជាមូល ( ជាឫសគល់ )

២-**ដោយកម្ម** ជាកាយកម្ម

៣-**ដោយទ្វារ** ជាកាយទ្វារតែម្យ៉ាង

៤-**ដោយសាវជ្ជៈ** បុគ្គលដែលត្រូវកន្ទងល្មើស មានគុណធម៌ច្រើន មានទោសធ្ងន់

- បុគ្គលដែលត្រូវកន្ទងល្មើស នោះមានគុណធម៌តិច មានទោសស្រាល ( ក៏ឈ្មោះថា កាមេសុមិច្ឆាចារៈ មិនមានទោសនោះមិនមានឡើយ)

-ប្រសិនបើ មិនមានឆន្ទៈរួមគ្នាទេដោយការបង្ខិតបង្ខំមានទោសធ្ងន់

-ប្រសិនបើ មិនមានឆន្ទៈ រួមគ្នា មានទោសស្រាល

-កិលេស និងសេចក្តីព្យាយាមខ្លាំង មានទោសធ្ងន់

-កិលេស និងសេចក្តីព្យាយាមខ្សោយ មានទោសស្រាល

**ពោលដោយអង្គ កាមេសុមិច្ឆាចារៈមានអង្គ ៤**

១-**អគ្គមនីយវត្ថុ** វត្ថុដែលមិនគួរទាក់ទង (ស្ត្រី២០ពួក )

២-**តស្មឹសេវនចិត្តំ** មានចិត្តគិតនឹងសេពនូវវត្ថុ ដែលមិនគួរនោះ

៣-**សេវនបយោគោ** ព្យាយាមក្នុងការសេពនោះ

៤-**មគ្គេនមគ្គប្បដិបត្តិ អភិវាសនំ** ញ៉ាំងមគ្គនឹងមគ្គឲ្យដល់គ្នា

កាលបើគ្រប់អង្គ៤នេះហើយ សីលរមែងដាច់ ដល់នូវភាពជាកម្មបថ នាំឲ្យទៅកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គទេសីលមិនដាច់តែជាទុច្ចរិតកម្មមិនឲ្យផលនាំឲ្យបដិសន្ធិទេ តែឲ្យផលក្នុងបវត្តិកាល ។

កាមេសុមិច្ឆាចារៈមានប្រយោគ១គឺ សាហត្ថិកបយោគ ( ធ្វើដោយខ្លួនឯង ) ។

**ផលរបស់កាមេសុមិច្ឆាចារៈមាន១១ប្រការគឺ**

១-មានអ្នកដទៃស្អប់ខ្ពើមច្រើន

២-មានជនបំណាំងអាក្រក់មកលើខ្លួនច្រើន

៣-ខាតបង់ទ្រព្យសម្បត្តិ

៤-ក្រីក្រជាស្មូមយាចក

៥-កើតជាមនុស្សស្រី

៦-កើតជាមនុស្សខ្ទើយ

៧-កើតជាបុរសក្នុងត្រកូលថោកទាប

៨-បានទទួលនូវការខ្មាស់អៀនជានិច្ច

៩-មានរាងកាយមិនស្អាត

១០-ច្រើនទៅដោយវិតក្កៈ សេចក្ដីកង្វល់

១១-ព្រាត់ប្រាស អ្នកជាទីស្រឡាញ់របស់ខ្លួន

គប្បីជ្រាបថា ផលរបស់កាមេសុមិច្ឆាចារៈមានច្រើនដទៃទៀត ។

**អធិប្បាយមុសាវាទ**

ពាក្យមុសាវាទ ចែកជា២បទគឺ **មុសា** + **វាទ** = **មុសាវាទ**

**មុសា** ប្រែថា ខុសឬកុហក **វាទ** ប្រែថា ការពោល

សេចក្ដីព្យាយាមតាមផ្លូវវាចា (វចីបយោគ) សេចក្ដីព្យាយាមតាមផ្លូវកាយ(កាយបយោគ)ដែលទំលាយប្រយោជន៍អ្នកដទៃដោយបំរុងពោលឲ្យខុស (**វិសំវាទនចេតនា**) ឈ្មោះថា **មុសាវាទ** ក៏ចេតនាតាំងឡើងដោយសេចក្ដីព្យាយាមផ្លូវកាយ ឬផ្លូវវាចា ដែលពោលឲ្យឃ្លាតចាកការពិត ។ន័យម៉្យាងទៀត រឿងដែលមិនពិត ឈ្មោះថា **មុសា** ការឲ្យអ្នកដទៃដឹងរឿងមិន

ពិតនោះ ដោយវាទៈ ឈ្មោះថា **មុសាវាទ** ។

## ចំណែកមុសាវាទដោយអាការៈ៥

១-**ដោយមូល** មុសាវាទ កើតព្រោះលោភៈ ទោសៈ មោហៈជាមូល ដូច ជាប្រាថ្នាចង់បានវត្ថុរបស់អ្នកដទៃទប់ចិត្តមិនបានក៏ពោលពាក្យកុហក ឲ្យគេខូចប្រយោជន៍ មុសាវាទនោះ មានលោភៈនិងមោហៈ ជាមូល ។ ចំណែក មុសាវាទ ដែលមានទោសៈ និងមោហៈជាមូល ដូចជាកាលមាន សេចក្តីក្រោធ ហើយក៏ពោលពាក្យកុហក ឲ្យគេខូចប្រយោជន៍ឬសាបសូន្យ ដោយប្រការណាមួយ យ៉ាងនេះឈ្មោះថា មានទោសៈនិងមោហៈជាមូល

២-**ដោយកម្ម** ជាវចីកម្ម ព្រោះការធ្វើនោះ សម្រេចដោយការពោល ការនិយាយ ឬក៏ ជាការធ្វើឲ្យគេយល់ខុសការពិត

៣-**ដោយទ្វារ** កើតបានដោយទ្វារ២គឺ វចីទ្វារ និងកាយទ្វារ មុសា-វាទវចីទ្វារ បានដល់ ការនិយាយកុហក មុសាវាទកាយទ្វារ បានដល់ ការ ធ្វើឲ្យគេដឹងតាមផ្លូវកាយ ដូចជាញាក់មុខញាក់មាត់ សរសេរសំបុត្រ ឬ សំ ដែងកិរិយាផ្សេងៗ ឲ្យគេដឹង ដោយមិនពោលវាចា មិននិយាយទេ ។

៤-**ដោយសាវជ្ជៈ** គឺ

-និយាយធ្វើឲ្យខាតបង់ប្រយោជន៍ច្រើន មានទោសច្រើន

-និយាយធ្វើឲ្យខាតបង់ប្រយោជន៍តិច មានទោសតិច

-បុគ្គលដែលខ្លួនកុហកនោះ មានគុណធម៌ច្រើនមានទោសច្រើន

-បុគ្គលដែលខ្លួនកុហកនោះ មានគុណធម៌តិចមានទោសស្រាល

-កិលេសនិងសេចក្តីព្យាយាមខ្លាំងក្លា មានទោសច្រើន

-កិលេសនិងសេចក្តីព្យាយាមខ្សោយ មានទោសស្រាល

៥-ដោយអង្គមុសាវាទមាន អង្គ ៤

១-**អតថំវត្ថុ** វត្ថុមិនពិត

២-**វិសំវាទនចិត្តំ** គិតនឹងពោលឲ្យខុស

៣-**តជ្ជោវាយាមោ** ព្យាយាមនឹងពោលឲ្យខុស

៤-**បរស្សតទត្ថវិជាននំ** ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្តីនោះ ។ កាលគ្រប់អង្គ៤ហើយ សីលរមែងដាច់ ដល់នូវភាពជាកម្មបថ អាចឲ្យផល កើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ៤ទេ គឺជាទុច្ចរិតកម្មឲ្យផលក្នុងបវត្តិកាល ។

## ប្រយោគ របស់មុសាវាទមាន៤ប្រការគឺ

១-**សាហត្ថិកបយោគ** សេចក្តីព្យាយាមកុហកដោយខ្លួនឯង ។

២-**អាណត្តិកបយោគ** ប្រើគេឲ្យទៅកុហក ។

៣-**និស្សគ្គិយបយោគ** សរសេររឿងរ៉ាវមិនពិត ផ្ញើឲ្យអ្នកដទៃដូចជាសំបុត្រជាដើម ឬបោះចោលប្រាថ្នា ឲ្យអ្នកដទៃឃើញពាក្យកុហកនោះ ។

៤-**ថាវរបយោគ** សរសេររឿងដែលមិនពិតបិទប្រកាសទុក ឬដូចជាចារិកអក្សរក្នុងទីណាដែលតាំងនៅយូរ មានលើផ្ទាំងថ្មជាដើម ។

## អនរិយវោហារ ៨ ប្រការ

អនរិយវោហារគឺពាក្យពោលរបស់អ្នកដែលមិនមែនជាអរិយបុគ្គល ឬ ពាក្យរបស់ពាលជនដែលជាពាក្យកុហកទាំងដឹងខ្លួន

១-វត្ថុដែលខ្លួនបានឃើញ ពោលថាមិនបានឃើញ

២-វត្ថុដែលខ្លួនបានឮ ពោលថាមិនបានឮ
៣-វត្ថុដែលខ្លួនបានជួប ពោលថាមិនបានជួប
៤-វត្ថុដែលខ្លួនបានដឹង ពោលថាមិនបានដឹង
៥-វត្ថុដែលខ្លួនមិនបានឃើញ ពោលថាបានឃើញ
៦-វត្ថុដែលខ្លួនមិនបានឮ ពោលថាបានឮ
៧-វត្ថុដែលខ្លួនមិនបានជួប ពោលថាបានជួប
៨-វត្ថុដែលខ្លួនមិនបានដឹង ពោលថាបានដឹង

ពាក្យថាជួប ក្នុងទីនេះសំដៅដល់ការ បានដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ការពោលនូវ **អនរិយវោហារ** នេះចាត់ជាមហាសាវជ្ជៈ ។

**ទោសរបស់មុសាវាទមាន៨ប្រការ**

១-ជាអ្នកនិយាយមិនច្បាស់
២-មានធ្មេញមិនរាបស្មើ
៣-មាត់មានក្លិនស្អុយ
៤-ក្អកចេញចំហាយក្តៅ
៥-ភ្នែកមិននៅត្រង់កន្លែងប្រក្រតី
៦-ពោលវាចាចុងអណ្តាត ឬចុងមាត់
៧-មានអកប្បកិរិយាមិនល្អ
៨-មានចិត្តវិកវរវិកលចរិត

គប្បីជ្រាបថា មុសាវាទ មានទោសដទៃទៀតច្រើន ។

**៥ បិសុណាវាទ**

ពាក្យថាបិសុណាវាទ ចែកជាពីរបទគឺ **បិសុណ + វាទ=បិសុណាវាទ** **បិសុណៈ** ប្រែថាស៊កសៀត ឬញុះញង់ **វាទៈ**ប្រែថា ការពោល ដូច្នោះពាក្យថា **បិសុណាវាទ** ឬបិសុណាវាចា បានដល់ **សង្កិលិដ្ឋចេតនា**ជាចេតនារបស់អ្នកដែលសៅហ្មង ព្រោះលោភៈ ទោសៈ បានបង្ខំ ឬជំរុញឲ្យនិយាយ ចាក់ដោត ស៊កសៀត ដើម្បីឲ្យខ្លួនជាទីស្រឡាញ់ នៃអ្នកដទៃ និង ដើម្បីបៀតបៀនចំពោះអ្នកដែលខ្លួនមិនពេញចិត្តនោះៗ ។

**ចំណែកបិសុណាវាទដោយអាការៈ ៥ប្រការ**

១-**ដោយមូល** កើតព្រោះលោភៈ ទោសៈ និងមោហៈជាមូល

២-**ដោយកម្ម** ជាវិចីកម្ម

៣-**ដោយទ្វារ** មានទ្វារពីរគឺ វចីទ្វារ និងកាយទ្វារ

៤-**ដោយសាវជ្ជៈ**គឺ

-បុគ្គលដែលខ្លួនញុះញង់ មានគុណច្រើន មានទោសធ្ងន់

-បុគ្គលដែលខ្លួនញុះញង់ មានគុណតិចមានទោសស្រាល

-និយាយស៊កសៀតឲ្យបុគ្គលពីរនាក់បែកគ្នាមានទោសធ្ងន់

-និយាយស៊កសៀតមិនដល់ថ្នាក់ធ្វើឲ្យបែកគ្នាមានទោសស្រាល

-កិលេសនិងសេចក្តីព្យាយាមខ្លាំង មានទោសធ្ងន់

-កិលេសនិងសេចក្តីព្យាយាមខ្សោយ មានទោសស្រាល

**៥ ដោយអង្គ បិសុណាវាចាមានអង្គ ៤គឺ**

១-**ភិន្ទិតព្វោបរោ** មានមនុស្សដទៃដែលខ្លួនប្រាថ្នាញុះញង់

២-**ភេទបុរេក្ខារតា វា បិយកម្យតា វា** ប្រាថ្នាឲ្យគេបែកគ្នា

ឬ ប្រាថ្នាឲ្យគេស្រឡាញ់ខ្លួន

៣-**តជ្ជោវាយាមោ** ព្យាយាមនឹងពោលញុះញង់

៤-**តទត្ថវិជាននំ** អ្នកដទៃបានដឹងនូវរឿងនោះ

កាលគ្រប់អង្គ៤នេះ ហើយរមែងដល់នូវភាពជាកម្មបថអាចឲ្យផល កើតនៅក្នុងអបាយភូមិ បើមិនគ្រប់អង្គ៤ទេ ជាទុច្ចរិតកម្ម អាចឲ្យផលក្នុងបវត្តិកាល ។

## ប្រយោគក្នុង បិសុណាវាទ មានពីរយ៉ាង គឺ

១-**កាយបយោគ** ការស៊ិកសៀតដោយកាយមានការ សម្តែងកិរិយា-មារយាទ ឲ្យគេដឹងនូវសេចក្តីនោះ

២-**វចីបយោគ** ការស៊ិកសៀតដោយវាចា គឺនិយាយញុះញង់ ឲ្យគេបែកបាក់គ្នា ។

## ផលរបស់បិសុណាវាទមាន៤ប្រការគឺ

១-តិះដៀលខ្លួនឯង

២-មានអ្នកដទៃនិយាយ ស៊ិកសៀតមកលើខ្លួនច្រើន

៣-ត្រូវពួកបណ្ឌិតតិះដៀល

៤-ច្រើនដោយការ បែកមិត្តជាទីស្រលាញ់

គប្បីជ្រាបថា បិសុណាវាទ មានទោសដទៃទៀតច្រើន ។

## ៦ អធិប្បាយផរុសវាទ

ពាក្យថាផរុសវាទ ចែកជា៣បទគឺ **ផរ + ឧស + វាទ=ផរុសវាទ**

ផរៈ ប្រែថាផ្សាយទៅ ឧសៈ ប្រែថាក្តៅក្រហាយ វាទៈ ប្រែថា ការ

ពោល រួមសេចក្តីមកថា **ផរុសវាទ** ប្រែថា ផ្សាយទៅនូវវាចា ក្តៅក្រហាយ ផរុសវាចា តាំងឡើងដោយ **ទុដ្ឋល្វចេតនា**(ចេតនាគ្រោតគ្រាត) របស់អ្នកនិយាយពាក្យមិនជាទីស្រឡាញ់ មិនធ្វើឲ្យសប្បាយចិត្ត ព្រោះត្រូវទោសគ្របសង្កត់និងដើម្បីទម្លាយបុគ្គលដទៃឲ្យវិនាស ការពោលសម្តីដែលសំរេចជា ផរុសវាចានោះ សំខាន់គឺ ត្រង់ចេតនាគ្រោតគ្រាត ដែលប្រកបដោយទោស សូម្បីពាក្យនិយាយចេញមក ជាពាក្យពិរោះ សុខុមក៏ដោយ តែមានចេតនាគ្រោតគ្រាត ពាក្យនិយាយនោះក៏ចាត់ទុកជា ផរុសវាចាដែរ ដូចជាពិភាក្សាអំពីការសម្លាប់មនុស្សជាដើម សូម្បីពោលវាចា សុភាពក៏ដោយចុះក៏ចាត់ថា ជា វាចាគ្រោតគ្រាតដែរ ។

**ចំណែកផរុសវាទ ដោយអាការៈ៤ប្រការ**

១-**ដោយមូល** កើតព្រោះ ទោសមូល និងមោហមូល

២-**ដោយកម្ម** ជាវចីកម្ម

៣-**ដោយទ្វារ** កើតបានទ្វារពីរ គឺវចីទ្វារ និងកាយទ្វារ

៤-**ដោយសាវជ្ជៈ** គឺ

-បុគ្គលដែលខ្លួនជេរប្រទេចនោះមានគុណច្រើន មានទោសច្រើន

-បុគ្គលដែលខ្លួនជេរប្រទេចនោះ មានគុណតិច មានទោសតិច

-ជេរប្រទេច ប្រកបដោយកិលេសខ្លាំង មានទោសច្រើន

-ជេរប្រទេច ប្រកបដោយកិលេសខ្សោយ មានទោសតិច

**៥ ដោយអង្គ ផរុសវាទមានអង្គ៣គឺ**

១-**អក្កោសិតញ្ញោបរោ** មានអ្នកដទៃដែលគប្បីជេរប្រទេច

២-**កុប្បិតចិត្តំ** មានចិត្តកំរើក គឺសេចក្តីក្រោធ

៣-**អក្កោសនា** បានជេរប្រទេច

កាលគ្រប់អង្គ៣នេះហើយ រមែងដល់នូវភាព ជាកម្មបថ អាចឲ្យផលនាំឲ្យបដិសន្ធិ ក្នុងអបាយភូមិ បើមិនគ្រប់អង្គ៣ នេះទេ ជាទុច្ចរិតកម្មឲ្យផលក្នុងបវត្តិកាល ។

## អក្កោសវត្ថុ១០

ពាក្យថា **អក្កោសវត្ថុ**គឺ វត្ថុជាគ្រឿងជេរប្រទេច ពោលចាក់ដោត ក៏ធម៌ឈ្មោះថា **អក្កោសវត្ថុ**នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សំដែង ក្នុងគម្ពីរមហាវិភង្គ នូវអក្កោសវត្ថុ១០ប្រការគឺ

**ជាតិ១ ឈ្មោះ១ គោត្ត១ ការងារ១ សិល្បសាស្ត្រ១ អាពាធ១**

**ភេទ១ កិលេស១ អាបត្តិ១ ពាក្យជេរដ៏ថោកទាប១ ។**

ដែលហៅថា ជាតិ គឺជាតិមានពីរយ៉ាង បានដល់**ហីនជាតិ**(ជាតិថោកទាប)១ **ឧក្កដ្ឋជាតិ**(ជាតិខ្ពង់ខ្ពស់)១។

ដែលហៅថា **ហីនជាតិ** គឺជាតិមនុស្សចណ្ឌាលជាតិជាងត្បាញផែងជាតិអ្នកនេសាទ ជាតិអ្នកធ្វើរទេះ ជាតិអ្នកបោលសម្រាមជាតិទាំងនេះហៅថា **ហីនជាតិ**។

ដែលហៅថា **ឧក្កដ្ឋជាតិ** គឺជាតិក្សត្រិយ៍ ជាតិព្រាហ្មណ៍ ជាតិ ទាំងនេះហៅថា **ឧក្កដ្ឋជាតិ** ។

ដែលហៅថា **នាម** គឺ នាមមានពីរយ៉ាង បានខាងឯ **ហីននាម១ ឧក្ក-**

ដ្ឋនាម១ ។

ដែលហៅថា **ហីននាម** គឺ អវកណ្ណកនាម ជវកណ្ណកនាម ធនិដ្ឋកនាម សវិដ្ឋកនាម កុលវឌ្ឍកនាម ( នាមទាំង៥នេះជាឈ្មោះពួកមនុស្សដែលជាខ្ញុំបម្រើគេ) ពុំនោះសោត នាមណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ នាមទាំងនេះ ហៅថា **ហីននាម** ។

ដែលហៅថា**ឧក្កដ្ឋនាម**គឺនាមដែលប្រកបព្រមចំពោះដោយព្រះពុទ្ធ ប្រកបព្រមចំពោះដោយព្រះធម៌ ប្រកបព្រមចំពោះដោយព្រះសង្ឃពុំនោះសោត នាមណាដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនមើលងាយ គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ នាមទាំងនេះហៅថា **ឧក្កដ្ឋនាម** ។

ដែលហៅថា **គោត្ត** គឺគោត្តមានពីរយ៉ាង បានខាងហីនគោត្ត១ ឧក្កដ្ឋគោត្ត១ ។

ដែលហៅថា **ហីនគោត្ត** គឺ ការទ្វាជគោត្ត ពុំនោះសោត គោត្តណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ គោត្តទាំងនេះ ហៅថា **ហីនគោត្ត** ។

ដែលហៅថា **ឧក្កដ្ឋគោត្ត** គឺ គោតមគោត្ត មោគ្គល្លានគោត្ត កច្ចាយនគោត្ត វាសេដ្ឋគោត្ត ពុំនោះសោត គោត្តណាដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនមើលងាយ គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ គោត្តទាំងនេះហៅថា **ឧក្កដ្ឋគោត្ត** ។

ដែលហៅថា ការងារគឺការងារមានពីរយ៉ាង បានដល់ការងារដ៏ថោកទាប១ ការងារដ៏ខ្ពង់ខ្ពស់១ ។

ដែលហៅថា ការងារដ៏ថោកទាប គឺការងាររបស់អ្នកចាំងឈើ ការងាររបស់អ្នកចោលផ្កា (ចោលសម្រាម) ពុំនោះសោត ការងារណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ ការងារទាំងនេះ ហៅថា ការងារដ៏ថោកទាប ។

ដែលហៅថា ការងារដ៏ខ្ពង់ខ្ពស់ គឺ ការភ្ជួររាស់ ការជួញប្រែ ការរក្សាគោពុំនោះសោត ការងារណាដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ ការងារទាំងនេះ ហៅថា ការងារដ៏ខ្ពង់ខ្ពស់ ។

ដែលហៅថា សិល្បសាស្ត្រ គឺ សិល្បសាស្ត្រ មានពីរយ៉ាង បានដល់សិល្បសាស្ត្រដ៏ថោកទាប១ សិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់១ ។

ដែលហៅថា សិល្បសាស្ត្រដ៏ថោកទាប គឺ សិល្បសាស្ត្រអ្នកត្បាញផែង សិល្បសាស្ត្រអ្នកធ្វើផ្ទាំង សិល្បសាស្ត្រអ្នកត្បាញសំពត់ សិល្បសាស្ត្រ-អ្នកធ្វើស្បែក (អ្នកធ្វើរថ) សិល្បសាស្ត្រខ្មាន់ប្រកេស ពុំនោះសោត សិល្ប-សាស្ត្រ ណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ សិល្បសាស្ត្រទាំងនេះ ហៅថា សិល្បសាស្ត្រដ៏ថោកទាប ។

ដែលហៅថា សិល្បសាស្ត្រខ្ពង់ខ្ពស់ គឺ រាប់ដោយដៃទទេ រាប់ដោយពិធីនព្វន្ត ការសរសេរអក្សរ ពុំនោះសោត សិល្បសាស្ត្រណា ដែលគេមិន

មើលងាយ គេមិនបន្ទាបបន្ថោកគេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ សិល្បសាស្រ្តទាំងនេះ ហៅថា សិល្បសាស្រ្តដ៏ខ្ពង់ខ្ពស់ ។

បណ្តាអាពាធទាំងឡាយ សុទ្ធតែថោកទាប ទាំងអស់ ចំណែកខាងអាពាធទឹកនោមផ្អែម (រោគប្រមេះ) ហៅថា អាពាធយ៉ាងស្រាល ។

ដែលហៅថា ភេទ គឺភេទមានពីរយ៉ាង បានដល់ភេទដ៏ថោកទាប១ ភេទដ៏ខ្ពង់ខ្ពស់១ ។

ដែលហៅថា ភេទដ៏ថោកទាបគឺ ភេទខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ភេទទាំងនេះ ហៅថា ភេទដ៏ថោកទាប ។

ដែលហៅថា ភេទខ្ពង់ខ្ពស់ គឺ ភេទមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ភេទទាំងនេះ ហៅថា ភេទខ្ពង់ខ្ពស់ ។

ឯកិលេសទាំងឡាយ សុទ្ធតែថោកទាបទាំងអស់ ។

ឯអាបត្តិទាំងឡាយ សុទ្ធតែថោកទាបទាំងអស់ ចំណែកខាងសោតាបត្តិ នឹងសមាបត្តិសុទ្ធតែខ្ពង់ខ្ពស់ទាំងអស់ ។

ដែលហៅថា ជេរ គឺជេរមានពីរយ៉ាងបានដល់ជេរយ៉ាងថោកទាប១ ជេរយ៉ាងខ្ពង់ខ្ពស់១ ។

ដែលហៅថា ជេរយ៉ាងថោកទាបគឺ ជេរថា លោកជាសត្វឱដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក លោកគ្មានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ជេរដោយ **យអក្ខរ** ក្តី ដោយ **ភអក្ខរ** ក្តី (យអក្ខរនិងភអក្ខរនេះជាឈ្មោះមេ

ថុនធម្ម) ដោយនិម្មិតបុរសនិងនិម្មិតស្រីក្តី ជេរទាំងនេះ ហៅថា ជេរយ៉ាងថោកទាប ។

ដែលហៅថា ជេរយ៉ាងខ្ពង់ខ្ពស់ គឺ ជេរថា លោកជាបណ្ឌិត លោកឆ្លៀវឆ្លាស លោកជាអ្នកប្រាជ្ញលោកជាពហុសូត្រ លោកជាធម្មកថិក លោកគ្មានគតិអាក្រក់ទេ លោកមានតែគតិល្អម្យ៉ាង ជេរទាំងនេះហៅថាជេរយ៉ាងខ្ពង់ខ្ពស់ ។

ពាក្យជេរទាំងនេះជាពាក្យមានមកក្នុងព្រះបាលី ចំណែកឯពាក្យ ដទៃទៀតមានច្រើនយ៉ាង សរុបសេចក្តីមក ដោយន័យថា ការពោលឯណាដែលប្រាថ្នាភាពអាប់អោនចាក់ដោតចំពោះអ្នកដទៃ សូម្បីការពោលវាចាបែបណាក៏ដោយ វាចានោះឈ្មោះថា ជេរទាំងអស់ ។

## ប្រយោគរបស់ផរុសវាចាមាន២ប្រការ

១-**កាយបយោគ** ព្យាយាមសម្តែងកិរិយាអាក្រក់ផ្សេងៗ ធ្វើឲ្យអ្នកដទៃដឹងថាខ្លួនខឹងក្រោធ មិនពេញចិត្ត ឬសរសេរសំបុត្រដោយពាក្យជេរណាមួយ មានពាក្យជេរដោយគោត្តជាដើម ។

២-**វិចីបយោគ** ព្យាយាមដោយវាចាជាផរុសវាចា ។

## ផលរបស់ផរុសវាចាមាន ៤ប្រការ

១-វិនាសទ្រព្យ

២-ឮ សំឡេងមិនពេញចិត្ត

៣-មានវាចាមិនពិរោះ

៤-ស្លាប់ដោយអាការៈវង្វេង ។

## ៧ អធិប្បាយសម្ផប្បលាបៈ

**សម្ផប្បលាប** ចែក ជា២បទគឺ **សម្ផ + បលាប = សម្ផប្បលាប**

**សម្ផ** ប្រែថា ពោយពាយឥតប្រយោជន៍ **បលាប** ប្រែថាការពោល

សរុបសេចក្តីមកថា ការពោលនូវ វាចាឥតប្រយោជន៍ ឈ្មោះថា សម្ផប្បលាបៈ បានដល់ **អនត្ថវិញ្ញាបិកាចេតនា** គឺចេតនាចង់ឲ្យ អ្នកដទៃដឹងរឿងមិនមែនជាប្រយោជន៍ ពាក្យថា **អនត្ថ** ប្រែថា មិនមែនប្រយោជន៍ ឬ មិនមានប្រយោជន៍ ពាក្យថា **វិញ្ញាបិកា** ប្រែថា ចង់ឲ្យអ្នកដទៃដឹង បើដោយលោភចិត្ត និយាយឲ្យគេដឹង ដោយសេចក្តីរីករាយនូវរឿង មិនមានប្រយោជន៍នោះ បើដោយទោសចិត្ត និយាយឲ្យគេដឹង នូវរឿងដែល ឥតប្រយោជន៍នោះ ដោយសេចក្តីមិនពេញចិត្ត ក្នុងខណៈណា ដែលអ្នកនិយាយមានចិត្ត ប្រកបដោយ លោភៈ ទោសៈ និងមោហៈ មិនមានចេតនាចង់ឲ្យគេដឹងរឿងឥតប្រយោជន៍នោះ យ៉ាងនេះគឺជាទ្វារ របស់ចិត្តអកុសលចិត្តប៉ុណ្ណោះ មិនមែនជាទ្វាររបស់ អកុសលកម្មបថទេ តែក្នុងខណៈណា និយាយចង់ឲ្យគេដឹង រឿងមិនជាប្រយោជន៍នោះ ខណៈនោះជាទ្វារ របស់អកុសលកម្មបថ ។

### ពោលដោយអាការៈរបស់សម្ផប្បលាបៈ មាន ៥ប្រការ

១-**ដោយមូល** កើតព្រោះលោភៈ ទោស មោហៈ ជាមូល

២-**ដោយកម្ម** ជាវចីកម្ម

៣-**ដោយទ្វារ** កើតបានទ្វារ២គឺ វចីទ្វារ និងកាយទ្វារ

៤-**ដោយសាវជ្ជៈ** គឺ

- និយាយច្រើនមានទោសច្រើន

- និយាយតិចមានទោសតិច

-អ្នកដទៃកាន់យកនូវរឿងរ៉ាវឥតប្រយោជន៍នោះ មានទោសច្រើន

-អ្នកដទៃមិនកាន់យកនូវរឿងរ៉ាវឥតប្រយោជន៍នោះ មានទោសតិច (ព្រោះមិនបានខូចខាតប្រយោជន៍) ។

**៥ដោយអង្គ សម្ផប្បលាបៈ មានអង្គ២គឺ**

១-**និរត្ថកថា បុរេក្ខារតា** ប្រាថ្នានិយាយនូវរឿង ឥតខ្លឹមសារដែលមិនប្រកបដោយប្រយោជន៍នោះ ។

២-**តថារូបី កថាកថនំ** បាននិយាយនូវរឿង ឥតប្រយោជន៍នោះ ។

កាលគ្រប់អង្គ២ នេះហើយ រមែងដល់នូវភាពជាកម្មបថ អាចឲ្យផល បដិសន្ធិ ក្នុងអបាយភូមិ បើមិនគ្រប់អង្គទេ ឈ្មោះថាជាទុច្ចរិតកម្ម មិនមែនជាកម្មបថទេ អាចឲ្យផលក្នុងបវត្តិកាល ។

**ផលរបស់សម្ផប្បលាបៈ មាន៤ប្រការ គឺ**

១-ជា អធម្មវាទីបុគ្គល

២-មិនមាន អ្នកដទៃជ្រះថ្លានឹងវាចារបស់ខ្លួន

៣-ជា អ្នកមិនមានអំណាច

៤-រមែងវិកលចរិត

គប្បីជ្រាបថា ផលរបស់សម្ផប្បលាបៈ មានដទៃទៀតច្រើន ។

**ពោលដោយអភិជ្ឈា**

អភិជ្ឈាជាមនោកម្ម បានដល់ចេតនាដែលប្រព្រឹត្តទៅជាមួយលោភៈដ៏ខ្លាំងក្លា រហូតមានគំនិតចង់បានទ្រព្យរបស់អ្នកដទៃមកជារបស់ខ្លួន នេះហៅថា អភិជ្ឈាប្រសិនបើពេញចិត្ត ក្នុងរបស់អ្នកដទៃថាល្អស្អាត តែមិនមានចិត្តបង្អោនរបស់នោះមកជារបស់ខ្លួនទេ នោះមិនមែនជាអភិជ្ឈាទេ គឺគ្រាន់តែជាលោភៈ ចិត្តប៉ុណ្ណោះ ។

## លោភៈមាន២យ៉ាង

១-**ធម្មិយលោភ** សេចក្តីប្រាថ្នាប្រកបដោយធម៌ ប្រកបដោយសុច្ចរិត

២-**អធម្មិយលោភ** សេចក្តីប្រាថ្នាមិនប្រកបដោយធម៌ ប្រកបដោយទុច្ចរិតកម្ម ។

## ពោលដោយអាការៈរបស់អភិជ្ឈា ៥យ៉ាង

១-**ដោយមូល** ជាលោភៈ និងមោហមូល

២-**ដោយកម្ម** ជាមនោកម្ម ព្រោះចេតនានោះ ប្រព្រឹត្តទៅ ជាមួយលោភៈ ដ៏ខ្លាំង រហូតដល់ចង់បង្អោនវត្ថុ របស់អ្នកដទៃ មកជារបស់ខ្លួន

៣-**ដោយទ្វារ** កើតបាន៣ទ្វារ គឺ មនោទ្វារ វចីទ្វារ កាយទ្វារ តាមមនោទ្វារដូចជា ខណៈចិត្តដែលគិតចង់យកវត្ថុរបស់អ្នកដទៃដោយឧបាយនៃទុច្ចរិតកម្មណាមួយ នេះជាមនោទ្វារ ចំណែកវចីទ្វារគឺនិយាយចេញមកដើម្បីឲ្យបាននូវរបស់នោះ ចំណែកកាយទ្វារ គឺធ្វើទុច្ចរិតកម្មដោយផ្លូវកាយដើម្បីបានរបស់នោះ ។

៤-**ដោយសាវជ្ជៈ** គឺមានសេចក្តីដូចគ្នានឹងអទិន្នាទានកម្មបថដែរ ។

*៥- **ដោយអង្គ** អភិជ្ឈាមានអង្គ២គឺ*

*១ **បរភណ្ឌំ** ទ្រព្យសម្បត្តិរបស់អ្នកដទៃ*

*២ **អត្តនោបរិណាមនំ** មានចិត្តគិតបង្អោនមកជារបស់ខ្លួន ។*

## *ផលរបស់អភិជ្ឈាមាន ៤ប្រការ*

*១- រមែងសាបសូន្យចាកទ្រព្យសម្បត្តិ និងគុណធម៌*

*២- រមែងបដិសន្ធិក្នុងត្រកូលថោកទាប*

*៣- ច្រើនបានទទួលនូវភាពតិះដៀល*

*៤- មិនមានលាភសក្ការៈ*

*គប្បីជ្រាបថា ផលរបស់អភិជ្ឈា មានដទៃទៀតច្រើន ។*

## *ពោលដោយព្យាបាទៈ*

*ព្យាបាទៈ ជាមនោកម្ម បានដល់ចេតនាដែលប្រព្រឹត្តទៅជាមួយនឹងសេចក្តីក្រោធដ៏ខ្លាំងក្លា រហូតគិតប្រាថ្នាឲ្យគេវិនាស នេះជាមនោកម្មបថ ។ ប៉ុន្តែកាលបើសេចក្តីក្រោធកើតឡើង មិនបានចង់ឲ្យគេវិនាសនោះទេ នេះគ្រាន់តែជាទោសចិត្ត មិនមែនជាកម្មបថ ។*

## *ពោលដោយអាការៈ៥របស់ព្យាបាទៈ*

*១-**ដោយមូល** ព្យាបាទៈកើតឡើងព្រោះទោសៈ និងមោហៈ ជាមូល*

*២-**ដោយកម្ម** ជាមនោកម្ម ព្រោះចេតនានោះប្រព្រឹត្តទៅ ជាមួយសេចក្តីក្រោធ*

*៣-**ដោយទ្វារ** កើតបានទ្វារ៣ កាយទ្វារ វចីទ្វារ និងមនោទ្វារ ដូចខណៈ ដែលសេចក្តីក្រោធកើតឡើងខ្លាំងក្លា ចង់ឲ្យគេវិនាស ដោយទុច្ចរិត*

កម្មផ្សេងៗ នេះជាមនោទ្វារ ឯវចីទ្វារ គឺកាលមានចិត្តចង់ឲ្យគេវិនាសហើយ ក៏ប្រើអ្នកដទៃឲ្យទៅធ្វើនូវសេចក្តីវិនាសដល់អ្នកដែលខ្លួនស្អប់នោះចំណែកកាយទ្វារវិញ កាលបើមានចិត្តប្រាថ្នាចង់ឲ្យគេវិនាសហើយ ក៏ធ្វើនូវទុច្ចរិតកម្មផ្សេងៗ ដោយខ្លួនឯងផ្ទាល់ ។

៤-**ដោយសាវជ្ជៈ** គឺមានន័យដូចនៅក្នុងផរុសវាទដែរ

៥-**ដោយអង្គ** ព្យាបាទមានអង្គ២គឺ

**១បរសត្តោ** អ្នកដទៃក្រៅពីខ្លួន

**២តស្សបវិនាសចិន្តា** ចិត្តគិតឲ្យអ្នកដទៃនោះវិនាស ។

កាលគ្រប់អង្គ២ នេះហើយ ជាកម្មបថអាចឲ្យផល នាំឲ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គទេនោះ មិនដល់នូវភាពជាកម្មបថទេឲ្យផលក្នុងបវត្តិកាល ។

## ផលរបស់ព្យាបាទៈមាន៤ប្រការ

១-មានរូបកាយអាក្រក់

២-មានរោគភ័យបៀតបៀន

៣-ជាអ្នកមានអាយុខ្លី

៤-ស្លាប់ដោយគ្រឿងប្រហារ

## មិច្ឆាទិដ្ឋិ

ពាក្យថាមិច្ឆាទិដ្ឋិចែកជា២បទគឺ **មិច្ឆា + ទិដ្ឋិ=មិច្ឆាទិដ្ឋិ** ប្រែថា ការយល់ឃើញខុស ។

**មិច្ឆា** ប្រែថា ខុស **ទិដ្ឋិ** ប្រែថា ការយល់ឃើញ រួមសេចក្តីមកដោយ

*ន័យថា ការយល់ឃើញឯណា ដែលមិនត្រឹមត្រូវ គឺការយល់ឃើញដោយប្រក្រតី ខុសពីសភាវៈពិត ជាធម៌បដិបក្ខជាមួយ* ***កម្មស្សកតាបញ្ញា*** *ធម៌នោះឈ្មោះថា* ***មិច្ឆាទិដ្ឋិ*** *ចំពោះ មិច្ឆាទិដ្ឋិនេះ ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែងទុកយ៉ាងច្រើនដូចជាសក្កាយទិដ្ឋិ សេចក្ដីប្រកាន់ថា ខន្ធ៥ជារបស់ខ្លួន និងទិដ្ឋិដទៃ៦២ប្រការទៀតសំរាប់មិច្ឆាទិដ្ឋិជាមនោទុច្ចរិតនេះ សំដៅដល់ និយតៈមិច្ឆាទិដ្ឋិ៣ប្រការប៉ុណ្ណោះ ដែលជាមិច្ឆាទិដ្ឋិគ្រោតគ្រាត អាចសំរេចទៅជាអកុសលកម្មបថ ទិដ្ឋិដទៃទៀត ត្រឹមតែសាមញ្ញទិដ្ឋិប៉ុណ្ណោះនិយតមិច្ឆាទិដ្ឋិ៣ប្រការគឺ នត្ថិកទិដ្ឋិ មានគំនិតយល់ថា ធ្វើអ្វីក៏ដោយផលដែលគប្បីបានទទួលមិនមានសេចក្ដីយល់ខុសនេះចាត់ជាឧច្ឆេទទិដ្ឋិ គឺឃើញថាសត្វទាំង-ឡាយស្លាប់ហើយសូន្យមិនកើតទៀត ឬមិនមានកម្លាំងកម្មនាំឲ្យបដិសន្ធិទេក្នុងសាមញ្ញផលសូត្រសំដែងនូវនិត្ថិកទិដ្ឋិ១០ប្រការ យ៉ាងនេះថា*

*១-**នត្ថិទិន្នំ** យល់ឃើញថាការធ្វើទានមិនមានផល*

*២-**នត្ថិយិដ្ឋំ** យល់ឃើញថាការបូជាផ្សេងៗមិនមានផល*

*៣-**នត្ថិហុតំ** យល់ឃើញថាការគោរពទទួលមិនមានផល*

*៤-**នត្ថិសុកត ទុក្កតានំ កម្មានំ ផលវិបាកោ** យល់ឃើញថាការធ្វើអំពើល្អ និងអំពើអាក្រក់មិនបានទទួលផលឡើយ*

*៥-**នត្ថិ អយំលោកោ** យល់ឃើញថាភពនេះមិនមាន*

*៦-នត្ថិ **បរោលោកោ** យល់ឃើញថាភពខាងមុខមិនមាន*

*៧-**នត្ថិ មាតា** យល់ឃើញថាមាតាមិនមានគុណ*

*៨-**នត្ថិ បិតា** យល់ឃើញថាបិតាមិនមានគុណ*

៩-**នត្ថិឧបបាតិកា** យល់ឃើញថាសត្វដែលផុសកើតឡើងជំជាត់មួយរំពេច ដូចជានរក ប្រេត ទេវតា ព្រហ្មមិនមាន

១០-**នត្ថិ លោកេ សមណព្រាហ្មណា សមគតា សម្មាបដិបន្នា យេឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ** យល់ឃើញថាសមណព្រាហ្ម ដែលត្រាស់ដឹងក្នុងលោកនេះនិងក្នុងលោកខាងមុខដោយខ្លួនឯងនឹងអាចដឹកនាំអ្នកដទៃបាន សមណៈព្រាហ្មដែលយល់ព្រមព្រៀងដោយសាមគ្គី និងបដិបត្តិ ល្អប្រពៃ ទាំងនោះរមែងមិនមាន ។

-**អហេតុកទិដ្ឋិ** គឺមានសេចក្តីយល់ឃើញថា សត្វទាំងឡាយកំពុងទទួល នូវសេចក្តីសុខ និងសេចក្តីទុក្ខមិនមានហេតុនាំឲ្យកើតទេ ។

-**អកិរិយទិដ្ឋិ** យល់ឃើញថាការធ្វើផ្សេងៗរបស់សត្វទាំងឡាយនោះមិនសំរេចទៅជាបុណ្យជាបាបទេ ។

## ពោលដោយអាការៈ៥របស់មិច្ឆាទិដ្ឋិ

១-**ដោយមូល** មិច្ឆាទិដ្ឋិកើតព្រោះមោហៈ និងលោភៈជាមូល ។

២-**ដោយកម្ម** ជាមនោកម្ម ព្រោះចេតនាកើតឡើងប្រព្រឹត្តទៅ ជាមួយ នឹងការគិតឃើញតាមផ្លូវចិត្ត ។

៣-**ដោយទ្វារ** កើតបានទ្វារ៣គឺ កាយទ្វារ វចីទ្វារ និងមនោទ្វារ តាមកាយទ្វារដូចជាការយល់ខុសយ៉ាងនោះហើយ ក៏ធ្វើទុច្ចរិត ផ្សេងៗតាមទ្វារកាយ តាមវចីទ្វារ កាលយល់ខុសយ៉ាងនោះហើយ ក៏និយាយរឿងដែលខុសនោះ តាមមនោទ្វារបានដល់ចេតនាគឺគំនិត យល់ខុសនោះឯង ។

៤-**ដោយសាវជ្ជៈគឺ**

-មានអាសេវនៈ (គឺសេព) ច្រើនមានទោសធ្ងន់

-មានអាសេវនៈតិចមានទោសស្រាល

-និយតមិច្ឆាទិដ្ឋិ មានទោសធ្ងន់

-អនិយតមិច្ឆាទិដ្ឋិ មានទោសស្រាល

**៥-ដោយអង្គ មិច្ឆាទិដ្ឋិ មាន២អង្គគឺ**

១-**វត្ថុនោ ច គហិតា ការវិបរិតតា** សភាពនៃវត្ថុនោះមិនពិតដូចការយល់របស់មានមិច្ឆាទិដ្ឋិនោះប្រកាន់យក ។

២-**យថា ច តំ គណ្ហាតិ តថា ភាវេន តស្សូបដ្ឋានំ** មានការប្រកាន់នូវរឿងមិនពិតនោះថា ជារឿងពិត កាលគ្រប់អង្គ២នេះហើយ ក៏ដល់នូវ ភាពជាកម្មបថ អាចឲ្យផល បដិសន្ធិក្នុងអបាយភូមិ បើមិនគ្រប់អង្គទេមិនជាកម្មបថ ឲ្យផលក្នុងបវត្តិកាល គប្បីជ្រាបថា បណ្តាអកុសលកម្មបថទាំងឡាយ អកុសលកម្មបថទី១០គឺមិច្ឆាទិដ្ឋិអាចមានទោសច្រើនជាង អកុសលកម្មបថទាំង៩ខាងដើម ម្យ៉ាងទៀត និយតមិច្ឆាទិដ្ឋិ នេះតែងតែនាំឲ្យបដិសន្ធិក្នុងលោកន្តរនរក ។

## ផលរបស់មិច្ឆាទិដ្ឋិមាន៤ប្រការ

១-ឆ្ងាយអំពីរស្មីព្រះសទ្ធម្ម

២-បញ្ញាអាក្រក់លាមក

៣-បដិសន្ធិក្នុងពួកមនុស្សព្រៃ

៤-ជាអ្នកមានឋានៈ ទាបមិនស្មើគេ

គប្បីជ្រាបថា មិច្ឆាទិដ្ឋិមានទោសដទៃទៀតច្រើន អនេក ។

## វិនិច្ឆ័យ អកុសលកម្មបថ ដោយអាការៈ៥ប្រការទៀតគឺ

១-**ធម្មតោ** ដោយធម្ម គឺអង្គធម៌

២-**កោដ្ឋាសតោ** ដោយកោដ្ឋាស គឺចំណែក

៣-**អារម្មណតោ** ដោយអារម្មណ៍

៤-**វេទនាតោ** ដោយវេទនា(ការសោយអារម្មណ៍)

៥-**មូលតោ** ដោយមូល(ឬសគល់)

១-**ធម្មតោ** ដោយធម៌ បណ្ដាអកុសលកម្មបថ១០គឺ អកុសលកម្មបថ ៧តាមលំដាប់គឺ( កាយកម្ម៣ វចីកម្ម៤ ) ដោយអង្គធម៌ គឺ ចេតនាប៉ុណ្ណោះ អកុសលកម្មបថ៣ទៀត (គឺមនោកម្ម៣) ដោយអង្គធម៌ គឺចេតសិកដែល ប្រកបនឹងចេតនា ។

-**អភិជ្ឈា** អង្គធម៌ គឺលោភៈដែលប្រកបនឹងចេតនា

-**ព្យាបាទៈ** អង្គធម៌ គឺទោសៈដែលប្រកបនឹងចេតនា

-**មិច្ឆាទិដ្ឋិ** អង្គធម៌ គឺទិដ្ឋិដែលប្រកបនឹងចេតនា

២-**ដោយកោដ្ឋាស** អកុសលកម្មបថ៨ គឺកាយកម្ម៣ វចីកម្ម៤ និង មិច្ឆាទិដ្ឋិ១ ជាអកុសលកម្មបថប៉ុណ្ណោះ អកុសលកម្មបថ២ គឺអភិជ្ឈា១ ព្យាបាទ១ ជាកម្មបថផង ជាមូលផង ។

៣-**ដោយអារម្មណ៍ បាណាតិបាត** មានសង្ខារជាអារម្មណ៍ ព្រោះ មាន **ជីវិតិន្ទ្រិយចេតសិក** (ជីវិតរបស់សត្វ ) មកជាអារម្មណ៍

-**អទិន្នាទាន** មានសត្វ ឬសង្ខារជាអារម្មណ៍

-**កាមេសុមិច្ឆាចារៈ** មានសង្ខារជាអារម្មណ៍ ដោយអំណាចផោដ្ឋព្វៈ

(អាចារ្យពួកខ្លះថាមានសត្វជាអារម្មណ៍ដែរ)

**-មុសាវាទ** មានសត្វ ឬសង្ខារជាអារម្មណ៍

**- បិសុណាវាទ** មានសត្វ ឬសង្ខារជាអារម្មណ៍

**-ផរុសវាទ** មានសត្វប៉ុណ្ណោះជាអារម្មណ៍

**-សម្ផប្បលាបៈ** មានសត្វ ឬសង្ខារជាអារម្មណ៍

**-អភិជ្ឈា** មានសត្វ ឬសង្ខារជាអារម្មណ៍

**-ព្យាបាទៈ** មានសត្វជាអារម្មណ៍ប៉ុណ្ណោះ

**-មិច្ឆាទិដ្ឋិ** មានសង្ខារជាអារម្មណ៍ដោយអំណាចនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ៣

៤-**ដោយវេទនា**

-បាណាតិបាត ប្រកបដោយទុក្ខវេទនា (ទោមនស្ស-វេទនា) សូម្បីព្រះរាជាកំពុងសើចក៏ដោយ ពេលព្រះអង្គត្រាស់ថាឯងសម្លាប់ វាដែលជាចោរនេះទៅ យ៉ាងនេះ ចេតនា ដែលសំរេច ជាចេតនាសម្បយុត្តជាមួយទុក្ខវេទនា ។

**-អទិន្នាទាន** ប្រកបដោយវេទនា៣ ពេលរីករាយ ត្រេកអរក្នុងការកាន់យក គឺជាសុខវេទនា(សោមនស្សវេទនា) ពេលកាន់យកមានការភ័យខ្លាចឬទាំងពិចារណាផលនៃការលួច គឺជាទុក្ខវេទនាពេលលួចតាំងនូវភាពជាកណ្តាល គឺអទុក្ខមសុខវេទនា ។

**-កាមេសុមិច្ឆាចារៈ** មានវេទនា២គឺ សុខវេទនានិងអទុក្ខមសុខវេទនា

**-មុសាវាទ** មានវេទនា៣

-**បិសុណាវាទ** មានវេទនា៣

-**ផរុសវាទ** មានវេទន១គឺទុក្ខវេទនា

-**សម្ផប្បលាបៈ** មានវេទនា៣

-**អភិជ្ឈា** មានវេទនា២គឺ សុខវេទនានិង ឧបេក្ខាវេទនា

-**ព្យាបាទៈ** មានទុក្ខវេទនាតែ១

-**មិច្ឆាទិដ្ឋិ** មានវេទនា២គឺ សុខវេទនា និងឧបេក្ខាវេទនា

៥-**ដោយមូល**

-**បាណាតិបាត** មានមូល២គឺ ទោសៈនិងមោហៈ ជាមូល

-**អទិន្នាទាន** មានមូល៣គឺ លោភៈ ទោសៈនិង មោហៈ ជាមូល

-**កាមេសុមិច្ឆាចារៈ** មានមូល២គឺ លោភៈ និងមោហៈ ជាមូល

-**មុសាវាទ បិសុណាវាទ និងសម្ផប្បលាបៈ** មានមូលដូចគ្នានឹងអនិន្នាទាន

-**ផរុសវាទ** មានមូលដូចបាណាតិបាត

-**អភិជ្ឈា** និង **ព្យាបាទ** មានមូលតែមួយគឺមោហៈ

-**មិច្ឆាទិដ្ឋិ** មានមូល២ដូចគ្នានឹង**កាមេសុមិច្ឆាចារៈ**

**អកុសលមូល៣ជាហេតុឲ្យកើតអកុសលកម្មបថ១០**

១-**លោភមូលចិត្ត៨ដួង** ជាហេតុឲ្យកើតទុច្ចរិត៧ គឺកាយកម្ម២ អទិន្នាទាន និងកាមេសុមិច្ឆាចារៈ ក្នុងវចីកម្ម៣គឺ មុសាវាទ បិសុណាវាទ និងសម្ផប្បលាបៈ ក្នុងមនោកម្ម២គឺ អភិជ្ឈានិង មិច្ឆាទិដ្ឋិ ។

២-**ទោសមូលចិត្ត២ដួង** ជាហេតុឲ្យកើតទុច្ចរិត៧គឺ កាយកម្ម២

បាណាតិបាត និងអទិន្នាទាន ក្នុងវចីកម្ម៤ គឺមុសាវាទ ជាដើមក្នុង មនោ-កម្ម១ គឺ ព្យាបាទ: ។

៣-**មោហមូលចិត្ត២ដួង** ជាហេតុឲ្យកើតទុច្ចរិត១០គឺ កាយកម្ម៣ វចីកម្ម៤ មនោកម្ម៣ ។

## ចប់អកុសលកម្មបថដោយសង្ខេប

## អហេតុកចិត្ត១៨ដួង

ក្នុងខណ:ដែលពេញចិត្ត ឬមិនពេញចិត្តជាអកុសលចិត្តដែលមាន លោភ:ជាមូល ឬមានទោស:ជាមូល ប៉ុន្តែមុននឹងពេញចិត្ត ក៏ត្រូវតែជាចិត្ត ដែលដឹងអារម្មណ៍តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តទាំងនេះ មិនមែនជាអកុសល ឬកុសលទេ គឺជាចិត្តដែលប្រាសចាកហេតុ ។ចេតសិក ដែលជាហេតុ មាន៦ដួង ។ ចេតសិក៣ដួង ជាអកុសលហេតុគឺ លោភ: ទោស: និងមោហ: ចេតសិក៣ដួងទៀត ជាសោភណ:ហេតុ គឺ អលោភ: អទោស: និងអមោហ: ។

ចិត្ត ឬចេតសិកដែលមានហេតុកើតរួម ឈ្មោះថា សហេតុកចិត្ត ។ ចិត្តដែលមិនប្រកបដោយហេតុឈ្មោះថា អហេតុកចិត្ត ។ ក្នុង១ថ្ងៃៗ មាន អហេតុកចិត្ត កើតច្រើនណាស់ ដូចជាក្នុងខណ:ឃើញរូប ឮសំឡេង ធុំក្លិន ដឹងរស ដឹងផោដ្ឋព្វ: គឺចិត្តនេះឯងកើតឡើងមុន សហេតុក:ចិត្ត (កុសល ឬ អកុសល ) ។

អហេតុកចិត្ត១៨ដួង ជាវិបាកចិត្តមាន១៥ដួង ជាកិរិយាចិត្តមាន៣ ដួង ដែលចែកជា៣ប្រភេទគឺ ជា អហេតុកអកុសលវិបាកចិត្ត៧ដួង ជា

អហេតុកកុសលវិបាកចិត្ត៨ដួង ជា អហេតុកកិរិយាចិត្ត៣ដួង ។

## អកុសលវិបាកចិត្ត៧ដួង

**១-ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណ អហេតុក អកុសលវិបាកចិត្តំ** ចក្ខុវិញ្ញាណ ដែលជា អហេតុកអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ឃើញរូបមិនល្អ) ។

**២-ឧបេក្ខាសហគតំ សោតវិញ្ញាណ អហេតុក អកុសលវិបាកចិត្តំ** សោតវិញ្ញាណ ដែលជា អហេតុកអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ឮ សំឡេងមិនល្អ) ។

**៣-ឧបេក្ខាសហគតំ ឃានវិញ្ញាណ អហេតុក អកុសលវិបាកចិត្តំ** ឃានវិញ្ញាណ ដែលជា អហេតុកអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា(ធុំក្លិនមិនល្អ) ។

**៤-ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណ អហេតុក អកុសលវិបាកចិត្តំ** ជីវ្ហាវិញ្ញាណ ដែលជា អហេតុកអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ដឹងរសមិនល្អ) ។

**៥-ទុក្ខសហគតំ កាយវិញ្ញាណ អហេតុក អកុសលវិបាកចិត្តំ** កាយវិញ្ញាណដែលជា អហេតុកអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយទុក្ខវេទនាមាន(ផោដ្ឋព្វៈមិនល្អ) ។

**៦-ឧបេក្ខាសហគតំ មនោធាតុ អហេតុក អកុសលវិបាកចិត្តំ** មនោធាតុដែលជា អហេតុកអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ធ្វើកិច្ច) ទទួលអារម្មណ៍មិនល្អឯណានិមួយក្នុងបញ្ចទ្វារ (ធ្វើសម្ប-

ដិច្ចន្នកិច្ច ក្នុងបញ្ចទ្វារ ) ។

៧-**ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុអហេតុក អកុសលវិបាកចិត្តំ** មនោវិញ្ញាណធាតុ ដែលជា អហេតុកអកុសលវិបាកចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនាមានអារម្មណ៍មិនល្អតាមទ្វារទាំង៦ ។ចិត្តនេះធ្វើកិច្ច៥យ៉ាងគឺ

១-**បដិសន្ធិកិច្ច** កិច្ចបន្តភពជាតិកំណើត

២-**ភវង្គកិច្ច** កិច្ចរក្សាភពជាតិកំណើត

៣ -**សន្តីរណកិច្ច** កិច្ចពិចារណាអារម្មណ៍ក្នុងបញ្ចទ្វារ

៤-**តទាលម្ពណកិច្ច** កិច្ចទទួលអារម្មណ៍បន្ទាប់អំពីជវន

៥-**ចុតិកិច្ច** កិច្ចឃ្លាតចាកភព

បណ្តាចិត្តទាំង១២១ដួងមានតែចិត្ត១ដួងតែប៉ុណ្ណោះ ដែលធ្វើ បដិសន្ធិកិច្ចក្នុងអបាយភូមិគឺអហេតុកចិត្តអកុសលដួងទី៧ ។

## អធិប្បាយអហេតុកអកុសលវិបាកចិត្ត៧ដួង

អកុសលវិបាកចិត្ត ជាអហេតុកចិត្ត បានដល់ចិត្តមិនប្រកបដោយហេតុ៦គឺលោភៈទោសៈ មោហៈ អលោភៈអទោសៈ អមោហៈដែលចិត្តនេះកើតឡើង ជាផលរបស់អកុសលកម្មដែលបានធ្វើទុកហើយ អកុសលចិត្តដែលមិនមានកម្លាំងមិនដល់ភាពជាកម្មបថក៏មាន អកុសលចិត្តមានកម្លាំងដល់ភាពជាកម្មបថក៏មាន អកុសលចិត្តទាំងអស់នោះរលត់ទៅហើយរមែងជាបច្ច័យ ឲ្យអកុសលវិបាកចិត្តកើតឡើង ដូចជាកម្មអាក្រក់ ដែលសត្វបានធ្វើក្នុងជាតិនេះក្តី ជាតិមុនៗក្តី ជាបច្ច័យឲ្យកើតអកុសលវិបាកចិត្តនេះឯង។

១-**ចក្ខុវិញ្ញាណ** ជាអហេតុកចិត្តកើតឡើងព្រមជាមួយឧបេក្ខាវេទនា

កើតឡើងទទួលផលរបស់អកុសលកម្មដែលបានធ្វើទុកហើយ ។ចក្ខុវិញ្ញាណនេះកើតឡើងមួយខណៈ ឬច្រើនខណៈក៏ដោយ រមែងមានវណ្ណៈ (ពណ៌ )ជាអារម្មណ៍ប៉ុណ្ណោះ មិនមានសត្វបុគ្គលជាអារម្មណ៍ទេ មានត្រឹមតែរូបារម្មណ៍ (ពណ៌) ជាអារម្មណ៍ប៉ុណ្ណោះ ។ ប្រសិនបើ អកុសលកម្ម ឲ្យផល ក៏ធ្វើឲ្យចក្ខុវិញ្ញាណ ឃើញរូបារម្មណ៍ដែលមិនល្អ ប្រសិនបើជាកុសលឲ្យផល ក៏ឃើញរូបល្អ ការឃើញរូបល្អ ឬមិនល្អ មិនប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នា ឬទៅតាមអំណាចនៃអ្នកណាមួយឡើយ ។ កាលបើកម្មណាមានឱកាសហើយ ក៏ឲ្យផលពុំខានឡើយ ការស្គាល់ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍មិនមែនជាកិច្ចរបស់ចក្ខុវិញ្ញាណទេព្រោះចក្ខុវិញ្ញាណ ធ្វើទស្សនកិច្ចមានរូបារម្មណ៍គឺពណ៌ប៉ុណ្ណោះ ជាអារម្មណ៍ ចិត្តដែលដឹងថារូបនេះល្អ ឬ មិនល្អ បានដល់ជវនចិត្ត ។ ចក្ខុវិញ្ញាណដែលមានពណ៌ ជាអារម្មណ៍កើតឡើងប្រកបដោយឧបេក្ខាវេទនា ព្រោះអាស្រ័យឧបាទាយរូបប៉ះខ្ទប់នឹងចក្ខុបសាទ មិនមែនចក្ខុបសាទ ប៉ះខ្ទប់និងមហាភូតរូបទេ ។ ដូច្នេះវេទនាចេតសិក កើតឡើង ជាឧបេក្ខាវេទនាប៉ុណ្ណោះ ។

២-**សោតវិញ្ញាណ** ជាអហេតុកចិត្ត កើតព្រមជាមួយឧបេក្ខាវេទនា មានន័យដូចគ្នានឹងក្នុងចក្ខុវិញ្ញាណដែរ ។

៣-**ឃានវិញ្ញាណ** ជាអហេតុកចិត្ត កើតព្រមជាមួយឧបេក្ខាវេទនា មានន័យដូចគ្នានឹងក្នុងចក្ខុវិញ្ញាណដែរ ។

៤-**ជីវ្ហាវិញ្ញាណ** ជាអហេតុកចិត្ត កើតព្រមជាមួយឧបេក្ខាវេទនា មានន័យដូចគ្នានឹងចក្ខុវិញ្ញាណដែរ ។

**៥កាយវិញ្ញាណ** ជាអហេតុកអកុសលវិបាក កើតព្រមជាមួយទុក្ខ-វេទនា ឬសុខវេទនា ព្រោះកុសល ឬអកុសលឲ្យផល ។ កាយវិញ្ញាណកើតព្រមជាមួយទុក្ខវេទនា រមែងប្រព្រឹត្តទៅតាម សភាវធម៌ ដែលប៉ះខ្ទប់បានដល់មហាភូតរូប៣គឺ ធាតុដីមានលក្ខណៈរឹងទន់ ធាតុភ្លើង មានលក្ខណៈក្តៅ ត្រជាក់ ធាតុខ្យល់មានលក្ខណៈ ញ័រ ឬតឹង កាលបើធាតុទាំង៣នេះ ធាតុណាមួយប៉ះខ្ទប់ នឹង កាយបសាទរូប ដែលជាឧបាទាយរូប ប៉ះខ្ទប់នឹងមហាភូតរូប ទុក្ខវេទនាក៏កើតឡើង ។

**៦-អកុសលវិបាកមនោធាតុ** ធ្វើសម្បដិច្ឆន្នកិច្ច គឺកិច្ចទទួលអារម្មណ៍ អំពីបញ្ចវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ទោះបីជា អកុសលវិបាកក្តី ឬ កុសលវិបាកក្តី ចិត្តនេះជាមនោធាតុ គឺជាតុដឹងអាស្រ័យហទយវត្ថុទើបកើតឡើង ។

ដែលឈ្មោះថាធាតុ ព្រោះអត្ថថាទ្រទ្រង់ ឬ សូន្យចាកសត្វបុគ្គលជាដើម។

**៧-អកុសលវិបាកមនោវិញ្ញាណធាតុ** ធ្វើកិច្ច៥យ៉ាងមានបដិសន្ធិកិច្ចជាដើម តែមិនមែនធ្វើកិច្ចដំណាលគ្នាទេ ។

## អហេតុកកុសលវិបាកចិត្ត៨ដួង

**១-ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អហេតុក កុសលវិបាកចិត្តំ** ចក្ខុវិញ្ញាណ ដែលជា អហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា(ឃើញរូបល្អ)។

២-**ឧបេក្ខាសហគតំ សោតវិញ្ញាណំ អហេតុក កុសលវិបាកចិត្តំ** សោតវិញ្ញាណដែលជា អហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ឮសំឡេងល្អ)។

៣-**ឧបេក្ខាសហគតំ ឃានវិញ្ញាណំ អហេតុក កុសលវិបាកចិត្តំ** ឃានវិញ្ញាណ ដែលជា អហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ធុំក្លិនល្អ)។

៤-**ឧបេក្ខាសហគតំ ជីវ្ហាវិញ្ញាណំ អហេតុក កុសលវិបាកចិត្តំ** ជីវ្ហាវិញ្ញាណ ដែលជា អហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា(ដឹងរសល្អ)។

៥-**សុខសហគតំ កាយវិញ្ញាណំ អហេតុក កុសលវិបាកចិត្តំ** កាយវិញ្ញាណ ដែលជា អហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសុខវេទនា (ទទួលផោដ្ឋព្វៈល្អ) ។

៦-**ឧបេក្ខាសហគតំ មនោធាតុ អហេតុក កុសលវិបាកចិត្តំ** មនោធាតុដែលជា អហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ទទួលអារម្មណ៍ល្អ អំពីបញ្ចទ្វារ ចិត្តនេះធ្វើសម្បដិច្ឆន្នកិច្ច ។

៧-**សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុក កុសលវិបាកចិត្តំ** មនោវិញ្ញាណធាតុ ដែលជាអហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយ សោមនស្សវេទនា ។

៨-**ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុក កុសលវិបាកចិត្តំ** មនោវិញ្ញាណធាតុ ដែលជា អហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយ

ឧបេក្ខាវេទនា (ធ្វើកិច្ច៥យ៉ាង មានបដិសន្ធិកិច្ចជាដើម) ។

**អហេតុកកុសលវិបាក៨ដួង** នេះកើតឡើងអំពីមហាកុសលចិត្តដែលធ្វើទុកហើយក្នុង អតីតជាតិ ឬក្នុងបច្ចុប្បន្នជាតិ ដូចមានការធ្វើទាន រក្សាសីលជាដើម ទើបឲ្យឃើញរូបល្អ ឮសំឡេងពិរោះ ដឹងក្លិនក្រអូប ដឹងរសជាតិឆ្ងាញ់ ដឹងផោដ្ឋព្វៈប្រសើរ ម្យ៉ាងទៀតអហេតុកកុសលវិបាកចិត្ត មាន ៨ដួង ច្រើនជាងអកុសលវិបាកចិត្ត១ដួង គឺមនោវិញ្ញាណធាតុ ដែលជាសោមនស្សសន្តីរណកិច្ចពិចារណានូវអតិឥដ្ឋារម្មណ៍ ព្រោះសន្តីរណកិច្ចជាកុសលវិបាក អាចទទួលអារម្មណ៍បាន២ផ្នែកគឺ ឥដ្ឋមជ្ឈត្តារម្មណ៍បានដល់អារម្មណ៍ធម្មតា អតិឥដ្ឋារម្មណ៍បានដល់ អារម្មណ៍ ល្អយ៉ាងក្រៃលែង ពេលដែល អតិឥដ្ឋារម្មណ៍កើតឡើង អហេតុកកុសលវិបាកចិត្ត ដួងទី៧ កើតឡើង ពិចារណាអារម្មណ៍នោះ ពេលដែលឥដ្ឋមជ្ឈត្តារម្មណ៍មានប្រាកដអហេតុកកុសលវិបាកចិត្តដួងទី៨កើតឡើង ។

ផ្នែកខាងអកុសលវិបាកចិត្ត មានតែអនិដ្ឋារម្មណ៍ប៉ុណ្ណោះ មកប្រាកដមិនមាន អតិអនិដ្ឋារម្មណ៍ទេ ។

អតិឥដ្ឋារម្មណ៍ (អារម្មណ៍ល្អក្រៃលែងបានដល់អ្វី? គឺបានដល់ការឃើញសរីរៈព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែលគ្មានអ្វីប្រៀបស្មើ ការឃើញភិក្ខុសង្ឃរបស់អ្នកដែលមានសទ្ធាមាំទាំល្អជាដើម ។ ក្នុងការស្តាប់សំឡេង ល្អក្រៃលែង ដូចជាស្តាប់ព្រះសូរសៀងនៃព្រះពុទ្ធជាម្ចាស់ ឬសូម្បីបានស្តាប់ពាក្យថា**ពុទ្ធោ លោកេ ឧប្បន្នោ**(ព្រះពុទ្ធជាម្ចាស់កើតឡើងក្នុងលោកហើយ) របស់អ្នកដែលមានសទ្ធាឈ្មោះថាទទួលនូវ អតិឥដ្ឋារម្មណ៍ ព្រោះ សោម-

នស្សសន្តីរណៈ  មានឱកាសកើតឡើង  និងការទទួលនូវ ក្ខិនល្អ រសល្អ ផោដ្ឋព្វារម្មណ៍ល្អ  សោមនស្សសន្តីរណៈក៏កើតឡើង អតិឥដ្ឋារម្មណ៍មាន នៅក្នុងទេវលោកច្រើនជាងនៅក្នុងមនុស្សលោក ។

## អហេតុកកិរិយាចិត្ត៣ដួង

១-**ឧបេក្ខាសហគតំ មនោធាតុ អហេតុកកិរិយាចិត្តំ** មនោធាតុដែលជាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា  (កើតមុនបញ្ចវិញ្ញាណធ្វើអាវជ្ជនកិច្ច ក្នុងបញ្ចទ្វារ) ។

២-**ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ** មនោវិញ្ញាណធាតុដែលជាអហេតុកកិរិយាចិត្តប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា កើតតាម បញ្ចទ្វារ ធ្វើ**វោដ្ឋវនកិច្ច** (កិច្ចកំណត់ដឹងអារម្មណ៍)នៅខាងមុខសន្តីរណកិច្ច បើនៅក្នុងមនោទ្វារ ធ្វើអាវជ្ជនកិច្ច (រំពឹងនឹករកអារម្មណ៍)។

៣-**សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ** មនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា កើតក្នុងទ្វារទាំង៦ធ្វើ ជវនកិច្ចតែម៉្យាងជាចិត្តរបស់ព្រះអរហន្ត ហៅថា**ហសិតុប្បាទចិត្ត** ចិត្តញញឹមរបស់ព្រះអរហន្ត ។

## ការប្រព្រឹត្តទៅនៃចិត្តក្នុងបញ្ចទ្វារមាន១៧ខណៈ

១- **អតីតភវង្គ**
២- **ភវង្គចលន** } ចិត្តផុតវិថី
៣- **ភវង្គុបច្ឆេទ**
៤- **បញ្ចទ្វារាវជ្ជនកិច្ច ឬអាវជ្ជនកិច្ច**

៥- **បញ្ចវិញ្ញាណ** (ចក្ខុទ្វារាវជ្ជនៈ សោតទ្វារាវជ្ជនៈ ឃានទ្វារាវជ្ជនៈ ជីវ្ហាទ្វារាវជ្ជនៈ កាយទ្វារាវជ្ជនៈ)

៦- **សម្បដិច្ឆន្នកិច្ច**

៧- **សន្តីរណកិច្ច**

៨- **វោដ្ឋវនកិច្ច**

៩- **ជវនកិច្ច**

១០-**ជវនកិច្ច**

១១-**ជវនកិច្ច**

១២-**ជវនកិច្ច**

១៣- **ជវនកិច្ច**

១៤- **ជវនកិច្ច**

១៥- **ជវនកិច្ច**

១៦- **តទាលម្ពណកិច្ច**

១៧- **តទាលម្ពណកិច្ច**

០- **ភវង្គបាត** គឺចិត្តប្រព្រឹត្តទៅក្នុងភវង្គ

## អធិប្បាយអហេតុកកិរិយាចិត្ត៣ដួង

-ពាក្យថា **បញ្ចទ្វារាវជ្ជន** ចែកជា៣បទគឺ **បញ្ច** + **ទ្វារ** + **អាវជ្ជន** ជា **បញ្ចទ្វារាវជ្ជន** **បញ្ច** ប្រែថា៥(ចំនួន៥) **ទ្វារ** ប្រែថាប្រឡោះប្រហោង **អាវជ្ជន** ប្រែថា រាវរក សរុបសេចក្ដីមក ប្រែថា រាវរកអារម្មណ៍ក្នុងទ្វារទាំង៥ ហើយចិត្តនេះ ជាកិរិយាចិត្ត កើតឡើង ព្រោះអារម្មណ៍ មានរូបារម្មណ៍ ជាដើម

មកប៉ះខ្ទប់ ជាបច្ច័យឲ្យកើតឡើង ប្រសិនបើបញ្ចទ្វារាវជ្ជនៈ ចិត្តនេះទទួល រូបារម្មណ៍ ចិត្តនេះ ហៅថាចក្ខុទ្វារាវជ្ជនៈ បើតាមផ្លូវត្រចៀក ហៅថា សោ-តទ្វារាវជ្ជនៈ បើតាមផ្លូវច្រមុះ ហៅថា ឃានទ្វារាវជ្ជនៈ បើតាមផ្លូវអណ្តាត ហៅថា ជិវ្ហាទ្វារាវជ្ជនៈ បើតាមផ្លូវកាយហៅថាកាយទ្វារាវជ្ជនៈ រួមទ្វារទាំង ៥នេះហៅថា បញ្ចទ្វារាវជ្ជនចិត្ត **អដ្ឋកថាចារ្យបាន ឧបមាថា** បញ្ចទ្វារវិថី-ចិត្ត ដូចជាសត្វពីងពាង អធិប្បាយថាសត្វពីងពាង១បានរាយ សំណាញ់ មានខ្សែ៥ធ្វើកន្ទេងដេកនៅកណ្តាល កាលខ្សែណាមួយត្រូវសត្វតូចៗ មាន សត្វសុច មូស ជាដើម មកប៉ះខ្ទប់ហើយសត្វពីងពាងនោះ ក៏ឃ្លាតចាក ទី កន្ទេងដេកធ្វើដំណើរទៅតាមខ្សែណាដែលសត្វមកប៉ះហើយ ក៏ស៊ីនូវសត្វ នោះទៅ រួចត្រឡប់មកកន្ទេងដើមវិញ ក្នុងរឿងឧបមានេះយ៉ាងណា

-បសាទរូបទាំង៥ដូចជាខ្សែពីងពាងទាំង៥

-ចិត្តដូចជាពីងពាងដែលដេកនៅកណ្តាលសម្បុក

-ពេលដេកអារម្មណ៍មកប៉ះខ្ទប់ដូចសត្វតូចៗដែលមកប៉ះខ្សែពីងពាង

-ពេលដែលកិរិយាមនោធាតុ ទទួលអារម្មណ៍ដែលមកប៉ះបសាទរូប ហើយធ្វើឲ្យភវង្គញ័រ ដូចជាការញ័ររបស់សត្វពីងពាង ដែលនៅកណ្តាល

-ការប្រព្រឹត្តទៅនៃវិថីចិត្តដូចពេលដែលសត្វពីងពាងរត់ទៅតាមខ្សែ

-ពេលដែលចិត្តសេពនូវអារម្មណ៍ ដូចជាពីងពាងបានស៊ីនូវសត្វ

-កាលដែលវិថីចិត្តនោះចូលកាន់ភវង្គវិញ ដូចសត្វពីងពាងត្រឡប់ ទៅដេកនៅកណ្តាលសម្បុកវិញ ។

ការដែលលោកឧបមារឿងសត្វពីងពាងនោះមកក៏ដើម្បីឲ្យជ្រាបថា កាលអារម្មណ៍ មកប៉ះខ្ទប់បសាទរូបហើយចិត្តអាស្រ័យក្នុងហទយវត្ថុកើត មុនចិត្តនៅក្នុងបសាទរូប ។

**មនោទ្វារាវជ្ជន** ប្រែថា ការពិចារណា អារម្មណ៍តាមផ្លូវចិត្ត ចែកជា ៣បទគឺ **មនោ+ទ្វារ+អាវជ្ជន=មនោទ្វារាវជ្ជន មនោ** ប្រែថា ចិត្ត **ទ្វារ** ប្រែថា ផ្លូវប្រឡោះ **អាវជ្ជន** ប្រែថា រាវរកឬការពិចារណា ចិត្តនេះកើតឡើងជាមួយ ឧបេក្ខាវេទនា ពិចារណាអារម្មណ៍តាម មនោទ្វារ និងធ្វើតួនាទីកាត់ក្តីនូវ អារម្មណ៍តាមបញ្ចទ្វារ បានន័យថាចិត្តនេះពិចារណា អារម្មណ៍តាម ទ្វារ ទាំង៦ បើអហេតុកកិរិយាចិត្តនេះ កើតក្នុងបញ្ចទ្វារវិថី ហៅថាវោដ្ឋវនៈ បើ កើតក្នុង មនោទ្វារវិថី ហៅថា មនោទ្វារាវជ្ជនៈ អហេតុកកិរិយា ដែលជា សោមនស្សជួងទី៣ ធ្វើ ជវនកិច្ច ជាចិត្តរបស់ព្រះអរហន្ត ហៅថា ហសិតុ-ប្បាទចិត្ត **ហសិតុប្បាទចិត្ត**នេះ ចែកជា៣បទគឺ**ហសិត+ឧប្បាទ+ចិត្ត=ហសិ-តុប្បាទចិត្ត ហសិត** ប្រែថា ញញឹម **ឧប្បាទ** ប្រែថាការកើតឡើង **ចិត្ត** ប្រែថា ដឹងអារម្មណ៍ សរុបសេចក្តីមកប្រែថា ចិត្តញញឹមកើតឡើង ដូចជារឿងព្រះ មហាមោគ្គល្លាន បានឃើញសត្វប្រេតនៅ នាជើងភ្នំគិជ្ឈកូដ ដែលកំពុង ទទួលនូវទុក្ខវេទនា ។ ការឃើញនោះគឺ ឃើញដោយកិរិយាអភិញ្ញាចិត្ត ដែលប្រព្រឹត្តទៅជាមួយការពិចារណាថា សភាពដូច្នេះ នឹងមិនកើតដល់ លោកឡើយ ហើយ **ហសិតុប្បាទចិត្ត**ក៏កើតឡើង ។

ក្នុងគម្ពីរសុពោធាលង្ការ បាន ពោលអំពីការសើចញញឹមមាន៦យ៉ាងគឺ

**១-សិត** ញញឹមមិនឃើញធ្មេញ បានដល់ការញញឹម របស់ព្រះដ៏

ព្រះភាគជាម្ចាស់

២-**ហសិត** ញញឹមល្មមឃើញធ្មេញ ជាការញញឹមរបស់ព្រះអរហន្ត ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន និងបុថុជ្ជន។ការញញឹមនេះ ក្រៅអំពីព្រះអរហន្តហើយ រមែងប្រកបដោយ ហេតុជាកុសល ឬ អកុសល

៣-**វិហសិត** សើចឮសំឡេងស្រាលៗ កើតមានក្នុងពួកបុថុជ្ជន និង ព្រះអរិយបុគ្គល៣ពួក (វៀរព្រះអរហន្ត)

៤-**អតិហសិត** សើចឮសំឡេងខ្លាំងៗ កើតចំពោះបុថុជ្ជន និងព្រះ សោតាបន្ន និងព្រះសកទាគាមី ។

៥-**ឧបហសិត** សើចរហូតដល់ញ័រកាយ ជាការសើចរបស់ បុថុជ្ជន

៦-**អវហសិត** សើចរហូតដល់ហូរទឹកភ្នែក ជាការសើចរបស់បុថុជ្ជន

**សិត** និង **ហសិត** ជាការញញឹមរបស់ព្រះអរហន្ត ជាចិត្តញញឹមមិនប្រកាន់ មាំក្នុងអារម្មណ៍ ដូចបុគ្គលដទៃឡើយ ចិត្តនេះមានកម្លាំងខ្សោយ ជាចិត្ត ពិសេស ហៅថា **ហសិតុប្បាទចិត្ត** ។ កាលដែលចិត្ត មានកម្លាំងតិចនេះឯង ទើបជា **អហេតុកចិត្ត** ចំណែកចិត្តសើចដទៃទៀត ជាសហេតុកចិត្ត ។

អហេតុកចិត្ត១៨ដួង សង្គ្រោះចូលក្នុងអសង្ខារិកៈ ព្រោះកើតឡើង ឯងៗដោយអាស្រ័យ **ឧបត្ថិហេតុ** គឺហេតុដែលប្រជុំគ្នាកើតឡើង សូម្បីតែ អ្នកដទៃដឹកនាំក៏ដោយ បើ**ឧបត្ថិហេតុ**មិនគ្រប់អង្គទេ ចិត្តមានចក្ខុវិញ្ញាណ ជាដើមរមែងមិនអាចកើតឡើងបានឡើយ ។

**ឧបត្ថិហេតុនៃអហេតុកចិត្ត១៨ដួង ក្នុងអដ្ឋសាលិនី** សម្ដែងទុកថា ហេតុឲ្យកើតចក្ខុវិញ្ញាណ២ដួងមាន ៤ប្រការ

១-**អសម្ភិន្នត្តាចក្ខុស្ស** ព្រោះចក្ខុបសាទមិនទាន់បែកធ្លាយ

២-**អាបាថគតត្តារូបានំ** ព្រោះរូបារម្មណ៍មកកាន់ដល់គន្លង

៣-**អាលោកសន្និស្សិតំ** អាស្រ័យដោយពន្លឺ

៤-**មនសិការហេតុកំ** មានមនសិការ ជាហេតុ ។

បណ្ដាបច្ច័យទាំង៤នោះ ចក្ខុនៃអ្នកស្លាប់ក្ដី ចក្ខុនៃអ្នកដែលមានជីវិត ដែលរលត់ក្ដី(ភ្នែកខ្វាក់ ) ឬ ចក្ខុដែលត្រូវទឹកប្រមាត់ ឬត្រូវទឹកស្លេស្ម ឬលោហិតបិទបាំងក្ដី ដែលមិនអាចជាបច្ច័យដល់ចក្ខុវិញ្ញាណនេះ ឈ្មោះថាចក្ខុបែកធ្លាយហើយ ប៉ុន្ដែបើនៅជាបច្ច័យបានឈ្មោះថា មិនទាន់បែកធ្លាយ សូម្បីតែចក្ខុបសាទមិនទាន់បាក់បែកធ្លាយ ក៏ដោយ ប៉ុន្ដែរូបារម្មណ៍(ពណ៌)នៅមិនទាន់មកកាន់គន្លង នឹងចក្ខុបសាទទេ

ចក្ខុវិញ្ញាណក៏កើតមិន

បាន ។ បើរូបារម្មណ៍នោះ មកកាន់គន្លងហើយ ប៉ុន្ដែ បច្ច័យគឺអាស្រ័យពន្លឺមិនមាន ចក្ខុវិញ្ញាណក៏កើតមិនបានប្រសិនបើពន្លឺដែលជាបច្ច័យនោះមាន ប៉ុន្ដែកិរិយាមនោធាតុ មិនញ៉ាំងភវង្គឲ្យផ្លាស់ប្ដូរទៅទេចក្ខុវិញ្ញាណក៏កើតមិនបាន ។កាលណាកិរិយាមនោធាតុញ៉ាំងភវង្គឲ្យផ្លាស់ប្ដូរគ្នាបានចក្ខុវិញ្ញាណទើបកើតឡើង ធ្វើទស្សនកិច្ច (កិច្ចឃើញរូប) ចក្ខុវិញ្ញាណ កាលកើតឡើងរមែងកើតព្រម ដោយសម្បយុត្តធម៌ទាំងឡាយ ដោយពិត ។ ដូច្នេះហើយទើបពោលថា ចក្ខុវិញ្ញាណកើត ព្រោះអាស្រ័យបច្ច័យ៤ប៉ុណ្ណោះ ។

**ហេតុឲ្យកើតសោតវិញ្ញាណ២ដួងមាន៤ប្រការ**

១-**អសម្ភិន្នត្តា សោតស្ស** ព្រោះសោតបសាទ នៅមិនទាន់បែកធ្លាយ

២-**អាបាថគតត្តា សទ្ទានំ** ដោយសំឡេងមកកាន់គន្លង នៃសោត-
បសាទ

៣-**អាកាសសន្និស្សិតំ** អាស្រយ័ដោយអាកាសគឺលំហ

៤-**មនសិការហេតុកំ** មានមនសិការៈជាហេតុ

បណ្តា បច្ច័យទាំង៤ ពាក្យថា អាស្រ័យ ដោយអាកាស គឺសោតវិញ្ញាណនោះ អាស្រ័យនូវអាកាសទើបកើតឡើង បើមិនមាននូវអាកាសទេក៏កើតមិនបាន ព្រោះកាលណាបុគ្គលបិទរន្ធត្រចៀកឲ្យជិត សោតវិញ្ញាណមិនអាចប្រព្រឹត្តទៅបាន ។ ពាក្យក្រៅពីនេះ គប្បីជ្រាបដោយន័យ ដែលពោលមក ហើយក្នុងចក្ខុវិញ្ញាណនោះចុះ ។

### ហេតុឲ្យកើតឃានវិញ្ញាណ២ដួង មាន៤ប្រការ

១-**អសម្ភិន្នត្តា ឃានស្ស** ព្រោះឃានបសាទមិនទាន់បែកធ្លាយ

២-**អាបាថគតត្តា គន្ធានំ** ដោយក្លិនទាំងឡាយមកកាន់គន្លងនៃឃាន
បសាទ

៣-**វាយោសន្និស្សិតំ** អាស្រ័យដោយវាយោគឺខ្យល់

៤-**មនសិការហេតុកំ** មានមនសិការៈជាហេតុ ។

បណ្តាបច្ច័យទាំង៤នោះ ពាក្យថាអាស្រ័យ ដោយវាយោ គឺ កាលណា វាយោបក់ផាត់នូវក្លិនទាំងឡាយចូលមករន្ធច្រមុះនោះ ឃានវិញ្ញាណទើបកើតឡើងប្រសិនបើវាយោគឺខ្យល់មិនមាន ឃានវិញ្ញាណ ក៏កើតមិនបាន ។

### ហេតុឲ្យកើតជីវ្ហាវិញ្ញាណ២ដួងមាន៤ប្រការ

១-**អសម្ភិន្នត្តា ជីវ្ហាយ** ព្រោះជីវ្ហាបសាទ នៅមិនទាន់បែកធ្លាយ

២-**អាបាថគតត្តា រសានំ** ព្រោះរសជាតិទាំងឡាយមកកាន់គន្លង

៣-**អាបោសន្និស្សិតំ** អាស្រ័យដោយអាបោគឺទឹក

៤-**មនសិការហេតុកំ** មានមនសិការៈ ជាហេតុ

**ហេតុឲ្យកើតកាយវិញ្ញាណ២ដួងមាន៤ប្រការ**

១-**អសម្ភិន្នត្តា កាយស្ស** ព្រោះកាយបសាទនៅមិនទាន់បែកធ្លាយ

២-**អាបាថគតត្តា ផោដ្ឋព្វានំ** ព្រោះផោដ្ឋព្វៈ មកកាន់គន្លងនៃកាយបសាទ

៣-**បឋវីសន្និស្សិតំ** អាស្រ័យដោយបឋវី គឺដី

៤-**មនសិការហេតុកំ** មានមនសិការៈ ជាហេតុ ។

បណ្តាបច្ច័យទាំង៤នោះ ពាក្យថាអាស្រ័យ ដោយបឋវី បានដល់បឋវី ធាតុដែលផ្គុំគ្នា គឺកាយបសាទនោះឯង ជាបច្ច័យ ទើបកាយវិញ្ញាណកើតឡើង បើកាយបសាទមិនមានទេ កាយវិញ្ញាណក៏មិនកើតឡើងបានដែរ ។

**ហេតុឲ្យកើតមនោធាតុ៣ដួង មាន៤ប្រការគឺ**

១-មាន បសាទរូបទាំង៥គឺ ចក្ខុ សោត ឃាន ជីវ្ហា កាយ

២-មានអារម្មណ៍ទាំង៥គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មកកាន់គន្លង

៣-អាស្រ័យ **ហទយវត្ថុ** គឺ បេះដូង

៤-មានមនសិការៈ ជាហេតុ ។

មនោធាតុ៣ដួងគឺ បញ្ចទ្វារាវជ្ជនចិត្ត១ដួង សម្បដិច្ឆន្ន២ដួង ។ ចិត្ត៣ដួងនេះហៅថា មនោធាតុ ប្រែថា ធាតុដឹង ។ មនោវិញ្ញាណធាតុ ជាចិត្តដែលមានអំណាច អាចដឹងអារម្មណ៍បានច្រើនជាង បញ្ចវិញ្ញាណ និងមនោធាតុ គប្បីជ្រាបថា ចិត្តទាំងអស់មាន៨៩ដួង ឬ១២១ដួងនោះ វៀរទ្វិបញ្ចវិញ្ញាណធាតុ១០ដួង និងមនោធាតុ៣ដួងចេញហើយ នៅសល់ចិត្ត៧៦ដួង ឬ១០៨ដួងទាំងអស់នេះជាមនោវិញ្ញាណធាតុ ។

## ហេតុឲ្យកើតមនោវិញ្ញាណធាតុមាន៤ប្រការ

១-**អសម្ភិន្នត្តា មនស្ស** ព្រោះមនោនៅមិនទាន់បែកធ្លាយ

២-**អាបាថគតត្តា ធម្មានំ**ដោយធម្មារម្មណ៍ទាំងឡាយមកកាន់គន្លង

៣-**វត្ថុសន្និស្សិតំ** អាស្រ័យ ហទយវត្ថុ

៤-**មនសិការហេតុកំ** មានមនសិការៈជាហេតុ

បណ្តាបច្ច័យទាំង៤នោះ ពាក្យថា **មនោ** បានដល់ភវង្គចិត្តនោះបែកធ្លាយហើយក្តី មានកម្លាំងខ្សោយក្តី មិនអាចជាបច្ច័យដល់អាវជ្ជនៈចិត្តក្តី ឈ្មោះថា មនោគឺភវង្គបែកធ្លាយក្នុងសេចក្តីនេះ ។ ប៉ុន្តែពេលដែលអាចជាបច្ច័យ ដល់អាវជ្ជនៈចិត្តបាន ឈ្មោះថាមនោនៅមិនទាន់បែកធ្លាយ ។ ពាក្យថាធម្មារម្មណ៍មកកាន់គន្លង បានដល់ធម្មារម្មណ៍ជា អតីតៈ អនាគត និងបច្ចុប្បន្ន មកកាន់គន្លង ។ ពាក្យថាអាស្រ័យហទយវត្ថុ គឺអាស្រ័យបេះដូងប៉ុណ្ណោះទើបកើតឡើង វៀរហទយវត្ថុចេញហើយកើតមិនបាន បញ្ហានេះព្រះថេរៈ លោកពោលសំដៅដល់ **បញ្ចវោការភព** គឺភពមានខន្ធ៥ ។

ពាក្យថាមនសិការៈ ជាហេតុអធិប្បាយថាកិរិយាមនោវិញ្ញាណធាតុ

ញុំាង ភវង្គឲ្យផ្លាស់ប្តូរទៅសិន ទើប មនោវិញ្ញាណធាតុកើតឡើង ។

**កិច្ច៤យ៉ាង របស់អហេតុកចិត្ត១៨ដួង**

១-**ចក្ខុវិញ្ញាណ២ដួង** ធ្វើទស្សនកិច្ច (កិច្ចឃើញរូប)

២-**សោតវិញ្ញាណ២ដួង** ធ្វើសវនកិច្ច (កិច្ចឮសំឡេង)

៣-**ឃានវិញ្ញាណ២ដួង** ធ្វើឃាយនកិច្ច (កិច្ចដឹងក្លិន)

៤-**ជីវ្ហាវិញ្ញាណ២ដួង** ធ្វើសាយនកិច្ច (កិច្ចជញ្ជក់រសជាតិ)

៥-**កាយវិញ្ញាណ២ដួង** ធ្វើផុសនកិច្ច (កិច្ចពាល់ត្រូវ)

៦-**វិបាកមនោធាតុ២ដួង** ធ្វើសម្បដិច្ឆន្នកិច្ច (កិច្ចទទួលនូវអារម្មណ៍)

៧-**អហេតុកវិបាកមនោវិញ្ញាណធាតុ**២ដួងធ្វើកិច្ច៥គឺ

-**បដិសន្ធិកិច្ច** កិច្ចបន្តភពជាតិកំណើត

-**ភវង្គកិច្ច** កិច្ចរក្សាភពជាតិកំណើត

-**ចុតិកិច្ច** កិច្ចឃ្លាតចាកភព

-**សន្តីរណកិច្ច** កិច្ចពិចារណាអារម្មណ៍

-**តទាលម្ពណកិច្ច** កិច្ចទទួលអារម្មណ៍ពីជវន

៨-**អហេតុកវិបាកមនោវិញ្ញាណធាតុ** ដែលជាសោមនស្ស ២ដួង ធ្វើកិច្ច២ គឺ

-**សន្តីរណកិច្ច** កិច្ចពិនិត្យ ពិចារណាអារម្មណ៍

-**តទាលម្ពណកិច្ច** កិច្ចទទួលអារម្មណ៍ពីជវន

៩-**អហេតុកកិរិយាមនោធាតុ**១ដួងធ្វើអាវជ្ជនកិច្ច កិច្ចពិចារណាពាវរកបញ្ចារម្មណ៍

១០-**អហេតុកកិរិយាមនោវិញ្ញាណធាតុ**១ដួង ធ្វើកិច្ច២គឺ

-**វោដ្ឋវនកិច្ច** កិច្ចកំណត់អារម្មណ៍តាមបញ្ចទ្វារ

-**អាវជ្ជនកិច្ច** កិច្ចទទួលអារម្មណ៍តាមមនោទ្វារ

១១-**អហេតុកកិរិយាមនោវិញ្ញាណធាតុ** ដែលជាសោមនស្ស១ដួង ធ្វើជវនកិច្ចគឺការ សេពនូវអារម្មណ៍ធ្វើឲ្យកើត ការញញឹមរបស់ព្រះអរហន្ត (ហៅថា **ហសិតុប្បាទចិត្ត**) ។

**ចំណែកអហេតុកចិត្ត១៨ដួងដោយន័យ១៤យ៉ាង**

១-**ន័យដោយជាតិ** ជាវិបាកជាតិ១៥ដួង កិរិយាជាតិ៣ដួង

២-**ន័យដោយភូមិ** ជាកាមាវចរភូមិ

**អហេតុកចិត្ត១៨ កើតក្នុងភូមិដូចនេះ**

-**ឃានវិញ្ញាណ២ដួង** ជីវ្ហាវិញ្ញាណ២ដួង កាយវិញ្ញាណ២ដួងកើតក្នុង កាមភូមិ១១ជាន់

-**ចក្ខុវិញ្ញាណ២ដួង** សោតវិញ្ញាណ២ដួង បញ្ចទ្វារាវជ្ជន១ដួង សម្បដិច្ឆន្ន២ដួង សន្តីរណៈ៣ដួងកើតបាន២៦ភូមិគឺ កាមភូមិ១១រូបភូមិ១៥

-**មនោទ្វារាវជ្ជនៈ** កើតបាន៣០ភូមិ

-**ហសិតុប្បាទចិត្ត១ដួង** កើតបាន២២ភូមិ គឺកាមសុគតិភូមិ ៧ជាន់ និងរូបភូមិ១៥ជាន់ ។

៣-**ន័យដោយវេទនា** ជាសុខវេទនា១ ទុក្ខវេទនា១ ជាសោមនស្ស-២ ឧបេក្ខាវេទនា១៤

៤-**ន័យដោយហេតុ** ជា នហេតុ និងជាអហេតុកចិត្តទាំង១៨ដួង

៥-**ន័យដោយសង្ខារ** សង្គ្រោះជាអសង្ខារិកៈ ទាំង១៨ដួង

៦-**ន័យដោយសម្បយុត្ត** ជាញាណវិប្បយុត្ត ទាំង១៨ដួង

៧-**ន័យដោយសោភណៈ** ជាអសោភណចិត្ត ទាំង១៨ដួង

៨-**ន័យដោយឈាន** ជាអឈានចិត្តទាំង១៨ដួង

៩-**ន័យដោយលោកីយៈ** ជាលោកិយចិត្តទាំង១៨ដួង

១០-**ន័យដោយកិច្ច** អហេតុកចិត្ត១៨ដួងធ្វើកិច្ច១៤

១១-**ន័យដោយអារម្មណ៍** អហេតុកចិត្ត១៨ដួងទទួលអារម្មណ៍៦

១២-**ន័យដោយទ្វារ** អហេតុកចិត្ត១៨ដួង កើតបាន៦ទ្វារ

១៣-**ន័យដោយវត្ថុ** អហេតុកចិត្ត១៨ដួងកើតត្រង់វត្ថុ៦

១៤-**ន័យដោយវិញ្ញាណធាតុ** អហេតុកចិត្ត១៨ដួង ជាវិញ្ញាណធាតុ ៧គឺចក្ខុវិញ្ញាណធាតុ២ដួង សោតវិញ្ញាណធាតុ២ដួង ឃានវិញ្ញាណធាតុ២ ដួង ជីវ្ហាវិញ្ញាណធាតុ២ដួង កាយវិញ្ញាណធាតុ២ដួង មនោធាតុ៣ដួង មនោវិញ្ញាណធាតុ៥ដួង ។

**ចប់អហេតុកចិត្ត១៨ដួង**

**សោភណចិត្ត៥៩ ឬ៩១ដួង**

ក្រៅអំពី អសោភណចិត្ត៣០ដួង គឺ អកុសលចិត្ត១២ដួង អហេតុកចិត្ត១៨ដួង មានចិត្ត៥៩ដួង ឬ៩១ដួង ដែលជាសោភណចិត្ត ។

**សោភណចិត្តមាន៤ប្រភេទគឺ**

១-**កាមាវចរសោភណចិត្ត** ២៤ដួង

២-**រូបាវចរសោភណចិត្ត** ១៥ដួង

៣-**អរូបាវចរសោភណចិត្ត** ១២ដួង

៤-**លោកុត្តរសោភណចិត្ត** ៨ដួង ឬ៤០ដួង

រួមទាំងអស់គឺ សោភណចិត្ត ៥៩ដួង ឬ៩១ដួង ។

ពាក្យថា សោភណចិត្តនោះ សំដៅដល់ចិត្តដែលមានសោភណចេតសិកប្រកបជាមួយ សោភណចិត្តនោះ មានវចនត្ថថា **សោភណេហិ យុត្តនីតិ សោភណានិ** ចិត្តដែលប្រកបដោយធម៌ដ៏ល្អទាំងឡាយ ឈ្មោះថាសោភណចិត្ត ។

## កាមាវចរសោភណៈចិត្ត២៤

ក្នុងចិត្ត២៤នេះចែកជា៣ ប្រភេទគឺ

១-កាមាវចរកុសល៨ (មហាកុសល)

២-កាមាវចរវិបាក៨ (មហាវិបាក)

៣-កាមាវចរកិរិយា៨ (មហាកិរិយា)

ពាក្យថាបុញ្ញំ ប្រែថាបុណ្យ ប្រើជំនួសពាក្យថាកុសលមានវចនត្ថថា **អត្តនោ សន្តានំ បុនាតិ សោធេតីតិ បុញ្ញំ** ប្រែថា ធម្មជាតិណាមែង ជំរះសន្តានចិត្តនៃខ្លួនឲ្យបរិសុទ្ធព្រោះហេតុនោះធម្មជាតិនោះឈ្មោះថាបុណ្យៗ

## កុសលមានអត្ថ៥យ៉ាងគឺ

១-**អរោគយត្ថ** មានអត្ថថា

មិនមានរោគគឺមិនមានកិលេសមានរាគៈ

ទោសៈ មោហៈជាដើម ដែលឈ្មោះថារោគ ព្រោះចាក់ដោតគឺប្រទូស្តរាយ

ចិត្តឲ្យទន់ខ្សោយ ។

២-**សុន្ទរត្ថ** មានអត្ថថា ជាធម៌ល្អស្អាតគឺជាប្រយោជន៍ ឧបត្ថម្ភគាំទ្រដល់ពពួកសត្វទាំងឡាយ។

៣-**ឆេកត្ថ** មានអត្ថថា ឈ្លាសវៃ ប៉ិនប្រសប់

៤-**អនវជ្ជត្ថ** មានអត្ថថា មិនមានទោសដែលគួរតិះដៀល

៥-**សុខវិបាកត្ថ** មានអត្ថថា មានសេចក្តីសុខជាផល

## លក្ខណាទិចតុក:របស់កុសលចិត្ត

-**អនវជ្ជសុខ វិបាកលក្ខណំ** មានសេចក្តីសុខជាផលគឺមិនមានទោសជាលក្ខណ:

-**អកុសលវិទ្ធំ សនរសំ** មានការកំចាត់នូវអកុសលចិត្ត។

-**វោទានបច្ចុប្បដ្ឋានំ** មានការផ្ទូរផង់ជាអាការ:ប្រាកដ។

-**យោនិសោមនសិការបទដ្ឋានំ** មានយោនិសោមនសិការ: គឺការត្រិះរិះដោយត្រូវទំនង ជាហេតុជិត ។

## មហាកុសល៨ដួង

១-**សោមនស្សសហគតំ ញាណសម្បយុត្តំអសង្ខារិកំ មហាកុសលចិត្តំ** ប្រែថាមហាកុសលចិត្តដែលកើតព្រមជាមួយ សោមនស្សវេទនាប្រកបដោយបញ្ញាជាអសង្ខារិក: ។

២-**សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** ប្រែថា មហាកុសលចិត្តដែលកើតព្រមជាមួយ សោមនស្សវេទនាប្រកបដោយបញ្ញា ជាសសង្ខារិក: ។

៣-**សោមនស្សសហគតំញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសល-**

**ចិត្តំ** ប្រែថា មហាកុសលចិត្ត ដែលកើតឡើងព្រមជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញា ជាអសង្ខារិកៈ ។

៤- **សោមនស្សសហគតំញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** ប្រែថា មហាកុសលចិត្តដែលកើត ព្រមជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញាជាសសង្ខារិកៈ ។

៥-**ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** ប្រែថា មហាកុសលចិត្ត ដែលកើតព្រមជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញាជាអសង្ខារិកៈ ។

៦- **ឧបេក្ខាសហគតំញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** ប្រែថា មហាកុសលចិត្តដែលកើតព្រមជាមួយ ឧបេក្ខាវេទនាប្រកបដោយបញ្ញា ជាសសង្ខារិកៈ ។

៧- **ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** ប្រែថា មហាកុសលចិត្ត ដែលកើតព្រមជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា ជាអសង្ខារិកៈ ។

៨- **ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** ប្រែថា មហាកុសលចិត្ត ដែលកើតព្រមជាមួយ ឧបេក្ខាវេទនាមិនប្រកបដោយបញ្ញា ជាសសង្ខារិកៈ ។

ចិត្តទាំង៨ដួងនេះឈ្មោះថា សហេតុកកាមាវចរកុសលចិត្ត ឬហៅថា កាមាវចរកុសលចិត្ត ឬក៏ហៅថាមហាកុសលចិត្ត ។

**មហាកុសល៨ដួង ចែកជាច្រើនប្រភេទដូចជា**

មហាកុសលសោមនស្ស៤ដួង មហាកុសលញាណសម្បយុត្ត៤ដួង មហាកុសលញាណវិប្បយុត្ត៤ដួង អសង្ខារិកៈ៤ដួង សសង្ខារិកៈ៤ដួង ជាដើម។

## អធិប្បាយមហាកុសល៨ដួង

១-**កុសលចិត្តដួងទី១** បុគ្គលណាអាស្រ័យនូវហេតុ នៃសោមនស្ស គឺសេចក្តីសប្បាយរីករាយ នៅក្នុងការធ្វើទានដោយមានទេយ្យធម៌ និងបដិគ្គាហកៈ (អ្នកទទួល)ហើយមាននូវសម្មាទិដ្ឋិ ឬបញ្ញាជាខាងដើមដោយ គិតថាទានដែលឲ្យហើយ មានផលយ៉ាងនេះជាដើម មានចិត្តមិនរួញរា មិនចាំបាច់អ្នកដទៃដាស់តឿន ក្នុងការធ្វើកុសលទាំងឡាយ មានទាន សីលភាវនាជាដើម ក្នុងពេលនោះ ចិត្តរបស់បុគ្គលនោះជាចិត្តសហគតដោយសោមនស្ស សម្បយុត្តដោយញាណ ជាអសង្ខារិកៈ គឺកុសលដួងទី១កើតឡើង ។

២-**កុសលចិត្តដួងទី២** ពេលណាបុគ្គលត្រេកអរ សប្បាយរីករាយ មាននូវ សម្មាទិដ្ឋិជាខាងដើម ប៉ុន្តែចិត្តរួញរាដោយមច្ឆរិយៈ(សេចក្តីកំណាញ់) ឬក្នុងពេលនោះមានអ្នកដទៃដឹកនាំ ទើបធ្វើបុណ្យទៅបានដូច្នេះចិត្តនេះឯង ជាចិត្តសហគតដោយសោមនស្ស សម្បយុត្តដោយញាណ ជាសសង្ខារិកៈ ។

៣-**កុសលដួងទី៣** ឧបមាថាកូនក្មេងម្នាក់ ដែលមិនទាន់ដឹងអ្វីច្រើននៅឡើយ ពេលឃើញញាតិរបស់ខ្លួនធ្វើការ គោរពចំពោះព្រះសង្ឃ ខ្លួនឯងក៏សប្បាយរីករាយ ធ្វើទៅតាមញាតិនោះដែរ ដោយការសំពះ ឬឲ្យវត្ថុណាមួយ ដល់អ្នកដទៃជាដើម ។ ក្នុងពេលនោះ ចិត្តរបស់ក្មេងនោះ ជា

ចិត្តសហគត ដោយសោមនស្ស មិនប្រកបដោយញាណ ជាអសង្ខារិកៈ ។

៤-**កុសលដួងទី៤** ឧបមាថា ក្នុងក្មេងដែលមិនទាន់ដឹងអ្វី ច្រើននោះត្រូវពពួកញាតិជួយណែនាំ ឲ្យកូននោះចេះសំពះព្រះសង្ឃជាដើមហើយក្មេងនោះ ក៏ធ្វើតាមដោយរីករាយ ក្នុងពេលនោះ ចិត្តរបស់ក្មេងនោះសហគតដោយសោមនស្ស មិនប្រកបដោយញាណជាសសង្ខារិកៈ។

ក្នុងកុសលចិត្តកើតព្រមជាមួយឧបេក្ខា៤ដួងនោះ ព្រះថេរៈ លោកពោលថាក្នុងពេលណាបុគ្គលមិនមានហេតុឲ្យសោមនស្សកើតឡើងដូចជាមិនសំបូរដោយទេយ្យធម៌ឬបដិគ្គាហកៈជាដើម ទើបពេលនោះកុសលចិត្តសហគតៈដោយឧបេក្ខាកើតឡើង ចំពោះសម្បយុត្តនិងសង្ខារមានន័យដូចខាងលើ កុសលចិត្តនឹងកើតឡើងបាន ព្រោះយោនិសោមនសិការៈ ហើយយោនិសោមនសិការៈ កើតឡើងបាន ត្រូវអាស្រ័យហេតុដែលជាអតីតនិងបច្ចុប្បន្នជាបច្ច័យផងដែរ ក្នុងអង្គុត្តរនិកាយចតុកនិបាត បានសំដែងនូវហេតុធ្វើឲ្យកុសល កើតឡើង មាន៤ប្រការ គឺ

## ចក្កធម៌៤ប្រការ

១-**បដិរូបទេសវាស** នៅក្នុងប្រទេសដ៏សំគួរ

២-**សប្បុរិសូបសំសេវ** សេពគប់ សប្បុរស

៣-**អត្តសម្មាបណិធិ** តម្កល់ខ្លួនទុកដោយប្រពៃ

៤-**បុព្វេកតបុញ្ញតា** ភាពជា អ្នកបានធ្វើបុណ្យមកហើយ ក្នុងកាលមុន ពាក្យថាចក្កគឺការដល់ព្រម ដោយបច្ច័យទាំង៤ ជាបច្ច័យឲ្យកើតយោនិសោមនសិការៈព្រោះការរស់នៅក្នុងអាវាស ឬ ប្រទេសដ៏សមគួរមានវត្ថុ

ល្អៗ ដូចជានៅកន្លែងមាន សប្បុរស រមែងមានការឃើញជាដើមក្នុងផ្នែកល្អៗ ក្នុង ព្រះអដ្ឋកថា លោកពោលថា ការនៅក្នុងអាវាស ដែលប្រាកដទៅដោយពុទ្ធបរិស័ទ្ធ ឬនៅក្នុងស្រុក និគម ដែលមានសប្បុរសហៅថាបដិរូប-ទេសវាសៈការសេពគប់សប្បុរសមានព្រះពុទ្ធជាដើម និងសាវ័កពុទ្ធជាដើម ឈ្មោះថា **សប្បុរិសូបសំសេវ**។

ការតំកល់ខ្លួនដោយប្រពៃ ក្នុងគុណធម៌ មានសទ្ធាក្នុងខ្លួនជាដើមឈ្មោះថា **អត្តសមាបណិធិ** ។

ភាពជាអ្នកបាន សន្សំកុសលទុកក្នុងកាលមុនមានការធ្វើទាន រក្សាសីលជាដើម ឈ្មោះថា **បុព្វេកតបុញ្ញតា** ។

មហាកុសលដែលចែកជា៨ដួងនោះ ក៏ព្រោះវេទនាជាសោមនស្សខ្លះ ជាឧបេក្ខាខ្លះ ជាញាណសម្បយុត្តខ្លះ ជាញាណវិប្បយុត្តខ្លះ ហើយ ជាអសង្ខារិកៈខ្លះ ជាសសង្ខារិកៈខ្លះ ។ ដើម្បីឲ្យជ្រាបច្បាស់នូវធម៌ទាំងនេះ គួរជ្រាបនូវបច្ច័យនៃធម៌ទាំង អស់នេះផង ។

### ហេតុឲ្យកើតកុសល សោមនស្សមាន៦ប្រការ

១-**សោមនស្ស បដិសន្ធិកតា** ជាអ្នកបដិសន្ធិដោយសោមនស្ស

២-**សទ្ធា ពហុលតា** ជាអ្នកច្រើនទៅដោយសទ្ធា

៣-**វិសុទ្ធ ទិដ្ឋិតា** មានការឃើញបរិសុទ្ធ ស្អាតជាសម្មាទិដ្ឋិ

៤-**អានិសំសទស្សាវិតា** ឃើញអានិសង្សនៃកុសល

៥-**ឥដ្ឋារម្មណសមាយោគោ** ប្រកបដោយឥដ្ឋារម្មណ៍ ( អារម្មណ៍ដែលគួរប្រាថ្នា ) ។

៦-**កស្សចិបិឡាភាវោ** មិនមានឧបស័គ្គ ស្ទាក់ពារាំង បុគ្គលអ្នកបដិសន្ធិក្នុងលោកនេះ ដោយកុសលវិបាក ប្រកបដោយសោមនស្ស តែងមានចិត្តរីករាយ មិនចូលចិត្តមានសេចក្ដីទុក្ខច្រើន ពេលកម្មជាកុសលក្ដី ឬជាអកុសលក្ដី តែងជាអ្នកច្រើនដោយសោមនស្ស ។

បុគ្គលច្រើនទៅដោយសទ្ធា មានការឃើញប្រាសចាកមន្ទិលឃើញអានិសង្សនៃកុសល រមែងធ្វើកុសលដោយចិត្តសោមនស្ស ។ បុគ្គលដែលជួបប្រសព្វនឹងឥដ្ឋារម្មណ៍តាមផ្លូវភ្នែក ត្រចៀកជាដើម តែងតែត្រេកអរពេញចិត្ត កាលធ្វើកុសលក៏ជាសោមនស្ស តែបើមនសិការៈ មិនល្អទេ ក៏ជាសោមនស្សនៃលោភមូលចិត្តវិញក៏មាន ។ ការធ្វើកុសលគ្រប់យ៉ាងមិនមានឧបសគ្គឯណាមកពារាំងទេ ក៏ជាហេតុឲ្យកុសលកើតព្រមនឹងសោមនស្ស ។

## ហេតុឲ្យកើតកុសលឧបេក្ខាមាន៦ប្រការ

១-**ឧបេក្ខា បដិសន្ធិកតា** ជាអ្នកបដិសន្ធិដោយឧបេក្ខា

២-**អប្បសទ្ធតា** ជាអ្នកមានសទ្ធាតិច

៣-**អវិសុទ្ធទិដ្ឋិតា** មានការឃើញមិនល្អ

៤-**អានិសំសអទស្សាវិតា** មិនឃើញឬមិនយល់ ក្នុងអានិសង្សនៃកុសលនោះ ។

៥-**មជ្ឈត្តារម្មណសមាយោគោ** ជួបប្រសព្វ និងអារម្មណ៍ ដែលជាកណ្ដាល

៦-**កស្សចិ បិឡិកតា** មានឧបស័គ្គ ស្ទាក់ពារាំង

## ហេតុឲ្យកើតកុសលញាណសម្បយុត្តមាន៧ប្រការ

១-**បរិបុច្ឆកតា** ចូលចិត្តសាកសួរបញ្ហាធម៌

២-**វត្ថុវិសទកិរិយតា** ស្អាតទាំងកាយ និងចិត្តព្រមទាំងវត្ថុ

៣-**ឥន្ទ្រិយសម្បត្តិបដិបាទនតា** សម្បូរដោយឥន្ទ្រិយសម្បត្តិ មានសទ្ធិន្ទ្រិយ ជាដើម

៤-**ទុប្បញ្ញា បុគ្គលបរិវជ្ជនា** មិននៅជិតមនុស្សល្ងង់ ឬបុគ្គលពាល

៥-**បញ្ញាវន្ត បុគ្គលសេវនតា** សេពគប់ជាមួយនឹងបណ្ឌិតអ្នកប្រាជ្ញ

៦-**គម្ភីរញាណចរិយាយ បច្ចវេក្ខណា** ពិចារណាធម៌ដោយបញ្ញាយ៉ាងជ្រាលជ្រៅ

៧-**តទ ធិមុត្តតា** បង្អោនចិត្តស្វែងរកធម៌ធ្វើឲ្យកើតបញ្ញា

**ហេតុឲ្យកើតកុសលញាណវិប្បយុត្តមាន៧ប្រការ**

១-**អបរិបុច្ឆកតា** ជាអ្នកមិនចូលចិត្តសាកសួរបញ្ហាធម៌

២-**វត្ថុអវិសទតា** ជាអ្នកមិនស្អាតទាំងកាយទាំងចិត្តនិងវត្ថុ

៣-**ឥន្ទ្រិយអសមត្តបដិបាទនតា** ជាអ្នកមិនបរិបូរណ៍ដោយឥន្ទ្រិយសម្បត្តិ មានសទ្ធិន្ទ្រិយជាដើម

៤-**ទុប្បញ្ញា បុគ្គលសេវនតា** សេពគប់ជាមួយមនុស្សមិនមានបញ្ញា

៥-**បញ្ញាវន្តបុគ្គលបរិវជ្ជនា** គេចចេញអំពីមនុស្សមានបញ្ញា

៦-**គម្ភីរញាណចរិយាយអបច្ចវេក្ខណា** មិនពិចារណាដោយបញ្ញាដ៏ជ្រាលជ្រៅ

៧-**អតទ ធិមុត្តតា** មិនបង្អោនចិត្ត ទៅដោយបញ្ញាក្នុងធម៌

**ហេតុឲ្យកើតអសង្ខារិក:មាន៦ប្រការ**

១-**អសង្ខារិកកម្មជនិតបដិសន្ធិកតា** បដិសន្ធិដោយកម្ម ដែលជាអសង្ខារិកៈ

២-**កល្លកាយចិត្តតា** ជាអ្នកមានកាយ និងចិត្តរឹងមាំ

៣-**សីតុណ្ហាទីនំ ខមនពហុលតា** អត់ធន់ ចំពោះក្តៅ និងត្រជាក់ជាដើម

៤-**កត្តព្វកម្មេសុ ទិដ្ឋានិសំសតា** បានឃើញប្រយោជន៍ ក្នុងការងារដែលគប្បីធ្វើ

៥-**កម្មេសុចិណ្ណវសិតា** មានការជំនាញក្នុងការងារទាំងឡាយ

៦-**ឧតុភោជនាទិ សប្បាយលាភោ** មានឧតុនឹងអាហារ ជាដើមល្អប្រសើរ

ហេតុឲ្យកើតសសង្ខារិកៈមាន៦ប្រការ

១-**សសង្ខារិកកម្មជនិតបដិសន្ធិកតា** បដិសន្ធិដោយកម្មដែលជាសសង្ខារិកៈ

២-**អកល្លកាយចិត្តតា** ជាអ្នកមានកាយ និងចិត្តមិនរឹងមាំ

៣-**សីតុណ្ហាទីនំ អខមនពហុលតា** មិនមានសេចក្តីអត់ធន់ចំពោះក្តៅ និងត្រជាក់ជាដើម

៤-**កត្តព្វកម្មេសុអទិដ្ឋានិសំសតា** មិនបានឃើញផលនៃការងារដែលគប្បីធ្វើ

៥-**កម្មេសុអចិណ្ណវសិតា** មិនមានជំនាញក្នុងការងារដែលធ្វើ

៦-**ឧតុភោជនាទិអសប្បាយលាភោ** មិនមានការសប្បាយក្នុង ឧតុ

និងភោជនជាដើម

## មហាកុសល២ប្រភេទគឺ

១-មហាកុសលញាណវិប្បយុត្ត ៤ដួង ។

២-មហាកុសលញាណ សម្បយុត្ត ៤ដួង ។

ក្នុងមហាកុសលចិត្ត ទាំង២ប្រភេទនោះ ជាចិត្តប្រកបដោយកុសលហេតុ២គឺ**អលោភហេតុ** និង**អទោសហេតុ** ហៅថា **ទ្វិហេតុកកុសល**

ចំណែកមហាកុសល ដែលជាញាណសម្បយុត្ត ប្រកបដោយហេតុ៣គឺ**អលោភហេតុ អទោសហេតុ** និង**អមោហហេតុ** ហៅថា**តិហេតុកកុសល**

កាលដែលមហាកុសលចិត្ត ជា**ញាណវិប្បយុត្ត** មាន **អលោភហេតុ** និង**អទោសហេតុ** កើតរួមគ្នា ក៏ព្រោះការធ្វើកុសលណាក៏ដោយដូចជាមានការឲ្យទាន និងរក្សាសីលជាដើម កាលដែល កុសលនោះកើតឡើងបាន ក៏ព្រោះខណៈ នោះ មិនមានលោភៈ មិនមានទោសៈ ប្រសិនបើមានលោភៈនៅក្នុងខណៈនោះ ការលះបង់វត្ថុណាមួយឲ្យទៅជាទាន គឺបានដោយលំបាក ឬមានទោសៈនៅក្នុងខណៈ នោះ ការធ្វើទានជាដើម ក៏បានដោយលំបាកដូចគ្នា ដូច្នេះកុសលនេះទើបមានហេតុ២គឺអលោភៈនិងអទោសៈកើតរួមគ្នា។ចំណែកកុសលជាញាណសម្បយុត្ត ត្រូវមានកុសលចេតនាសីល៣ប្រភេទ កើតរួមជាមួយចិត្ត គឺអលោភហេតុ **អទោសហេតុ** និង**អមោហហេតុ** ការធ្វើបុណ្យណា ក៏ដោយឲ្យតែប្រកបដោយបញ្ញា រមែងជាបុណ្យប្រសើរបំផុត ។

## ហេតុឲ្យកើតបញ្ញា៣ប្រការទៀត

១-**សុតមយបញ្ញា** បញ្ញាកើតអំពីការស្តាប់

២-**ចិន្តាមយបញ្ញា** បញ្ញាកើតអំពីការគិត

៣-**ភាវនាមយបញ្ញា** បញ្ញាកើតអំពីការចម្រើន

បញ្ញាទាំងឡាយនឹងកើតឡើង ព្រោះអាស្រ័យបច្ច័យ នាំឲ្យកើត ព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្តាប់ធម៌មាន៥ប្រការ ។

១-អ្នកស្តាប់ធម៌រមែងបានស្តាប់នូវធម៌ណាដែលមិនទាន់បានស្តាប់

២-ធម៌ណាដែលបានស្តាប់ហើយ រមែងយល់កាន់តែច្បាស់

៣-អ្នកស្តាប់ធម៌ រមែងលះបង់នូវសេចក្តីសង្ស័យក្នុងចិត្តបាន

៤-អ្នកស្តាប់ធម៌ រមែងធ្វើខ្លួនឲ្យយល់ឃើញត្រង់

៥-ចិត្តរបស់អ្នកស្តាប់ធម៌ រមែងស្អាតផូរផង់

ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្តាប់ព្រះធម៌មាន៥ប្រការនេះឯង ។

ចំណែកចិន្តាមយបញ្ញា គឺការត្រិះរិះប្រកបដោយបញ្ញាបានដល់នូវការត្រាស់ដឹង ដូចជាព្រះសម្មាសម្ពុទ្ធ ឬព្រះបច្ចេកពុទ្ធ ដែលព្រះអង្គបានត្រាស់ ដោយខ្លួនព្រះអង្គឯង ។

**ភាវនាមយបញ្ញា** គឺជាការចម្រើននូវវិបស្សនា កម្មដ្ឋានណាមួយ ហើយក៏កើតមាននូវបញ្ញា ឃើញច្បាស់នូវសង្ខារធម៌ទាំងឡាយ ។

## ចេតនាក្នុងមហាកុសល៨ដួង

ចេតនាក្នុងមហាកុសល៨ដួងនេះ សម្តែងបាន២ន័យគឺ

**១-ដោយកម្មទ្វារ**

**២-ដោយបុញ្ញកិរិយាវត្ថុ១០**

មហាកុសលដោយកម្មទ្វារ៣ គឺកាយសុច្ចរិតកម្ម៣វចីសុច្ចរិតកម្ម៤ និងមនោសុច្ចរិតកម្ម៣ ។

**កាយសុច្ចរិតកម្ម៣នោះគឺ**

-ចេតនាវៀរចាកការសម្លាប់សត្វ១

-ចេតនាវៀរចាកការលួចទ្រព្យរបស់គេ១

-ចេតនាវៀរចាកការប្រព្រឹត្តខុសក្នុងកាម១

**វចីសុច្ចរិតកម្ម៤នោះគឺ**

-ចេតនាវៀរចាកការនិយាយកុហក១

-ចេតនាវៀរចាកការនិយាយញុះញង់១

-ចេតនា វៀរចាក ការជេរប្រទេច១

-ចេតនា វៀរចាក ការនិយាយឥតប្រយោជន៍១

**មនោកម្ម៣ គឺ**

-អនភិជ្ឈា  មិនគិតសម្លឹងរំពៃទ្រព្យអ្នកដទៃ

-អព្យាបាទៈ មិនគិតបៀតបៀនសត្វដទៃ

សម្មាទិដ្ឋិ ការយល់ត្រូវ ។

**មហាកុសល៨ដួងដោយបុញ្ញកិរិយាវត្ថុ១០**

**១-ទានមយ** បុណ្យសម្រេចដោយការធ្វើទានគឺការលះបង់វត្ថុ ឲ្យ

ជាប្រយោជន៍ដល់អ្នកដទៃ

២-**សីលមយ** បុណ្យសម្រេចដោយការរក្សាសីល

៣-**ភាវនាមយ** បុណ្យសម្រេចដោយការចំរើន**សមថ** និង**វិបស្សនា**

៤-**អបចាយនមយ** បុណ្យសម្រេចដោយការគោរព ចំពោះអ្នកដែលគួរគោរព

៥-**វេយ្យាវច្ចមយ** បុណ្យសម្រេចដោយការខ្វល់ខ្វាយ ជួយធ្វើក្នុងកិច្ចការជាបុណ្យកុសល

៦-**បត្តិទានមយ** បុណ្យសម្រេចដោយការ ឧទ្ទិស ឬចែករំលែកកុសលដល់អ្នកដទៃ

៧-**បត្តានុមោទនាមយ** បុណ្យសម្រេចដោយការអនុមោទនាកុសលអំពីអ្នកដទៃ

៨-**ធម្មទេសនាមយ** បុណ្យសម្រេចដោយការសម្ដែងធម៌

៩-**ធម្មសវនមយ** បុណ្យសម្រេចដោយការស្ដាប់ព្រះធម៌

១០-**ទិដ្ឋុជុកម្ម** បុណ្យសម្រេចដោយ ការធ្វើទិដ្ឋិឲ្យត្រូវត្រង់

បុញ្ញកិរិយាវត្ថុ១០នេះការពោលដោយសង្ខេបមានត្រឹមតែ៣ប៉ុណ្ណោះ គឺទានមយៈ១បត្តិទានមយៈ១បត្តានុមោទនាមយៈ១រួមទាំង៣នេះសង្គ្រោះនៅក្នុងទាន ។

សីលមយៈ១ អបចាយនៈ១វេយ្យាវច្ចមយៈ១រួមទាំង៣នេះសង្គ្រោះចូលនៅក្នុងសីល ។

ភាវនាមយៈ១ធម្មទេសនាមយៈ១ធម្មសវនមយៈ១ រួមទាំង៣នេះ

សង្គ្រោះចូលនៅក្នុងភាវនា ។

ចំណែកទិដ្ឋុជុកម្មនោះ សង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង៣ ឬ៩ ខាងដើមគឺប្រព្រឹត្តទៅក្នុងទានក៏បាន ប្រព្រឹត្តទៅក្នុងសីលក៏បាន ប្រព្រឹត្តទៅក្នុងភាវនាក៏បាន ព្រោះបើគ្មាន ទិដ្ឋុជុកម្មហើយកុសលនោះៗ ក៏មិនបរិបូរណ៍ឡើយ ។

### ចំណែកមហាកុសល៨ប្រកបដោយចេតនា៤

១-**បុព្វចេតនា** ចេតនាមុនធ្វើ

២-**មុញ្ចនចេតនា** ចេតនាកំពុងធ្វើ

៣-**អបរចេនា** ចេតនាពេលធ្វើរួចហើយ

៤-**អបរាបរចេតនា** ចេតនាពេលនឹកដល់កុសល ដែលខ្លួនបានធ្វើយូរមកហើយ

ចេតនាក្នុងមហាកុសល ដែលជា តិហេតុកកុសល និងជាទុហេតុកកុសលមាន២ប្រភេទគឺ

១-**ឧក្កដ្ឋកុសលំ** កុសលថ្នាក់ឧក្រិដ្ឋ

២-**ឱមកកុសលំ** កុសលថ្នាក់រង

បណ្តាកុសលទាំង២ប្រភេទនេះ កាលបុគ្គលឲ្យទានឬរក្សាសីលជាដើមមុនធ្វើកុសលនោះ (បុព្វចេតនា) កំពុងធ្វើ ( មុញ្ចនចេតនា ) ធ្វើរួចហើយ (អបរចេតនា) មានចិត្ត មិនប្រកបដោយអកុសល គឺមានចិត្តបរិសុទ្ធទាំង៣កាល ទានក្តី សីលក្តី របស់បុគ្គលនោះ ទោះជា តិហេតុកកុសល ឬទ្វិហេតុកកុសលក៏ដោយ ក៏ចាត់ទុកជាកុសលឧក្រិដ្ឋដែរ ប៉ុន្តែបើបុព្វចេតនា

ក្តីបុញ្ញចេតនាក្តី អបរចេតនាក្តី មានអកុសលលាយឡំ គឺមានចេតនា មិនបរិសុទ្ធទាំង៣កាល កុសលនោះទោះជា តិហេតុកកុសលក៏ដោយ ជាទុហេតុកកុសលក៏ដោយ ក៏ចាត់ជា**ឱមកកុសល**ដែរ ។

## ចំណែកកុសលដោយសភាពជាឧក្រិដ្ឋនិងឱមកៈ៤

១-**តិហេតុកកុសល** ប្រភេទឧក្កដ្ឋៈ (ឧក្រិដ្ឋ)

២-**តិហេតុកកុសល** ប្រភេទឱមកៈ (ថ្នាក់រង)

៣-ទុ**ហេតុកកុសល** ប្រភេទឧក្កដ្ឋៈ (ឧក្រិដ្ឋ)

៤-**ទុហេតុកកុសល** ប្រភេទឱមកៈ (ថ្នាក់រង)

## ចំណែកកុសលឧក្រិដ្ឋនិងឱមកៈ៨

១-**តិហេតុកកុសល ឧក្រិដ្ឋ** (ថ្នាក់ទី១) ហៅថា **តិហេតុកឧក្កដ្ឋុកដ្ឋ**

២-**តិហេតុកកុសល ឧក្រិដ្ឋ** (ថ្នាក់រង) ហៅថា **តិហេតុកឧក្កដ្ឋោមក**

៣-**តិហេតុកកុសល ឱមកៈ**(ថ្នាក់ទី១) ហៅថា **តិហេតុកឱមកុក្កដ្ឋ**

៤-**តិហេតុកកុសល ឱមកៈ**(ថ្នាក់រង) ហៅថា **តិហេតុឱមកោមក**

៥-**ទុហេតុកកុសល ឧក្រិដ្ឋ** (ថ្នាក់ទី១) ហៅថា **ទុហេតុកុឧក្កដ្ឋុកដ្ឋ**

៦-**ទុហេតុកកុសល ឧក្រិដ្ឋ** (ថ្នាក់រង) ហៅថា **ទុហេតុក ឧក្កដ្ឋោមក**

៧-**ទុហេតុកកុសល ឱមកៈ** (ថ្នាក់ទី១) ហៅថា **ទុហេតុកឱមកុក្កដ្ឋ**

៨-**ទុហេតុកកុសល ឱមកៈ** (ថ្នាក់រង) ហៅថា **ទុហេតុកឱមកោមក**

សភាពនៃកុសលទាំង៨ប្រការ ដែលពោលមកហើយនេះ អាស្រ័យដោយមុញ្ចនចេតនា ជាប្រធានគឺខណៈដែលមុញ្ចនចេតនា កើតឡើង បើប្រកបដោយបញ្ញាហៅថា **តិហេតុកកុសល** ប៉ុន្តែបើមុញ្ចនចេតនាមិនប្រកប

ដោយបញ្ញាទេ កុសលនោះ ហៅថាទុហេតុកកុសល ។

## ញាណសម្បយុត្ត៤ន័យ

ន័យទី១ **តិហេតុកឧក្កដ្ឋុក្កដ្ឋ** កើតឡើងព្រោះបុព្វចេតនាល្អ មុញ្ចនចេតនាល្អ អបរចេតនាល្អ អបរាបរចេតនាល្អ ។

ន័យទី២ **តិហេតុកឧក្កដ្ឋោមក** កើតឡើងព្រោះបុព្វចេតនាល្អ មុញ្ចនចេតនាល្អ អបរចេតនាល្អ អបរាបរចេតនាមិនល្អ ។

ន័យទី៣ **តិហេតុកឱមកុក្កដ្ឋ** កើតឡើងព្រោះបុព្វចេតនាល្អ មុញ្ចនចេតនាល្អ អបរចេតនាមិនល្អ អបរាបរចេតនាល្អ ។

ន័យទី៤ **តិហេតុកឱមកោមក** កើតឡើងព្រោះបុព្វចេតនាល្អ មុញ្ចនចេតនាល្អ អបរចេតនាមិនល្អ អបរាបរចេតនាមិនល្អ ។ចំណែកញាណវិប្ប-យុត្ត៤ន័យក៏មានសេចក្ដីដូចគ្នានិងញាណសម្បយុត្ត៤ន័យនោះដែរ ។

## អានិសង្សរបស់តិហេតុកកុសល៤ន័យ

ន័យទី១ **តិហេតុកឧក្កដ្ឋុក្កដ្ឋ** ជាញាណសម្បយុត្ត ឧក្រិដ្ឋថ្នាក់ទី១ បានទទួលនូវវិបាក ១៦ដួងគឺមហាវិបាកចិត្ត៨ដួង អហេតុកកុសលវិបាក៨ដួង ហើយមានអានិសង្សខ្ពស់បំផុតអាចកើតក្នុងស្ថាន មនុស្ស និងទេវតា ហើយបរិបូរណ៍ដោយមនុស្សសម្បត្តិ ទេវតាសម្បត្តិទាំងប្រកបដោយបញ្ញា អាចធ្វើ មគ្គ ផល ព្រះនិព្វាន និងឈាន សមាបត្តិ ឲ្យកើតឡើងបានក្នុងបច្ចុប្បន្នជាតិនេះ តាមសមគួរ ដល់ឧបនិស្ស័យហើយបុគ្គលនោះមានសេចក្ដីសុខ តាំងពីកើតរហូតដល់ស្លាប់ ។

ន័យទី២ **តិហេតុកឧក្កដ្ឋោមក** ជាញាណសម្បយុត្ត ឧក្រិដ្ឋថ្នាក់រង បានទទួលវិបាក១៦ដួងដូចគ្នាអាចកើតបានក្នុងស្ថានមនុស្ស ឬទេវតា ប៉ុន្តែមិនល្អរហូតនោះទេ ដូចជាក្នុងវ័យចំណាស់ ក៏មិនសូវមានសេចក្ដីសុខ។

ន័យទី៣ **តិហេតុកឱមកុក្កដ្ឋ** ជាញាណសម្បយុត្តឱមកៈថ្នាក់ឧក្រិដ្ឋ បានទទួលវិបាក១២ដួង គឺមហាវិបាកជាញាណសម្បយុត្ត៤ដួង អហេតុក-កុសលវិបាក៨ដួង អាចកើតបានក្នុងស្ថានមនុស្ស និងទេវតា មានសេចក្ដីសុខក្នុងកាមគុណ មិនសូវសំបូរ ដូចជាកាលនៅក្មេងមិនល្អ ពេញវ័យល្អ ពាក់កណ្ដាលអាយុល្អ កាលដល់វ័យចាស់មិនល្អ

ន័យទី៤ **តិហេតុកឱមកោមក**ជាញាណសម្បយុត្តឱមកថ្នាក់រងបាន បានទទួលវិបាក១២ដួងដូចគ្នា កើតបានក្នុងស្ថានមនុស្ស និងទេវតាមានសេចក្ដីសុខ មិនស្មើ ពេលនៅក្មេងមិនល្អ ពេញវ័យមិនល្អ ពាក់កណ្ដាលអាយុល្អ ពេលចាស់មិនល្អ។

## ចំណែកអានិសង្សតាមន័យបែបទុហេតុកៈ

ន័យទី១ **ទុហេតុកឧក្កដ្ឋុក្កដ្ឋ** ជាញាណវិប្បយុត្ត ឧក្រិដ្ឋថ្នាក់ទី១អាចញ៉ាំងវិបាក១២ដួងឲ្យកើតឡើង គឺមហាវិបាក ជាញាណវិប្បយុត្ត៤ដួង អហេតុកកុសលវិបាក៨ដួង អាចកើតបានក្នុងស្ថានមនុស្សទេវតាជាបុគ្គលបរិបូរណ៌ដោយសម្បត្តិ មានសេចក្ដីសុខតាំងពីកើតរហូតដល់ស្លាប់ ប៉ុន្តែមិនអាចញ៉ាំង មគ្គ ផល ព្រះនិព្វាន ឈាន សមាបត្តិ ឲ្យកើតបានទេ ព្រោះបដិសន្ធិដោយ **ទុហេតុកកុសល**។

ន័យទី២ **ទុហេតុកឧក្កដ្ឋោមក** ជាញាណវិប្បយុត្ត ឧក្រិដ្ឋ ថ្នាក់រង

ដូចគ្នានិងន័យទី១ដែរ អាចកើតបានក្នុងស្ថានមនុស្ស ទេវតា មានសេចក្ដីសុខច្រើន តែដល់ពេលវ័យចាស់មិនសូវមានសេចក្ដីសុខទេ ហើយបុគ្គលនោះមិនអាចសម្រេចគុណធម៌ថ្នាក់ខ្ពស់បានឡើយ ព្រោះ បដិសន្ធិដោយ **ទុហេតុកកុសល**។

ន័យទី៣ **ទុហេតុកឱមកុក្កដ្ឋ** ជាញាណវិប្បយុត្តឧក្រិដ្ឋ ថ្នាក់ទី១ បានទទួលវិបាក ដែលជាអហេតុកកុសល៨ដួងប៉ុណ្ណោះ អាចកើតក្នុងស្ថានមនុស្ស ទេវតា ប៉ុន្តែមានសេចក្ដីសុខតិចតួច មិនស្មើនឹងន័យទី២ទេ ។

ន័យទី៤ **ទុហេតុកឱមកោមក** ជាកុសលញាណវិប្បយុត្ត ប្រភេទថ្នាក់ទាបបំផុត ញុំាងឲ្យអហេតុកកុសល៨ដួង កើតឡើងបានក្នុងសុគតិភូមិ គឺក្នុងមនុស្សភូមិ និងទេវតាជាន់ទាប ។ បុគ្គលណាដែលបដិសន្ធិដោយកុសលនេះ រមែងជាមនុស្សមានសតិបញ្ញាតិចតួច ឬជាមនុស្សឆ្កួត គ ថ្លង់ ខ្វិនខ្វាក់អំពីកំណើតថែមទាំងមិនអាចចំរើននូវ **សមថនិងវិបស្សនា**បានទេ។

**វិធីរាប់កាមាវចរកុសលឲ្យបានចំនួនច្រើនជាង៨ដួង**

បុរាណាចារ្យទាំងឡាយ បានពោលទុកជាគាថាដូច្នេះថា

**កាមេន បុញ្ញវត្ថុហិ គោចរាធិបតិហិ កម្ម**

**ហីនាទិតោ ចេវ គណេយ្យនយកោវិទោ**

ប្រែថា បណ្ឌិតឆ្លាតក្នុងន័យ គួររាប់កុសលចិត្តដោយ បុញ្ញកិរិយាវត្ថុទាំងឡាយ និងដោយអារម្មណ៍ អធិបតីដោយកម្ម និងដោយប្រភេទនៃចិត្ត ថ្នាក់ទាបជាដើម តាមលំដាប់ដូច្នេះ ។

**កុសល៨ដួង អាចរាប់បាន៨០ដួង ព្រោះអធិប្បាយថា**

កុសល១ដួងរាប់ជា១០ ដោយប្រព្រឹត្តទៅតាមអំណាច បុញ្ញកិរិយាវត្ថុ១០ ។ កុសល៨០ដួង យកទៅគុណជាមួយអារម្មណ៍៦ មានរូបារម្មណ៍ជាដើមស្មើ៤៨០ដួង យក៤៨០ទៅចែកឲ្យ២ ស្មើ២៤០ដួង ។ ២៤០ដួងជាញាណវិប្បយុត្តគុណ និង៣គឺអធិបតី៣ (ឆន្ទៈវិរិយៈចិត្ត)ស្មើ៧២០ដួង។ យក ២៤០ដួង ដែលជាញាណសម្បយុត្តគុណនិង៤ គឺអធិបតី៤ (ឆន្ទៈ វិរយៈ ចិត្ត វិមំសា) ស្មើ ៩៦០ដួង យក ៩៦០ដួង បូកជាមួយ ៧២០ដួង ស្មើ ១៦៨០ដួង យក ១៦៨០ដួង គុណនិង កម្ម៣ (គឺ កាយកម្ម វចីកម្ម មនោកម្ម) ស្មើ ៥០៤០ដួង យក ៥០៤០ដួង គុណនិង កុសល៣ (គឺកុសលថ្នាក់ខ្ពស់១ កុសលថ្នាក់កណ្តាល២ កុសលថ្នាក់ទាប១) ស្មើ ១៥១២០ដួង ។

## ចំណែកមហាកុសលដោយន័យ១៤

១-**ន័យដោយជាតិ** មហាកុសល៨ ជាកុសលជាតិ

២-**ន័យដោយភូមិ** ជាកាមាវចរភូមិ អាចកើតបាន៣០ភូមិ (វៀរអសញ្ញីសត្តភូមិ)

៣-**ន័យដោយវេទនា** មហាកុសល៨ដួង ជាសោមនស្សវេទនា៤ដួង ជាឧបេក្ខាវេទនា៤ដួង

៤-**ន័យដោយហេតុ** ជានហេតុ និងជា តិហេតុកៈផង ទុហេតុកៈផង

៥-**ន័យដោយសម្បយុត្ត** ជាញាណសម្បយុត្ត៤ដួង ជាញាណវិប្បយុត្ត៤ដួង

៦-**ន័យដោយសង្ខារ** ជាអសង្ខារិកៈ៤ដួង ជាសសង្ខារិកៈ៤ដួង

៧-**ន័យដោយសោភណៈ** ជាកាមាវចរសោភណចិត្ត

៨-**ន័យដោយឈាន** ជាអឈានចិត្ត

៩-**ន័យដោយលោកិយៈ** ជាលោកិយចិត្ត

១០-**ន័យដោយកិច្ច** ជាចិត្តធ្វើជវនកិច្ច

១១-**ន័យដោយអារម្មណ៍** ជាចិត្តដឹងនូវអារម្មណ៍ទាំង៦

១២-**ន័យដោយទ្វារ** កើតបានតាមទ្វារ៦

១៣-**ន័យដោយវត្ថុ** មហាកុសល៨ សំរាប់បញ្ចវោការភពគឺភពដែលមានខន្ធ៥ មហាកុសលកើតត្រង់ **ហទយវត្ថុ**

១៤-**ន័យដោយវិញ្ញាណធាតុ** មហាកុសល៨ ជាមនោវិញ្ញាណធាតុ

**ចប់មហាកុសល៨ដួង**

## មហាវិបាក៨ដួង

សហេតុកកាមាវចរវិបាកចិត្ត និយមហៅថា កាមាវចរវិបាក ឬមហាវិបាកព្រោះជាចិត្តដែលជាផលនៃមហាកុសលចិត្តដូចជាមហាកុសលចិត្ត ជាសោមនស្សញាណសម្បយុត្ត ជាអសង្ខារិកៈក៏ឲ្យផលជាមហាវិបាកសោមនស្សញាណសម្បយុត្ត អសង្ខារិកៈ ដូចគ្នា កាមាវចរវិបាកចិត្តនោះកាលពោលដោយទូទៅមាន ២៣ដួងគឺ អហេតុកអកុសលវិបាក៧ដួង អហេតុកកុសលវិបាក៨ដួង មហាវិបាក៨ដួង ។

អកុសលវិបាក៧ដួងជាផលរបស់អកុសលចិត្ត១២ដួងអហេតុកកុសលវិបាក៨ដួងនិងមហាវិបាក៨ដួងរួមជា១៦ដួងជាផលនៃមហាកុសល៨ដួង។

អហេតុកកុសលវិបាកចិត្ត គឺចិត្តដែលជាផលនៃមហាកុសលតែមិនប្រកបដោយហេតុណាមួយ កាលកើតឡើងទទួលអារម្មណ៍ល្អ ទូទៅក្នុង

កាមភូមិ រូបភូមិតាមសមគួរ ។ មហាវិបាកចិត្ត គឺជាផលនៃមហាកុសល តែប្រកបដោយហេតុ កាលកើតឡើងទទួលអារម្មណ៍ល្អណាមួយ និងកើតបានចំពោះនៅក្នុងកាមភូមិប៉ុណ្ណោះ ។

**មហាវិបាក៨ដួងគឺ**

**១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា ។

**២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ ។

**៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា ។

**៤-សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញា មានកម្លាំងខ្សោយ ។

**៥- ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ដែលប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា ។

៦-**ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ដែលប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ ។

៧-**ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ដែលប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា ។

៨-**ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត ដែលប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មានកម្លាំងខ្សោយ ។

## អត្ថរបស់វិបាក

វិបាកធម៌ទាំងឡាយ ដែលជាផលរបស់កុសល និងអកុសលដែលពិសេសជាងគ្នានិងគ្នា ឈ្មោះថាវិបាក ។ ផលដែលពិសេសជាងគ្នានិងគ្នានោះ គឺកុសលឲ្យផលល្អ ជាឥដ្ឋផល ចំណែកអកុសលឲ្យផលមិនល្អ ជាអនិដ្ឋផល ។

## ធម៌ដែលជាផលមាន២យ៉ាង

១-**មុខផល** ជាផលដោយត្រង់បានដល់វិបាកចិត្ត និងចេតសិកដែលកើតឡើងទទួលអារម្មណ៍ ព្រោះជានាមធម៌ និងដឹងអារម្មណ៍បានដូចជាធម៌ដែល ជាហេតុគឺកុសលចិត្ត ឬអកុសលចិត្តនោះឯង ។

២-**សាមញ្ញផល** ជាផលធម្មតាបានដល់ កម្មជរូបដែលជារូបធម៌ដូចជា ហទយវត្ថុរូប និងបសាទរូបជាដើម ដែលកើតអំពីវិបាក ។

## មហាវិបាកផ្សេងគ្នាអំពីមហាកុសល

មហាវិបាកផ្សេងអំពីមហាកុសលគឺ ក្នុងមហាកុសលទាំងឡាយផ្សេងគ្នាដោយបុញ្ញកិរិយាវត្ថុដោយអារម្មណ៍ជាដើម ប៉ុន្តែក្នុងមហាវិបាកមិនមានន័យដូចនៅក្នុងមហាកុសលទេ ហើយមហាវិបាកចិត្តនោះមិនបានញុំាងសត្វបញ្ញត្តិឲ្យជាអារម្មណ៍ គឺ ករុណា មុទិតានិងវិរតិ៣គឺ **សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ** មិនមានធម៌ទាំងនេះ ដូចមហាកុសលទេ ។

## មហាវិបាកធ្វើកិច្ច៤

១-**បដិសន្ធិកិច្ច** គឺបដិសន្ធិចិត្តដែលធ្វើកិច្ចបន្ត ភពជាតិថ្មី

២-**ភវង្គកិច្ច** ធ្វើកិច្ចរក្សាភពជាតិកំណើត

៣-**ចុតិកិច្ច** ធ្វើកិច្ចឃ្លាតចាកភព

៤-**តទាលម្ពណកិច្ច** ធ្វើកិច្ចទទួលអារម្មណ៍អំពីជវន

កុសលកម្មឲ្យផលផ្សេងគ្នា៧យ៉ាង ក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសកៈ ចូឡកម្មវិភង្គសូត្រ មានសំដែង ថា

១-មានអាយុវែង ព្រោះមិនសម្លាប់សត្វ

២-មិនសូវមានរោគ ព្រោះមិនបៀតបៀនសត្វ

៣-មានសម្បុរភ្លឺថ្លា ព្រោះមិនមានសេចក្តីក្រោធ

៤-មានយសច្រើន ព្រោះមិនច្រណែន មិនប្រទូស្តរាយអ្នកដទៃ

៥-មានភោគសម្បត្តិច្រើន ព្រោះមានការធ្វើទាន

៦-កើតក្នុងត្រកូលខ្ពង់ខ្ពស់ ព្រោះជាអ្នកមិនរឹងត្អឹង ចេះគោរពរាប់អានអ្នកដ៏ទៃ

៧-មានបញ្ញាច្រើន ព្រោះសាកសួរបញ្ហាធម៌ និងសិក្សាព្រះធម៌បានច្រើន

## ចំណែកមហាវិបាក៨ដួងដោយន័យ១៤

១-**ន័យដោយជាតិ** មហាវិបាក៨ដួង ជាវិបាកជាតិ

២-**ន័យដោយភូមិ** ជាកាមាវចរភូមិ (កើតបាន ក្នុងសុគតិភូមិ៧)

៣-**ន័យដោយវេទនា** ជាសោមនស្ស៤ដួង ជាឧបេក្ខា៤ដួង

៤-**ន័យដោយហេតុ** ជានហេតុផង ជាទុហេតុផង និងជាតិហេតុផង

៥-**ន័យដោយសម្បយុត្ត** ជាញាណសម្បយុត្ត៤ដួង ជាញាណវិប្បយុត្ត៤ដួង

៦-**ន័យដោយសង្ខារ** ជាអសង្ខារិកៈ ៤ដួង ជាសសង្ខារិកៈ ៤ដួង

៧-**ន័យដោយសោភណៈ**ជាសោភណចិត្ត

៨-**ន័យដោយឈាន** ជាអឈានចិត្ត

៩-**ន័យដោយលោកិយៈ** ជាលោកិយចិត្ត

១០-**ន័យដោយកិច្ច** ជាចិត្តធ្វើកិច្ច៤យ៉ាងគឺ បដិសន្ធិកិច្ច ភវង្គកិច្ច តទាលម្ពណកិច្ច ចុតិកិច្ច

១១-**ន័យដោយអារម្មណ៍** ជាចិត្តទទួលអារម្មណ៍ទាំង៦

១២-**ន័យដោយទ្វារ** ជាចិត្តអាស្រ័យទ្វារ៦និងមិន អាស្រ័យទ្វារ៦

១៣-**ន័យដោយវត្ថុ** ជាចិត្តអាស្រ័យ ហទយវត្ថុ

១៤-**ន័យដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

ចប់មហាវិបាក៨ដួង ។

## មហាកិរិយាចិត្ត ៨ ដួង

មហាកិរិយាចិត្ត ឬកាមាវចរកិរិយាចិត្តនេះ មិនមែនជាកុសលចិត្តផង មិនមែនជាអកុសលចិត្តផង ទាំងមិនមែនជាវិបាកចិត្តផង គឺជាអព្យាកតចិត្ត គឺត្រឹមតែជាការធ្វើ ដែលមាន២ប្រភេទគឺ

**១-អហេតុកកិរិយាចិត្ត៣ដួង**

**២-សហេតុកកិរិយាចិត្ត៨ដួង**

បណ្តា**អព្យាកតចិត្ត**ទាំងនោះ ពាក្យថា កិរិយា បានដល់ការធ្វើ ក្នុងកិរិយាទាំង១១ដួងនេះ កិរិយាចិត្តណាមិនដល់ភាពជាជវន កិរិយាចិត្តនោះរមែងមិនមានផល ដូចផ្កាឈើដែលជ្រុះ គឺមិនអាចមានផ្លែបានឡើយ ។ កិរិយាចិត្តណាដល់ភាពជាជវន កិរិយាចិត្តនោះ ក៏មិនមានផល ដូចដើមឈើមានផ្កា ប៉ុន្តែមិនមានឫស កិរិយាចិត្តនេះត្រឹមតែជាការធ្វើប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅដោយការញុំាងកិច្ចនោះឲ្យសំរេចក្នុងអហេតុកកិរិយាចិត្ត៣ដួង និង ក្នុងសហេតុកកិរិយាចិត្ត៨ដួងនោះ អហេតុកកិរិយាចិត្តបានពោលរួចមកហើយ បន្ទាប់អំពីនេះទៅនឹងពោលអំពីសហេតុកកិរិយាចិត្ត៨ដួង ។ចិត្ត៨ដួងនេះជាចិត្តឲ្យសំរេចការធ្វើ ការនិយាយ ការគិតនៃព្រះអរហន្ត ជាកិរិយាចិត្តដល់ភាពជាជវន សោយអារម្មណ៍ ជាសោមនស្ស ឬឧបេក្ខាមិនជាហេតុនៃតណ្ហា និងឧបាទានទេ ដូចនេះមិនអាចឲ្យកើត

ផលក្នុងអនាគតបានឡើយ ។

## មហាកិរិយាចិត្ត ៨ដួង

**១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្តដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនាមិនប្រកបដោយបញ្ញាមានកំលាំងខ្លាំងក្លា ។

**២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្តដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនាមិនប្រកបដោយបញ្ញា មានកំលាំងខ្សោយ ។

**៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកំលាំងខ្លាំងក្លា ។

**៤-សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកំលាំងខ្សោយ ។

**៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ដែលប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកំលាំងខ្លាំងក្លា ។

**៦-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ដែលប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកំលាំងខ្សោយ ។

៧- **ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ដែលប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មានកំលាំងខ្លាំងក្លា ។

៨-**ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត ដែលប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មានកំលាំងខ្សោយ ។

(ចិត្តទាំង៨ដួងនេះ ឈ្មោះថា សហេតុកកាមាវចរចិត្ត )

មហាកិរិយាចិត្តនៃព្រះអរហន្តដែលកើតព្រមនឹងសោមនស្សវេទនា តែងកើតក្នុងទ្វារទាំង៦ ក្នុងចក្ខុទ្វារ ព្រះខីណាស្រពកាលឃើញកន្វែង ដ៏សមគួរ ដល់ការបំពេញសេចក្ដីព្យាយាម ហើយតែងតែសោមនស្ស ដោយមហាកិរិយាចិត្តដួងនេះ ។ ក្នុងសោតទ្វារ នៅពេលដែលភិក្ខុចែក **ភណ្ឌៈ** កាលបុគ្គល ឈ្មោកឡូឡា អ៊ូអែ ព្រះអរហន្តលោកក៏កើតសោមនស្សដោយចិត្តនេះថា តណ្ហាជាហេតុឲ្យញាប់ញ័រ យ៉ាងនេះយើងបានលះហើយ ។ ក្នុងឃានទ្វារ ពេលលោកបូជាព្រះចេតិយ៍ដោយគ្រឿងក្រអូប ឬដោយផ្កាឈើ លោកក៏សោមនស្សដោយចិត្តនេះ ។ ក្នុងជីវ្ហាទ្វារ ព្រះខីណាស្រពរំលែកនូវបិណ្ឌបាតព្រមដោយរស ដែលបានមកយ៉ាងណា ក៏សោមនស្សដោយចិត្តនេះថា សារាណីយធម៌ (គឺធម៌ជាទីតាំងនៃការឲ្យរលឹកដល់) យើងបានបំពេញហើយ ។ ក្នុងកាយទ្វារ ព្រះខីណាស្រពបំពេញនូវ **អភិសមាចារិកវត្ត** ជានិច្ចក៏ដល់នូវសោមនស្សនៃចិត្តនេះថា វត្តបដិបត្តិ របស់យើង ពេញបរិបូរណ៌ហើយយ៉ាងនេះ ។ ព្រះខីណាស្រព តែងតែមាន

សោមនស្ស ក្នុងបញ្ចទ្វារយ៉ាងនេះ ជាមុនសិន ប៉ុន្តែក្នុងមនោទ្វារចិត្តសោមនស្សព្រះខីណាស្រព តែងតែកើងឡើង ព្រោះប្រារព្ធរឿង អតីតៈនិង អនាគត ដូចព្រះអង្គទ្រង់រលឹកដល់ ហេតុដែលព្រះអង្គទ្រង់បានធ្វើហើយ ដូចជាកាលសោយព្រះជាតិជា **ជោតិបាល ជាមឃទេវរាជ**ជាដើម ទើបព្រះអង្គធ្វើការញញឹមឲ្យប្រាកដ តែការលឹកនោះ ជាកិច្ចនៃ **បុព្វេនិវាសានុស្សតិញ្ញាណ** និងសព្វញ្ញុត្តញ្ញាណក្នុងទីបំផុតនៃព្រះញាណទាំងពីរនេះ ចិត្តដួងនេះ រមែងកើតសេចក្តីរីករាយ ។ ក្នុងអនាគត ព្រះអង្គក៏បានធ្វើការញញឹមឲ្យប្រាកដថា នឹងមានព្រះបច្ចេកពុទ្ធ ដែលមានសំលេងដូចសំលេងពិណដូចសំលេងសំភោយ៉ាងនេះឯការរលឹកនោះជាកិច្ចរបស់ **អនាគតំសញ្ញាណ** និង **សព្វញ្ញុតញ្ញាណ** តែក្នុងទីបំផុតនៃព្រះញាណទាំងពីរនេះ ចិត្តដួងនេះ រមែងកើតសេចក្តីរីករាយ ។

មហាកិរិយាចិត្តដែលកើតឡើងព្រមនឹង ឧបេក្ខាវេទនានោះ តែងតែប្រាកដក្នុងខណៈ ដែលលោកពិចារណាអារម្មណ៍ ដែលមកប៉ះខ្ទប់ក្នុងទ្វារទាំង៦ដោយឆឡង្គុបេក្ខា មិនមានការញាប់ញ័រក្នុងប្រការណាៗឡើយ ។ ម្យ៉ាងទៀតមហាកិរិយាចិត្តរបស់ព្រះខីណាស្រពនោះគ្រាខ្លះក៏ប្រកបដោយបញ្ញា គ្រាខ្លះក៏មិនប្រកបដោយបញ្ញា ត្រង់ដែលមិនប្រកបដោយបញ្ញា ដូចជាខណៈឈរ ដើរ ជាដើម មិនចាំបាច់បញ្ញា ក៏ដើរ អង្គុយ ដេកបានដែរ ។

ក្នុងមហាកិរិយា៨ដួងនេះ មានឈ្មោះហៅច្រើនយ៉ាងគឺ

**១-កាមាវចរកិរិយា**

**២-កាមសោភណកិរិយា**

៣-**សហេតុកកិរិយា**

៤-**មហាកិរិយា**

១-ពាក្យថា **កាមាវចរកិរិយា** នោះ  គឺជាចិត្តដែលមិនរាប់ចូល ក្នុងប្រភេទចិត្តជាហេតុ និងជាផលទេ គឺជាចិត្តដែលប្រព្រឹត្តទៅដោយមិនបានផលវិញ ឬជាកម្ម ដែលចាត់នៅក្នុងប្រភេទនៃ **អហោសិកម្ម** ដូចនេះកាមាវ-ចរកិរិយានេះទើបមិនហៅថាជា **កុសល** និង **អកុសល** ហើយកិរិយាចិត្តដូងនេះក៏ជាចិត្តនៃព្រះ **អរហន្ត**មិនមាននៅក្នុងបុថុជ្ជនតែជាតិជាកាមាវចរទើបហៅថា **កាមាវចរកិរិយា** ។

២-ពាក្យថា **កាមសោភណកិរិយា**នោះ ព្រោះកាមកិរិយាចិត្តដូងនេះប្រកបដោយ **សោភណចេតសិក** ដោយហេតុនេះទើប ហៅថា **កាមសោភណកិរិយា** ។

៣-ពាក្យថា **សហេតុកកិរិយា** នោះក៏ព្រោះចិត្ត៨នោះ ប្រកបដោយ អលោភហេតុ  អទោសហេតុ  អមោហហេតុ  ដូច្នោះហើយទើប ហៅថា សហេតុកកិរិយា ។

៤-ពាក្យ **មហាកិរិយា**នោះ ក៏ព្រោះថាច្រើនទៅដោយអារម្មណ៍ និងទ្វារជាដើម ដូចនិងមហាកុសលដែរ ដូច្នោះទើប ហៅថា មហាកិរិយា ។

តើមហាកុសលនិងមហាកិរិយាខុសគ្នាយ៉ាងដូចម្ដេច ?មហាកុសលជាចិត្តកើតក្នុងចិត្តសន្តាននៃបុថុជ្ជន និងព្រះសេក្ខបុគ្គល  មហាកិរិយា ជាចិត្តកើតក្នុងចិត្តសន្តាននៃព្រះអរហន្ត ដូច្នេះចិត្តជាបុណ្យឯណា ដែលនៅក្នុងព្រះអរហន្តចិត្តនោះឯង ឈ្មោះថា **មហាកិរិយាចិត្ត** ។

ចិត្តកើតឡើងនៅក្នុងខណៈនៃការធ្វើទានជាដើម របស់ព្រះអរហន្ត ការធ្វើទាននោះមិនបានផលនៅពេលអនាគតទៀតឡើយ ព្រោះលោកមិនមាន  កិលេសតណ្ហា ដែលជាហេតុនាំឲ្យមានជាតិ គឺការកើតបន្តទៀតទេ ។

**ចំណែកមហាកិរិយា៨ដួងដោយន័យ១៤**

១-**ន័យដោយជាតិ** ជាជាតិកិរិយា

២-**ន័យដោយភូមិ** ជាកាមភូមិ (កើតបាន២៦ភូមិ)

៣-**ន័យដោយវេទនា** ជាសោមនស្ស៤ឧបេក្ខា៤

៤-**ន័យដោយហេតុ** ជានហេតុ និងជាសហេតុកចិត្ត(ជាទុហេតុកចិត្តផង ជាតិហេតុកចិត្តផង )

៥-**ន័យដោយសម្បយុត្ត** ជាញាណសម្បយុត្ត៤ ញាណវិប្បយុត្ត៤

៦-**ន័យដោយសង្ខារ** ជាអសង្ខារិក៤ សសង្ខារិក៤

៧-**ន័យដោយសោភណៈ** ជាកាមាវចរសោភណចិត្ត

៨-**ន័យដោយឈាន** ជាអឈានចិត្ត

៩-**ន័យដោយលោកិយៈ** ជាលោកិយចិត្ត

១០-**ន័យដោយកិច្ច** ជាចិត្តធ្វើជវនកិច្ច

១១-**ន័យដោយអារម្មណ៍** ជាចិត្តដឹងនូវអារម្មណ៍៦

១២-**ន័យដោយទ្វារ** កើតបានក្នុង៦ទ្វារ

១៣-**ន័យដោយវត្ថុ** កើតត្រង់ហទយវត្ថុ

១៤-**ន័យដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

**ចប់កាមាវចរចិត្ត៥៤ដួង**

រូបាវចរសោភណចិត្ត ១៥ដួង

-រូបាវចរកុសល ៥ដួង

-រូបាវចរវិបាក ៥ដួង

-រូបាវចរកិរិយា ៥ដួង

ពាក្យថា រូបាវចរសោភណចិត្ត ប្រែថា សោភណចិត្តដែលប្រព្រឹត្តទៅក្នុងរូប បានដល់ រូបឈាន ។

ពាក្យថាឈាន មានន័យពីរយ៉ាង

ន័យទី១ សំដៅដល់ការសម្លឹង ពិចារណាដុតកំដៅនូវសភាវបដិបក្ខនូវនីវរណធម៌ ជាដើមឲ្យអស់ទៅ ។

ន័យទី២ សំដៅដល់ចិត្តដែលចុះតាំងមាំ ក្នុងអារម្មណ៍ នៃកម្មដ្ឋានមានបឋវីកសិណ ជាដើម ដោយអំណាចនៃអប្បនាសមាធិ ទើបហៅថាឈាន ។

ពាក្យរូបឈាន មានន័យថា ឈានដែលបានមក អំពីការសម្លឹងរូបដូចជាបឋវីកសិណជាដើម ដូច្នេះទើបហៅថារូបឈាន ឬ រូបាវចរឈាន ។

រូបាវចរកុសល ៥ដួង

១ វិតក្កវិចារបីតិសុខេកគ្គតា សហិតបឋមជ្ឈាន កុសលចិត្តំ បឋមជ្ឈាន កុសលចិត្ត ១ដួង ប្រកបដោយ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា

២ វិចារបីតិសុខេកគ្គតា សហិតទុតិយជ្ឈាន កុសលចិត្តំ ទុតិយជ្ឈា

នកុសលចិត្ត ១ដួងប្រកបដោយ វិចារ បីតិ សុខ ឯកគ្គតា

៣ បីតិសុខេកគ្គតា សហិតតតិយជ្ឈាន កុសលចិត្តំ តតិយជ្ឈាន កុសលចិត្ត១ដួងប្រកបដោយ បីតិ សុខ ឯកគ្គតា

៤ សុខេកគ្គតា សហិតចតុត្ថជ្ឈាន កុសលចិត្តំ ចតុត្ថជ្ឈាន កុសលចិត្ត១ដួងប្រកបដោយ សុខ ឯកគ្គតា

៥ ឧបេក្ខេកគ្គតា សហិតបញ្ចមជ្ឈាន កុសលចិត្តំ បញ្ចមជ្ឈាន កុសលចិត្ត១ដួង ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា

អធិប្បាយអង្គ៥នៃបឋមឈាន

១ វិតក្កោ វិតក្កៈ

បណ្ដាអង្គទាំងនោះ វិតក្កៈ ស័ព្ទ មាន វចនត្ថថា វិតក្កេតីតិ វិតក្កោ វិតក្កនំ វិតក្កោ ធម៌ដែលឈ្មោះថា វិតក្កៈ ព្រោះអត្ថថា ត្រិះរិះ គឺនឹកគិត (អដ្ឋសាលិនី) ចំណែកក្នុងអភិធម្មត្ថវិភាវិនីដីកា ពោលថា អារម្មណំ វិតក្កេតិ សម្បយុត្តធម្មេ អភិនីរោបេតីតិ វិតក្កោ ធម៌ដែលឈ្មោះថា វិតក្កព្រោះអត្ថថា ត្រិះរិះ គឺយកសម្បយុត្តធម៌ ឡើងឆ្ពោះកាន់អារម្មណ៍ ប្រៀបដូចអ្នកស្រុកម្នាក់អាស្រ័យរាជអាមាត្យ ដែលស្និទ្ធស្នាលជាមួយព្រះរាជា អ្នកស្រុកម្នាក់នោះអាចចូលគាល់ព្រះរាជាក្នុងព្រះរាជវាំង បានយ៉ាងណា? ចិត្តដែលអាស្រ័យ វិតក្ក ក៏អាចឡើងឆ្ពោះកាន់អារម្មណ៍បានដូច្នោះដែរ។

មានពាក្យសួរថាប្រសិនបើយ៉ាងនោះឈានចិត្តដែលមិនមានវិតក្កៈ និងឡើងឆ្ពោះកាន់អារម្មណ៍បានដូចម្ដេច?

ឆ្លើយថា សូម្បីឈានចិត្តដែលមិនមានវិតក្កៈ ក៏អាចឡើងឆ្ពោះកាន់

អារម្មណ៍បាន ដោយកំលាំងវិតក្កៈនោះឯងប្រៀបដូចជាអ្នកស្រុកម្នាក់នោះ មិនមានពួកអាមាត្យនាំ ផ្លូវចូលរាជវាំងក៏ដោយ ក៏អាចចូលរាជវាំងបាន ព្រោះធ្លាប់ស្គាល់ផ្លូវ យ៉ាងណាឈានចិត្តដែលមិនមានវិតក្កៈ ក៏អាចឡើង ឆ្ពោះកាន់អារម្មណ៍បានដែរ ។ ដែលឈ្មោះថា ធ្លាប់ស្គាល់ក្នុងទីនេះបាន ដល់ការអប់រំចិត្ត ដែលកើតឡើងដោយអំណាច នៃការប្រព្រឹត្តទៅរឿយៗ ក្នុងសន្តានចិត្តដែលមានវិតក្កៈ ។ ម្យ៉ាងទៀត ចិត្តដែលមិនមានវិតក្កៈដូចជា បញ្ចវិញ្ញាណ សូម្បីមិនមានវិតក្កក៏អាចឡើងឆ្ពោះកាន់អារម្មណ៍បានដោយ កំលាំងនៃ វត្ថុនិងអារម្មណ៍ប៉ះខ្ទប់នឹងគ្នាហើយឈានមានទុតិយជ្ឈាន ជា ដើម រមែងឡើងឆ្ពោះកាន់អារម្មណ៍បានដោយកំលាំងនៃការចំរើនឈាន ពី ជាន់ទាបទៅ ។ វិតក្កៈ ក្នុងអង្គឈាននេះ មានការកំចាត់បង់ នូវថីនមិទ្ធនី-វរណៈ (ដោយ វិក្ខម្ភនបហានៈ) ។

២ វិចារោ វិចារៈ

វិចារស័ព្ទ មានវចនត្ថថា អារម្មណេ តេន វិចរតីតិ វិចារោ ធម៌ដែល ឈ្មោះថា វិចារៈ ព្រោះអត្ថថា ជាហេតុពិចារណាអារម្មណ៍នៃចិត្ត ។

តើវិតក្កៈ និងវិចារៈខុសគ្នាដូចម្ដេច? វិតក្កៈ ជាការព្រមព្រៀងដំបូង នៃចិត្តប្រៀបដូចជាការគោះរគាំងដំបូងដោយអត្ថថាគ្រោតគ្រាតជាងវិចារៈ ជាធម៌ទៅមុនវិចារៈ ចំណែកវិចារៈជាការស្រាវជ្រាវប្រៀបដូចជាសម្លេងខ្ទរ នៃរគាំងនោះ ។ ម្យ៉ាងទៀតវិតក្កៈប្រៀបដូចជាសត្វបក្សី ទទះស្លាបបំរុងនឹង ហើរទៅឰដ៏អាកាសចំណែកវិចារៈប្រៀបដូចជាបក្សីដែលបានត្រដាងស្លាប នៅឰដ៏ហើយនោះ ។

៣ បីតិ

បីតិ មានវចនត្ថថា បិនយតិ កាយចិត្តំ តប្បេតិ វឌ្ឍេតីតិ វា បីតិ ធម្មជាតិ ដែលឈ្មោះថា បីតិ ព្រោះអត្ថថា ញ៉ាំងកាយនិងចិត្តឲ្យឆ្អែតឲ្យរីករាយឬថាញ៉ាំងកាយនិងចិត្តឲ្យចំរើន ។ បីតិនោះមានការ ឆ្អែតជាលក្ខណៈ បានដល់មានការទទួលអារម្មណ៍ដែលគួរ (ដល់កាយនិងចិត្ត)ជាលក្ខណៈ គឺធ្វើកាយនិងចិត្តឲ្យត្រេកអរ ។

បីតិ (សេចក្ដីត្រេកអរ ៥យ៉ាង)

១ ខុទ្ទកា បីតិ សេចក្ដីត្រេកអរតិចតួច គ្រាខ្លះក៏ព្រឺរោម ព្រឺស្បែក គ្រាខ្លះហូរទឹកភ្នែកក៏មាន ។

២ ខណិកា បីតិ សេចក្ដីត្រេកអរមួយជួរខណៈ ប្រាកដដូចផ្លេកបន្ទោរ ។

៣ ឱកន្តិកា បីតិ បីតិកើតឡើងធ្វើកាយឲ្យញាប់ញ័រ ប្រាកដដូចរលកទឹកបោកខ្ទប់មកត្រូវ ។

៤ ឧព្វេង្គា បីតិ បីតិខ្លាំងអាចញ៉ាំងកាយឲ្យអណ្ដែតឡើង ។

៥ ផរណា បីតិ បីតិធ្វើឲ្យត្រជាក់ជ្រួតជ្រាប ទូទៅក្នុងកាយដូចសំឡីជប់ដោយប្រេងល្ង ។

បីតិដែលជាអង្គឈាន គឺផរណាបីតិ បីតិនេះអាចប្រហារ ព្យាបាទនីវរណៈ បានដោយវិក្ខម្ភនបហានៈ ចំណែកបីតិ៤ដទៃទៀតមិនរាប់ថាជាអង្គឈានទេ ព្រោះមានកម្លាំងតិច ។

៤ សុខៈ

ពាក្យថា សុខៈ មានវចនត្ថថា សម្បយុត្តធម្មេ សុខយតីតិ សុខំ ធម្មជាតិឈ្មោះថាសុខៈ ព្រោះអត្ថថា ញ៉ាំងសម្បយុត្តធម៌ឲ្យសប្បាយ ។

ពាក្យថា សុខៈជាឈ្មោះនៃសោមនស្សវេទនា ដែលមានការសោយនូវអារម្មណ៍ ដែលជាទីប្រាថ្នាជាលក្ខណៈ សុខៈ គឺសោមនស្សវេទនាក្នុងអង្គឈាននេះប្រហារនូវ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ។

ម្យ៉ាងទៀតបីតិ និងសុខៈនេះមានសភាវៈជិតប្រហាក់ប្រហែល នឹងគ្នាច្រើនគួរ គប្បីកំណត់ដឹងនូវសេចក្តីផ្សេងគ្នាយ៉ាងនេះគឺ

- បីតិ បានដល់សេចក្តីត្រេកអរក្នុងការបាននូវឥដ្ឋារម្មណ៍

- សុខៈបានដល់ការសោយរសឥដ្ឋារម្មណ៍ដែលបានហើយបីតិមានក្នុងទីណា សុខៈ ក៏មានក្នុងទីនោះ សុខៈ មានក្នុងទីណា បីតិមិនពិតថាមានក្នុងទីនោះទេ ។ បីតិ សង្គ្រោះចូលក្នុងសង្ខារខន្ធ សុខៈសង្គ្រោះចូលក្នុងវេទនាខន្ធ ។

ឧបមា បីតិ និងសុខៈ

បីតិ ប្រៀបដូចជាក្នុងពេលដែលបុគ្គល នឿយហត់កណ្តាល ផ្លូវកន្តារ បានឃើញ បានឮសម្លេងទឹកហូរ ក្នុងព្រៃជាដើម មិនទាន់បានផឹក ក៏កើតសេចក្តីរីករាយថាយើងនឹងបានផឹកនឹងបានងូតទឹកឲ្យត្រជាក់សប្បាយ ឯចំណែកសុខនោះ ប្រៀបដូចជាបុគ្គលដែលបានជ្រកម្លប់បានផឹកបានងូតតាមសប្បាយ ។

៥ ឯកគ្គតា

ឯកគ្គតា ចិត្តនេះមានវចនត្ថថា នានាលម្ពនវិក្ខេបាភាវេន ឯកំ អារម្មណំ អគ្គំ ឥមស្សាតិ ឯកគ្គំ ចិត្តំ តស្ស ភាវោ ឯកគ្គតា សមាធិចិត្តដែលឈ្មោះថា ឯកគ្គំ ដោយអត្ថថា មានអារម្មណ៍តែមួយព្រោះមិនមានការរាយមាយក្នុងអារម្មណ៍ផ្សេងៗភាវៈ នៃចិត្តមានអារម្មណ៍តែមួយនោះឈ្មោះថា ឯកគ្គតា គឺសមាធិ សមាធិឈ្មោះថា មានការមិនរាយមាយជាលក្ខណៈ ព្រោះមិនឲ្យសហជាតិធមទាំងឡាយរាយមាយខ្ចាត់ខ្ចាយ។ ដូចជាព្រះរាជាមេទ័ពទៅកាន់ទីកន្លែងកងទ័ពចម្បាំង ទ័ពទាំងនោះតែងប្រជុំគ្នាកុះករត្រង់កន្លែងដែលព្រះអង្គ យាងទៅ ទ័ពតែងព្រមព្រៀងកំចាត់ សត្រូវនិងតែងព្រមស្របតាមព្រះរាជា ។ ម្យ៉ាងទៀត ឈ្មោះថា សមាធិ គឺឯកគ្គតា នៃចិត្តនេះ មានសេចក្តីមិនរវើរវាយជាលក្ខណៈ មានការប្រមូលមកនូវសហជាតធម៌ទាំងឡាយ ចូលជាមួយគ្នាជារស (កិច្ច) ដូចទឹកធ្វើកម្ទេចល្អិតឲ្យជាប់គ្នាជាដុំៗ មានការចូលទៅស្ងប់ជាបច្ចុប្បដ្ឋាន ឬ មានញាណគឺចិត្តតាំងមាំហើយ ជាក់ច្បាស់ តែងឃើញតាមសេចក្តីពិត ជាពិសេសសមាធិមានសុខៈជាបទដ្ឋាន ។ បណ្ឌិតគប្បីជ្រាបការ តាំងនៅនៃចិត្ត ដូចការតាំងនៅនៃអណ្តាតប្រទីបដែលស្ងប់ខ្យល់ដូច្នោះ ឯកគ្គតានៃចិត្តនេះ ប្រហារនូវ កាមឆន្ទនីវរណៈ ។

សមាធិមាន៣យ៉ាង

១ ខណិក សមាធិ បានដល់ចិត្តដែលតាំងមាំក្នុងអារម្មណ៍បានមួយ ដួរខណៈ

២ ឧបចារ សមាធិ បានដល់ចិត្តតាំងមាំក្នុងអារម្មណ៍ជិតដល់ឈាន

ចិត្ត

៣ អប្បនា សមាធិ បានដល់ចិត្តតាំងមាំក្នុងអារម្មណ៍ ដែលកំណត់ទុកកិលេសមិនអាចចូលរំខានបាន ឈានចិត្តនោះរមែងកើតឡើងដោយអប្បនា សមាធិនេះ ។

## ប្រភេទនៃឈានចិត្ត

ន័យក្នុងព្រះអភិធម្ម ចំនែកឈានទាំង៥ហៅថា បញ្ចកន័យ ចំពោះមនុស្សបុគ្គលដែលមានបញ្ញាទន់ខ្សោយមិនអាចពិចារណាឃើញទោសនៃវិតក្ក និងវិចារ ទាំងពីរនេះបានក្នុងខណៈជាមួយគ្នា ។ ឈាន៥នោះគឺ

១ បឋមជ្ឈាន មានអង្គ៥គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា

២ ទុតិយជ្ឈាន មានអង្គ៤គឺ វិចារ បីតិ សុខ ឯកគ្គតា

៣ តតិយជ្ឈាន មានអង្គ៣គឺ បីតិ សុខ ឯកគ្គតា

៤ ចតុត្ថជ្ឈាន មានអង្គ២គឺ សុខ ឯកគ្គតា

៥ បញ្ចមជ្ឈាន មានអង្គ២គឺ ឧបេក្ខា ឯកគ្គតា

## អធិប្បាយ បឋមជ្ឈាន

ឈ្មោះថាឈាន ព្រោះចូលសម្ងឹងពិចារណាអារម្មណ៍ និងព្រោះដុតកំដៅនូវធម៌ ជាសឹកសត្រូវ ហើយដែលហៅថា បឋម (ទី១)ព្រោះជាខាង

ដើមដោយលំដាប់នៃទេសនា និងដោយលំដាប់ នៃការកើតឡើង ព្រោះហេតុនោះ ទើបឈ្មោះថា បឋមជ្ឈាន បានដល់ការប្រជុំនៃអង្គឈានទាំង៥ មាន វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ដូចក្នុងគម្ពីរវិភង្គ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា ឈ្មោះថាឈានបានដល់ វិតក្កៈវិចារៈបីតិ សុខៈ ឯកគ្គតា យ៉ាងនេះ ។

## បឋមជ្ឈានកុសលចិត្ត

កុសលចិត្តដែលសម្បយុត្តដោយបឋមជ្ឈាន ឈ្មោះថាបឋមជ្ឈានកុសលចិត្តមានពាក្យសួរថាបើសម្បយុត្តធម៌ដទៃមានផស្សៈជាដើមកើតក្នុងខណៈនោះដែរ ព្រោះហេតុអ្វីទើបសម្តែងថាបឋមជ្ឈានមានតែអង្គ ៥

ឆ្លើយថា អង្គទាំង៥នេះមានកិច្ចតួនាទី សម្ងឹងពិចារណាអារម្មណ៍ និងជាបដិបក្ខដោយត្រង់ចំពោះកាមច្ឆន្ទនីវរណៈជាដើម ។

អង្គឈានទាំង៥ បដិបក្ខនិងនីវរណ៥

| | | |
|---|---|---|
| ១ | ឯកគ្គតា | ជាបដិបក្ខ និង កាមច្ឆន្ទៈ |
| ២ | បីតិ | ជាបដិបក្ខ និង ព្យាបាទៈ |
| ៣ | វិតក្កៈ | ជាបដិបក្ខ និង ថីនមិទ្ធៈ |
| ៤ | សុខៈ | ជាបដិបក្ខ និង ឧទ្ធច្ចកុក្កុច្ចៈ |
| ៥ | វិចារៈ | ជាបដិបក្ខ និង វិចិកិច្ឆា |

ដូចពាក្យរបស់បុរាណាចារ្យទាំងឡាយបានពោលទុក ថា

ឧបនិជ្ឈានកិច្ចត្តា កាមាទិបដិបក្ខតោ
សន្តេសុ ច អញ្ញេសុ បញ្ចេវជ្ឈានសញ្ញិតា

កាលធម៌ដទៃមានផស្សៈជាដើម មានធម៌៥យ៉ាងប៉ុណ្ណោះ ដែលលោកហៅថាឈាន ព្រោះមានការសម្លឹងពិចារណាអារម្មណ៍ និងព្រោះជាបដិបក្ខនឹងនីវរណៈ មានកាមឆន្ទនីវរណៈ ជាដើមក្នុងសារត្ថបកាសិនីអដ្ឋកថាសំយុត្តនិកាយ មហាវីរវគ្គ បានពោលនូវ ការលះ នីវរណៈ៥យ៉ាងនេះគឺ

១ កាមឆន្ទ លះដោយធម៌៣គឺ ដោយ តទង្គនិស្សរណៈ (វិបស្សនា) ១ ដោយវិក្ខម្ភននិស្សរណៈ (អសុភឈាន) ១ ដោយសមុច្ឆេទនិស្សរណៈ (អរហត្តមគ្គ) ១ ។

២ ព្យាបាទ លះដោយធម៌២គឺ ដោយ វិក្ខម្ភននិស្សរណ (មេត្តាឈាន) ១ ដោយសមុច្ឆេទនិស្សរណៈ (អានាគាមិមគ្គ) ១ ។

៣ ថីនមិទ្ធ លះដោយធម៌២គឺ ដោយ វិក្ខម្ភននិស្សរណៈ (អាលោកសញ្ញា) ១ដោយសមុច្ឆេទនិស្សរណ (អរហត្តមគ្គ) ១ ។

៤ ឧទ្ធច្ចកុក្កុច្ច លះដោយ វិក្ខម្ភននិស្សរណៈ ដោយសមថកម្មដ្ឋានណាមួយកុក្កុច្ចៈលះជាសមុច្ឆេទដោយអានាគាមិមគ្គឧទ្ធច្ចៈលះជាសមុច្ឆេទដោយអរហត្តមគ្គ ។

៥ វិចិកិច្ឆា លះដោយ វិក្ខម្ភននិស្សរណៈ គឺឈានណាមួយនិងលះជាសមុច្ឆេទ ដោយសោតាបត្តិមគ្គ ។

ឈាន២យ៉ាងគឺ

១ អារម្មណូបនិជ្ឈាន បានដល់សមាបត្តិ៨

២ លក្ខណូបនិជ្ឈាន បានដល់វិបស្សនាមគ្គនិងផល

បណ្តាឈានទាំងពីរនោះ សមាបត្តិ៨ ព្រះយោគាវចរ (គឺអ្នកត្រាច់ចុះកាន់សេចក្តីព្យាយាម) រមែងសម្លឹងពិចារណាអារម្មណ៍ដែលជាកសិណមានបឋវីកសិណជាដើម ព្រោះហេតុនោះឈាននោះទើបហៅថា អារម្មណូបនិជ្ឈាន ។ ចំណែកវិបស្សនា ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះការសម្លឹងពិចារណានូវលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។

មគ្គចិត្ត ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះកិលេសដែលវិបស្សនាកំចាត់ហើយ រមែងសំរេចដោយមគ្គ។ ចំណែកផលចិត្ត ឈ្មោះថា លក្ខណូបនិជ្ឈានដែរ ព្រោះសម្លឹងលក្ខណៈ ដែលជាសច្ចៈ គឺនិរោធសច្ចៈ ។

សមថកម្មដ្ឋាន៤០ ដោយសង្ខេប

១ កសិណ ១០

២ អសុភ ១០

៣ អនុស្សតិ ១០

៤ ព្រហ្មវិហារ ៤

៥ អរូបឈាន ៤

៦ អាហារេបដិកូលសញ្ញា ១

៧ ចតុធាតុវវដ្ឋាន ១

កសិណ ១០

| | |
|---|---|
| ១ បឋវីកសិណ | កសិណដី |
| ២ អាបោកសិណ | កសិណទឹក |

៣ តេជោកសិណ កសិណភ្លើង

៤ វាយោកសិណ កសិណខ្យល់

៥ នីលកសិណ កសិណពណ៌ខៀវ

៦ បីតកសិណ កសិណពណ៌លឿង

៧ លោហិតកសិណ កសិណពណ៌ក្រហម

៨ ឱទាតកសិណ កសិណពណ៌ស

៩ អាកាសកសិណ កសិណអាកាស

១០ អាលោកកសិណ កសិណពន្លឺ

អសុភ: ១០

១ ឧទ្ធុមាតកអសុភ សាកសពហើមប៉ោង

២ វិនីលកអសុភ សាកសពហើមពណ៌ខៀវ

៣ វិបុព្វកអសុភ សាកសពហើមហូរខ្ទុះ

៤ វិច្ឆិទ្ទកអសុភ សាកសពដាច់ពាក់កណ្ដាលខ្លួន

៥ វិក្ខាយិតកអសុភ សាកសពត្រូវសត្វកកេរស៊ីរលួយ

៦ វិក្ខិត្តកអសុភ សាកសពដាច់ដៃដាច់ជើង

៧ ហតវិក្ខិត្តកអសុភ សាកសពត្រូវគេកាប់ស្នាមរវាម

៨ លោហិតកអសុភ សាកសពមានឈាមស្រោចពេញខ្លួន

៩ បុឡុវកអសុភ សាកសពមានដង្កូវចោះស៊ី

១០ អដ្ឋិកអសុភ សាកសពមានតែរាងឆ្អឹង

អនុស្សតិ ១០

១ ពុទ្ធានុស្សតិ សេចក្តីរលឹកដល់គុណព្រះពុទ្ធ

២ ធម្មានុស្សតិ សេចក្តីរលឹកដល់គុណព្រះធម៌

៣ សង្ឃានុស្សតិ សេចក្តីរលឹកដល់គុណព្រះសង្ឃ

៤ សីលានុស្សតិ សេចក្តីរលឹកដល់សីល

៥ ចាគានុស្សតិ សេចក្តីរលឹកដល់ទាន

៦ ទេវតានុស្សតិ សេចក្តីរលឹកដល់ទេវតា

៧ ឧបសមានុស្សតិ សេចក្តីរលឹកដល់គុណព្រះនិព្វាន

៨ មរណានុស្សតិ រលឹកដល់សេចក្តីស្លាប់

៩ កាយគតាសតិ សេចក្តីរលឹកដល់រូបកាយដែល ប្រជុំដោយអាការៈទាំង ៣២

១០ អានាបានស្សតិ សេចក្តីរលឹកដល់ខ្យល់ដង្ហើមចេញចូល ។

ព្រហ្មវិហារ ៤

១ មេត្តា សេចក្តីរាប់អាន

២ ករុណា សេចក្តីអាណិតអាសូរ

៣ មុទិតា សេចក្តីត្រេកអរតាម

៤ ឧបេក្ខា សេចក្តីស្មោះស្មើមិនលំអៀង ។

អរូបជ្ឈាន ៤

១ អាកាសានញ្ចាយតន អាកាសមិនមានទីបំផុត

២ វិញ្ញាណញ្ចាយតន វិញ្ញាណមិនមានទីបំផុត

៣ អាកិញ្ចិញ្ញាយតន អ្វីតិចតួចមិនមាន

៤ នេវសញ្ញានាសញ្ញាយតន វិញ្ញាណល្អិតប្រណិតក្រៃពេក ។

អាហារេបដិកូលសញ្ញា ១

- អាហារេបដិកូលសញ្ញា គឺសេចក្តីសំគាល់ នូវអាហារថា ជារបស់គួរខ្ពើមរអើម ។

ចតុធាតុវវដ្ឋាន ១

- ចតុធាតុវវដ្ឋាន គឺការកំណត់បែកធាតុទាំង ៤ មានបឋវីធាតុជាដើមដោយសសម្ភារៈ មានកេសា (សក់ )ជាដើម ។

ក្នុងអារម្មណ៍កម្មដ្ឋាន ៤០នេះអារម្មណ៍ដែលនឹងធ្វើឲ្យបានសម្រេចដល់អប្បនាសមាធិ មានត្រឹមតែ ៣០ប៉ុណ្ណោះព្រោះដូច្នោះគប្បីជ្រាបសមថកម្មដ្ឋាន ៤០ ដោយពិស្តារដែលបានពោលមកហើយក្នុងគម្ពីរវិសុទ្ធិមគ្គបឋមភាគ បានពោលសមថកម្មដ្ឋាន ៤០ ដោយអាការៈ ១០ គឺ

១ សង្ខាតនិទ្ទេសតោ ដោយការសម្តែងចំនួនកម្មដ្ឋាន

២ ឧបចារប្បនាវហតោ ដោយជាកម្មដ្ឋាន នាំមកនូវឧបចារឈាននិងអប្បនាឈាន

៣ ឈានប្បភេតោ ដោយប្រភេទនៃឈាន

៤ សមតិក្កមតោ ដោយការកន្លង (អង្គឈាន និងអារម្មណ៍)

៥ វឌ្ឍនាវឌ្ឍនតោ ដោយកម្មដ្ឋានគួរពង្រីក និងមិនគួរពង្រីក (និមិត្ត )

៦ អារម្មណតោ ដោយអារម្មណ៍

៧ ភូមិតោ ដោយភូមិ

៨ គហណតោ ដោយការកាន់យក

៩ បច្ចយតោ ដោយបច្ច័យ

១០ ចរិយានុកូលតោ ដោយសមគួរដល់ចរិត ។

១ សង្ខាតនិទ្ទេសតោ ដោយការសម្ដែងចំនួនបានដល់ សមថកម្មដ្ឋាន ៤០ គឺ កសិណ ១០ អសុភៈ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ អរូបឈាន ៤ អាហារេបដិកូលសញ្ញា ១ ចតុធាតុវវដ្ឋាន ១

២ ឧបចារប្បនាវហតោ ដោយការនាំមកនូវឧបចារៈនិងអប្បនា ក្នុងកម្មដ្ឋានទាំងនោះ អនុស្សតិ ១០ (វៀរកាយគតាសតិ និងអានាបានស្សតិ) នៅសល់ ៨ទៀត និងអាហារេបដិកូលសញ្ញា១ ចតុធាតុវវដ្ឋាន១ទាំង១០ នេះជាកម្មដ្ឋាននាំមកត្រឹមតែឧបចារៈឈានប៉ុណ្ណោះ កម្មដ្ឋានដែលសល់ពីនោះជាអប្បនាវហ (អាចបានសម្រេចដល់អប្បនា)

៣ ឈានប្បភេតោ ដោយប្រភេទនៃឈាន កសិណ១០អានាបានស្សតិ ១ ចំរើនដល់ចតុត្ថជ្ឈាន (ឈានទី៤)ដោយចតុកន័យ ។ អសុភ១០ កាយគតាសតិ១ចំរើនដល់ត្រឹមតែបឋមជ្ឈាន ដោយចតុកន័យ ។

ព្រហ្មវិហារ ៣ ខាងដើម (មេត្តា ករុណា មុទិតា) អាចចំរើនបានដល់តតិយជ្ឈាន ដោយចតុកន័យ ។

ព្រហ្មវិហារទី ៤ និងអរូបឈាន អាចប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាន ដោយចតុកន័យ ។

៤ សមតិក្កមតោ ដោយការកន្លង បានដល់ការកន្លង២យ៉ាង គឺកន្លងអង្គឈាន១និងកន្លងអារម្មណ៍១ ការកន្លងអង្គឈានដូចជាទុតិយជ្ឈានដោយចតុកន័យ កន្លង វិតក្កៈ វិចារៈ ជាដើម ។ ក្នុងព្រហ្មវិហារ៤ក៏ដូចគ្នា ព្រហ្មវិហារទី៤ក៏កន្លងសោមនស្ស ។ ចំណែកការកន្លងអារម្មណ៍តែងមានក្នុងអរូបឈាន៤គឺ អាកាសានញ្ចាយតនៈកន្លងអារម្មណ៍ក្នុងកសិណ៩ខាងដើមហើយទើបសម្រេចបានអរូបឈានថ្នាក់ខ្ពស់ក៏កន្លងអារម្មណ៍ថ្នាក់ទាបប្រព្រឹត្តទៅដោយលំដាប់ ។

៥ វឌ្ឍនាវឌ្ឍនតោ ដោយការគួរពង្រីកនិងមិនគួរពង្រីកគឺ កសិណ១០ គួរពង្រីកនិមិត្ត ។ អាណាបានស្សតិ១ កាយគតាសតិ១ អសុភ១០ព្រហ្មវិហារ៤អរូបឈាន៤ មិនគួរពង្រីកព្រោះមិនកើតប្រយោជន៍ ។

៦ អារម្មណតោ ដោយអារម្មណ៍ បណ្តាកម្មដ្ឋានទាំង៤០ នេះកម្មដ្ឋាន២២គឺ កសិណ១០ អសុភ១០ អានាបានស្សតិ១ កាយគតាសតិ១ មានអារម្មណ៍ជាបដិភាគនិមិត្ត កម្មដ្ឋានដែលនៅសល់១៨ទៀត មិនមានអារម្មណ៍ជាបដិភាគនិមិត្តទេ ដោយន័យនោះ កម្មដ្ឋាន១២គឺ អនុស្សតិ១០ វៀរអានាបានស្សតិ១ កាយគតាសតិ១ នៅសល់៨ និងអាហារេបដិកូលសញ្ញា១ ចតុធាតុវវដ្ឋាន១វិញ្ញាណញ្ចាយតនៈ១នេវសញ្ញានាសញ្ញាយតនៈ១ ទាំង១២នេះមានសភាវធម៌ ជាអារម្មណ៍ កម្មដ្ឋាន២២គឺ កសិណ១០ អសុភ១០អានាបានស្សតិ១កាយគតាសតិ១ទាំងនេះមាននិមិត្តជាអារម្មណ៍ កម្មដ្ឋានដែលសល់៦ទៀតគឺ ព្រហ្មវិហារ៤អាកាសានញ្ចាយតនៈ១អាកិញ្ចញ្ញាយតនៈ១ ជា នវត្តព្វារម្មណ៍(មានអារម្មណ៍ដែលមិនគប្បីពោល)កម្មដ្ឋា-

ន៨ គឺ វិបុព្វកអសុភ លោហិតកអសុភ បុឡុវកអសុភ អានាបានស្សតិ អបោកសិណ តេជោកសិណ វាយោកសិណ និងពន្លឺថ្ងៃ (ដែលចូលតាមចន្លោះ) ជាដើម ដែលជាអារម្មណ៍ ក្នុងកសិណទាំងនេះជា ចលិតារម្មណ៍ មានអារម្មណ៍ញាប់ញ័រដែលថាអារម្មណ៍ញាប់ញ័រទាំងនេះ ក៏នៅជាខាងដើមប៉ុណ្ណោះ អាចជា បដិភាគនិមិត្ត ដ៏មាំបាន អារម្មណ៍នៃកម្មដ្ឋានដែលនៅសល់៣២ ជានចលិតារម្មណ៍ មានអារម្មណ៍មិនញាប់ញ័រ ។

៧) ភូមិតោ ដោយភូមិ បណ្តាកម្មដ្ឋាន៤០នេះ កម្មដ្ឋាន១២គឺអសុភៈ១០ កាយគតាសតិ១ អាហារេបដិកូលសញ្ញា១ រមែងមិនមានក្នុងពួកទេវតា ព្រោះក្នុងទេវលោកមិនមានអសុភ និងអាហារដែលជាបដិកូល (គឺអាហារគួរខ្ពើមរអើមឡើយ) ។ កម្មដ្ឋាន ១៣ គឺ អសុភ១០ កាយគតាសតិ១ អាហារេបដិកូលសញ្ញា១ និងអានាបានស្សតិ១ កម្មដ្ឋានទាំងនេះមិនមាន ក្នុងព្រហ្មលោកទេ ព្រោះព្រហ្មលោកមិនមានគ្រឿងស្មោកគ្រោក ជាពិសេសមិនមានខ្យល់ដង្ហើមចេញចូល ដូច្នេះហើយអានាបានស្សតិកម្មដ្ឋាន មិនមានក្នុងព្រហ្មលោកទេចំណែកឯក្នុងអរូបព្រហ្មកម្មដ្ឋានដទៃ វៀរអរូបជ្ឈាន ៤ មិនអាចមានក្នុងអរូបព្រហ្មទេ ក្នុងពួកមនុស្សកម្មដ្ឋានរមែងប្រព្រឹត្តទៅបានគ្រប់យ៉ាង ។

៨ គហណតោ ដោយការកាន់យក បានដល់ការកាន់យកដោយភ្នែកមើលដោយការប៉ះខ្ទប់ និងដោយការស្តាប់ ។ ក្នុងការកាន់យក៣យ៉ាងនោះ កម្មដ្ឋាន ១៩ គឺកសិណ ១០វៀរវាយោកសិណ ១ និងអសុភ ១០ គឺយកដោយការមើលទើបធ្វើឲ្យកើតនិមិត្តបាន ។ កាយគតាសតិ១ កាន់យក

ដោយការមើល និងដោយការស្តាប់ គឺ តចបញ្ចកកម្មដ្ឋាន កាន់យកដោយភ្នែកមើល ក្រៅពីនោះកាន់យកដោយការស្តាប់ ។ អានាបានស្សតិកាន់យកដោយការប៉ះខ្ទប់ វាយោកសិណ កាន់យកដោយការមើល និងកាន់យកដោយការប៉ះខ្ទប់ នៅសល់ដទៃទៀត១៨ កាន់យកដោយការស្តាប់ ។ កម្ម-ដ្ឋាន៤០នោះ ឧបេក្ខាព្រហ្មវិហារ១ និងអរូបកម្មដ្ឋាន៤ ព្រះយោគាវចរ ជាអាទិកម្មិកបុគ្គល (ជាអ្នកមិនទាន់ជំនាញ)មិនគួរកាន់យកទេ នៅសល់៣៥ ក្រៅពីនោះទើបគួរកាន់យក ។

៩ បច្ចយតោ ដោយបច្ច័យ បានដល់កសិណ៩វៀរអាកាសកសិណ ១ ជាបច្ច័យដល់រូបឈាន កសិណជាបច្ច័យដល់អភិញ្ញា ។ ព្រហ្មវិហារ៣ ខាងដើមជាបច្ច័យដល់ព្រហ្មវិហារទី៤ ។

អរូបឈានថ្នាក់ក្រោម ៗ ជាបច្ច័យដល់អរូបឈានថ្នាក់ខ្ពស់ នេវ-សញ្ញានាសញ្ញាយតនៈ ជាបច្ច័យដល់និរោធសមាបត្តិ ។ កម្មដ្ឋានទាំងអស់ (ទាំងសមថទាំងវិបស្សនា) ជាបច្ច័យដល់សុខវិហារ និងភពសម្បត្តិ ។

១០ ចរិយានុកូលតោ ដោយការសមគួរដល់ចរិត មានអធិប្បាយថា ក្នុងកម្មដ្ឋាន៤០នោះ កម្មដ្ឋាន១១គឺ អសុភ១០ កាយគតាសតិ១សមគួរដល់បុគ្គលជារាគចរិត ។ កម្មដ្ឋាន៨គឺ ព្រហ្មវិហារ៤ វណ្ណកសិណ៤ សមគួរដល់បុគ្គលជាទោសចរិត ។អានាបានស្សតិ សមគួរដល់បុគ្គលជាមោហចរិតនិងបុគ្គលជាវិតក្កចរិត ។ អនុស្សតិ៦ខាងដើមសមគួរដល់បុគ្គលជាសទ្ធាចរិត។ កម្មដ្ឋាន៤ គឺមរណានុស្សតិ១ ឧបសមានុស្សតិ១ ចតុធាតុវវដ្ឋាន១ និងអាហារេបដិកូលសញ្ញា១ សមគួរដល់បុគ្គលជាពុទ្ធិចរិត ។ កសិណ៦ វៀរ

វណ្ណកសិណ៤ និងអរូបឈាន៤ សមគួរដល់បុគ្គលគ្រប់ចរិត ។ ម្យ៉ាងទៀត កសិណទាំងឡាយកសិណណាមួយ ជាបរិត្តារម្មណ៍សមគួរដល់បុគ្គល ជាវិតក្កចរិត និងកសិណណាមួយដែលជាអប្បនារម្មណ៍ សមគួរដល់ បុគ្គលជាមោហចរិត ។

ការចំរើនសមថភាវនា គឺចំរើនរូបឈានប្រកបដោយអង្គឈាន ៥ មានវិតក្កៈ ជាដើមនោះ អាចបញ្ចប់នូវនីវរណ៥មិនឲ្យកើតឡើងបានព្រោះចិត្ត តាំងមាំក្នុងអារម្មណ៍តែមួយ រហូតដល់ឈានចិត្តកើត ។

ពេលឈានចិត្តកើតហើយ អង្គឈាននោះឯងតែងកំចាត់បង់ នូវនីវរណៈ៥ ដោយវិក្ខម្ភនបហានៈ ។

ម្យ៉ាងទៀតពេលឈានចិត្តនឹងកើតឡើង សមាធិរមែងកើតឡើងតាមលំដាប់ គឺ ខណិកសមាធិ ឧបចារសមាធិ និងអប្បនាសមាធិ ។ ឈានចិត្តកើតឡើងគ្រាដំបូងបានត្រឹម តែមួយខណៈនៃចិត្តតែប៉ុណ្ណោះ ហើយក៏ជាភវង្គ ។ បើមិនឲ្យមកជាភវង្គទេត្រូវហ្វឹកហាត់រហូតទាល់តែស្ទាត់ជំនាញ (ដែលហៅថាវសី៥យ៉ាង) ។

ឯឈាន រូបាវចរកុសលចិត្តនឹងកើតឡើងនោះ វិថីចិត្តនឹងកើតឡើងតាមលំដាប់ យ៉ាងនេះគឺ

១ ភវង្គចលន
២ ភវង្គុបច្ឆេទ
៣ មនោទ្វារាវជ្ជន
៤ បរិកម្ម

៥ ឧបចារ　　　　　មហាកុសលញាណសម្បយុត្ត

៦ អនុលោម

៧ គោត្រភូ

៨ ឈានគឺរូបាវចរកុសលចិត្ត

០ ភវង្គបាត　ចិត្តជាភវង្គកាលភវង្គចលនៈ　គឺការញ័រនៃភវង្គរលត់ទៅ　ភវង្គុបច្ឆេទកើតរួច　ក៏រលត់តពីនោះ មនោទ្វារាវជ្ជនៈគឺអហេតុកកិរិយាចិត្តក៏កើតឡើងធ្វើកិច្ច　ពិចារណាអារម្មណ៍តាមមនោទ្វារ ។ កាលមនោទ្វារាវជ្ជនចិត្តរលត់ទៅ មហាកុសលញាណសម្បយុត្ត៤ដួងណាមួយក៏ធ្វើ　បរិកម្ម　ឧបចារៈ អនុលោម　គោត្រភូ។ពេលដែលគោត្រភូចិត្តរលត់ទៅ　ឈានចិត្តក៏កើតឡើង តែមួយខណៈ ប៉ុណ្ណោះរួចហើយចិត្តក៏ជាភវង្គ តទៅយ៉ាងនេះឯង ។

## ទុតិយជ្ឈាន

កាលព្រះយោគាវចរ ហ្វឹកហាត់ព្យាយាមចូល បឋមជ្ឈាន រហូត ជំនាញល្អដល់ព្រមដោយវសីទាំង៥គឺ

១ អាវជ្ជនវសី　　　ជំនាញឬស្ទាត់ក្នុងការនឹករក

២ សមាបជ្ជវសី　　　ស្ទាត់ក្នុងការចូលកាន់ឈាន

៣ អធិដ្ឋានវសី　　　ស្ទាត់ក្នុងការឲ្យឈានតាំងនៅមាំ

៤ វុដ្ឋានវសី　　　ស្ទាត់ក្នុងការចេញចាកឈាន

៥ បច្ចវេក្ខណវសី　　　ស្ទាត់ក្នុងការពិចារណាអង្គឈាន

ព្រះយោគាវចរ ចូលឈាន　ចេញចាកឈានរហូតទាល់តែស្ទាត់

ហើយហ្វឹកហាត់ដោយពិចារណាថា នឹករកអ្វី ទោះបីឈាន នឹងកើតបាន ឆាប់រហ័ស ហ្វឹកហាត់ដោយវិធីយ៉ាងនោះរឿយៗ រហូតស្ទាត់ល្អ ហៅថា អាវជ្ជនវសី ។ សមាបជ្ជនវសីគឺចូលឈានដែលស្ទាត់នោះជារឿយៗ ។

អធិដ្ឋានវសី គឺស្ទាត់ក្នុងការឲ្យឈានកើតរលត់ជាប់បន្ត មិនដាកវត្ត គឺឲ្យឈានតាំងនៅតាមសេចក្តីត្រូវការ ។ វុដ្ឋានវសីគឺដោយការតាំងចិត្តនឹង ចេញចាកពីឈានក្នុងពេលណា ក៏ចេញបានក្នុងពេលនោះមិនយឺតយូរ ។ បច្ចវេក្ខណវសីគឺ កាលបើចេញចាកពីឈានហើយ ពិចារណាដើម្បីលះនូវ អង្គឈានដែលគ្រោតគ្រាតចេញ ដើម្បីធ្វើឲ្យអប្បនាសមាធិតាំងនៅមាំ ក្រៃ លែងឡើង ។ រ មែងពិចារណាឃើញថាវិតក្កៈ នេះជាអង្គឈានដែលគ្រោត គ្រាតជាងវិចារៈ ព្រោះជិតដល់នឹងកាមារម្មណ៍ ។

ដូច្នោះកាលនឹងឡើងកាន់ទុតិយជ្ឈានទើបលោកសម្លឹងបដិភាគនិ-មិត្តដើម្បីឲ្យចិត្តជាអប្បនាសមាធិ ដោយមិនមានវិតក្កៈ តទៅ ព្យាយាមប្រឹង ប្រែងរហូតដល់ឈានចិត្តមិនមានវិតក្កៈ កើតឡើងប៉ុន្តែ គង់នៅមានវិចារៈ បីតិ សុខ ឯកគ្គតា ប៉ុណ្ណោះ ។ កាលបើទុតិយជ្ឈាន នឹងកើតនោះក៏ត្រូវមាន វិថីចិត្តដែលកើតមុនគឺ មហាកុសលញាណសម្បយុត្តចិត្ត ដែលជាបរិកម្ម ឧបចារៈ អនុលោម និងគោត្រភូ ដូចគ្នានឹងបឋមឈានដែរ ។

## តតិយជ្ឈាន

កាលព្រះយោគាវចរ ស្ទាត់ជំនាញក្នុងទុតិយជ្ឈាន ល្អប្រកបដោយ វសី៥ហើយ ក៏សម្លឹងនូវបដិភាគនិមិត្តឡើងទៅកាន់ឈានទី៣ ដោយពិចារ ណាឃើញវិចារៈជាអង្គនៃឈានគ្រោតគ្រាតជិតនឹងវិតក្កៈដែលធ្វើឲ្យវិនាស

បានផាយ កាលបើឃើញទោសនៃវិចារៈហើយ ក៏ចូលឈានសម្ទឹងបដិភាគនិមិត្ត ដើម្បីឲ្យអប្បនាសមាធិកើតឡើង ដោយមិនមានវិចារ រហូតដល់តតិយជ្ឈាន កើតមានទំនងដូចមុនដែរ ។

## ចតុត្ថជ្ឈាន

កាលព្រះយោគាវចរ ចម្រើនតតិយជ្ឈាន ស្ទាត់ជំនាញល្អប្រកបដោយវសី៥ហើយ ក៏ព្យាយាមកន្ទងឡើងកាន់ឈានទី៤ ដោយពិចារណាឃើញបីតិ ដែលកើតឡើងក្នុងតតិយជ្ឈាន ជាសេចក្ដីត្រេកអរជ្រួតជ្រាប ទូទៅទាំងកាយទាំងចិត្ត ដែលគិតថា ជាសភាពដែលនៅគ្រោតគ្រាតដើម្បីឲ្យចិត្តប្រណិតក្រៃលែងឡើងកើតរួមជាមួយ ។ វិថីចិត្ត ដែលកើតមុនចតុត្ថ-ជ្ឈានមានទំនងដូចនឹងឈានមុនដែរ ។

## បញ្ចមជ្ឈាន

កាលព្រះយោគាវចរចម្រើនចតុត្ថជ្ឈានស្ទាត់ជំនាញល្អប្រកបដោយវសី៥ហើយក៏ពិចារណាឃើញទោសរបស់សុខៈថា ជាសភាពដែលគ្រោតគ្រាតជាងឧបេក្ខាព្រោះសុខនោះនៅញាប់ញ័រមិនតាំងមាំដូចឧបេក្ខាវេទនាទេ ទើបសំឡឹងបដិភាគនិមិត្ត ចម្រើនអប្បនាសមាធិ ដើម្បីលះសុខៈ រហូតបញ្ចមជ្ឈាន កើតប្រកបដោយអង្គ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

មហាកុសលញាណសម្បយុត្ត ដែលធ្វើបរិកម្ម ឧបចារៈ អនុលោម និងគោត្រភូ ដែលកើតមុនបញ្ចមជ្ឈាននោះ កើតព្រមជាមួយឧបេក្ខាវេទនា ព្រោះឈានទី៥នេះ មាន ឧបេក្ខា និង ឯកគ្គតា ។

មហាកុសលញាណសម្បយុត្ត ដែលធ្វើបរិកម្ម ឧបចារៈ អនុលោម និងគោត្រភូ ដែលកើតមុនបញ្ចមជ្ឈាននោះ កើតព្រមនឹងឧបេក្ខាវេទនា ព្រោះឈានទី៥នេះ មានឧបេក្ខា និងឯកគ្គតាជាអង្គឈាន ចំណែកឈាន ៤ទៀតក្រៅពីនេះ មហាកុសលនោះកើតព្រមនឹងសោមនស្សវេទនា ។

ម្យ៉ាងទៀត មហាកុសលញាណសម្បយុត្តចិត្ត ដែលកើតក្នុងរវាង ការចម្រើន សមថភាវនានោះ ពេលខ្លះក៏កើតព្រម នឹងសោមនស្សវេទនា ពេលខ្លះក៏កើតព្រមនឹង ឧបេក្ខាវេទនា ។

## ចំណែករូបាវចរកុសលចិត្ត៥ដួងដោយន័យ១៤

១ **ន័យដោយជាតិ** ជាកុសលជាតិ

២ **ន័យដោយភូមិ** ជារូបាវចរភូមិ (កើតបាន២២ភូមិវៀរអបាយភូមិ ៤ អសញ្ញីសត្តភូមិ១ អរូបភូមិ៤ )

៣**ន័យដោយវេទនា** ជាសោមនស្សវេទនា៤ដួង គឺបឋមជ្ឈាន ទុតិ- យជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈាន ជាឧបេក្ខា១ដួងគឺបញ្ចមជ្ឈាន

| | |
|---|---|
| ៤ **ន័យដោយហេតុ** | ជានហេតុ និងជា តិហេតុកចិត្ត |
| ៥ **ន័យដោយសម្បយុត្ត** | ជាញាណសម្បយុត្ត |
| ៦ **ន័យដោយសង្ខារ** | ជាសសង្ខារិកៈ |
| ៧ **ន័យដោយសោភណ** | ជារូបាវចរសោភណចិត្ត |
| ៨ **ន័យដោយឈាន** | ជារូបាវចរឈាន |
| ៩ **ន័យដោយលោកិយ** | ជាលោកិយចិត្ត |
| ១០ **ន័យដោយកិច្ច** | ធ្វើជវនកិច្ច |

១១ **ន័យដោយអារម្មណ៍** មានធម្មារម្មណ៍ជាអារម្មណ៍

១២ **ន័យដោយទ្វារ** ដឹងអារម្មណ៍តាមមនោទ្វារ

១៣ **ន័យដោយវត្ថុ** អាស្រ័យហទយវត្ថុ

១៤ **ន័យដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

**រូបាវចរវិបាកចិត្ត៥ដួង**

១ **វិតក្ក វិចារ បីតិ សុខេកគ្គតាសហិត បឋមជ្ឈានវិបាកចិត្តំ** បឋមជ្ឈានកុសលចិត្តប្រកបព្រមដោយ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា

២ **វិចារ បីតិ សុខេកគ្គតាសហិត ទុតិយជ្ឈានវិបាកចិត្តំ** ទុតិយជ្ឈានវិបាកចិត្តប្រកបព្រមដោយវិចារៈ បីតិ សុខៈ ឯកគ្គតា

៣ **បីតិ សុខេកគ្គតាសហិតតតិយជ្ឈានវិបាកចិត្តំ**តតិយជ្ឈានវិបាក-ចិត្ត ប្រកបព្រមដោយ បីតិ សុខៈ ឯកគ្គតា

៤ **សុខេកគ្គតាសហិតចតុត្ថជ្ឈានវិបាកចិត្តំ** ចតុត្ថជ្ឈានវិបាកចិត្តប្រកបព្រមដោយ សុខ ឯកគ្គតា

៥ **ឧបេក្ខេកគ្គតាសហិតបញ្ចមជ្ឈានវិបាកចិត្តំ** បញ្ចមជ្ឈានវិបាកចិត្ត ប្រកបព្រមដោយ ឧបេក្ខា ឯកគ្គតា ។ (សេចក្តីអធិប្បាយ នៃអង្គវិបាក-ឈាននេះ ក៏មានសេចក្តីដូចគ្នានឹងរូបាវចរកុសលដែរ) ។

តើរូបាវចរកុសលនិងរូបាវចរវិបាកខុសគ្នាត្រង់ណា? បើមើលទៅតាមអង្គឈាននិមួយ ៗ របស់រូបាវចរកុសល និងរូបាវចរវិបាកគឺដូចគ្នាប៉ុន្តែអ្វីដែលខុសពីគ្នានោះគឺ រូបាវចរកុសលជាហេតុឯរូបាវចរវិបាកជាផល រូបា-វចរកុសលធ្វើជវនកិច្ចតែម្យ៉ាង ឯរូបាវចរវិបាកធ្វើ បដិសន្ធិកិច្ច ភវង្គកិច្ច

ចុតិកិច្ច ។

## អធិប្បាយរូបាវចរវិបាក

កាមាវចរវិបាក តែងដូចគ្នាខ្លះ មិនដូចគ្នាខ្លះ ជាមួយកុសលចិត្តនៃខ្លួន ដូច្នោះហើយ វិបាកនៃកាមាវចរកុសលនោះ ទើបលោកមិនបានចែកឲ្យវិបាកស្របតាមកុសលឡើយ ។ ចំណែករូបាវចរវិបាកនេះ តែងស្របគ្នាជាមួយកុសលរបស់ខ្លួន ប្រៀបដូចជាស្រមោលទាំងឡាយ មានស្រមោលដំរីសេះ និងដើមឈើជាដើមតែងតែដូចដំរី សេះនិងដើមឈើជាដើមនោះ។

ម្យ៉ាងទៀតកាមាវចរកុសលតែងឲ្យវិបាកក្នុងកាលណាខ្លះ(មិនទៀងទាត់ ) ចំណែករូបាវចរកុសល តែងឲ្យវិបាកក្នុងភពទី២ តែម្យ៉ាងប៉ុណ្ណោះ ដោយហេតុនេះហើយ ទើបលោកចែកឲ្យស្របដូចកុសលរបស់ខ្លួន គឺ

១ **បឋមជ្ឈានកុសល** ឲ្យផលជាបឋមជ្ឈានវិបាក បដិសន្ធិក្នុងបឋមជ្ឈានភូមិ ។

២ **ទុតិយជ្ឈានកុសល** ឲ្យផលជាទុតិយជ្ឈានវិបាក បដិសន្ធិក្នុងទុតិយជ្ឈាន ភូមិ ។

៣ **តតិយជ្ឈានកុសល** ឲ្យផលជាតតិយជ្ឈានវិបាក បដិសន្ធិក្នុងតតិយជ្ឈាន ភូមិ ។

៤ **ចតុត្ថជ្ឈានកុសល** ឲ្យផលជាចតុត្ថជ្ឈានវិបាក បដិសន្ធិក្នុងចតុត្ថជ្ឈាន ភូមិ ។

៥ **បញ្ចមជ្ឈានកុសល** ឲ្យផលជាបញ្ចមជ្ឈានវិបាក បដិសន្ធិក្នុងបញ្ចមជ្ឈាន ភូមិ ។ បុគ្គលអ្នកបដិសន្ធិក្នុងរូបាវចរភូមិ ដោយរូបាវចរវិបាក

ចិត្តជារូបព្រហ្ម បុគ្គលនោះរមែងមានចក្ខុបសាទ សោតបសាទ តែមិនមាន ឃានបសាទ ជីវ្ហាបសាទ និងកាយបសាទ ខណៈដែលចក្ខុវិញ្ញាណឬសោតវិញ្ញាណរបស់ព្រហ្មនោះកើតឡើង គប្បីជ្រាបថា ចក្ខុវិញ្ញាណក្តីសោតវិញ្ញាណក្តី មិនមែនជាផលរបស់រូបាវចរកុសល ទាំង៥នោះទេ តែជាផលរបស់កាមាវចរកុសល ។

## រូបព្រហ្ម១៦

**១ បារិសជ្ជាភូមិ**

**២ បុរោហិតាភូមិ**

**៣ មហាព្រហ្មាភូមិ**

ព្រហ្មទាំង៣ភូមិនេះបដិសន្ធិដោយបឋមជ្ឈានវិបាកចិត្ត ។

**៤ បរិត្តាភាភូមិ**

**៥ អប្បមាណាភាភូមិ**

**៦ អាភស្សរាភូមិ**

ព្រហ្មទាំង៣ភូមិនេះ បដិសន្ធិដោយ ទុតិយជ្ឈានវិបាកចិត្ត (ជាចតុកន័យ) ឬតតិយជ្ឈានវិបាកជាបញ្ចកន័យ ។

**៧ បរិត្តាសុភាភូមិ**

**៨ អប្បមាណាសុភាភូមិ**

**៩ សុភកិណ្ហាភូមិ**

ទាំង៣ភូមិនេះ បដិសន្ធិដោយតតិយជ្ឈានវិបាកជាចតុកន័យ ។

**១០ វេហប្ផលាភូមិ** បដិសន្ធិដោយចតុត្ថជ្ឈានវិបាក ចតុកន័យ បញ្ច

មជ្ឈានវិបាកដោយបញ្ចកន័យ

១១ **អសញ្ញីសត្តភូមិ** មិនមានវិបាកចិត្ត ធ្វើតួនាទីបដិសន្ធិទេ ព្រហ្ម
នេះគឺបដិសន្ធិរូបប៉ុណ្ណោះ ។

១២ **អវិហាភូមិ**

១៣ **អតប្បាភូមិ**

១៤ **សុទស្សាភូមិ**

១៥ **សុទស្សីភូមិ**

១៦ **អកនិដ្ឋាភូមិ**

៥ភូមិនេះ ជាព្រហ្មជាន់សុទ្ធាវាស របស់ព្រះអនាគាមិបុគ្គល បដិសន្ធិដោយចតុត្ថជ្ឈានវិបាកចិត្ត ដោយចតុកន័យ ឬ បញ្ចមជ្ឈានវិបាកចិត្តដោយបញ្ចកន័យ ។

## អធិប្បាយព្រហ្មក្នុងព្រហ្មភូមិ

អ្នកបដិសន្ធិក្នុងព្រហ្មលោកមានសេចក្តីសុខប្រណិតជាងពួកទេវតា មានរូបកាយស្អាត មានសម្លេងពិរោះ ( ក្នុងទីនិកាយមហាវគ្គសំដែងថា )

### សម្លេងរបស់ព្រហ្មប្រកបដោយអង្គ៨គឺ

១ **វិសដ្ឋោ** មានសម្លេងពិរោះ

២ **វិញ្ញេយ្យោ** មានសម្លេងច្បាស់

៣ **មញ្ជូ** មានសម្លេងទន់ភ្លន់

៤ **សវនិយ្យោ** មានសម្លេងគួរចង់ស្តាប់

៥ **បិន្ទូ** មានសម្លេងមូល

៦ ***អវិសារី*** មានសម្លេងមិនញាប់ញ័រ

៧ ***គម្ភីរោ*** មានសម្លេងជ្រៅ

៨ ***និន្នាទី*** មានសំលេងឮរំពងខ្លាំង

*បណ្តាព្រហ្មដែលកើតក្នុងបឋមជ្ឈានភូមិនេះ មានមហាព្រហ្មជាធំ អាចបញ្ចេញពន្លឺរស្មីទៅបានឆ្ងាយ ព្រហ្មខ្លះបញ្ចេញពន្លឺរស្មីបានរហូតដល់ទៅ១០០០ចក្រវាឡ ព្រហ្មខ្លះបញ្ចេញទៅបានដល់រហូត២០០០ ចក្រវាឡខ្លះទៀតបាន៣០០០ ចក្រវាឡព្រោះកើតឡើងដោយវិបាក នៃឈានដែលប្រណិត មានអាយុ១មហាកប្ប ។ ប្រសិនបើ កើតដោយ វិបាកឈានថ្នាក់កណ្តាល ក៏មាន ឈ្មោះថា ព្រហ្មបុរោហិតា ( ព្រហ្មអ្នកជាទីប្រឹក្សា ) មានអាយុកន្លះមហាកប្ប ព្រហ្មបារិសជ្ជា មានអាយុ១ភាគ៣នៃមហាកប្ប ។ ព្រហ្មទាំង៣ពួកនេះ មានកាយផ្សេងគ្នាមាន សញ្ញាបដិសន្ធិតែមួយដូចគ្នា (**នានត្តកាយ ឯកត្តសញ្ញិនោ**) ដូចគ្នានឹងសត្វក្នុងអបាយភូមិ ។*

*ព្រហ្មដែលកើតក្នុងទុតិយជ្ឈានភូមិ មានអាភស្សរាព្រហ្មជាធំ កើតដោយវិបាកនៃទុតិយជ្ឈាន ឬតតិយជ្ឈាន ដែលប្រណិត មានរស្មីចេញពីសរីរៈ ដូចអណ្តាតភ្លើង មានអាយុ៨មហាកប្ប ។ វិបាកថ្នាក់កណ្តាល តែងកើតជាព្រហ្ម ឈ្មោះអប្បមាណាភាព្រហ្ម មានអាយុ៤មហាកប្ប ( មានតំណែងដូចនឹងបុរោហិតាព្រហ្ម )។វិបាកថ្នាក់ខ្សោយតែងកើតជាព្រហ្មឈ្មោះ បរិត្តាភាព្រហ្ម មានអាយុ២មហាកប្ប ( មានតំណែងដូចនឹងព្រហ្មឈ្មោះបារិសជ្ជា )។ព្រហ្មទាំង៣ពួកនេះមានកាយដូចគ្នាមានសញ្ញាផ្សេងគ្នាព្រោះសញ្ញាខ្លះមិនមានវិតក្កៈតែមានវិចារៈ សញ្ញាខ្លះមិនមានទាំងវិតក្កទាំងវិចារៈ*

ព្រហ្មដែលកើតក្នុងតតិយជ្ឈានភូមិ មានព្រហ្មឈ្មោះ សុភកិណ្ហាព្រហ្ម ជាធំកើតឡើង ដោយវិបាកនៃចតុត្ថជ្ឈានដែលប្រណិត មានរស្មីថ្លាស្អាត ដូចរស្មីដួងព្រះចន្ទ គឺមានរស្មីចេញពីសរីរៈ ជាផ្នាំងៗភ្លឺព្រោងព្រាត មានអាយុ៦មហាកប្ប ។ វិបាកថ្នាក់កណ្តាល កើតជាព្រហ្ម ឈ្មោះថា អប្បមាណសុភាព្រហ្ម មានអាយុ៣២មហាកប្ប (មានតំណែងដូចព្រហ្មបុរោហិតា) ។ វិបាកថ្នាក់ខ្សោយ កើតជាព្រហ្មឈ្មោះថា បរិត្តាសុភាព្រហ្ម មានអាយុ១៦មហាកប្ប (មានតំណែងដូចបារិសជ្ជាព្រហ្ម) ។

ព្រហ្មទាំង៣ពួកនេះ មានកាយដូចគ្នា មានសញ្ញាបដិសន្ធិតែមួយដូចគ្នា ។

ព្រហ្មដែលកើតក្នុងចតុត្ថជ្ឈានភូមិ មានឈ្មោះថា វេហប្ផលាព្រហ្ម កើតឡើងដោយវិបាកនៃបញ្ចមជ្ឈាន ដែលមានឯកគ្គតា និងឧបេក្ខាជាអង្គ ជាឈានមាំមួន មានផលសម្បូរណ៍ មិនញាប់ញ័រ តែងប្រព្រឹត្តតាមឈាន មិនដូចបឋមជ្ឈានភូមិ៣ ទុតិយជ្ឈានភូមិ៣ និងតតិយជ្ឈានភូមិ៣ ដែលប្រកបដោយសោមនស្សទេ ។ ព្រហ្មជាន់នេះនឹងមិនត្រូវវិនាសទៅដោយភ្លើង ដោយទឹក និងដោយខ្យល់ឡើយ តែងមានអាយុខេយ្យពេញ៥០០ មហាកប្ប ។

ចំណែកក្នុងសុទ្ធាវាសភូមិ៥ ដែលកើតក្នុងចតុត្ថជ្ឈានភូមិដែរ គឺ**អវិហា អតប្បា សុទស្សា សុទស្សី** និង**អកនិដ្ឋាភូមិ** នេះតាំងនៅ ក្នុងចំណែកវិវដ្តៈ ជាភូមិរស់នៅនៃព្រះអនាគាមិបុគ្គល តាំងនៅជាជាន់ៗ ឡើងទៅតាមលំដាប់នៃភូមិ មិនដូចភូមិដទៃៗ មានបឋមជ្ឈានភូមិជាដើមនោះទេ ។

***អវិហា*** *ប្រែថា មិនវិនាសចាកសម្បត្តិ ( មិនប្រាសចាកវិហារធម៌) ព្រហ្មនេះមានអាយុ១០០០មហាកប្ប ។*

***អតប្បា*** *ប្រែថា មិនក្តៅក្រហាយ (មានសេចក្តីស្ងប់ត្រជាក់) ព្រហ្មនេះមានអាយុ២០០០មហាកប្ប ។*

***សុទស្សា*** *ប្រែថាឃើញវត្ថុផ្សេងៗបានល្អ(ព្រោះ បរិបូរណ៍ដោយចក្ខុបសាទគឺចក្ខុទិព្វ ធម្មចក្ខុ បញ្ញាចក្ខុ ) ព្រហ្មនេះមានអាយុ៤០០០មហាកប្ប*

***សុទស្សី*** *ប្រែថាឃើញវត្ថុផ្សេងៗបានល្អក្រៃលែងជាងសុទស្សាព្រហ្ម ព្រហ្មនេះមានអាយុ៨០០០មហាកប្ប ។*

***អកនិដ្ឋា*** *ប្រែថា ជាព្រហ្មដែលមានគុណសម្បត្តិក្រៃលែងជាងព្រហ្មជាន់ទី១ ទី២ ទី៣ និងទី៤នៃសុទ្ធាវាសព្រហ្ម។ព្រហ្មនេះមានអាយុ១៦០០០មហាកប្ប ។*

*សុទ្ធាវាសភូមិ៥មិនមានរហូតគ្រប់កាលនោះទេ គឺមិនកើតឡើងក្នុងលោក ក្នុងពេលលង្វើគចាកព្រះពុទ្ធជាម្ចាស់ រហូតដល់១សែនកប្បខ្វះមួយអសង្ខេយ្យកប្បខ្វះ ។ កាលណាបើព្រះពុទ្ធជាម្ចាស់ ទ្រង់ឧប្បត្តិហើយនោះឯង សុទ្ធាវាស៥នេះទើបកើតឡើង ក្នុងដែនកំណត់វេលា ១៦០០០មហាកប្ប ។*

### ***ចំណែករូបាវចរវិបាកចិត្ត៥ដួងដោយន័យ១៤យ៉ាង***

**១ ន័យដោយជាតិ** *ជាវិបាកជាតិ*

**២ ន័យដោយភូមិ** *ជារូបភូមិ*

**៣ ន័យដោយវេទនា** *ដូចគ្នានឹងកុសលឈាន គឺបឋមជ្ឈាន ទុតិ-*

យជ្ឈាន តតិយជ្ឈានចតុត្ថជ្ឈានជាសោមនស្ស បញ្ចមជ្ឈានជាឧបេក្ខា។

៤ **ន័យដោយហេតុ** ជានហេតុ និងជា តិហេតុកចិត្ត

៥ **ន័យដោយសម្បយុត្ត** ជាញាណសម្បយុត្ត

៦ **ន័យដោយសង្ខារ** ជាសសង្ខារិកៈ

៧ **ន័យដោយសោភណៈ** ជារូបាវចរសោភណចិត្ត

៨ **ន័យដោយឈាន** ជាផលនៃឈាន

៩ **ន័យដោយលោកិយៈ** ជាលោកិយចិត្ត

១០ **ន័យដោយកិច្ច** មាន៣គឺ បដិសន្ធិកិច្ច ចុតិកិច្ច ភវង្គកិច្ច

១១ **ន័យដោយអារម្មណ៍** កុសលចិត្តមានអារម្មណ៍ណា ជាកម្មដ្ឋានវិបាកចិត្តក៏មានអារម្មណ៍នោះ

១២ **ន័យដោយទ្វារ** ដឹងអារម្មណ៍បានដោយមិនត្រូវអាស្រ័យទ្វារ(ជាទ្វារវិមុត្តិ)

១៣ **ន័យដោយវត្ថុ** អាស្រ័យហទយវត្ថុ

១៤ **ន័យដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

## ចប់រូបាវចរវិបាកចិត្ត៥ដួង

## រូបាវចរកិរិយាចិត្ត៥ដួង

បាលីរូបាវចរវិបាកក្តីបាលីរូបាវចរកិរិយាក្តីដូចគ្នានឹងរូបាវចរកុសលដែរ ផ្សេងគ្នាត្រង់រូបាវចរកិរិយាចិត្ត ជាកិរិយាចិត្តរបស់ព្រះអរហន្តប៉ុណ្ណោះ

## រូបាវចរកិរិយាចិត្ត៥ដួង

**១ វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតបឋមជ្ឈាន កិរិយាចិត្តំ**

បឋមជ្ឈានកិរិយាចិត្តកើតព្រមនឹង វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

២ **វិចារ បីតិ សុខេកគ្គតា សហិតទុតិយជ្ឈាន កិរិយាចិត្តំ** ទុតិយជ្ឈានកិរិយាចិត្តកើតព្រម នឹង វិចារៈ បីតិ សុខៈ ឯកគ្គតា ។

៣ **បីតិ សុខេកគ្គតា សហិតតតិយជ្ឈាន កិរិយាចិត្តំ** តតិយជ្ឈាន កិរិយាចិត្តកើតព្រម នឹង បីតិ សុខៈ ឯកគ្គតា

៤ **សុខេកគ្គតា សហិតចតុត្ថជ្ឈាន កិរិយាចិត្តំ** ចតុត្ថជ្ឈានកិរិយាចិត្តកើតព្រម នឹង សុខៈ ឯកគ្គតា ។

៥ **ឧបេក្ខេកគ្គតា សហិតបញ្ចមជ្ឈាន កិរិយាចិត្តំ** បញ្ចមជ្ឈានកិរិយាចិត្តកើតព្រម នឹង បីតិ ឯកគ្គតា ។

រូបាវចរកិរិយាចិត្ត ជារូបឈានចិត្តរបស់ព្រះខីណាស្រព គឺរូបាវចរឈានរបស់ព្រះខីណាស្រព ជាកិរិយា មិនមែនជាកុសល មិនមែនជាអកុសល មិនមែនជាកម្មវិបាក ជាទិដ្ឋធម្មសុខវិហារ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះ ។

### ចំណែករូបាវចរកិរិយាចិត្តដួងដោយន័យ១៤យ៉ាង

១ **ន័យដោយជាតិ** ជាកិរិយាជាតិ

២ **ន័យដោយភូមិ** ជារូបភូមិ (កើតបាន២២ភូមិ)

៣ **ន័យដោយវេទនា** ជាសោមនស្ស៤ ឧបេក្ខា១

៤ **ន័យដោយហេតុ** ជានហេតុ និងជាតិហេតុ

៥ **ន័យដោយសម្បយុត្ត** ជាញាណសម្បយុត្ត

៦ **ន័យដោយសង្ខារ** ជាសសង្ខារិកៈ

៧ **ន័យដោយសោភណៈ**ជារូបាវចរសោភណៈ

៨ **ន័យដោយឈាន** ជារូបាវចរឈាន

៩**ន័យដោយលោកិយៈ** ជាលោកិយចិត្តព្រោះមិនមាននិព្វាន ជាអារម្មណ៍

១០ **ន័យដោយកិច្ច** ធ្វើជវនកិច្ច

១១ **ន័យដោយអារម្មណ៍** មានធម្មារម្មណ៍ជាអារម្មណ៍

១២ **ន័យដោយទ្វារ** ដឹងអារម្មណ៍តាមមនោទ្វារប៉ុណ្ណោះ

១៣ **ន័យដោយវត្ថុ** កើតត្រង់ហទយវត្ថុ

១៤ **ន័យដោយវិញ្ញាណធាតុ**ជាមនោវិញ្ញាណធាតុ

**នីវរណធម៌៥**

**បញ្ចមេភិក្ខវេ នីវរណា អន្ធករណា អចក្ខុករណា អញ្ញាណករណា**

**បញ្ញានិរោធិយា វិឃាតបក្ខិយា អនិព្វានសំវត្តនិកា ។**

ម្នាលភិក្ខុទាំងឡាយ ក្នុងនីវរណៈ៥ប្រការនេះជាធម្មជាតិធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ជាហេតុរលត់ទៅនៃបញ្ញា ជាបក្សពួកនៃសេចក្ដីចង្អៀតចង្អល់ មិនមែនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

នីវរណៈធម៌៥គឺ **កាមច្ឆន្ទនីវរណៈព្យាបាទនីវរណៈថីនមិទ្ធនីវរណៈឧទ្ធច្ចកុក្កុច្ចនីវរណៈវិចិកិច្ឆានីវរណៈ**។

នីវរណៈធម៌ទាំង៥នេះ ជាធម្មជាតិធ្វើឲ្យខ្វាក់ធ្វើមិនឲ្យមានចក្ខុធ្វើមិនឲ្យដឹង ជាហេតុរលត់ទៅនៃបញ្ញា ជាបក្សពួកនៃសេចក្ដីចង្អៀតចង្អល់ មិនមែនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

## សេចក្ដីប្រៀបធៀបនៃនីវរណៈ

១ **កាមច្ឆន្ទនីវរណ** ប្រៀបដូចជាភាជនដាក់ទឹកដែលលាយពណ៌ផ្សេងៗ (មិនអាចឆ្លុះមើលមុខជាដើមបាន)

២ **ព្យាបាទនីវរណ** ប្រៀបដូចជាភាជនដាក់ទឹកដែលកំពុងតែពុះកញ្ជ្រោល

៣ **ថីនមិទ្ធនីវរណ** ប្រៀបដូចជាភាជនដាក់ទឹកដែលពេញទៅដោយសារាយ និងចក

៤ **ឧទ្ធច្ចកុក្កុច្ចនីវរណ** ប្រៀបដូចជាភាជនដាក់ទឹកដែលត្រូវខ្យល់ធ្វើឲ្យញ័ររំជួល

៥ **វិចិកិច្ឆានីវរណ** ប្រៀបដូចជាភាជនដាក់ទឹកដែលល្អក់មិនអាចឆ្លុះមើលមុខរបស់ខ្លួនបាន។

## សេចក្ដីប្រៀបធៀបម្យ៉ាងទៀត

- **កាមច្ឆន្ទនីវរណ** ប្រៀបដូចជាបុរស ជំពាក់បំណុលគេ
- **ព្យាបាទនីវរណ** ប្រៀបដូចជាបុរសមានជម្ងឺក្ដៅក្រហាយក្នុងខ្លួន
- **ថីនមិទ្ធនីវរណ** ប្រៀបដូចជាបុរស ជាប់គុកមិនមានសេរីភាព
- **ឧទ្ធច្ចកុក្កុច្ចនីវរណ** ប្រៀបដូចជាបុរសអ្នកបម្រើគេគឺមានសេចក្ដីក្ដៅក្រហាយជាច្រើនក្នុងខ្លួន
- **វិចិកិច្ឆានីវរណ** ប្រៀបដូចជាបុរស ដើរផ្លូវឆ្ងាយហើយបានជួប

ផ្លូវបែកជាពីរពាវែកចិត្តមិនប្រាកដថាដើរទៅផ្លូវណាមួយ ។

## អរូបាវចរចិត្ត១២ដួង

អរូបាវចរចិត្ត១២ដួងគឺ អរូបាវចរកុសល៤ដួង អរូបាវចរវិបាក៤ដួង អរូបាវចរកិរិយា៤ដួង

## អរូបាវចរកុសល៤ដួង

ពាក្យថា អរូបាវចរចិត្ត គឺជាចិត្តដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ នៃអរូបជ្ឈាន ។ ពាក្យថា អរូបឈាននោះ សំដៅដល់ឈានដែលមិនសំឡឹងនូវរូប ឬឈានដែលមិនមានរូបជាអារម្មណ៍ គឺបានដល់អារម្មណ៍ ៤ គឺអាកាស១ វិញ្ញាណ១ អាកិញ្ចញ្ញាយតនៈ១ សញ្ញា១

ពាក្យថាអរូបាវចរកុសល មានន័យថា កុសលកម្មដែលជាហេតុឲ្យទៅកើតក្នុងអរូបព្រហ្ម ។ ម្យ៉ាងទៀត ព្រោះកុសលនេះកើតឡើង ដោយអាស្រ័យអារម្មណ៍ដែលជាអរូប ។

## អរូបាវចរកុសល៤ដួង គឺ

១- **ឧបេក្ខេកគ្គតាសហិតំអាកាសានញ្ចាយនកុសលចិត្តំ** អរូបាវចរកុសលចិត្តដួងទី ១ កើតព្រមដោយ **ឧបេក្ខា** ឯកគ្គតា ជា **អាកាសានញ្ចាយតនកុសល**

២- **ឧបេក្ខេកគ្គតាសហិតំវិញ្ញាណញ្ចាយតន កុសលចិត្តំ** អរូបាវចរកុសលចិត្តដួងទី២ កើតព្រមដោយឧបេក្ខា ឯកគ្គតា ជា វិញ្ញាណញ្ចាយតនកុសល ។

៣- **ឧបេក្ខេកគ្គតាសហិតំអាកិញ្ចញ្ញាយតន កុសលចិត្តំ** អរូបាវចរ

ចិត្តដួងទី៣ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជាអាកិញ្ចញ្ញាយតនកុសល

**៤- ឧបេក្ខេកគ្គតាសហិតំ នេវសញ្ញានាសញ្ញាយតនកុសលចិត្តំ** អរូបាវចរចិត្តដួងទី៤ កើតព្រមដោយឧបេក្ខា **ឯកគ្គតា** ជានេវសញ្ញានា-សញ្ញាយតនកុសល ។

**អធិប្បាយអរូបជ្ឈាន៤ដួង**

១- **អាកាសានញ្ចាយតន** បែកចេញជា៣បទគឺ **អាកាស** + **អនញ្ច** + **អាយតន** = **អាកាសានញ្ចាយតន**

- **អាកាស** ប្រែថា ទីដែលទំនេរ សំដៅដល់ **កសិណុគ្ឃាដិមាកាស**

- **អនញ្ច** ប្រែថា រកទីបំផុតមិនមាន (ជាអនន្តៈ)

- **អាយតន** ប្រែថា ទីកើត

ឈានឈ្មោះថា **អាកាសានញ្ចាយតន** ព្រោះអត្ថថា មានអាកាសមិនមានទីបំផុត ជាទីកើតនៃកុសលចិត្ត ដែលសម្បយុត្តជាមួយ អាកាសានញ្ចាយតនៈ នោះ ឈ្មោះថា អាកាសានញ្ចាយតនកុសលចិត្ត ។

**អាកាសមាន៤**

១ **អជដាកាស** បានដល់អាកាសមេឃ

២ **បរិច្ឆន្នាកាស** បានដល់អាកាសកសិណ

៣ **កសិណុគ្ឃាដិមាកាស** បានដល់អាកាសដែលអាស្រ័យមកអំពីកសិណ៩ (វៀរអាកាសកសិណ)

៤ **បរិច្ឆេទាកាស** បានដល់អាកាសរូប

(អាកាសានញ្ចាយតនៈ សំដៅដល់ កសិណុគ្ឃាដិមាកាសប៉ុណ្ណោះ)

**ការចំរើនអាកាសានញ្ចាយតនឈាន**

ព្រះយោគាវចរ ដែលចំរើនអរូបឈានកម្មដ្ឋានឲ្យកន្លងនូវរូបឈាននោះ ដំបូងត្រូវមាន រូបាវចរបញ្ចមជ្ឈាន ព្រមទាំងវសី ៥ មានការស្ទាត់ជំនាញល្អហើយ ក៏ឃើញទោសរបស់រូបឈានផ្សេងៗ ដែលខ្លួនបានហើយនោះ ។ លោកមិនមែនត្រឹមតែឃើញទោសនៃរូបឈានប៉ុណ្ណោះទេ រមែងឃើញដល់ទោសនៃរូបកាយទៀតផងគឺលោកគិតថា មានរូបក៏ត្រូវមានទុក្ខទោស លំបាកកាយ មានការទទួលនូវអាជ្ញា និងរោគាព្យាធិផ្សេងៗ ជាដើម ប្រសិន មិនមានរូបរាងកាយទេ ទុក្ខផ្សេងៗ រោគផ្សេងៗ តាមផ្លូវកាយក៏មិនមាន ឯការដែលនឹងផុតចាករូបរាងកាយនោះទៅបាន ក៏ត្រូវអាស្រ័យការចំរើនឈានមិនមានរូប (អរូបឈាន) ជាអារម្មណ៍ ។

កាលព្រះយោគាវចរឃើញទោសនៃរូប និងវិធីដើម្បីចេញឲ្យផុតអំពីរូបយ៉ាងនេះហើយ ក៏ចូលរូបឈានទី៥ ដែលខ្លួនធ្លាប់បានហើយនោះ។ កាលចេញអំពីឈានទី៥ពិចារណាឃើញទោសនៃរូបកម្មដ្ឋាន ដែលជាអារម្មណ៍ហើយ ក៏ចូលឈាននោះ ផ្សាយពង្រីកនិមិត្ត (រូបកម្មដ្ឋាន)នោះ ឲ្យមិនមានទីបំផុត គឺផ្សាយចេញទៅបានដល់មួយចក្រវាឡជាដើម ។ ដោយការផ្សាយ ពង្រីកទៅនូវនិមិត្តនៃរូបកម្មដ្ឋានដែលជាអារម្មណ៍ ច្រើនដល់ត្រឹមណាៗ ក៏មិនមានទីបំផុត ក៏កាន់តែឃើញថា ត្រង់ដែលការផ្សាយនិមិត្តចេញទៅបាននោះ ក៏ព្រោះអាកាសមិនមានទីបំផុត អាកាសដែលល្ហល្ហេវ

នោះ មិនមានការកើត មិនមានការវិនាសរកទីបំផុតមិនមាន ។

កាលឃើញសភាពមិនមានទីបំផុតនៃអាកាស ក៏បើកសញ្ញា គឺមិនដាក់ចិត្តទៅក្នុងរូបនិមិត្តដែលជាអារម្មណ៍នោះ យកចិត្តទុកដាក់ចំពោះតែសភាពនៃអាកាសមិនមានទីបំផុត (អាកាសោ អនន្តោ) ក្នុងខណៈចិត្តគិតដល់អាកាសមិនមានទីបំផុត ពេលនោះនៅមានរូបនិមិត្តដែលពង្រីកផ្សាយទៅដែរ ទាំងឧបចារសមាធិ ក៏កើតឡើងជាលំដាប់ ។ កាលដែលឃើញដល់អាកាសមិនមានទីបំផុតរឿយៗទៅ អប្បនាសមាធិ ក៏កើតឡើង ដោយមានអាកាសដែលមិនមានទីបំផុតនេះជាទីតាំង ឲ្យកើតបឋមអរូបជ្ឈាន ហៅថាអាកាសានញ្ចាយតនកុសលចិត្ត ជាកសិណុគ្ឃាដិមាកាសបញ្ញត្តិ ដែលបានបើករូបកសិណចេញ ជាអារម្មណ៍ ។

## អរូបវិថី

អរូបវិថីមានពីរ **អាទិកម្មិកអរូបជ្ឈាន**របស់**មន្ទបុគ្គល** (បុគ្គលអ្នកបានសម្រេចធម៌យឺតយូរ)១ និងអាទិកម្មិកអរូបជ្ឈាន របស់តិក្ខបុគ្គល (បុគ្គ-លអ្នកសម្រេចធម៌លឿនរហ័ស)១

## អរូបឈានវិថីរបស់មន្ទបុគ្គល

១ ភវង្គចលន
២ ភវង្គុបច្ឆេទ } ( ចិត្តផុតវិថី )
៣ មនោទ្វារាវជ្ជន
**៤ បរិកម្មជវន**
**៥ ឧបចារជវន** } មហាកុសលឧបេក្ខាញាណសម្បយុត្ត២ដួង

៦ អនុលោមជវនៈ

៧ គោត្រភូជវនៈ

៨ បឋមអរូបជ្ឈានជវនៈ គឺអាកាសានញ្ចាយតនកុសលចិត្ត

០ ភវង្គបាត ចិត្តជាភវង្គ

## អាទិកម្មិកអរូបជ្ឈានវិថីរបស់តិក្ខបុគ្គល

១ ភវង្គចលនៈ
២ ភវង្គុបច្ឆេទ } ចិត្តផុតវិថី

៣ មនោទ្វារាវជ្ជនៈ

៤ ឧបចារជវនៈ
៥ អនុលោមជវនៈ } មហាកុសលឧបេក្ខាញាណសម្បយុត្ត២ដួង
៦ គោត្រភូជវនៈ

៧ បឋមអរូបជ្ឈានជវនៈ គឺអាកាសានញ្ចាយតនកុសលចិត្ត

០ ភវង្គបាត ចិត្តជាភវង្គ

## អធិប្បាយអប្បនាវិថី

ទី១ ភវង្គចលនៈ ទី២ ភវង្គុបច្ឆេទចិត្ត២ដួងនេះជាចិត្តផុតវិថីបាន ដល់វិបាកចិត្ត ដែលសម្បយុត្តដោយបញ្ញា ជាតិហេតុកវិបាកចិត្ត មាន អារម្មណ៍ដើមគឺ អារម្មណ៍មុនចុតិនៃជាតិមុន ។ ទី៣ មនោទ្វារាវជ្ជនៈ ជា អហេតុកកិរិយាចិត្ត ។ ទី៤ បរិកម្ម ទី៥ ឧបចារ ទី៦ អនុលោម ទី៧គោត្រ ភូ បានដល់ មហាកុសលឧបេក្ខាញាណសម្បយុត្ត២ដួងណាមួយ ទី៨បឋ មអរូបជ្ឈាន បានដល់ អាកាសានញ្ចាយតនកុសលចិត្ត ឈាននេះមានអា

កាសបញ្ញត្តិដែលបើកពីរូបាវចរបញ្ចមជ្ឈាន ជាអារម្មណ៍ ហៅថា កសិណុ-គ្ឃាដិមាកាសបញ្ញត្តិ ។

## វិញ្ញាណញ្ចាយតនចិត្ត

ពាក្យថា **វិញ្ញានញ្ចាយតន** ចែកចេញជា៣បទគឺ **វិញ្ញាណ+អានញ្ច+អាយតន=វិញ្ញានញ្ចាយតន**

**វិញ្ញាណ** ប្រែថា ចិត្តដឹងច្បាស់នូវអារម្មណ៍ **អនញ្ច** ប្រែថា មិនមានទីបំផុត **អាយតន** ប្រែថា ជាទីតាំង សរុបសេចក្តីមកដោយន័យ ថា ជាអាយតនៈមួយកន្លែង ដែលវិញ្ញាណមិនមានទីបំផុត ។

### ការចំរើនវិញ្ញាណញ្ចាយតនៈ

ព្រះយោគាវចរបុគ្គល កាលស្ទាត់ជំនាញ ក្នុងអាកាសានញ្ចាយតនឈានហើយ មានប្រាថ្នានឹងចំរើនអរូបជ្ឈានទីពីរ ត្រូវធ្វើវសីទាំង៥ឲ្យស្ទាត់ ហើយពិចារណាឃើញទោសរបស់អាកាសានញ្ចាយតនឈាន ឃើញសេចក្តីស្ងប់ប្រណិតរបស់វិញ្ញាណញ្ចាយតនឈានហើយក៏ចូលឈានទាញយកបឋមអរូបជ្ឈានជាអារម្មណ៍ ដោយបង្អោនដល់សភាពរបស់វិញ្ញាណ ដែលមានអាកាសមិនមានទីបំផុតជាអារម្មណ៍ ថា វិញ្ញាណមិនមានទីបំផុត (**វិញ្ញាណំ អនន្តំ**) រហូតដល់អរូបជ្ឈានទីពីរកើតឡើង មានអាកាសានញ្ចា-យតនចិត្ត ជាអារម្មណ៍ នេះឯងហៅថា វិញ្ញាណញ្ចាយតនឈាន ឬហៅថា ទុតិយអរូបជ្ឈានចិត្ត ។

### អប្បនាវិថីនៃវិញ្ញាណញ្ចាយតនៈ

១ភវង្គចលន
២ភវង្គុបច្ឆេទ } ចិត្តផុតវិថី
៣មនោទ្វារាវជ្ជន

៤បរិកម្មជវន
៥ឧបចារជវន } មហាកុសលឧបេក្ខាញាណសម្បយុត្ត២ដួង
៦អនុលោមជវន
៧គោត្រភូជវន

៨អរូបជ្ឈានជវន គឺវិញ្ញាណញ្ចាយតនកុសលចិត្ត

០ភវង្គបាត ចិត្តជាភវង្គ

ពាក្យថា **អាកិញ្ចញ្ញាយតន** បែកចេញជា៣បទ គឺ **ន + កិញ្ចន + អាយតន = អាកិញ្ចញ្ញាយតន**

**ន** ប្រែថា មិនមាន

**កិញ្ចន** ប្រែថាសេសសល់

**អាយតន** ប្រែថាជាទីតាំង

សរុបសេចក្ដីមកដោយន័យថា ជាអាយតនៈ មួយកន្លែងដែលវិញ្ញាណសូម្បីបន្តិចក៏មិនមាន ។

**ការចំរើនអាកិញ្ចញ្ញាយតនៈ**

ព្រះយោគាវចរ កាលបើប្រាថ្នានឹងចំរើនអរូបជ្ឈានទី៣ ត្រូវធ្វើវសីទាំង៥ឲ្យស្ទាត់ ក្នុងវិញ្ញាណញ្ចាយតនៈ ជាមុនសិនចេញអំពីឈាននោះ ហើយក៏ពិចារណាឃើញទោសរបស់**វិញ្ញាណញ្ចាយតន**ថា បើដាក់ការចូល

ឈានះនេះជានិច្ចហើយ ឈាននេះអាចវិនាសត្រឡប់ទៅតាំងនៅក្នុងអាកាសានញ្ចាយតនឈានវិញ ឯសមាធិដែលកើតពីវិញ្ញាណញ្ចាយតនឈាននេះ ក៏នៅគ្រោតគ្រាត មិនប្រណិតស្មើនឹងអាកិញ្ចញ្ញាយតនឈាន ទើបដាក់ចិត្តដល់សភាពមិនមានអ្វី របស់អរូបជ្ឈានទី១ជារម្មណ៍ ប្រៀបដូចជាសាលាដ៏ធំជាទីប្រជុំនៃព្រះសង្ឃធ្វើសង្ឃកម្ម ដែលជាអារម្មណ៍របស់អរូប-ជ្ឈានទី២នោះឥឡូវនេះ សង្ឃធ្វើកិច្ចស្រេចហើយក៏ចេញពីសាលាទាំងអស់អង្គដោយមិនមានសល់នៅក្នុងសាលានោះសូម្បីមួយអង្គចិត្តក៏បង្អោនទៅក្នុងសភាពមិនមានអ្វីទៀតឡើយ (**នត្ថិ កិញ្ចិ**) រហូតដល់អរូបជ្ឈានចិត្តនោះកើតឡើងដោយមាន នត្ថិភាវបញ្ញត្តិជាអារម្មណ៍ ។ អរូបជ្ឈាននេះឈ្មោះថា **អាកិញ្ចញ្ញាយតនឈាន ឬ តតិយអរូបជ្ឈាន ។**

អប្បនាវិថីរបស់ អាកិញ្ចញ្ញាយតនឈាន ដូចគ្នានឹងបឋមអរូបជ្ឈាន ឬ ទុតិយអរូបជ្ឈានដែរ ផ្សេងគ្នាតែត្រង់ពាក្យថា អាកិញ្ចញ្ញាយតនចិត្តប៉ុណ្ណោះ ។

## នេវសញ្ញានាសញ្ញាយតនៈ

ពាក្យថា នេវសញ្ញានាសញ្ញាយតន ចែកចេញជា៦បទគឺ **ន** + **ឯវ** + **សញ្ញា** + **ន** + **អសញ្ញា** + **អាយតន** = **នេវសញ្ញានាសញ្ញាយតន**

**ន** ប្រែថាមិនមែន

**ឯវ** ប្រែថានោះឯង

**សញ្ញា** ប្រែថាមានសញ្ញា

**អសញ្ញា** ប្រែថាមិនមានសញ្ញា

**អាយតន** ប្រែថាជាទីតាំង

សរុបសេចក្តីមកដោយន័យថា ជាអាយតនមួយកន្លែង ដែលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនព្រោះមិនមានសញ្ញាគ្រោតគ្រាត មានតែសញ្ញាល្អិតៗ នេវសញ្ញានាសញ្ញានោះឯង ជាអាយតនៈ ។

**ចំណែកអរូបាវចរចិត្ត១២ដួងដោយន័យ១៤**

១ **ន័យដោយជាតិ** ជាកុសលជាតិ៤ដួង ជាវិបាកជាតិ៤ដួង ជាកិរិយាជាតិ៤ដួង

២ **ន័យដោយភូមិ** ជារូបាវចរភូមិទាំង១២ដួង

៣ **ន័យដោយវេទនា** ជាឧបេក្ខាវេទនាទាំង១២ដួង

៤ **ន័យដោយហេតុ** ជានហេតុនិងជាតិហេតុកចិត្តទាំង១២ដួង

៥ **ន័យដោយសម្បយុត្ត** ជាញាណសម្បយុត្តទាំង១២ដួង

៦ **ន័យដោយសង្ខារ** ជាសសង្ខារិកៈ ទាំង១២ដួង

៧ **ន័យដោយសោភណៈ** ជាអរូបាវចរសោភណៈ ទាំង១២ដួង

៨ **ន័យដោយឈាន** ជាបញ្ចមជ្ឈាន (បញ្ចកន័យ) ទាំង១២ដួង

៩ **ន័យដោយលោកិយៈ** ជាលោកិយចិត្តទាំង១២ដួង

១០ **ន័យដោយកិច្ច** អរូបាវចរកុសល៤ និងអរូបាវចរកិរិយា៤ ធ្វើជវនកិច្ច អរូបាវចរវិបាក៤ដួង ធ្វើកិច្ច៣គឺ បដិសន្ធិ ភវង្គ ចុតិ

១១ **ន័យដោយអារម្មណ៍** មានធម្មារម្មណ៍ជាអារម្មណ៍ទាំង១២ដួង

១២ **ន័យដោយទ្វារ** អរូបាវចរកុសល៤ និងអរូបាវចរកិរិយា៤ ដឹងអារម្មណ៍តាមមនោទ្វារ ចំណែកអរូបាវចរវិបាក៤ដួង ដឹងអារម្មណ៍

ដោយមិនអាស្រ័យទ្វារ (ទ្វារវិមុត្តិ)

១៣ **ន័យដោយវត្ថុ** អរូបាវចរកុសល៤ អរូបាវចរកិរិយា៤កើតក្នុងបញ្ចវោការភូមិ អាស្រ័យហទយវត្ថុ បើកើតក្នុងចតុវោការភូមិ មិនបាច់អាស្រ័យហទយវត្ថុទេ ។

១៤ **ន័យដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុទាំង១២ដួង

ចប់អរូបាវចរចិត្ត១២ដួង

## លោកុត្តរសោភណចិត្ត៨ដួង

ពាក្យថា **លោកុត្តរ** បែកជា២បទគឺ **លោក+ឧត្តរ =លោកុត្តរ** ប្រែថា ផុតលោក ឬលើពីលោក ។

ពាក្យថា **លោកុត្តរចិត្ត** គឺចិត្តដែលលើពីលោកឬផុតលោកនោះមានន័យថា ជាចិត្តដែលមានអារម្មណ៍ឡើងផុតពី សភាវធម៌មាននៅក្នុងលោក ឬថា ជាចិត្តដែលមានអំណាចទទួលអារម្មណ៍សភាវធម៌ក្រៅពីលោកឬផុតពីលោកបាន អារម្មណ៍នោះ គឺបានដល់ព្រះនិព្វាន ។

ក្នុងចិត្ត៨៩ដួង ចិត្តដែលអាចទទួលព្រះនិព្វានជាអារម្មណ៍បានប្រាកដ មានតែ៨ដួងប៉ុណ្ណោះ ក្រៅពីនោះសូម្បីមានចិត្តខ្លះនឹងទទួលអារម្មណ៍ព្រះនិព្វានបានក៏មិនប្រាកដ ដូច្នោះទើបហៅចិត្ត៨ដួងនោះថាលោកុត្តរចិត្ត

ក្នុងលោកុត្តរចិត្ត៨ដួងនេះ បែកចេញជាពីរប្រភេទគឺ មគ្គចិត្ត៤ដួង ឈ្មោះថា លោកុត្តរកុសលចិត្ត មួយប្រភេទ និង ផលចិត្ត៤ដួង ឈ្មោះថា លោកុត្តរវិបាកចិត្ត មួយប្រភេទ តែមិនមានលោកុត្តរកិរិយាចិត្តឡើយ ។

## លោកុត្តរកុសលចិត្ត៤ដួង

**សោតាបត្តិមគ្គចិត្តំ      សកទាគាមិមគ្គចិត្តំ**

**អនាគាមិមគ្គចិត្តំ      អរហត្តមគ្គចិត្តញ្ចេតិ**

**ឥមានិ ចត្តារិបិ លោកុត្តរកុសលចិត្តានិ នាម ។**

ប្រែថា សោតាបត្តិមគ្គចិត្ត១ដួង      សកទាគាមិមគ្គចិត្ត១ដួង

អនាគាមិមគ្គចិត្ត១ដួង      អរហត្តមគ្គចិត្ត១ដួង

ចិត្តទាំង៤ដួងនេះ ឈ្មោះថា លោកុត្តរកុសលចិត្ត ។

**សោតាបត្តិមគ្គចិត្ត**

ពាក្យថា សោតាបត្តិមគ្គចិត្ត គឺ**សោត+អាបត្តិ+មគ្គ+ចិត្ត=សោតាបត្តិមគ្គចិត្ត** ។

**សោត** ប្រែថា ក្រសែ គឺថា អរិយមគ្គមានអង្គ៨បណ្ឌិតហៅថា**សោត** ដោយហូរតម្រង់ទៅ គឺចូលកាន់ព្រះនិព្វាន  ឬដូចជាក្រសែទឹក ដោយការហូរទៅកាន់សមុទ្ទ គឺព្រះនិព្វាន ។

**អាបត្តិ** ប្រែថា ការដល់ហើយ គឺការសម្រេចតាំងពីខាងដើម ជាការសេពគ្រាដំបូងនូវ សោតនោះ ។

**មគ្គ** ដោយអត្ថថា ការស្វែងរកព្រះនិព្វាន ឬអ្នកការព្រះនិព្វានស្វែងរក ឬដោយអត្ថថា ការទៅសម្លាប់កិលេសទាំងឡាយ ។

ចិត្តដែលសម្បយុត្តជាមួយមគ្គនោះ ឈ្មោះថា **មគ្គចិត្ត** ។

**មគ្គចិត្ត** ដែលបានសម្រេចក្រសែ គ្រាដំបូងឈ្មោះថា **សោតាបត្តិមគ្គចិត្ត** បានដល់មគ្គចិត្តរបស់ព្រះអរិយបុគ្គល  ដំបូងដែលមានបដិសន្ធិទៀតយ៉ាងច្រើន៧ជាតិក្នុងលោកនេះ ។

## សកទាគាមិមគ្គចិត្ត

ពាក្យថា **សកទាគាមិមគ្គចិត្ត សក៏+អាគាមី+មគ្គ+ចិត្ត=សកទាគាមិមគ្គចិត្ត។**

សក៏ ប្រែថា មួយដង មួយវារៈ

អាគាមី ប្រែថា ត្រឡប់មក

សកទាគាមិមគ្គចិត្ត គឺមគ្គចិត្តដែលញ៉ាំងឲ្យបុគ្គលត្រឡប់មក កាន់កាមលោកម្ដងទៀត បានដល់ចិត្តរបស់ព្រះអរិយបុគ្គលទី២ ដែលត្រឡប់មកបដិសន្ធិក្នុងកាមភូមិតែម្ដងប៉ុណ្ណោះ។

## អនាគាមិមគ្គចិត្ត

ពាក្យថា **អនាគាមិមគ្គចិត្តគឺអន+អាគាមី+មគ្គ+ចិត្ត=អនាគាមិមគ្គចិត្ត**

**អនាគាមិមគ្គចិត្ត** គឺមគ្គចិត្តដែលញ៉ាំង ឲ្យបុគ្គលមិនចាំបាច់ត្រឡប់មកកាន់កាមលោក សូម្បីតែម្ដងទៀតនោះទេ បានដល់មគ្គចិត្ត របស់ព្រះអរិយបុគ្គលថ្នាក់ទី៣ ដែលមិនត្រូវមកបដិសន្ធិក្នុងកាមលោក។

## អរហត្តមគ្គចិត្ត

ពាក្យថា **អរហត្តមគ្គចិត្ត** គឺ **អរហត្ត+មគ្គ+ចិត្ត=អរហត្តមគ្គចិត្ត**

ឈ្មោះថា ព្រះអរហន្ត ដោយអត្ថថា គួរដល់ការបូជាដ៏វិសេសព្រោះភាពជាព្រះទក្ខិណេយ្យបុគ្គល ដ៏កំពូល ។ ម្យ៉ាងទៀតឈ្មោះថា **អរហន្ត**

ដោយអត្ថថា **កាំ** (កាំកង់ដែលវិលទៅ) គឺកិលេស ឬកិលេសដែលជាកាំនៃសង្សារចក្រ ត្រូវលោក កាច់បំបាក់អស់ហើយ។ ម្យ៉ាងទៀត ឈ្មោះថា **អរ-**

**ហន្ត** ព្រោះមិនមានការត្រឡប់មកក្នុងការធ្វើបាបកម្មទេ បានដល់ព្រះអរិយបុគ្គលថ្នាក់ទី៤ ។ ភាវៈនៃបុគ្គលទី៤នោះ ឈ្មោះថា **អរហត្ត** ។ ពាក្យថា **អរហត្ត** នោះជាឈ្មោះ នៃផលទី៤។ មគ្គជាហេតុនៃព្រះអរហត្តនោះឈ្មោះថា **អរហត្តមគ្គ** ។ ចិត្តដែលសម្បយុត្តដោយអរហត្តមគ្គនោះ ឈ្មោះថា អរហត្តមគ្គចិត្ត ។

ក្នុងមគ្គ៤ដួងនោះ ចាត់ជាលោកុត្តរកុសល

ពាក្យថា លោកុត្តរកុសលនេះ ព្រោះជាកុសលដែលធ្វើឲ្យឆ្លងផុតចាកលោក៣ មានកាមលោក១ រូបលោក១ អរូបលោក១ ។

**កាមលោក** បានដល់ កាមភូមិ១១ជាន់

**រូបលោក** បានដល់ រូបភូមិ ១៦ជាន់

**អរូបលោក** បានដល់ អរូបភូមិ៤ភូមិ (រួមជា៣១ភូមិ ) ។

ន័យម្យ៉ាងទៀត ពាក្យថាលោកុត្តរកុសលនេះព្រោះជាកុសលដែលធ្វើឲ្យឆ្លងផុតពីបុថុជ្ជន ទៅជា អរិយបុគ្គល ។

ន័យម្យ៉ាងទៀត ពាក្យថាលោកុត្តរកុសលនេះព្រោះជាកុសលដែលកើតឡើង មានព្រះនិព្វានជាលោកុត្តរធម៌ ជាអារម្មណ៍ ។

ន័យម្យ៉ាងទៀត ពាក្យថាលោកុត្តរកុសលនេះព្រោះជាកុសលដែលមានអំណាចផុតលើស ពីកុសលជាលោកិយៈ ទាំងឡាយ រំលត់អកុសលឲ្យដាច់ជាសមុច្ឆេទបាន ។

**ន័យទី១** ដែលហៅថា ឆ្លងផុតលោកនោះគឺ មគ្គចិត្តដួងទី១ ហៅថា **បឋមមគ្គ** គឺ សោតាបត្តិមគ្គចិត្ត និងមគ្គចិត្តដួងទី២ ហៅថា ទុតិយមគ្គគឺ

សកទាគាមិមគ្គចិត្ត ចិត្ត២ដួងនេះធ្វើឲ្យផុតពីកាមលោក គឺអបាយភូមិ៤ ។ មគ្គចិត្តដួងទី៣ ហៅថា តតិយមគ្គចិត្ត គឺអនាគាមិមគ្គចិត្ត ចិត្ត១ដួងនេះធ្វើឲ្យផុតពីកាមលោកទាំង១១ភូមិ ។ មគ្គចិត្តដួងទី៤ ហៅថា ចតុត្ថមគ្គចិត្ត ចិត្ត១ដួងនេះធ្វើឲ្យផុតពីលោកទាំងអស់ (៣១ភូមិ) ។

**ន័យទី២** ដែលហៅថា ឆ្លងផុតពីបុថុជ្ជនទៅជាអរិយបុគ្គល គឺ

មគ្គចិត្តដួងទី១ ធ្វើទៅជាព្រះសោតាបន្នបុគ្គល មគ្គចិត្តដួងទី២ ធ្វើធ្វើឲ្យទៅជា ព្រះសកទាគាមិបុគ្គល មគ្គចិត្តដួងទី៣ ធ្វើឲ្យទៅជាព្រះអនាគាមីបុគ្គល និងមគ្គចិត្តដួងទី៤ ធ្វើឲ្យទៅជាព្រះអរហន្ត ។

**ន័យទី៣** ដែលថា មានព្រះនិព្វានជាអារម្មណ៍ គឺព្រះនិព្វានជាលោកុត្តរធម៌ ហើយលោកុត្តរកុសលទាំង៤ដួងនេះ ដែលជាបច្ច័យកើតឡើងបាន ក៏ដោយព្រះនិព្វានជាអារម្មណប្បច្ច័យ ទើបកើតឡើង ។

**ន័យទី៤** ដែលហៅថា រំលត់អកុសលឲ្យដាច់ជាសមុច្ឆេទបាន ក៏គឺដោយហេតុមានព្រះនិព្វាន ជាអារម្មណ៍នោះឯង ។

លោកុត្តរកុសល ពោលគឺ មគ្គចិត្ត៤ដួង តាមសេចក្តីផ្សេងគ្នានៃការប្រកបរបស់ **អដ្ឋង្គិកមគ្គ** មានសោតាបត្តិមគ្គជាដើម គឺដោយអំណាចនៃការលះសំយោជនៈបាន ។ ការដែលលះ សំយោជនៈបានផ្សេងៗគ្នា ក៏ព្រោះឥន្ទ្រិយ៍៥ មានសទ្ធាជាដើម មានកម្លាំងផ្សេងៗគ្នា គឺឥន្ទ្រិយ៍៥របស់ សោតាបត្តិមគ្គ មិនចាស់ក្លា របស់សកទាគាមិមគ្គចាស់ក្លា របស់អនាគាមិមគ្គចាស់ក្លាជាង របស់អរហត្តមគ្គចាស់ក្លាជាទីបំផុត នោះឯង ។

សួរថា ការប្រហារកិលេសទាំងនោះ តើលោកុត្តរកុសល ប្រហារកិ-

លេសជាអតីតៈ ឬកិលេសជាអនាគត ឬថា កិលេសជាបច្ចុប្បន្ន ?

ឆ្លើយថា ការប្រហារបង់ របស់អរិយមគ្គនោះនឹងថាប្រហារក្នុងកាលណាមួយបណ្តាកាលទាំង៣នោះ ក៏មិនមាន ព្រោះកិលេសជាអតីតៈ បានរលត់ មុនទៅហើយ ចំណែកកិលេសអនាគត ក៏មិនទាន់កើតឡើង ដែរ ឯចំណែកកិលេសបច្ចុប្បន្ន ក៏មិនមានប្រាកដក្នុងពេលនោះមានប្រាកដ តែលោកុត្តរកុសលប៉ុណ្ណោះ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ការប្រហារកិលេសនោះគឺថាតាំងអំពីមគ្គចិត្តកើតប្រាកដឡើង កិលេសដែលនឹង ប្រាកដទៀតក៏មិនមានឱកាសឡើយ គឺរមែងមិនប្រាកដដោយពិត មានសេចក្តីថាអរិយមគ្គកាត់ផ្តាច់បង់នូវ ឬសគល់នូវពូជរបស់កិលេសវដ្តៈមិនឲ្យមានតទៅទៀតបាន ឧបមាដូចជាដើមឈើមានផ្លែ ដែលគេបេះអស់ហើយ មានបុរសម្នាក់មកកាត់ផ្តាច់ឫសកែវនៃដើមឈើនោះ សូម្បីថា បើដើមឈើនោះនៅរស់ក៏ដោយក៏មិនអាចឲ្យផលទៀតបានទេ ។ ក្នុងរឿងនេះ ការកាត់ដើមឈើនៃបុរសនោះនឹងថាប្រហារផលផ្លែក្នុងអតីតៈ ក៏មិនមែនព្រោះផលក្នុងអតីតៈនោះ អ្នកស្រុកបេះអស់ហើយ នឹងថា ប្រហារផលក្នុង អនាគត ក៏មិនមែន ព្រោះផលក្នុងអនាគតនោះមិនទាន់ប្រកដឡើងឡើយទាំងថា ប្រហារផលក្នុងបច្ចុប្បន្ននោះ ក៏មិនមែនដែរ ព្រោះថាផលក្នុងបច្ចុប្បន្ននេះមិនមានយ៉ាងណា ការប្រហារកិលេសរបស់អរិយមគ្គ ក៏យ៉ាងនោះដែរ គឺពោលដោយកាលទាំង៣មិនបាន គ្រាន់តែថា កិលេសក្នុងកាលជាអនាគតនោះ រមែងមិនប្រាកដទៀតដោយពិត ។

## អកុសល៩កង

អកុសលធម៌ គឺបាបធម៌ដែលព្រះអរិយបុគ្គលទាំងឡាយលោកលះបង់ អកុសលធម៌នោះ មាន៩ប្រភេទ គឺ

**អាសវៈ៤ ឱឃៈ៤ យោគៈ៤ គន្ថៈ៤ ឧបាទានៈ៤**

**នីវរណៈ៥ អនុស័យ៧ សំយោជនៈ១០ កិលេស១០**

**អាសវៈ៤**

ធម៌ដែលឈ្មោះថា **អាសវ** ព្រោះអត្ថថាហូរទៅ ឬជាគ្រឿងត្រាំទុកយ៉ាងយូរ អាសវៈនោះ មាន៤គឺ

១ **កាមាសវ** ធម្មជាតិដែលជាគ្រឿងត្រាំ គឺ កាម បានដល់កាមភព

២ **ភវាសវ** ធម្មជាតិដែលជាគ្រឿងត្រាំ នៅក្នុងរូបភព អរូបភព ឬនៅក្នុងរូបជ្ឈាន និងអរូបជ្ឈាន

៣ **ទិដ្ឋាសវ** ធម្មជាតិដែលជាគ្រឿងត្រាំ គឺ មិច្ឆាទិដ្ឋិ (សេចក្តីយល់ឃើញខុស)

៤ **អវិជ្ជាសវ** ធម្មជាតិដែលជាគ្រឿងត្រាំ គឺ សេចក្តីល្ងង់

**ឱឃៈ៤**

ធម៌ដែលឈ្មោះថា **ឱឃ** ព្រោះអត្ថថា ត្រជាប គឺញ៉ាំងសត្វមានកិលេសឲ្យលិចលង់ចុះ ក្នុងអន្លង់ វដ្តៈ ឱឃៈនោះមាន៤ គឺ

១ **កាមោឃ** ធម្មជាតិជាគ្រឿងធ្វើសត្វឲ្យលិចចុះ ក្នុងអន្លង់ គឺកាមគុណ ។

២ **ភវោឃ** ធម្មជាតិជាគ្រឿងធ្វើសត្វឲ្យលិចចុះ ក្នុងអន្លង់ គឺរូបភព និងអរូបភព ។

៣ **ទិដ្ឋោឃ** ធម្មជាតិជាគ្រឿងធ្វើសត្វឲ្យលិចចុះ ក្នុងអន្ទង់ គឺ មិច្ឆាទិដ្ឋិ (សេចក្តីយល់ឃើញខុស) ។

៤ **អវិជ្ជោឃ** ធម្មជាតិជាគ្រឿងធ្វើសត្វឲ្យលិចចុះ ក្នុងអន្ទង់ គឺ អវិជ្ជា (សេចក្តីល្ងិតល្ងង់) ។

## យោគៈ៤

ធម្មជាតិណា ប្រកបសត្វឲ្យនៅក្នុងវដ្តទុក្ខ ធម្មជាតិនោះឈ្មោះថា **យោគ** ក៏យោគធម៌នោះ មាន៤គឺ

១ **កាមយោគ** ធម្មជាតិដែលប្រកបសត្វឲ្យជាប់ស្អិត នៅក្នុងកាមគុណ ។

២ **ភវយោគ** ធម្មជាតិដែលប្រកបសត្វឲ្យជាប់ជំពាក់ស្អិតនៅក្នុងភព (រូបភព និងអរូបភព) ។

៣ **ទិដ្ឋិយោគ** ធម្មជាតិដែលប្រកបសត្វឲ្យជាប់ស្អិតនៅក្នុងទិដ្ឋិ គឺ សេចក្តីយល់ឃើញខុស ។

៤ **អវិជ្ជាយោគ** ធម្មជាតិដែលប្រកបសត្វឲ្យជាប់ស្អិតនៅក្នុង អវិជ្ជា គឺ សេចក្តីល្ងង់ខ្លៅ ។

## គន្ថៈ៤

ធម្មជាតិណា ដែលជាគ្រឿងចងសត្វឲ្យ នៅក្នុងភព ធម្មជាតិនោះឈ្មោះថា **គន្ថ** ក៏ធម៌ឈ្មោះថា គន្ថៈនោះ មាន៤ គឺ

១ **អភិជ្ឈាកាយគន្ថ** ធម្មជាតិដែលជាគ្រឿងចង នាមកាយរូបកាយឲ្យនៅក្នុងអារម្មណ៍ គឺ កាមារម្មណ៍ ។

២ **ព្យាបាទកាយគន្ថ** ធម្មជាតិដែលជាគ្រឿងចង នាមកាយរូបកាយឲ្យនៅក្នុងសេចក្តីក្រោធ ។

៣ **សីលព្វតបរាមាសកាយគន្ថ** ធម្មជាតិដែលជាគ្រឿង ចងនាមកាយរូបកាយ ឲ្យនៅក្នុងការប្រព្រឹត្តបដិបត្តិខុស ។

៤ **ឥទំសច្ចាភិនិវេសកាយគន្ថ** ធម្មជាតិដែលជាគ្រឿងចង នាមកាយរូបកាយ ឲ្យនៅក្នុងការប្រកាន់ខុស ហើយយល់ថាត្រូវ ។

## ឧបាទាន៤

ធម្មជាតិណា រមែងប្រកាន់មាំ ក្នុងអារម្មណ៍ ធម្មជាតិនោះឈ្មោះថាឧបាទាន ក៏ធម៌ឈ្មោះថា ឧបាទាននោះមាន៤ គឺ

១ **កាមុបាទាន** ធម្មជាតិដែលប្រកាន់មាំក្នុងកាម

២ **ទិដ្ឋុបាទាន** ធម្មជាតិដែលប្រកាន់ខុស(ការប្រកាន់ខុស)

៣ **សីលព្វតុបាទាន** ធម្មជាតិដែលប្រកាន់ក្នុងការប្រព្រឹត្ត បដិបត្តិខុស ។

៤ **អត្តវាទុបាទាន** ធម្មជាតិដែលប្រកាន់ក្នុងរូបក្ខន្ធជាដើមថា ជារបស់ខ្លួន ។

## នីវរណៈ៥

ធម្មជាតិណាជាគ្រឿងរារាំងកុសលផ្សេងៗមិនឲ្យកើតឡើងធម្មជាតិនោះ ឈ្មោះថា **នីវរណៈ** ក៏នីវរណធម៌ នោះមាន៥គឺ

១ **កាមច្ឆន្ទនីវរណ** ធម្មជាតិដែលជាគ្រឿងរារាំង គឺកាម (សេចក្តីប្រាថ្នាក្នុងរូបជាដើម ។

២ **ព្យាបាទនីវរណៈ** ធម្មជាតិដែលជាគ្រឿងរាំងគឺ **ព្យាបាទ** ។

៣ **ថីនមិទ្ធនីវរណៈ** ធម្មជាតិដែលជាគ្រឿងរាំង គឺ**ថីនមិទ្ធ** (សភាពនៃការងងុយងោកងក់) ។

៤ **ឧទ្ធច្ចកុក្កុច្ចនីវរណៈ** ធម្មជាតិដែលជាគ្រឿងរាំង គឺ **ឧទ្ធច្ចកុក្កុច្ច** (សេចក្តីរាយមាយ និងសេចក្តីក្តៅក្រហាយស្តាយក្រោយ) ។

៥ **វិចិកិច្ឆានីវរណៈ** ធម្មជាតិដែលជាគ្រឿងរាំង គឺ **វិចិកិច្ឆា** (សេចក្តីសង្ស័យ) ។

## អនុស័យ៧

ធម្មជាតិដែលដេកសម្ងំ ដំល្អិត នៅក្នុងសន្តានរបស់ ពពួកសត្វ ទាំងឡាយ ធម្មជាតិនោះ ឈ្មោះថា អនុស័យ ក៏ធម៌ឈ្មោះថាអនុស័យ នោះមាន៧ គឺ

១ **កាមរាគានុស័យ** ធម្មជាតិដែលដេកសម្ងំ ដំល្អិត នៅក្នុងសន្តានរបស់ពពួកសត្វគឺ (កាមរាគៈ) ។

២ **ភវរាគានុស័យ** ធម្មជាតិដែលដេកសម្ងំ ដំល្អិត នៅក្នុងសន្តានរបស់ពពួកសត្វគឺ សេចក្តីត្រេកអរក្នុងភព ។

៣ **បដិឃានុស័យ** ធម្មជាតិដែលដេកសម្ងំ ដំល្អិត នៅក្នុងសន្តានរបស់ពពួកសត្វគឺ បដិឃៈ សេចក្តីថ្នាំងថ្នាក់ ។

៤ **មានានុស័យ** ធម្មជាតិដែលដេកសម្ងំ ដំល្អិត នៅក្នុងសន្តានរបស់ពពួកសត្វគឺ មានៈ (ការលើកតម្កើងខ្លួន) ។

៥ **ទិដ្ឋានុស័យ** ធម្មជាតិដែលដេកសម្ងំ ដំល្អិត នៅក្នុងសន្តាន របស់

ពពួកសត្វគឺ ទិដ្ឋិ (ការយល់ឃើញខុស) ។

៦ **វិចិកិច្ឆានុស័យ** ធម្មជាតិដែលដេកសម្ងំ ដ៏ល្អិត នៅក្នុងសន្តាន របស់ពពួកសត្វគឺ វិចិកិច្ឆា (សេចក្ដីសង្ស័យ)

៧ **អវិជ្ជានុស័យ** ធម្មជាតិដែលដេកសម្ងំ ដ៏ល្អិត នៅក្នុងសន្តាន របស់ពពួកសត្វគឺ អវិជ្ជា (សេចក្ដីល្ងង់) ។

## សំយោជនៈ១០

ធម្មជាតិណា ជាគ្រឿងរួបរឹតសត្វទុកក្នុងវដ្ដៈធម្មជាតិនោះឈ្មោះថា សំយោជន ក៏ធម៌ឈ្មោះថា សំយោជនៈ នោះមាន១០ គឺ

១ កាមរាគសំយោជន សេចក្ដីរួបរឹត គឺ កាម

២ បដិឃសំយោជន សេចក្ដីរួបរឹត គឺ បដិឃៈ

៣ ទិដ្ឋិសំយោជន សេចក្ដីរួបរឹត គឺ ទិដ្ឋិ

៤ សីលព្វតុបរាមាស សំយោជន សេចក្ដីរួបរឹត គឺ ការស្ទាប អង្អែលវត្តបដិបត្តិខុស

៥ វិចិកិច្ឆាសំយោជន សេចក្ដីរួបរឹត គឺការសង្ស័យ (សំយោជនៈទាំង ៥នេះឈ្មោះថា ឱរម្ភាគិយសំយោជន គឺ សំយោជនៈថ្នាក់ទាប)

៦ រូបរាគសំយោជន សេចក្ដីរួបរឹត នៅក្នុងរូបភព

៧ អរូបរាគសំយោជន សេចក្ដីរួបរឹត នៅក្នុងអរូបភព

៨ មានសំយោជន សេចក្ដីរួបរឹត គឺ មានៈ

៩ ឧទ្ធច្ចសំយោជន សេចក្ដីរួបរឹត គឺ ការរាយមាយ

១០ អវិជ្ជាសំយោជន សេចក្តីវិបរីត គឺ អវិជ្ជា ( សេចក្តី ល្ងង់ខ្លៅ ) (ទាំង៥នេះជា ឧទ្ធម្ភាគិយសំយោជន គឺ សំយោជនថ្នាក់ខ្ពស់)

កិលេស១០

ធម្មជាតិណា ដែលសៅហ្មង ធម្មជាតិនោះឈ្មោះថាកិលេស ក៏ធម៌ឈ្មោះថា កិលេសនោះ មាន១០ គឺ

១ លោភ សេចក្តីជាប់ជំពាក់

២ ទោស សេចក្តី ក្រោធ

៣ មោហ សេចក្តីវង្វេង

៤ មាន សេចក្តី លើកតម្កើងខ្លួន

៥ ទិដ្ឋិ សេចក្តីយល់ឃើញខុស

៦ វិចិកិច្ឆា សេចក្តីសង្ស័យ

៧ ថីន សេចក្តី ក្រាញរួញរា

៨ ឧទ្ធច្ច សេចក្តី រាយមាយ

៩ អហិរិក សេចក្តី មិនខ្មាសបាប

១០ អនោត្តប្ប សេចក្តី មិនខ្លើម មិនខ្លាចបាប

## មគ្គចិត្តលះបង់អកុសល៩កង

១ សោតាបត្តិមគ្គ លះបង់ទិដ្ឋាសវៈ ១ ទិដ្ឋោឃៈ ១ ទិដ្ឋិយោគៈ១ សីលព្វត្តបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ១ ទិដ្ឋុបាទាន១ អត្តវាទុបាទាន១ សីលព្វតុបាទាន១ វិចិកិច្ឆានីវរណៈ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ

(ដែលគ្រោតគ្រាត)១ ទិដ្ឋានុស័យ១ វិចិកិច្ឆានុស័យ១ ទិដ្ឋិសំយោជនៈ១ វិចិកិច្ឆាសំយោជនៈ ១ សីលព្វត្តបរាមាសសំយោជនៈ១ឥស្សាសំយោជនៈ ១ មច្ឆរិយសំយោជនៈ១ មិច្ឆាទិដ្ឋិកិលេស១និងលះបង់ វិចិកិច្ឆាកិលេស១ ។

ម្យ៉ាងទៀតធម៌ណា ដែលជាប់ទាក់ទងដោយ សភាវៈ ជា សក្កាយទិដ្ឋិ វិចិកិច្ឆានិងសីលព្វត្តបរាមាសៈគឺសោតាបត្តិមគ្គបានលះបង់អស់ហើយ ។

២ សកទាគាមិមគ្គ លះបង់អកុសលធម៌គ្រោតគ្រាត ដែលសល់អំពីបឋមមគ្គចិត្ត ឲ្យស្រាលស្តើង ។

៣ អនាគាមិមគ្គចិត្ត លះបង់កាមាសវៈ ១ កាមោឃៈ ១ កាមយោគៈ ១ ព្យាបាទកាយគន្ថៈ ១ ព្យាបាទនីវរណៈ ១ កាមច្ឆន្ទនីវរណៈ ១ កាមរាគានុស័យ១ បដិឃានុស័យ១ កាមរាគសំយោជនៈ ១ បដិឃសំយោជនៈ ១ ទោសកិលេស១ ។

ម្យ៉ាងទៀតធម៌ណា ដែលជាប់ទាក់ទងដោយ សភាវៈ ជាព្យាបាទ គឺ អនាគាមិមគ្គចិត្តបានលះបង់អស់ហើយ ។

៤ អរហត្តមគ្គចិត្ត លះបង់អកុសលធម៌ដែលនៅសល់ទាំងអស់អំពីមគ្គចិត្តខាងក្រោម ដែលនៅមិនទាន់លះ គឺលះឲ្យអស់ទៅ ។

មគ្គចិត្តលះអកុសល១២ដួង

សោតាបត្តិមគ្គចិត្ត លះលោភមូលចិត្តបាន៤ដួង គឺលោភទិដ្ឋិគតសម្បយុត្តចិត្ត៤ដួង និងមោហមូលចិត្តបាន១ដួងគឺមោហវិចិកិច្ឆាសម្បយុត្តចិត្ត១សរុបសោតាបត្តិមគ្គចិត្តលះអកុសលបាន៥ដួងក្នុងចំណោមអកុសលចិត្ត១២ដួង ។

សកទាគាមិមគ្គចិត្ត លះបង់អកុសលចិត្តគ្រោតគ្រាតដែលនៅសល់ពីបឋមមគ្គចិត្តលះបង់ហើយ ដោយ (តនុករបហានៈ) ។

អនាគាមិមគ្គចិត្ត លះទោសមូលចិត្តបាន២ដួង

អរហត្តមគ្គចិត្ត លះលោភចិត្ត៤ដួង គឺលោភទិដ្ឋិវិប្បយុត្ត និងលះមោហ១ដួង គឺ មោហឧទ្ធច្ចសម្បយុត្តចិត្ត សរុប អានាគាមិមគ្គចិត្តលះអកុ-សលចិត្ត បាន៥ដួង ក្នុងចំណោមអកុសល១២ដួង។

**មគ្គចិត្តលះអកុសលកម្មបថ១០**

**សោតាបត្តិមគ្គ** លះបាណាតិបាត១ អទិន្នាទាន១ កាមេសុមិច្ឆាចារៈ១ មុសាវាទ១ និង មិច្ឆាទិដ្ឋិ១ ។

**សកទាគាមិមគ្គចិត្ត** លះអកុសលកម្មបថគ្រោតគ្រាត ដែលនៅសល់ពីបឋមមគ្គលះបង់ហើយ ដោយ (តនុករបហានៈ) ។

**អនាគាមិមគ្គ** លះបង់បិសុណាវាទ១ ផរុស្សវាទ១ និងព្យាបាទ១ ។

**អរហត្តមគ្គ** លះសម្ផប្បលាបៈ និងអភិជ្ឈា ។ កាលដែលមគ្គចិត្តមា-នអំណាចសម្លាប់កិលេសដាច់ជាសមុច្ឆេទបាននោះ ក៏ដោយហេតុថា ក្នុងមគ្គចិត្ត៤ដួងនោះ ប្រកបព្រមដោយ ពោធិបក្ខិយធម៌៣៧ប្រការ ហើយពោធិបក្ខិយធម៌នោះ កាលបើបង្រួមចុះមក ក៏បានដល់ សីល សមាធិបញ្ញាទាំង៣នោះឯង ។

**លោកុត្តរវិបាកចិត្ត៤ដួង**

**សោតាបត្តិផលំចិត្តំសកទាគាមិផលំចិត្តំ**

**អនាគាមិផលំចិត្តំ អរហត្តផលំចិត្តញ្ចេតិ**

## ឥមានិ ចត្តារិបិ លោកុត្តរវិបាកចិត្តានិនាម ។

ប្រែថា សោតាបត្តិផលចិត្ត១ សកទាគាមិផលចិត្ត១ អនាគាមិផលចិត្ត១ អរហត្តផលចិត្ត១ ចិត្តទាំង៤ដួងនេះ ឈ្មោះថា លោកុត្តរវិបាកចិត្ត ។

សួរថា ហេតុអ្វីបានជាលោកុត្តរវិបាកមាន៤ប្រការ? ឆ្លើយថា ព្រោះជាផលរបស់លោកុត្តរកុសលនោះៗ គឺអាស្រ័យមគ្គចិត្តជាហេតុ ជាបច្ច័យឲ្យកើតឡើង ព្រោះហេតុនោះទើបហៅថា ផលចិត្ត ផលចិត្តនេះមិនមានតួនាទីប្រហារនូវកិលេសណាមួយដូចមគ្គចិត្តទេ ប៉ុន្តែមានព្រះនិព្វានជាអារម្មណ៍ និងប្រកបដោយពោធិបក្ខិយធម៌ទាំង៣៧ប្រការដូចគ្នា ។

## លោកុត្តរចិត្តដោយពិស្តារ

លោកុត្តរចិត្តមាន២ន័យគឺ សង្ខេប៨ដួង១ន័យ និងពិស្តារ៤០ដួង១ន័យ ។

## លោកុត្តរ៤០ដួងសំដែងតាមអង្គឈាន

លោកុត្តរចិត្តដោយពិស្តារមាន៤០ដួង ដោយអំណាចការរាប់លោកុត្តរចិត្ត៨ដួងក្នុងឈានទាំង៥ គឺ លោកុត្តរចិត្ត១ដួងប្រព្រឹត្តទៅក្នុងឈាន៥ ដូចជាសោតាបត្តិមគ្គចិត្ត១ដួង ក្នុងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន ត្រូវជាសោតាបត្តិមគ្គ៥ដូច្នេះឯង ។ ចំណែកលោកុត្តរកុសលចិត្ត៧ដួងទៀតក្នុងដួងនិមួយៗក៏ប្រព្រឹត្តទៅក្នុងឈានទាំង៥ដូចគ្នា ដូច្នេះត្រូវជា៤០ដួង គឺលោកុត្តរ៨គុណនិងឈាន៥ ត្រូវជាលោកុត្តរចិត្ត៤០ដួង ។

ក្នុងលោកុត្តរចិត្ត៤០ដួងនោះ ចំណែកដោយលោកុត្តរមគ្គជ្ឈានចិត្ត

២០ដួង និងលោកុត្តរវិបាកជ្ឈានចិត្ត២០ដួង

**លោកុត្តរមគ្គជ្ឈានចិត្ត២០ដួង គឺ**

**សោតាបត្តិមគ្គ៥ សកទាគាមិមគ្គ៥ អនាគាមិមគ្គ៥ និងអរហត្តមគ្គ៥**

ត្រូវជាលោកុត្តរមគ្គជ្ឈានចិត្ត២០ដួង ។

**សោតាបត្តិមគ្គជ្ឈានចិត្ត៥ដួង**

**១ វិតក្ក វិចារ បីតិ សុខេកគ្គតា សហិត**

**បឋមជ្ឈាន សោតាបត្តិមគ្គចិត្តំ ។**

សោតាបត្តិមគ្គបឋមជ្ឈានចិត្ត មានអង្គ៥គឺ វិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

**២ វិចារ បីតិ សុខេកគ្គតា សហិត ទុតិយជ្ឈាន សោតាបត្តិមគ្គចិត្តំ។**

សោតាបត្តិមគ្គទុតិយជ្ឈានចិត្ត មានអង្គ៤គឺ វិចារៈ បីតិ សុខៈនិងឯកគ្គតា ។

**៣ បីតិ សុខេកគ្គតា សហិត តតិយជ្ឈាន សោតាបត្តិមគ្គចិត្តំ**

សោតាបត្តិមគ្គតតិយជ្ឈានចិត្ត មានអង្គ៣គឺ បីតិ សុខៈ និងឯកគ្គតា ។

**៤ សុខេកគ្គតា សហិត ចតុត្ថជ្ឈាន សោតាបត្តិមគ្គចិត្តំ**

សោតាបត្តិមគ្គចតុត្ថជ្ឈានចិត្ត មានអង្គ២គឺ សុខៈ និងឯកគ្គតា ។

**៥ ឧបេក្ខេកគ្គតា សហិត បញ្ចមជ្ឈាន សោតាបត្តិមគ្គចិត្តំ**

សោតាបត្តិមគ្គបញ្ចមជ្ឈានចិត្ត មានអង្គ២គឺ ឧបេក្ខា និងឯកគ្គតា ។

**សកទាគាមិមគ្គជ្ឈានចិត្ត៥ដួង**

**១វិតក្ក វិចារ បីតិ សុខេកគ្គតា សហិត បឋមជ្ឈាន សកទាគាមិមគ្គចិត្តំ**

២ វិចារ បីតិ សុខេកគ្គតា សហិត ទុតិយជ្ឈាន សកទាគាមិមគ្គចិត្តំ

៣ បីតិ សុខេកគ្គតា សហិត តតិយជ្ឈាន សកទាគាមិមគ្គចិត្តំ

៤ សុខេកគ្គតា សហិត ចតុត្ថជ្ឈាន សកទាគាមិមគ្គចិត្តំ

៥ ឧបេក្ខេកគ្គតា សហិត បញ្ចមជ្ឈាន សកទាគាមិមគ្គចិត្តំ

អនាគាមិមគ្គជ្ឈានចិត្ត៥ដួង

១ វិតក្ក វិចារ បីតិ សុខេកគ្គតា សហិត បឋមជ្ឈាន អនាគាមិមគ្គចិត្តំ

២ វិចារ បីតិ សុខេកគ្គតា សហិត ទុតិយជ្ឈាន អនាគាមិមគ្គចិត្តំ

៣ បីតិ សុខេកគ្គតា សហិត តតិយជ្ឈាន អនាគាមិមគ្គចិត្តំ

៤ សុខេកគ្គតា សហិត ចតុត្ថជ្ឈាន អនាគាមិមគ្គចិត្តំ

៥ ឧបេក្ខេកគ្គតា សហិត បញ្ចមជ្ឈាន អនាគាមិមគ្គចិត្តំ

អរហត្តមគ្គជ្ឈានចិត្ត៥ដួង

១ វិតក្ក វិចារ បីតិ សុខេកគ្គតា សហិត បឋមជ្ឈាន អរហត្តមគ្គចិត្តំ

២ វិចារ បីតិ សុខេកគ្គតា សហិត ទុតិយជ្ឈាន អរហត្តមគ្គចិត្តំ

៣ បីតិ សុខេកគ្គតា សហិតតតិយជ្ឈាន អរហត្តមគ្គចិត្តំ

៤ សុខេកគ្គតា សហិត ចតុត្ថជ្ឈាន អរហត្តមគ្គចិត្តំ

៥ ឧបេក្ខេកគ្គតា សហិត បញ្ចមជ្ឈាន អរហត្តមគ្គចិត្តំ

លោកុត្តរវិបាកជ្ឈានចិត្ត២០ដួង គឺ

សោតាបត្តិផល៥ សកទាគាមិផល៥ អនាគាមិផល៥ និងអរហត្តផល៥ ត្រូវជាលោកុត្តរវិបាកជ្ឈានចិត្ត២០ដួង ។

សោតាបត្តិផលជ្ឈានចិត្ត៥ដួង

១វិតក្ក វិចារ បីតិ សុខេកគ្គតា សហិត បឋមជ្ឈាន  សោតាបត្តិផលចិត្តំ
២ វិចារ បីតិ សុខេកគ្គតា សហិតទុតិយជ្ឈាន សោតាបត្តិផលចិត្តំ
៣ បីតិ សុខេកគ្គតា សហិត តតិយជ្ឈាន សោតាបត្តិផលចិត្តំ
៤ សុខេកគ្គតា សហិត ចតុត្ថជ្ឈាន សោតាបត្តិផលចិត្តំ
៥ ឧបេក្ខេកគ្គតា សហិត បញ្ចមជ្ឈាន សោតាបត្តិផលចិត្តំ

សកទាគាមិផលជ្ឈានចិត្ត៥ដួង

១ វិតក្ក វិចារ បីតិ សុខេកគ្គតា សហិត បឋមជ្ឈាន សកទាគាមិផលចិត្តំ
២ វិចារ បីតិ សុខេកគ្គតា សហិតទុតិយជ្ឈាន សកទាគាមិផលចិត្តំ
៣ បីតិ សុខេកគ្គតា សហិត តតិយជ្ឈាន សកទាគាមិផលចិត្តំ
៤ សុខេកគ្គតា សហិត ចតុត្ថជ្ឈាន សកទាគាមិផលចិត្តំ
៥ ឧបេក្ខេកគ្គតា សហិត បញ្ចមជ្ឈាន សកទាគាមិផលចិត្តំ

អនាគាមិផលជ្ឈានចិត្ត៥ដួង

១ វិតក្ក វិចារ បីតិ សុខេកគ្គតា សហិត បឋមជ្ឈាន អនាគាមិផលចិត្តំ
២ វិចារ បីតិ សុខេកគ្គតា សហិត ទុតិយជ្ឈាន អនាគាមិផលចិត្តំ
៣ បីតិ សុខេកគ្គតា សហិត តតិយជ្ឈាន អនាគាមិផលចិត្តំ
៤ សុខេកគ្គតា សហិត ចតុត្ថជ្ឈាន អនាគាមិផលចិត្តំ
៥ ឧបេក្ខេកគ្គតា សហិត បញ្ចមជ្ឈាន អនាគាមិផលចិត្តំ

អរហត្តផលជ្ឈាន ចិត្ត៥ដួង

១ វិតក្ក វិចារ បីតិ សុខេកគ្គតា សហិត បឋមជ្ឈាន អរហត្តផលចិត្តំ
២ វិចារ បីតិ សុខេកគ្គតា សហិតទុតិយជ្ឈាន អរហត្តផលចិត្តំ

៣ បីតិ សុខេកគ្គតា សហិត តតិយជ្ឈាន អរហត្តផលចិត្តំ

៤ សុខេកគ្គតា សហិត ចតុត្ថជ្ឈាន អរហត្តផលចិត្តំ

៥ ឧបេក្ខេកគ្គតា សហិត បញ្ចមជ្ឈាន អរហត្តផលចិត្តំ

ចំណែកលោកុត្តរចិត្ត៨ដួងដោយន័យ១៤

១ **ន័យដោយជាតិ** ជាកុសលជាតិ៤ ជាវិបាកជាតិ៤

២ **ន័យដោយភូមិ** ជាលោកុត្តរភូមិទាំង៨ដួង ជា **អវត្ថានភូមិ** (មិនមានភូមិដោយចំពោះជារបស់ខ្លួន) កើតបាន២៦ភូមិវៀរអបាយភូមិ៤ និងអសញ្ញីសត្តភូមិ១

៣ **ន័យដោយវេទនា** ជាសោមនស្សវេទនា និងជា ឧបេក្ខាវេទនា (លោកុត្តរៈចិត្តណា ប្រកបដោយបីតិ គឺជាសោមនស្សវេទនា បើមិនប្រកបដោយ បីតិទេ ជាឧបេក្ខាវេទនា)

៤ **ន័យដោយហេតុ** ជានហេតុ និងជាសហេតុកៈចិត្ត

៥ **ន័យដោយសម្បយុត្ត** ជាញាណសម្បយុត្តចិត្ត

៦ **ន័យដោយសង្ខារ** ជាសសង្ខារិកៈចិត្ត

៧ **ន័យដោយសោភណៈ** ជាសោភណៈចិត្ត

៨ **ន័យដោយឈាន** លោកុត្តរៈចិត្ត ៨ដួង ជា អឈានចិត្ត លោកុត្តរៈ៤០ដួងជាឈានចិត្ត

៩**ន័យដោយលោកិយៈ** ជាលោកុត្តរចិត្ត

១០**ន័យដោយកិច្ច** ជាចិត្តធ្វើជវនកិច្ច

១១**ន័យដោយអារម្មណ៍** ជាធម្មារម្មណ៍ គឺមានព្រះនិព្វានជា អា-

រម្មណ៍

១២ **ន័យដោយទ្វារ** កើតឡើងបានអាស្រ័យមនោទ្វារ

១៣ **ន័យដោយវត្ថុ** សោតាបត្តិមគ្គចិត្ត១ អាស្រ័យហទយវត្ថុប៉ុណ្ណោះ លោកុត្តរៈ៧ដួងទៀត អាស្រ័យហទយវត្ថុក្នុង បញ្ចវោការភព ក្នុងចតុវោការភពមិនអាស្រ័យហទយវត្ថុទេ

១៤ **ន័យដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

## ព្រះសោតាបន្ន៣ប្រភេទ

១ ឯកពីជីសោតាបន្ន ឈ្មោះថា ឯកពីជីព្រោះអត្ថថា មានពូជ (ការកើត) ១ជាតិទៀត គឺព្រះសោតាបន្នបុគ្គលនោះ បដិសន្ធិតែម្តងទៀត ក៏បានសម្រេចអរហត្តផលហើយក៏បរិនិព្វាន ។

២ កោលំកោលសោតាបន្ន ឈ្មោះថា កោលំកោលសោតាបន្នព្រោះអត្ថថា ទៅពីត្រកូលមួយទៅកាន់ត្រកូលមួយ គឺព្រះសោតាបន្នបុគ្គលដែលត្រូវកើតឡើងពីរជាតិ ឬរហូត៦ជាតិទៀតទើបបរិនិព្វាន ។

៣ សត្តក្ខត្តុំបរមសោតាបន្ន ឈ្មោះថា សត្តក្ខត្តុំបរម ព្រោះអត្ថថា មានប្រាំពីរជាតិទៀតយ៉ាងច្រើន គឺព្រះសោតាបន្នបុគ្គលត្រូវកើតមិនហួសពីប្រាំពីរជាតិទៀតឡើយ ហើយបរិនិព្វាន ។

ក្នុងអត្ថកថា បុគ្គលបញ្ញត្តិពោលថា ព្រះសោតាបន្នបុគ្គល មានអធ្យាស្រ័យត្រេកអរក្នុងភព និងទៅកើតក្នុងទេវលោក ហើយនឹងតាំងនៅក្នុងអកនិដ្ឋភព បរិនិព្វានក្នុងភពនោះ មាន៧អង្គគឺ

១ អនាថបិណ្ឌិកសេដ្ឋី

២ មហាឧបាសិកាវិសាខា

៣ ចូឡរថទេវបុត្រ

៤ មហារថទេវបុត្រ

៥ អនេកវណ្ណទេវបុត្រ

៦ សក្កទេវរាជ

៧ នាគទត្តទេវបុត្រ

## សោតា២៤ពួកដោយពិស្តារ

សោតា៣ពួកគឺ ឯកពីជី១ កោលំកោល១សត្តក្ខត្តុំបរម១ប្រព្រឹត្តទៅក្នុងបដិបទា៤មានទុក្ខាបដិបទាជាដើមត្រូវជា១២គឺសោតា៣គុណបដិទា៤ត្រូវជា១២ពួក សោតា១២ពួកនោះប្រព្រឹត្តទៅជាសទ្ធាធុរៈ១និងបញ្ញាធុរៈ១ក៏ត្រូវជា២៤ពួកដោយប្រការយ៉ាងនេះឯង គឺសោតា៣ពួកប្រព្រឹត្តទៅក្នុងបដិបទា៤ជា១២ពួក សោតាទាំង១២ពួកនោះប្រព្រឹត្តទៅក្នុងសទ្ធាធុរៈ១និងបញ្ញាធុរៈ១ សរុបទាំងអស់ត្រូវជាសោតា២៤ពួក ។

## បដិបទា៤

១ **ទុក្ខាបដិបទាខិប្បាភិញ្ញា** បដិបត្តិលំបាកត្រាស់ដឹងរហ័ស

២ **ទុក្ខាបដិបទាទន្ធាភិញ្ញា** បដិបត្តិលំបាកត្រាស់ដឹងយឺត

៣ **សុខាបដិបទាខិប្បាភិញ្ញា** បដិបត្តិជាសុខត្រាស់ដឹងរហ័ស

៤ **សុខាបដិបទាទន្ធាភិញ្ញា** បដិបត្តិជាសុខត្រាស់ដឹងយឺត

## សកទាគាមី៥ ប្រភេទ

១ **ឥធ បត្វា ឥធ បរិនិព្វាយី** ព្រះសកទាគាមី អ្នកបានសំរេចក្នុង

មនុស្សលោកនេះ ហើយបរិនិព្វានក្នុងមនុស្សលោកនេះ ។

**២ តត្ថ បត្វា តត្ថ បរិនិព្វាយី** ព្រះសកទាគាមី អ្នកបានសំរេចក្នុងទេវលោកនោះហើយបរិនិព្វានក្នុងទេវលោកនោះ ។

**៣ ឥធ បត្វា តត្ថ បរិនិព្វាយី** ព្រះសកទាគាមី អ្នកបានសំរេចក្នុងមនុស្សលោកនេះ ហើយបរិនិព្វានក្នុងទេវលោកនោះ ។

**៤ តត្ថ បត្វា ឥធ បរិនិព្វាយី** ព្រះសកទាគាមី អ្នកបានសំរេចក្នុងទេវលោកនោះហើយបរិនិព្វានក្នុងមនុស្សលោកនេះ ។

**៥ ឥធ បត្វា តត្ថ និព្វត្តិត្វា ឥធ បរិនិព្វាយី** ព្រះសកទាគាមីអ្នកបានសំរេចក្នុងមនុស្សលោកនេះទៅកើត ក្នុងទេវលោក ចុតិអំពីទេវលោក មកកើតក្នុងមនុស្សលោក ទើបបរិនិព្វានក្នុងមនុស្សលោកនេះ ។

## ព្រះសកទាគាមីដោយពិស្តារមាន១២ពួក

សកទាគាមីបុគ្គល១២តើដូចម្តេច ? សកទាគាមីបុគ្គល១២នោះ គឺ

សកទាគាមីដែលបាន សំរេចដោយ សុញ្ញតវិមោក្ខ១

សកទាគាមីដែលបាន សំរេចដោយ អនិមិត្តវិមោក្ខ១

សកទាគាមីដែលបាន សំរេចដោយ អប្បណិហិតវិមោក្ខ១

ទាំង៣ពួកនេះ ប្រព្រឹត្តទៅក្នុងបដិបទា៤ មានទុក្ខាបដិបទាជាដើម គឺវិមោក្ខ៣ គុណបដិបទា៤ត្រូវជា១២ នេះឈ្មោះថាសកទាគាមី១២ពួក ។

## ព្រះអនាគាមី៥ប្រភេទ

**១អន្តរាបរិនិព្វាយី** បានដល់ព្រះអនាគាមី អ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយហើយ បរិនិព្វានមុនពាក់កណ្តាលអាយុខេយ្យ នៃភូមិនោះ

(អន្តរាបរិនិព្វាយីនេះ លោកចែកជា៣ប្រភេទ) គឺ

**អនាគាមិបុគ្គលឯណា** ដែលបដិសន្ធិក្នុងសុទ្ធាវាសណាមួយ ហើយមិនយូរប៉ុន្មាន បានសំរេចព្រះអរហត្ត ១

**អនាគាមិបុគ្គលឯណា** ដែលបដិសន្ធិក្នុងសុទ្ធាវាសណាមួយហើយដល់ពាក់កណ្តាលក្នុងពាក់កណ្តាលនៃអាយុខេយ្យ ឧទាហរណ៍ថា បើក្នុងឋាននោះមានអាយុ១០០០មហាកប្ប អនាគាមិបុគ្គលនោះ បានសំរេចព្រះអរហត្ត មុនអាយុ៥០០មហាកប្ប ១ ។

**អនាគាមិបុគ្គលឯណា** ដែលបានសំរេចព្រះអរហត្តក្នុងពាក់កណ្តាលអាយុ នៃឋាននោះៗ ១ ។

២ **ឧបហច្ចបរិនិព្វាយី** បានដល់ព្រះអនាគាមីអ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយ ហើយបរិនិព្វាន កន្លងពាក់កណ្តាលអាយុខេយ្យនៃភពនោះ ។

៣ **អសង្ខារបរិនិព្វាយី** បានដល់ព្រះអនាគាមី អ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយ ហើយសំរេចព្រះអរហត្តបរិនិព្វាន ដោយមិនមានការព្យាយាមខ្លាំងក្លា ។

៤ សសង្ខារបរិនិព្វាយី បានដល់ព្រះអនាគាមីអ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយហើយ សំរេចព្រះអរហត្តដោយលំបាក គឺព្យាយាមខ្លាំងក្លា ។

៥ ឧទ្ធំសោតោអកនិដ្ឋគាមី បានដល់ព្រះអនាគាមីអ្នកបដិសន្ធិ តាំងពីសុទ្ធាវាសភូមិខាងក្រោម គឺអតប្បាភូមិ ដែលមានអាយុ១០០០មហាកប្ប

ចុតិហើយ បដិសន្ធិក្នុងអវិហាភូមិមានអាយុ ២០០០មហាកប្ប ចុតិហើយ បដិសន្ធិក្នុងសុទស្សាភូមិមានអាយុ៤០០០មហាកប្ប ចុតិហើយបដិសន្ធិក្នុង សុទស្សីភូមិមានអាយុ៨០០០មហាកប្ប ចុតិហើយ បដិសន្ធិក្នុងអកនិដ្ឋាភូមិ ទើបបរិនិព្វានក្នុងឋាន អកនិដ្ឋានោះ ។

អ្នកសិក្សាគប្បីជ្រាបព្រះអនាគាមី៤ ប្រភេទនៃ ឧទ្ធំសោតោអកនិដ្ឋ-គាមី គឺ ។

១ បណ្តាព្រះអនាគាមីពួកនោះ ព្រះអនាគាមីអង្គណាមួយ ដែលបដិសន្ធិតាំងតែអវិហាភូមិ រហូតបដិសន្ធិក្នុងអកនិដ្ឋាភូមិ អង្គនោះឈ្មោះថា ឧទ្ធំសោតោ អកនិដ្ឋគាមី ។

២ ព្រះអនាគាមីអង្គណាមួយ បដិសន្ធិក្នុងសុទ្ធាវាស តាំងតែពីថ្នាក់ក្រោម រហូតដល់សុទស្សីភូមិ ទើបបរិនិព្វាន អង្គនេះឈ្មោះថា **ឧទ្ធំសោតោ-អកនិដ្ឋគាមី** អ្នកមានក្រសែខាងលើតែមិនទៅដល់អកនិដ្ឋាភូមិ ។

៣ ព្រះអនាគាមីអង្គណាមួយ ផ្លោះទៅកាន់អកនិដ្ឋាភូមិ នោះឯង តាំងអំពីសុទស្សីភូមិទៅ ហើយបរិនិព្វាន អង្គនោះឈ្មោះថា **ន ឧទ្ធំសោតោ-អកនិដ្ឋគាមី** ប្រែថា អ្នកមិនមានក្រសែខាងលើ តែផ្លោះទៅកាន់អកនិដ្ឋភូមិ

៤ព្រះអនាគាមីអង្គណាមួយបដិសន្ធិហើយក្នុងសុទ្ធាវាសខាងក្រោម បួនជាន់ណាមួយ ហើយបរិនិព្វានក្នុងឋាននោះៗ អង្គនោះ ឈ្មោះថា **នឧទ្ធំសោតោ នអកនិដ្ឋគាមី** ប្រែថា អ្នកមិនមានក្រសែ ក្នុងខាងលើ និងមិនផ្លោះទៅអកនិដ្ឋាភូមិ ។

## ព្រះអនាគា៤៨ដោយពិស្តារ

សួរថា តើព្រះអនាគាមី៤៨ពួកនោះដូចម្ដេចខ្លះ? ឆ្លើយថា ក្នុងអវិហាភូមិមួយ មានព្រះអនាគា១០ប្រភេទគឺ អន្តរាបរិនិព្វាយី៣ឧបហច្ចបរិនិព្វាយី១ ឧទ្ធំសោតោអកនិដ្ឋគាមី១ទាំង៥នេះប្រព្រឹត្តទៅជា**អសង្ខារបរិនិព្វាយី៥** ជា**សសង្ខារបរិនិព្វាយី៥** រួមជា១០។ ក្នុងអតប្បាភូមិក៏មាន១០សុទស្សាភូមិក៏មាន១០ សុទស្សីភូមិក៏មាន១០ រួមទាំងអស់ជា៤០ តែព្រះអនាគាមីដែលឈ្មោះថា **ឧទ្ធំសោតោ** មិនមានក្នុងអកនិដ្ឋភូមិ ទេមានតែអនាគាមីឈ្មោះថា **អន្តរាបរិនិព្វាយី៣ ឧបហច្ចបរិនិព្វាយី១** ដែលប្រព្រឹត្តទៅ ជា **អសង្ខារបរិនិព្វាយី៤សសង្ខារបរិនិព្វាយី៤** រួមជា៨ពួក៨ពួកនេះរួមនឹង ៤០ពួកខាងលើត្រូវជា៤៨ពួក ។

## ព្រះអរហន្ត២ប្រភេទ

១ ព្រះអរហន្តដែលសម្រេចដោយបញ្ញាវិមុត្តិ ។

២ ព្រះអរហន្តដែលសម្រេចដោយចេតោវិមុត្តិ ។

ព្រះអរហន្តបញ្ញាវិមុត្តិមិនមានឈានលាភីទេចំណែកឯព្រះអរហន្តដែលជាចេតោវិមុត្តិ មានឈានលាភី អង្គខ្លះបានវិជ្ជា៣ អង្គខ្លះបានអភិញ្ញា៦ អង្គខ្លះបានបដិសម្ភិទា៤ ។

## វិជ្ជា៣គឺ

១ **បុព្វេនិវាសានុស្សតិវិជ្ជា** វិជ្ជាជាជាគ្រឿងរលឹកជាតិក្នុងអតីតៈ ។

២ **ចុតូបបាតវិជ្ជា** វិជ្ជាជាគ្រឿងដឹងចុតិបដិសន្ធិរបស់សត្វតទៅមុខ។

៣ **អាសវក្ខយវិជ្ជា** វិជ្ជាជាគ្រឿងធ្វើឲ្យអស់កិលេស ។

## អភិញ្ញា៦

**១ ឥទ្ធិវិធិ** សំដែលឫទ្ធិ ។

**២ ទិព្វសោត** ត្រចៀកទិព្វ ។

**៣ ចេតោបរិយញ្ញាណ** ដឹងចិត្តអ្នកដទៃ ។

**៤ បុព្វេនិវាសានុស្សតិវិជ្ជា** វិជ្ជាជាជាគ្រឿងរលឹកជាតិក្នុងអតីត: ។

**៥ ចុតូបបាតវិជ្ជា** វិជ្ជាជាគ្រឿងដឹងចុតិបដិសន្ធិរបស់សត្វតទៅមុខ។

**៦ អាសវក្ខយវិជ្ជា** វិជ្ជាជាគ្រឿងធ្វើឲ្យអស់កិលេស ។

## បដិសម្ភិទា៤

**១ អត្ថបដិសម្ភិទា** បញ្ញាបែកព្រមក្នុងអត្ថ ។

**២ ធម្មបដិសម្ភិទា** បញ្ញាបែកព្រមក្នុងធម៌ ។

**៣ និរុត្តិបដិសម្ភិទា** បញ្ញាបែកព្រមក្នុងស័ព្ទពាក្យបញ្ញត្តិភាសា។

**៤ បដិភាណប្បដិសម្ភិទា** បញ្ញាបែកព្រមក្នុងញាណ ។

## ព្រះអរហន្ត១២ដោយពិស្តារ

ព្រះអរហន្ត១២ពួកនោះ គឺ ព្រះអរហន្តដែលបានសំរេចដោយ សុញ្ញតវិមោក្ខ១

ព្រះអរហន្តដែលបានសំរេចដោយអនិមិត្តវិមោក្ខ១

ព្រះអរហន្តដែលបានសំរេចដោយអប្បណិហិតវិមោក្ខ១

ទាំង៣ពួកនេះ ប្រព្រឹត្តទៅក្នុងបដិបទា៤ មានទុក្ខាបដិបទាដើម គឺវិមោក្ខ៣ គុណបដិបទា៤ត្រូវជា១២ នេះឈ្មោះ ព្រះអរហន្ត១២ពួក ។

សរុបព្រះអរិយបុគ្គល ទាំងអស់ដោយពិស្តារគឺ សោតាបន្ន២៤ពួក

សកទាគាមី១២ពួក អនាគាមី៤៨ពួក និងព្រះអរហន្ត១២ពួក រួមទាំងអស់ជា៩៦ពួក ។ (មានក្នុងអដ្ឋកថាបុគ្គលបញ្ញត្តិ ឈ្មោះបរមត្ថទីបនី )

## ចំណែកចិត្ត១២១ដួងដោយន័យ១៤

### ១ ន័យដោយជាតិ

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយជាតិនោះគឺ

- ជាអកុសលជាតិ ១២ ដួង បានដល់លោភមូលចិត្ត៨ ដួង ទោសមូលចិត្ត២ដួង និងមោហមូលចិត្ត២ដួង ។

- ជាកុសលជាតិ ៣៧ដួង បានដល់មហាកុសល៨ដួង រូបាវចរកុសល៥ដួង អរូបាវចរកុសល៤ដួង និងលោកុត្តរកុសល២០ដួង ។

- ជាវិបាកជាតិ ៥២ដួង បានដល់អហេតុកអកុសលវិបាក ៧ដួង អហេតុកកុសលវិបាក៨ដួងមហាវិបាក៨ដួងរូបាវចរវិបាក៥ដួង អរូបាវចរវិបាក៤ដួង និង លោកុត្តរវិបាក ២០ដួង ។

- ជាកិរិយាជាតិ ២០ដួង បានដល់ អហេតុកកិរិយា៣ដួង មហាកិរិយា៨ដួង រូបាវចរកិរិយា៥ដួង អរូបាវចរកិរិយា៤ដួង ។

### ២ ន័យដោយភូមិ

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយភូមិ នោះគឺ

- ជាកាមាវចរភូមិ ៥៤ដួង បានដល់ កាមាវចរចិត្តទាំង ៥៤ដួង
- ជារូបាវចរភូមិ ១៥ដួង បានដល់ រូបាវចរចិត្តទាំង១៥ដួង
- ជាអរូបាវចរភូមិ ១២ដួង បានដល់ អរូបាវចរចិត្តទាំង១២ដួង
- ជាលោកុត្តរភូមិ ៤០ដួង បានដល់ លោកុត្តរចិត្តទាំង៤០ដួង

## ៣ ន័យដោយវេទនា

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយវេទនា នោះគឺ

- ជាសុខវេទនា ១ដួង បានដល់សុខសហគតកាយវិញ្ញាណ១ដួង
- ជាទុក្ខវេទនា ១ដួង បានដល់ ទុក្ខសហគតកាយវិញ្ញាណ១ដួង
- ជាសោមនស្សវេទនា ៦២ដួង បានដល់ លោភសោមនស្ស ៤ ដួង អហេតុសោមនស្ស ១ ដួង ហសិតុប្បាទ ១ ដួង មហាកុសលសោមនស្ស ៤ដួង មហាវិបាកសោមនស្ស ៤ ដួង មហាកិរិយាសោមនស្ស ៤ ដួង បឋមជ្ឈាន១១ដួង ( រូបាវចរកុសល១ រូបាវចរវិបាក១ រូបាវចរកិរិយា១ និងលោកុត្តរ៨ ) ទុតិយជ្ឈាន១១ដួង តតិយជ្ឈាន១១ដួង ចតុត្ថជ្ឈាន១១ដួង
- ជាទោមនស្សវេទនា ២ដួង បានដល់ទោសៈ ២ដួង
- ជាឧបេក្ខាវេទនា ៥៥ ដួង បានដល់ កាមាវចរឧបេក្ខា ៣២ ដួង (លោភៈ៤ មោហៈ២ អហេតុកចិត្ត១២ អហេតុកកិរិយា២ មហាកុសល៤ មហាវិបាក៤ មហាកិរិយា៤ ) រូបាវចរបញ្ចមជ្ឈាន៣ដួង (កុសល១ វិបាក១ កិរិយា ១ ) អរូបាវចរ ១២ដួង និងលោកុត្តរបញ្ចមជ្ឈាន ៨ដួង ។

## ៤ ន័យដោយហេតុ

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយហេតុ នោះគឺ

-ចិត្តទាំង១២១ដួងនោះជានហេតុទាំងអស់ជា អហេតុកចិត្ត១៨ដួង ជាសហេតុកចិត្ត១០៣ដួង ។

## ៥ ន័យដោយសម្បយុត្ត

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយសម្បយុត្តនោះគឺ

-ជាសម្បយុត្តចិត្ត៨៧ដួង បានដល់ចិត្តជាញាណសម្បយុត្ត៧៩ដួង (មហាកុសល ៤មហាវិបាក ៤ មហាកិរិយា ៤ មហគ្គត:២៧ លោកុត្តរ:៤០) ទិដ្ឋិគតសម្បយុត្ត៤ដួង បដិឃសម្បយុត្ត២ដួង វិចិកិច្ឆាសម្បយុត្ត១ដួង និង ឧទ្ធច្ចសម្បយុត្ត១ដួង ។

-ជាវិប្បយុត្តចិត្ត៣៤ បានដល់ ទិដ្ឋិគតវិប្បយុត្ត៤ ដួងអហេតុក:១៨ ដួង មហាកុសល ៤ ដួង មហាវិបាក ៤ ដួង មហាកិរិយា៤ដួង ។

## ៦ ន័យដោយសង្ខារ

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយសង្ខារ នោះគឺ

-ជាអសង្ខារិកចិត្ត ៣៧ ដួង គឺលោភ:៤ដួង ទោស:១ដួង មោហ:២ ដួង អហេតុក:១៨ ដួង មហាកុសល៤ដួង មហាវិបាក៤ដួង មហាកិរិយា៤ ដួង

-ជាសសង្ខារិកចិត្ត ៨៤ ដួង បានដល់ លោភ: ៤ដួង ទោស: ១ដួង មហាកុសល ៤ដួង មហាវិបាក ៤ដួង មហាកិរិយា ៤ដួង មហគ្គត:២៧ដួង និង លោកុត្តរ: ៤០ដួង ។

## ៧ ន័យដោយសោភណ:

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយសោភណ: នោះគឺ

-ជាអសោភណចិត្ត ៣០ដួង បានដល់ អកុសលចិត្ត ១២ដួង អហេ- តុកចិត្ត ១៨ដួង

-ជាសោភណចិត្ត ៩១ដួង បានដល់ កាមាវចរសោភណ: ២៤ដួង

មហគ្គត: ២៧ដួង និងលោកុត្តរ: ៤០ដួង ។

## ៨ ន័យដោយឈាន

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយឈាន នោះគឺ

-ជាអជ្ឈានចិត្ត ៥៤ដួង បានដល់ អកុសលចិត្ត ១២ដួង អហេតុកចិត្ត១៨ដួង កាមាវចរសោភណ: ២៤ដួង

-ជាឈានចិត្ត ៦៧ដួង បានដល់ រូបាវចរចិត្ត ១៥ដួង អរូបាវចរចិត្ត ១២ដួង និងលោកុត្តរចិត្ត ៤០ដួង ។

## ៩ ន័យដោយលោកិយ:

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយលោកិយ: នោះគឺ

-ជាលោកិយចិត្ត ៨១ដួង បានដល់ កាមាវចរចិត្ត ៥៤ដួង និង មហគ្គតចិត្ត ២៧ដួង

-ជាលោកុត្តរចិត្ត ៤០ដួង ។

## ១០ ន័យដោយកិច្ច

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយកិច្ច នោះគឺ ចិត្ត ១២១ ដួងធ្វើកិច្ច ១៤

-ចិត្ត១៩ដួង ធ្វើបដិសន្ធិកិច្ច (ចិត្ត១៩ដួងគឺ អហេតុកវិបាក២ដួង មហាវិបាក៨ដួង មហគ្គតវិបាក៩ដួង)

-ចិត្ត១៩ដួង ធ្វើភវង្គកិច្ច (ចិត្ត១៩ដួងគឺ អហេតុកវិបាក២ដួង មហាវិបាក៨ដួង មហគ្គតវិបាក៩ដួង)

-ចិត្ត២ ដួង ធ្វើអាវជ្ជនកិច្ច (ចិត្ត២ដួងគឺអហេតុកកិរិយា២ដួង)

-ចិត្ត២ ដួង ធ្វើទស្សនកិច្ច (ចិត្ត២ដួងគឺ ចក្ខុវិញ្ញាណ២ដួង )

-ចិត្ត២ ដួង ធ្វើសវនកិច្ច (ចិត្ត២ដួងគឺ សោតវិញ្ញាណ២ដួង )

-ចិត្ត២ ដួង ធ្វើឃាយនកិច្ច (ចិត្ត២ដួងគឺ ឃានវិញ្ញាណ២ដួង )

-ចិត្ត២ ដួង ធ្វើសាយនកិច្ច (ចិត្ត២ដួងគឺ ជីវ្ហាវិញ្ញាណ២ដួង )

-ចិត្ត២ ដួង ធ្វើផុសនកិច្ច (ចិត្ត២ដួងគឺ កាយវិញ្ញាណ២ដួង )

-ចិត្ត២ ដួង ធ្វើសម្បដិច្ឆន្នកិច្ច (ចិត្ត២ដួងគឺ អហេតុកចិត្ត២ដួង )

-ចិត្ត៣ ដួង ធ្វើសន្តីរណកិច្ច (ចិត្ត៣ដួងគឺអហេតុកអកុសលវិបាក ១ដួង អហេតុកកុសលវិបាក២ដួង )

-ចិត្ត១ ដួង ធ្វើវោដ្ឋវនកិច្ច (ចិត្ត១ដួងគឺ អហេតុកកិរយា១ដួង)

-ចិត្ត៥៥ដួង ធ្វើជវនកិច្ច (ចិត្ត៥៥ដួងគឺ អកុសលចិត្ត១២ដួង ហសិតុប្បាទចិត្ត១ដួង មហាកុសលចិត្ត៨ដួង មហាកិរិយាចិត្ត៨ដួងមហគ្គត កុសលចិត្ត៩ដួង លោកុត្តរចិត្ត៨ដួង ឬ៤០ដួង )

-ចិត្ត១១ដួង ធ្វើតទាលម្ពណកិច្ច (ចិត្ត១១ដួងគឺ អហេតុកចិត្ត៣ដួង មហាវិបាក៨ដួង )

-ចិត្ត១៩ដួង ធ្វើចុតិកិច្ច (ចិត្ត១៩ដួងគឺ អហេតុកវិបាក២ដួង មហាវិបាក៨ដួង មហគ្គតវិបាក៩ដួង )

## ១១ ន័យដោយអារម្មណ៍

ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយអារម្មណ៍ នោះគឺ

-ចិត្ត ១២១ដួង ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង៦តាមសមគួរ

## ១២ ន័យដោយទ្វារ

*ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយទ្វារ នោះគឺ*

*-ចិត្ត ១២១ដួង  អាស្រ័យទ្វារទាំង ៦  និង មិនអាស្រ័យទ្វារទាំង ៦ (ទ្វារវិមុត្តិ) គឺ* ***បដិសន្ធិ ភវង្គ  ចុតិ*** *។*

## *១៣ ន័យដោយវត្ថុ*

*ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយវត្ថុ នោះគឺ*

*-ចិត្ត ១១៧ដួង កើតត្រង់ហទយវត្ថុ ចិត្ត ៤ដួងមិនអាស្រ័យ  ហទយវត្ថុ បានដល់ អរូបាវចរចិត្ត ។*

## *១៤ ន័យដោយវិញ្ញាណធាតុ*

*ចិត្ត១២១ដួងដែលប្រព្រឹត្តទៅក្នុងន័យដោយវិញ្ញាណធាតុ នោះគឺ*

*-ចិត្ត ១២១ដួង ជាទ្វិបញ្ចវិញ្ញាណ១០ ជាមនោធាតុ៣ជាមនោវិញ្ញា-ណធាតុ១០៨ ។*

## *អភិធម្មត្ថសង្គហភាគទី១ចប់*

---

នាមពុទ្ធបរិស័ទ ក្នុងនិងក្រៅប្រទេស ដែលមានសទ្ធាបរិច្ចាគប្រាក់
បោះពុម្ពសៀវភៅអភិធម្មត្ថសង្គហ ភាគ១ និងមេត្តាចិត្ត ភាគ១ ជាធម្មទាន

១ ឧ.សិ ប៉ាន់ សោមសួង និងបុត្រ ប៉ាន់ ហេន(ប្រទេសស្វីស) ៥០០ ដុល្លា

២ ឧ.ស អ៊ិត ហ៊្សួរ និងឧ.សិ សុវណ្ណារី ព្រមទាំងបុត្រ .............. ៥០០ ដុល្លា

៣ ឧ.សិ ព្រហ្ម ស៊ឹម ........................................................ ៥០០ ដុល្លា

៤ ឧ.សិ គុច ជួក ព្រមទាំងបុត្រធីតា គឺ អ៊ុយ សុគន្ធី
អ៊ុយ បូរិន្ទ អ៊ុយ សុធីរី អ៊ុយ សេរីវ័ន្ត អ៊ុយ ធីរ៉ា ៥០០ ដុល្លា
អ៊ុយ រត្ថា អ៊ុយ វាសនា អ៊ុយ ធីតា

៥ ឧ.សិ ជា សួន ព្រមទាំងបុត្រ .......................................... ៣០០ ដុល្លា

៦ ឧ.សិ អ៊ីង សាន ........................................................... ៣០០ ដុល្លា

៧ ឧ.សិ ម៉ៅ គឹមសឺន ព្រមទាំងបុត្រ ស្រុកស្មោង ............... ៣០០ ដុល្លា

៨ ឧ.សិ កុំ ឡាយ ព្រមទាំងបុត្រ ........................................ ២០៥ ដុល្លា

ឧ.សិ ដុះ ចំណាន និង ឧ.ស ដោត ឌី (ហៅអាំងប៊ុនស៊ុយ) ២០០ ដុល្លា

ឧ.សិ សៅ រិច (សព្វថ្ងៃរស់នៅស្រុកពួក, ម្តាយ រឹម បូរី) ..... ២០០ ដុល្លា

ឧ.ស រិម បូរី និងឧ.សិ រិមប៉ាន់ ម៉ានី (ប្រទេសស្វីស) .......... ២០០ ដុល្លា

ឧ.ស រិម ប៉ាន់ហុន ព្រមទាំងបុត្រ (ប្រទេសស្វីស) ............. ១០០ ដុល្លា

ឧ.សិ ពិន អែប (ប្រទេសស្វីស) ....................................... ១០០ ដុល្លា

ឧ.សិ អាំង បូរ៉ុំព្រមទាំងបុត្រ ........................................... ១០០ ដុល្លា

ឧ.សិ ឆេង ឃុនណារី ព្រមទាំងបុត្រ .............................. ១០០ ដុល្លា

ឧ.សិ ឆេង គឹមសុង និងម្តាយ ជា ទូច ............................. ១០០ ដុល្លា

ឧ.សិ ណារ៉ុត ព្រមទាំងក្មួយ ............................................ ១០០ ដុល្លា

ឧ.សិ ហ៊ុន សំអាត ........................................................ ១០០ ដុល្លា

ឧ.សិ ថាន់ ម៉ាឡាស៊ី ព្រមទាំងក្មួយនិងចៅ ..................... ១០០ ដុល្លា

ឧ.សិ ស៊ឹង សូនី និង ស្វាមី (នៅស្មោង)............................. ១០០ ដុល្លា

ឧ.ស ឆេង គឹមថៃ និងភរិយា (ប្រទេសស្វីស).................. ១០០ ដុល្លា

ឧ.សិ ឈឹម គឹមភ្លៀន .................................................... ១០០ ដុល្លា

ឧ.ស ស្វារ ប៊ុនថាំង + ស្វា សាលូន ................................ ១០០ ដុល្លា

ឧ.ស តាន់ ប៊ុនធឿន និង ឧ.សិ ឡាយ គីម ហៅមួយ ........ ១០០ ដុល្លា

ឧ.សិ ឈួន ឡូវ ព្រមទាំងបុត្រ ........................................ ១០០ ដុល្លា

ឧ.សិ សំរិត ថូ ព្រមទាំងបុត្រ........................................ ១០០ ដុល្លា

ព្រះតេជគុណ តៀម (វត្តព្រះព្រហ្មរ័ត្ន)............................ ៦២ ដុល្លា

ឧ.សិ ឆេង គឹមស៊ាង ..................................................... ៥០ ដុល្លា

ឧ.សិ ហង្ស ម៉ាឡៃ ........................................................ ៥០ ដុល្លា

ឧ.ស អ៊ុយ សឹង និងភរិយា ............................................ ៥០ ដុល្លា

ឧ.សិ ហួយ រឹម ............................................................ ៥០ ដុល្លា

ឧ.សិ ហួយ រ៉ាន់ ........................................................... ៥០ ដុល្លា

ឧ.សិ ម៉ៅ គឹមស៊ន និងស្វាមី .......................................... ៥០ ដុល្លា

កញ្ញា រិម រានណា + អីវ៉ាន់ (ប្រទេសស្វីស) ..................... ៥០ ដុល្លា

គ្រួសារ រិម វុទ្ធទ្រី និង ទេព្យ មនោរម្យ (ប្រទេសស្វីស) ...... ៥០ ដុល្លា

គ្រួសារ ដុងហាវ សេន + ឡាប (ប្រទេសស្វីស) ................. ៥០ ដុល្លា

ឧ.ស ខ្វាវ វ៉ា និង ឧ.សិ ប៉ែន ហ៊ាង ព្រមទាំងបុត្រ ............ ៥០ ដុល្លា

ឧ.សិ អ៊ុម ច័ន្ទ ............................................................. ៥០ ដុល្លា

ឧ.សិ អ៊ុង សុភាព ព្រមទាំងបុត្រ .................................... ៥០ ដុល្លា

| | |
|---|---|
| កញ្ញា សំអាន បាត់ដំបង .................................................. | ៥០ ដុល្លា |
| ឧ.សិ អ៊ីវ សៅមុនី ........................................................ | ៣០ ដុល្លា |
| ឧ.សិ តាំង គឹមសាយ ...................................................... | ៣០ ដុល្លា |
| ឧ.ស ហ៊ុន គឹមហេង និង ភរិយា ព្រមទាំងបុត្របាត់ដំបង | ៣០ ដុល្លា |
| កុមារា វ៉ែន បញ្ញារិទ្ធ និងកុមារា វ៉ែនបញ្ញារដ្ឋ(នៅស្ពោង)... | ៣០ ដុល្លា |
| លោក អៀន ជិវ៉ា + អ្នកស្រី ស៊ុន សាព៉ោ ........................... | ៣០ ដុល្លា |
| វេជ្ជបណ្ឌិត លី កុសល + អ្នកស្រី លួង ស៊ីពៅ + បុត្រ ....... | ២០ ដុល្លា |
| ឧ.សិ ប៊ុន ផាត់ (ប្រទេសស្វីស) ....................................... | ២០ ដុល្លា |
| ឧ.សិ សូវីឡា ................................................................ | ២០ ដុល្លា |
| ឧ.ស លី ហុកទាន និងឧ.សិ អាំង យុហៀក .................... | ២០ ដុល្លា |
| ឧ.សិ នូ ចាន់ឌិន ........................................................... | ២០ ដុល្លា |
| ឧ.សិ នួន សុន្ទារី ........................................................... | ២០ ដុល្លា |
| ឧ.សិ ប៊ីសាខន និងស្វាមីព្រមទាំងបុត្រ ........................... | ២០ ដុល្លា |
| ឧ.សិ សួស យ៉ាត ........................................................... | ២០ ដុល្លា |
| លោក ស៊ុន បាន និងឧ.សិ សេង គឹមនូ ព្រមទាំងបុត្រ ...... | ២០ ដុល្លា |
| ឧ.សិ អ៊ី ណៃហុង ព្រមទាំងបុត្រ ខេត្តកំពង់ធំ .................. | ២០ ដុល្លា |
| លោក យាយ មីន អាស្រមសមាធិ បាត់ដំបង ................. | ២០ ដុល្លា |
| កញ្ញា ឆ វី ...................................................................... | ២០ ដុល្លា |
| កញ្ញា ឈុន ឡាយ ........................................................ | ២០ ដុល្លា |
| ឧ.សិ ប៉ូ យ៉ុន និងស្វាមី ព្រមទាំងបុត្រ .............................. | ២០ ដុល្លា |
| ឧ.សិ កែ សុជាតិ ........................................................... | ១៥ ដុល្លា |
| ឧ.សិ សេង លី ............................................................... | ១៥ ដុល្លា |

ឧ.សិ ជិន ឡាយ ........................................................... ១៥ ដុល្លា

គ្រួសារ ឧ.ស គិម ហ៊ុល (ប្រទេសស្វីស) ....................១០ដុល្លា + ២០ហ្វ្រង់

លោកស្រី ចន្ទូ (ប្រទេសស្វីស) .......................................... ១០ ដុល្លា

អ្នកស្រី នួន រ៉ូ .................................................................. ១០ ដុល្លា

ឧ.សិ ហ៊ឹម ឈី ................................................................ ១០ ដុល្លា

ឧ.សិ អ៊ុប ជួក ................................................................ ១០ ដុល្លា

ឧ.សិ ជា ប៉ាត ................................................................ ១០ ដុល្លា

ឧ.សិ កែ កូយ ................................................................ ១០ ដុល្លា

ឧ.ស យក់ ហុង និង ឧ.សិ អ៊ូច អេង ................................ ១០ ដុល្លា

ឧ.សិ វន្នី ...................................................................... ១០ ដុល្លា

ឧ.ស លឿង មឿន និងឧ.សិ ឡយ វ៉ាន ............................ ១០ ដុល្លា

ឧ.សិ សេង យ៉ុន ............................................................ ១០ ដុល្លា

លោក ម៉ក់ ជឿន និងឧ.សិ ថៃ សូយ ................................ ១០ ដុល្លា

ឧ.ស អាំង ឃើ និងឧ.សិ សាបឿន ................................ ១០ ដុល្លា

ឧ.សិ យស់ សារំ ............................................................ ១០ ដុល្លា

ឧ.ស ទេព ឈយ ............................................................ ១០ ដុល្លា

ឧ.ស ពិន វ៉ាន់ថាយ និងឧ.សិ ម៉ិះ .................................. ១០ ដុល្លា

ឧ.ស កែ នី និងឧ.សិ កៅ ងីន ........................................ ១០ ដុល្លា

ឧ.ស ស្រី ឆេង និងឧ.សិ កង ផេង ព្រមទាំងបុត្រ ............ ១០ ដុល្លា

ឧ.ស ស្វាត់ ឃួន និងឧ.សិ គង់ រំ ..................................... ១០ ដុល្លា

ឧ.សិ ឯម ណារី ............................................................ ១០ ដុល្លា

ឧ.សិ ឌក សូផា ............................................................ ១០ ដុល្លា

ឧ.សិ ធឿន ............................................................................ ១០ ដុល្លា
លោកគ្រូ យឹម មុន្នី និងអ្នកស្រី យឹម សោភា+បុត្រ ........... ១០ ដុល្លា
ឧ.សិ អោម ចាន់ថន ......................................................... ១០ ដុល្លា
ឧ.សិ ហ៊ឹម លាំ ព្រមទាំងបុត្រ ............................................ ១០ ដុល្លា
ឧ.សិ ហ៊ី គា ........................................................................ ១០ ដុល្លា
ឧ.សិ មួង ម៉ិះ ...................................................................... ១០ ដុល្លា
ឧ.សិ សុខ កន ព្រមទាំងបុត្រ ........................................... ១០ ដុល្លា
ឧ.ស ប៊ុន ចេង និងឧ.សិ ង៉ែត វណ្ណារ៉ា ............................. ១០ ដុល្លា
លោក ហេង គឹមឡាក់ និងភរិយា ...................................... ១០ ដុល្លា
ឧ.សិ ង្វួន ណៃគី ព្រមទាំងបុត្រ ..........................៥ដុល្លា + ៥.០០០រៀល
ភិក្ខុ សួន តាំង ................................................................... ៥ ដុល្លា
លោកយាយ លួស ............................................................... ៥ ដុល្លា
លោកយាយ យ៉ាន ............................................................... ៥ ដុល្លា
ឧ.សិ អៀយ កៀត ............................................................. ៥ ដុល្លា
ឧ.សិ មួត ទិម .................................................................... ៥ ដុល្លា
ឧ.សិ តាត សេដ្ឋតម .......................................................... ៥ ដុល្លា
ឧ.សិ ប៉ែន វ៉ន ព្រមទាំងបុត្រ .............................................. ៥ ដុល្លា
ឧ.សិ តាន់ សាគុណ ........................................................... ៥ ដុល្លា
ឧ.សិ តាន់ គឹមហៀក ........................................................ ៥ ដុល្លា
ឧ.សិ ជួន សាលួត .............................................................. ៥ ដុល្លា
ឧ.ស ព្រហ្ម ទូច ................................................................... ៥ ដុល្លា
នាង គន្ធា ........................................................................... ៥ ដុល្លា

ឧ.សិ សេង ហួយ .......................................................... ៥ ដុល្លា

ឧ.សិ លឹម សៀង .......................................................... ៥ ដុល្លា

ឧ.សិ ពេញ ចិន .......................................................... ៥ ដុល្លា

ឧ.សិ ឡេង ស៊ីម៉ៃ .......................................................... ៥ ដុល្លា

អ្នកគ្រូ ទីវ សុមាលី .......................................................... ៥ ដុល្លា

អ្នកគ្រូ កែវ រតនសត្យា .......................................................... ៥ ដុល្លា

ជឿន សុជារិទ្ធិ .......................................................... ៥ ដុល្លា

ជឿន សុជារី .......................................................... ៥ ដុល្លា

ឧ.សិ លន់ រឿត .......................................................... ៥ ដុល្លា

ឧ.សិ សោម ផាន់ .......................................................... ៥ ដុល្លា

លោក យាយ ថូ .......................................................... ៥ ដុល្លា

ឧ.សិ សុខ សក់ .......................................................... ៥ ដុល្លា

យិន សុផល + មួន ស្រីលាក .......................................................... ៥ ដុល្លា

ឧ.សិ ព្រះ ស៊ឹប .......................................................... ៥ ដុល្លា

អន សំភាព + កែវ ស្រី .......................................................... ៥ ដុល្លា

ឧ.សិ នូ សារ៉េត .......................................................... ៤ ដុល្លា

ម៉ា ហុនថាវ .......................................................... ៣ ដុល្លា

ឧ.សិ ហុង គុណ .......................................................... ៣ ដុល្លា

២ ដុល្លា ចំនួន ២ នាក់ ..........................................................

១ ដុល្លា ចំនួន ៣ នាក់ ..........................................................

Jean Pierre Gallet និងអ្នកស្រី លី សុមេច ព្រមទាំងបុត្រ ៧០ អ៊ឺរ៉ូ

លោក ណាំ ស៊ុយម៉េង និង អ្នកស្រី លីវ៉ាវ៉ុនី ព្រមទាំងបុត្រ ៥០ អ៊ឺរ៉ូ

| | |
|---|---|
| Fam Sith Sarina (Swiss) ............................................. | ២៥ អឺរ៉ូ |
| គ្រួសារ ខេង គឹមស្រ៊ីង (ប្រទេសស្វីស) ............................. | ១៥ អឺរ៉ូ |
| លោកសៀងស៊ុយហេង និងអ្នកស្រី ភួងបុប្ផាព្រមទាំងបុត្រ | ១០ អឺរ៉ូ |
| គ្រួសារ ឡុក ប៊ុនហេង + បុប្ផា (ប្រទេសស្វីស) .................. | ៥០ ហ្វ្រង់ |
| គ្រួសារ ប៊ុន ម៉ា ខាំ មី (ប្រទេសស្វីស) ............................... | ៥០ ហ្វ្រង់ |
| គ្រួសារ ឧ.ស មាស សុខ + ឧ.សិ មាស ផុន (ប្រទេសស្វីស) | ៥០ ហ្វ្រង់ |
| ឧ.ស មាស លី និង ឧ.សិ ហ៊ួរ សាវ៉ន ព្រមទាំងប្រុត ........ | ៥០ ហ្វ្រង់ |
| លោក តាន់ រដ្ឋា និង អ្នកស្រី នាថ ព្រមទាំងបុត្រ ............ | ៥០ ហ្វ្រង់ |
| គ្រួសារ ឧ.ស ម៉ឺន ឈួន (ប្រទេសស្វីស) ........................... | ៤០ ហ្វ្រង់ |
| គ្រួសារ ឧ.សិ សៅ ណែម (ប្រទេសស្វីស) ......................... | ៣០ ហ្វ្រង់ |
| កញ្ញា ម៉ឺន សុភាព (ប្រទេសស្វីស) .................................... | ៣០ ហ្វ្រង់ |
| គ្រួសារ ម៉ឺន ប្រសើរ (ប្រទេសស្វីស) .................................. | ២០ ហ្វ្រង់ |
| គ្រួសារ ម៉ែន ស្រីពៅ + ចន្ធា (ប្រទេសស្វីស) .................... | ២០ ហ្វ្រង់ |
| លោកស្រី ម៉ឺន ចន្ធូ (ប្រទេសស្វីស) .................................. | ២០ ហ្វ្រង់ |
| គ្រួសារ ម៉ែន ប៉ាន់ហាង ព្រមទាំងបុត្រ (ប្រទេសស្វីស) ...... | ២០ ហ្វ្រង់ |
| ឧ.សិ ឈឹម ប៊ួយកានីកា (ប្រទេសស្វីស) ......................... | ២០ ហ្វ្រង់ |
| ឧ.សិ អ៊ុំ យឿន ព្រមទាំងបុត្រ (ប្រទេសស្វីស) ................. | ២០ ហ្វ្រង់ |
| ឧ.សិ ទូច សម្បត្តិ (ប្រទេសស្វីស) .................................. | ១០ ហ្វ្រង់ |
| ឧ.ស ប៊ុន ហ៊ួនហៃ (ប្រទេសស្វីស) ................................. | ១០ ហ្វ្រង់ |
| គ្រួសារ អ៊ួរ មៃ ព្រមទាំងបុត្រ (ប្រទេសស្វីស) ................... | ១០ ហ្វ្រង់ |
| គ្រួសារ ពិន ពូន (ប្រទេសស្វីស) ....................................... | ១០ ហ្វ្រង់ |
| យុវជន ម៉ឺន សុខា (ប្រទេសស្វីស) .................................... | ១០ ហ្វ្រង់ |

| | |
|---|---|
| លោក ម៉ឺន ប្រសិទ្ធ (ប្រទេសស្វីស) .................................. | ១០ ហ្វ្រង់ |
| ក្រុម ឧបាសក អ៊ុន អ៊ឹម ដំដែក .................................. | ១០០.០០០ រៀល |
| លោក ឈិត ឆាវ និងនាង មេ វីរៈ ............................... | ៥០.០០០ រៀល |
| ឧ.ស ស៊ុន សាយ ..................................................... | ៤០.០០០ រៀល |
| ឧ.ស ចាន់ ម៉ារា ....................................................... | ៤០.០០០ រៀល |
| អ្នកស្រី ចាន់ សូនា ...................................................... | ៣០.០០០ រៀល |
| លោកយាយ សេង ...................................................... | ៣០.០០០ រៀល |
| លោកតា ឈួន ......................................................... | ២០.០០០ រៀល |
| ឧ.សិ មៅ ស៊ឹមហេង និងឧ.សិ លឹម បូសាយ ............. | ២០.០០០ រៀល |
| លោកតា ហ៊ា និងយាយ លាន ព្រមទាំងបុត្រ និងចៅ .. | ២០.០០០ រៀល |
| លោក អ៊ឹង ប៊ុនធាយ និងអ្នកស្រី មៅ ស្រីមុំ + បុត្រ ..... | ២០.០០០ រៀល |
| នាង ឌុច នារី ............................................................ | ២០.០០០ រៀល |
| ឧ.សិ ម៉ម សុត ........................................................... | ២០.០០០ រៀល |
| ឧ.សិ សី រិន ................................................................ | ២០.០០០ រៀល |
| ឧ.សិ ហូ យឿម ........................................................ | ២០.០០០ រៀល |
| ឧ.សិ រឿម ................................................................ | ២០.០០០ រៀល |
| លោក ដួប វាសនា ព្រមទាំងបុត្រ ............................... | ២០.០០០ រៀល |
| ឧ.សិ ទូច .................................................................. | ២០.០០០ រៀល |
| ឧ.ស ឈិន និងឧ.សិ អ៊ី .............................................. | ២០.០០០ រៀល |
| ឧ.សិ អ៊ុន ................................................................. | ២០.០០០ រៀល |
| ឧ.សិ ហ៊ាង វុចលី ....................................................... | ២០.០០០ រៀល |
| ឧ.សិ ទឹម មុំ .............................................................. | ២០.០០០ រៀល |

អ្នកស្រី អ៊ុក យុតសួង ........................................................ ២០.០០០ រៀល
ឧ.សិ ពៅ ........................................................................... ២០.០០០ រៀល
ឧ.សិ ស៊ន់ ហែម ................................................................ ២០.០០០ រៀល
ឧ.សិ បឿន គីមហ៊ុន .......................................................... ២០.០០០ រៀល
ឧ.សិ លឹម ចាន់ថន ព្រមទាំងបុត្រ ........................................ ២០.០០០ រៀល
លោក យិន សុផល ............................................................. ១៥.០០០ រៀល
ឧ.សិ  ហុង គុណា ............................................................... ១៥.០០០ រៀល
ម៉ា កែ កូយ ........................................................................ ១៥.០០០ រៀល
ទា យុក បឿន និងទា យី កាពៅ .............................................. ១៥.០០០ រៀល
ឧ.សិ ពេជ្រ ហោ ១៥.០០០ រៀល
ភិក្ខុ  មុត សារឿន ............................................................. ១០.០០០ រៀល
សាមណេរ ថៃ សុផាត ........................................................ ១០.០០០ រៀល
លោកយាយ កាយ ហួន ........................................................ ១០.០០០ រៀល
ឧ.សិ  ហៀប ព្រមទាំងបុត្រ ................................................ ១០.០០០ រៀល
ឧ.សិ  ព្រះ ស៊ុប ................................................................ ១០.០០០ រៀល
ឧ.សិ  ឯក ម្លិះ ..................................................................... ១០.០០០ រៀល
លោក ប៉ោ ផ្លាង និងឧ.សិ យិន និត .................................... ១០.០០០ រៀល
ឧ.សិ  ផុំ ប៊ិច ..................................................................... ១០.០០០ រៀល
ឧ.សិ  សី វណ្ណា .................................................................. ១០.០០០ រៀល
ឧ.សិ  អុន ........................................................................... ១០.០០០ រៀល
ឧ.សិ  ផន ........................................................................... ១០.០០០ រៀល
ធូយ តាម និង នូយ ហេង ................................................... ១០.០០០ រៀល

ឧ.សិ ស៊ុយ លន់ ....................................................... ១០.០០០ រៀល

ឧ.សិ សោម សុភាព ................................................. ១០.០០០ រៀល

នាង គង់ .................................................................. ១០.០០០ រៀល

ឧ.សិ ប៉ាវ មុំ ............................................................. ១០.០០០ រៀល

លោកយាយ រៀល ..................................................... ១០.០០០ រៀល

ឧ.សិ ស៊ិម វ៉ាន់ ......................................................... ១០.០០០ រៀល

ឧ.សិ មួយ ............................................................... ១០.០០០ រៀល

ម៉ា ឈួន ឡូវ ............................................................ ១០.០០០ រៀល

ម៉ា ហឿន ហ៊ាប ........................................................ ១០.០០០ រៀល

ឧ.ស ហ៊ួ .................................................................. ១០.០០០ រៀល

ឧ.សិ មិន នួន .......................................................... ១០.០០០ រៀល

ឧ.សិ ប៊ុល គីមសាន ................................................. ១០.០០០ រៀល

ឧ.សិ ផ្ទែក មឿន ...................................................... ១០.០០០ រៀល

កញ្ញា ឡុង គង់ ......................................................... ១០.០០០ រៀល

នាង ហេង ឡុង ....................................................... ១០.០០០ រៀល

ម៉ា រួន .................................................................... ១០.០០០ រៀល

ឧ.សិ តាន់ ឡាង (ហៅវ៉ា) .......................................... ១០.០០០ រៀល

ឧ.សិ ម៉ឹង សាត ....................................................... ១០.០០០ រៀល

ឧ.សិ យឿម ............................................................ ១០.០០០ រៀល

ឧ.ស តាំង ប៊ុនជី ..................................................... ១០.០០០ រៀល

ខៀវ សុគន្ធ ............................................................. ១០.០០០ រៀល

ជឿន សុជាវ៉ា .......................................................... ១០.០០០ រៀល

ឧ.ស មាស ធឿន ..................................................... ១០.០០០ រៀល

ឧ.សិ សែន .............................................................. ១០.០០០ រៀល

ឧ.សិ ផល្លី ................................................................ ១០.០០០ រៀល

ឧ.សិ សៅហ៊ាញ ....................................................... ១០.០០០ រៀល

អ្នកគ្រូ វត្ន សារ៉េត ..................................................... ១០.០០០ រៀល

លោក ប៉ុល ញ៉ន និងភរិយា ....................................... ១០.០០០ រៀល

ឧ.ស ឡុង កាន និងភរិយា ....................................... ១០.០០០ រៀល

ឧ.សិ អ៊ុន ជាទី ........................................................ ១០.០០០ រៀល

ឧ.សិ យស់ សារ៉ុម .................................................... ១០.០០០ រៀល

ឧ.សិ តាន់ គីម ......................................................... ១០.០០០ រៀល

ឧ.សិ តាន់ អេន ....................................................... ១០.០០០ រៀល

ឧ.សិ ហាក់ ស្រន់ ...................................................... ១០.០០០ រៀល

ឧ.សិ សុខ សុគន្ធា ..................................................... ១០.០០០ រៀល

ឧ.សិ ថាប ស៊ីណាត ព្រមទាំងបុត្រ ............................ ១០.០០០ រៀល

ឧ.សិ ជិន រាជ ព្រមទាំងបុត្រ ..................................... ១០.០០០ រៀល

ឧ.សិ ជិន រ៉ាន់ ព្រមទាំងបុត្រ ..................................... ១០.០០០ រៀល

ឧ.សិ សួនសារុន ព្រមទាំងបុត្រ ................................. ១០.០០០ រៀល

ឧ.សិ ហេង គង់ ព្រមទាំងបុត្រ .................................. ១០.០០០ រៀល

៨.០០០ រៀល ចំនួន ១នាក់ .................................................................

៧.០០០ រៀល ចំនួន ២នាក់ .................................................................

៦.០០០ រៀល ចំនួន ១នាក់ .................................................................

៥.០០០ រៀល ចំនួន ២៦នាក់ ...............................................................

៤.០០០ រៀល ចំនួន ២នាក់ ........................................................................

៣.០០០ រៀល ចំនួន ៣នាក់ ......................................................................

២.៥០០ រៀល ចំនួន ១នាក់ ........................................................................

២.០០០ រៀល ចំនួន ៧នាក់ ........................................................................

១.៥០០ រៀល ចំនួន ១នាក់ ........................................................................

១.០០០ រៀល ចំនួន ២នាក់ ........................................................................

Sdasdfasdf